

ឯកសារគម្ពីរព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ៊ុិចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សន ចន និង ឧបាសិកា អ៊ូច សាវឿង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីសក់ ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ថៃ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សាវ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ដុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ខុទ្ទកនិកាយ វិមានវត្ថុ
## ចតុត្ថភាគ
## ៥៥

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០១

## ឧទ្ទិសកថា

យើងខ្ញុំ សូមថ្លង់ស្មារតីស្មូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានស្មូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !
ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដក

## ខុទ្ទកនិកាយ វិមានវត្ថុ

## ចតុត្ថភាគ

## ៥៥

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស វិមានវត្ថុ

# ចតុត្ថោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមោ បីឋវគ្គោ

### បឋមំ បីឋវិមានំ

(១) បីឋន្តេ សោវណ្ណមយំ ឧឡារំ
មនោជវំ គច្ឆតិ យេន កាមំ
អលង្កតេ មាល្យធរេ[១] សុវត្ថេ
ឱភាសសិ វិជ្ជុរិវព្ភកូដំ
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា
បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ

---

១ ឱ. ម. មល្យធរេ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ វិមានវត្ថុ

# បឋមភាគ

---

*សូមក្រាបថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

## បីឋវគ្គ ទី ១

### បីឋវិមាន ទី ១

[១] (*ព្រះមោគ្គល្លានសួរថា*) តាំងរបស់នាង ជាវិការៈ នៃមាស ដ៏ធំទូលាយ មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងភ្លឺស្វាងដូចជាផ្លេកបន្ទោរ ញុំាងទីបំផុតនៃពពកឲ្យភ្លឺច្បាស់ តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយ ឯណានីមួយជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង

នាង កាលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
អព្ភាគតានាសនកំ អទាសឹ
អភិវាទយឹ អញ្ជលិកំ អកាសឹ
យថានុភាវញ្ច អទាសិ ទានំ

តេន មេតាទិសោ វណ្ណោ តេន មេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា

អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមកាសិ បុញ្ញំ
តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

បីឋវិមានំ បឋមំ ។

នាងមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុរ

របស់នាងក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស

បានឲ្យអាសនៈដល់អាគន្តុកភិក្ខុ បានថ្វាយបង្គំ

ធ្វើអញ្ជលីកម្ម ឲ្យទានតាមអានុភាព (នៃខ្ញុំ)

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេច ដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណា នីមួយដែលជាទីពេញចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំនឹងប្រាប់ដល់

លោក កាលដែលខ្ញុំកើត ជាមនុស្ស បានធ្វើបុណ្យ

ណា ខ្ញុំមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុរ

របស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

ចប់ បីឋវិមាន ទី ១ ។

វិមានវត្ថុស្មឹ បឋមស្ស បីឋវគ្គស្ស ទុតិយំ បីឋវិមានំ

## ទុតិយំ បីឋវិមានំ

(២) បីឋន្តេ វេឡុរិយមយំ ឧឡារំ
មនោជវំ គច្ឆតិ យេន កាមំ
អលង្កតេ មាល្យធរេ សុវត្ថេ
ឱភាសសិ វិជ្ជុរិវព្ភកូដំ
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា
បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ
អហំ មនុស្សេសុ មនុស្សភូតា
អព្ភាគតានាសនកំ អទាសឹ
អភិវាទយឹ អញ្ជលិកំ អកាសឹ
យថានុភាវញ្ច អទាសិ ទានំ

## បីឋវិមាន ទី ២

(២) (ព្រះមោគ្គល្លានសួរថា) តាំងរបស់នាង ជាវិការៈនៃកែវពិទូរ្យ
ដ៏ឧត្តម មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាល
នាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ
នាងភ្លឺស្វាងដូចជាផ្លេកបន្ទោរ ញុំាងទីបំផុតនៃពពកឲ្យភ្លឺច្បាស់
តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង
ក្នុងទីនេះផង ភោគៈទាំងឡាយ ឯណានីមួយ ដែលជាទីគាប់ចិត្ត
ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាង កាលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាព ដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំ កាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស បាន
ឲ្យអាសនៈ ដល់អាគន្តុកកិក្ខុ បានថ្វាយបង្គំ
ធ្វើអញ្ជលីកម្ម បានឲ្យទាន តាមអានុភាព (នៃខ្ញុំ)

តេន មេ តាទិសោ វណ្ណោ តេន មេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា

អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមកាសិ បុញ្ញំ
តេនម្ហិ ឯវំ ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

បីឋវិមានំ ទុតិយំ ។

## តតិយំ បីឋវិមានំ

(៣) បីឋន្តេ សោវណ្ណមយំ ឧឡារំ
មនោជវំ គច្ឆតិ យេន កាមំ
អលង្កតេ មាល្យធរេ សុវត្ថេ
ឱភាសសិ វិជ្ជុរិវព្ភកូដំ

កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុរបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ បីឋវិមាន ទី ២ ។

# បីឋវិមាន ទី ៣

(៣) (ព្រះមោគ្គល្លានសួរថា) តាំងរបស់នាងជាវិការៈនៃមាស ធំទូលាយ មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងក៏ស្វាងដូចផ្លេកបន្ទោរ ញុំាងទីបំផុតនៃពពកឲ្យភ្លឺច្បាស់បាន តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី

វិមានវត្ថុស្មឹ បឋមស្ស បីឋវគ្គស្ស តតិយំ បីឋវិមានំ

កេនាសិ ឯវំជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ
អប្បស្ស កម្មស្ស ផលំ មមេទំ
យេនម្ហិ ឯវំជលិតានុភាវា
អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
អទ្ទសំ វិរជំ ភិក្ខុំ វិប្បសន្នមនាវិលំ
តស្ស អទាសិហំ(១) បីឋំ បសន្នា សេហិ បាណិភិ
តេនមេតាទិសោ វណ្ណោ តេន មេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា
អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមកាសិ បុញ្ញំ
តេនម្ហិ ឯវំជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។
បីឋវិមានំ តតិយំ ។

---

១ ឱ.ម. អទាសហំ ។

វិមានវត្ថុ បីឋវគ្គ ទី ១ បីឋវិមាន ទី ៣

នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាងក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំមានអានុភាពដ៏រុងរឿង យ៉ាងនេះ ដោយផលនៃកម្មណា
ផលនៃកម្មរបស់ខ្ញុំនេះ តិចណាស់ ខ្ញុំកាលដែលកើត
ជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក

បានឃើញភិក្ខុ ប្រាសចាកធូលីគឺកិលេស មានចិត្តថ្លា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនតាំងដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយ ឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ បីឋវិមាន ទី ៣ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

## ចតុត្ថំ បីឋវិមានំ

(៤) បីឋន្តេ វេឡុរិយមយំ ឧឡារំ
មនោជវំ គច្ឆតិ យេនកាមំ
អលង្កតេ មាល្យធរេ សុវត្ថេ
ឱភាសសិ វិជ្ជុរិវព្ភកូដំ
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា
បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ
អប្បស្ស កម្មស្ស ផលំ មមេទំ
យេនម្ហិ ឯវំ ជលិតានុភាវា
អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ

សុត្តន្តបិដក ខុទ្ទកនិកាយ វិមានវត្ថុ

## បីឋវិមាន ទី ៤

(៤) (ព្រះមោគ្គល្លានសួរថា) តាំងរបស់នាង ជាវិការៈនៃកែវពិទូរ្យ
ធំទូលាយ មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាល
នាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ
នាងភ្លឺស្វាងដូចផ្លេកបន្ទោរ ញុំាងទីបំផុតនៃពពកឲ្យភ្លឺច្បាស់បាន

តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង
ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត
ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវធីតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលកម្មនេះថា

ខ្ញុំមានអានុភាព ដ៏រុងរឿងយ៉ាងនេះ ដោយផលនៃកម្ម
ណា ផលនៃកម្មរបស់ខ្ញុំនេះតិចណាស់ ខ្ញុំកាលដែលកើត
ជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក

វិមានវត្ថុស្មឹ បឋមស្ស បីឋវគ្គស្ស បញ្ចមំ កុញ្ជរវិមានំ

អទ្ទសំ វិរជំ ភិក្ខុំ វិប្បសន្នមនាវិលំ
តស្ស អទាសហំ បីឋំ បសន្នា សេហិ បាណិហិ
តេន មេតាទិសោ វណ្ណោ តេន មេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា
អក្ខាមិ តំ ភិក្ខុ មហានុភាវ
មនុស្សភូតា យមហំ អកាសឹ
តេនម្ហិ ឯវំ ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

បីឋវិមានំ ចតុត្ថំ ។

# បញ្ចមំ កុញ្ជរវិមានំ

(៥) កុញ្ជរោ តេ វរារោហេ នានារតនកប្បនោ
រុចិរោ ថាមវា ជវសម្បន្នោ(១) អាកាសម្ហិ សមីហតិ
បទុមី បទុមបត្តក្ខិ(២) បទុមុប្បលជុតិន្ធរោ(៣)
បទុម(៤) ចុណ្ណាភិកិណ្ណង្គោ សោវណ្ណពោក្ខរមាលវា
បទុមានុសតំ មគ្គំ បទុម(៥)បត្តវិភូសិតំ
ឋិតំ វគ្គុមនុញ្ញាតិ មិតំ គច្ឆតិ វារណោ

---

១ ម. រុចិរោ ថាមសម្បន្នោ ។ ២ ឱ. បទុមី បទុមបត្តក្ខី ។ ម. បទុមិ បទុមបត្តក្ខិ ។ ៣ ឱ. ម. បទុមុប្បល. ។ ៤-៥ ឱ.ម. បទុ ។

បានឃើញភិក្ខុ ប្រាសចាកធូលីគឺកិលេស មានចិត្តថា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនតាំងដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេច ដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយ ឯណា នីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ បីឋវិមាន ទី ៤ ។

## កុញ្ជរវិមាន ទី ៥

(៥) (ព្រះមោគ្គល្លានសួរថា) ដំរីរបស់នាង ជាដំរីដ៏ប្រសើរ សម្រេចដោយកែវផ្សេងៗ ដ៏រុងរឿង មានកំឡាំងបរិបូណ៌ ដោយសន្ទុះ នឹងទៅក្នុងអាកាសបាន មានសម្បុរ ដូចផ្កាឈូក មានភ្នែកដូចត្របកឈូក ទ្រទ្រង់នូវសរីរៈ ដ៏រុងរឿង ដូចផ្កាឈូកនឹងផ្កាឧប្បល មានអវយវៈ ដ៏ពេយពាយដោយលំអងនៃផ្កាឈូក មានរបៀបនៃសម្បុរ ដ៏ល្អ ជាដំរីដើរល្អ មិនលោត ទៅល្មមប្រមាណ កាន់ផ្លូវដ៏ដេរដាសដោយផ្កាឈូក ដែលប្រដាប់ដោយត្របកឈូក

តស្ស បក្កមមានស្ស សោវណ្ណតិសា រតិស្សរា
តេសំ សុយ្យតិ និគ្ឃោសោ តុរិយេ បញ្ចង្គិកេ យថា
តស្ស នាគស្ស ខន្ធម្ហិ សុចិត្តា អលង្កតា
មហន្តំ អច្ឆរាសង្ឃំ វណ្ណេន អតិរោចសិ
ទានស្ស តេ ឥទំ ផលំ អថោ សីលស្ស វា បន
អថោ អញ្ជលិកម្មស្ស តំ មេ អក្ខាហិ បុច្ឆិតា(តិ)។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ
ទិស្វាន គុណសម្បន្នំ ឈាយឹ ឈានរតំ សតំ
អទាសឹ បុប្ផាភិកិណ្ណំ អាសនំ ទុស្សសន្ថតំ
ឧបឌ្ឍបទុមាលាហំ អាសនស្ស សមន្តតោ
អព្ភោកិរិស្សំ បត្តេហិ បសន្នា សេហិ បាណិហិ
តស្ស កម្មកុសលស្ស ឥទំ មេ តាទិសំ ផលំ
សក្ការោ គរុការោ ច ទេវានំ អបចិតា អហំ
យោ វេ សម្មាវិមុត្តានំ សន្តានំ ព្រហ្មចារិនំ
បសន្នោ អាសនំ ទជ្ជា ឯវំ នន្ទេ យថា អហំ

កាលដែលដំរីនោះ កំពុងដើរទៅ កណ្តឹងជាវិការៈនៃមាស មាន ស្នូរជាទីត្រេកអរ ស្នូរគឹកកងនៃកណ្តឹងទាំងនោះ លាន់ឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ នាងដែលមានសំពត់ល្អ មានខ្លួនប្រដាប់ហើយ (បិតទៅ) លើ-កនៃដំរីនោះ មានសម្បុររុងរឿងក្នុងពួកនៃស្រីអប្សរដ៏ច្រើន នេះជាផលបានរបស់នាង ឬសីល ឬអញ្ជលិកម្ម នាងដែលអាត្មាសួរហើយ ចូរប្រាប់រឿងនោះ ដល់អាត្មាចុះ ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា ខ្ញុំបានឃើញសាវ័កប្រកបដោយគុណធម៌ មានឈាន ត្រេកអរក្នុងឈាន ជាអ្នកស្ងប់រម្ងាប់ បានប្រគេនអាសនៈ ក្រាលនូវសំពត់ដ៏ពេយពាយដោយផ្កា ខ្ញុំមានសេចក្តីជ្រះថ្លាបានពេយពាយចុះ នូវផ្កាឈូកពាក់កណ្តាល ដោយទីជុំវិញអាសនៈដោយគ្រប់គទាំងឡាយ ដោយដៃរបស់ខ្លួន ផលប្រាកដដូច្នោះ របស់ខ្ញុំនេះជាផលនៃកុសលកម្មនោះ ខ្ញុំដែលពួកទេវតាបូជាហើយ ព្រោះគួរគេធ្វើសក្ការៈគោរព អ្នកណាមួយជ្រះថ្លាហើយ គប្បីឲ្យអាសនៈដល់លោកអ្នកមានចិត្តរួចស្រឡះហើយ ដោយប្រពៃ មានចិត្តស្ងប់រម្ងាប់ប្រព្រឹត្តព្រហ្មចារ្យ អ្នកនោះគប្បីត្រេកអរ ដូចខ្ញុំយ៉ាងនោះ

វិមានវត្ថុស្មឹ បឋមស្ស បីឋវគ្គស្ស ឆដ្ឋំ នាវាវិមានំ

តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា
អាសនំ ទាតព្វំ ហោតិ សរីរន្តិមធារិនន្តិ ។

កុញ្ជរវិមានំ បញ្ចមំ ។

## ឆដ្ឋំ នាវាវិមានំ

(៦) សុវណ្ណច្ឆទនំ នាវំ នារិ អារុយ្ហ តិដ្ឋសិ
ឱគាហសិ[១] បោក្ខរណិំ បទុមំ[២] ឆិន្ទសិ បាណិនា
កូដាគារា និវេសា តេ វិភត្តា ភាគសោ មិតា
ទទ្ទល្លមានា អាភន្តិ សមន្តា ចតុរោ ទិសា
កេន តេតាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

---
១ ឱ.ម. ឧគាហសិ ។ ២ ឱ.ម. បទ្មំ ។

ព្រោះហេតុនោះ បុគ្គលអ្នកប្រាថ្នា នូវគុណគឺសេចក្ដីល្អ
ដល់ខ្លួន ប្រាថ្នានូវភាពនៃផលដ៏ធំ គប្បីឲ្យនូវអាសនៈ
ដល់ព្រះខីណាស្រព ដែលទ្រទ្រង់នូវសរីរៈជាទីបំផុតចុះ ។

ចប់ កុញ្ជរវិមាន ទី ៥ ។

## នាវាវិមាន ទី ៦

(៦) (ព្រះមោគ្គល្លានសួរថា) ម្នាលនារី នាងឡើងឋិតនៅលើទូក ដែលមានដម្បូលជាវិការៈនៃមាស ហើយចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេកសាងដោយចំណែកដែលចែក (ស្មើគ្នា) ភ្លឺរុងរឿងដោយជុំវិញក្នុងទិសទាំង ៤ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
ទិស្វាន ភិក្ខុំ តសិតេ កិលន្តេ
ឧដ្ឋាយ ទាតុំ ឧទកំ អទាសឹ
យោ វេ កិលន្តាន បិបាសិតានំ
ឧដ្ឋាយ ទាតុំ ឧទកំ ទទាតិ
សីតោទកា តស្ស ភវន្តិ នជ្ជោ
បហូតមល្យា ពហុបុណ្ឌរីកា
តំ អាបគា អនុបរិយន្តិ[១] សព្វទា
សីតោទកា វាលុកសន្ថតា នទី
អម្ពា ច សាលា តិលកា ច ជម្ពុយោ
ឧទ្ទាលកា បាដលិយោ ច ផុល្លា
តំ ភូមិភាគេហិ ឧបេតរូបំ
វិមានសេដ្ឋំ ភុសសោភមានំ
តស្សេវ[២] កម្មស្ស អយំ វិបាកោ
ឯតាទិសំ បុញ្ញកតា លភន្តិ

១ ម. តមាសមន្តានុបរិយេន្តិ ។ ២ ម. តស្សេធ ។

ខ្ញុំ កាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក បានឃើញនូវពួកភិក្ខុស្រេកទឹក លំបាក ក៏សង្ហាត ប្រគេនទឹកឆាន់ ជនណាមួយ សង្ហាតឲ្យមកផឹក ដល់អ្នកលំបាក អ្នកស្រេកឃ្លាន ស្ទឹងមានទឹកត្រជាក់ មានសួនច្បារច្រើន មានឈូកច្រើន រមែងកើតមានដល់ជននោះ ស្ទឹងទាំងឡាយដែលមានទឹកត្រជាក់ ក្រាលដោយដីខ្សាច់ ព័ទ្ធជុំវិញទីនោះសព្វកាល ស្វាយក្តី រាំងក្តី ច្បារក្តី ព្រីងក្តី រាជព្រឹក្សក្តី ប្រទៀងក្តី ក៏មានផ្ការីកស្គុះស្គាយ ជនអ្នកធ្វើបុណ្យ តែងបានវិមានដ៏ប្រសើរ ល្អក្រៃពេក មានសភាពដ៏សមរម្យ តាមកម្មវិភាគទាំងឡាយនោះ នេះជាវិបាក នៃកម្មនោះឯង ពួកជនដែលបានធ្វើបុណ្យ រមែងបានអានិសង្សបែបនេះ

កូដាគារា និវេសា មេ  វិភត្តា ភាគសោ មិតា
ទទ្ទល្លមានា អាភន្តិ  សមន្តា ចតុរោ ទិសា
តេន មេ តាទិសោ វណ្ណោ  តេន មេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា  យេ កេចិ មនសោ បិយា
អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមហំ អកាសិំ[១]
តេនម្ហិ ឯវំ ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

នាវាវិមានំ ឆដ្ឋំ ។

## សត្តមំ នាវាវិមានំ

(៧) សុវណ្ណច្ឆទនំ នាវំ  នារិ អារុយ្ហ តិដ្ឋសិ[២]
ឱគាហសិ បោក្ខរណិំ  បទុមំ ឆិន្ទសិ បាណិនា
កូដាគារា និវេសា តេ  វិភត្តា ភាគសោ មិតា
ទទ្ទល្លមានា អាភន្តិ  សមន្តា ចតុរោ ទិសា
កេន តេ តាទិសោ វណ្ណោ  កេន តេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា  យេ កេចិ មនសោ បិយា

---

១ ឱ. យមកាសិ បុញ្ញំ ។ ២ ម. តិដ្ឋតិ ។

ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់ខ្ញុំ ដូចជាគេកាស់ដោយបំណែកដែលចែកស្មើគ្នា ភ្លឺរុងរឿង ជុំវិញ ក្នុងទិសទាំង ៤ ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់
ខ្ញុំក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ នាវាវិមាន ទី ៦ ។

## នាវាវិមាន ទី ៧

(៧) (ព្រះមោគ្គល្លានសួរថា) ម្នាលនារី នាងឡើងឋិតនៅលើទូក មានដម្បូលជាវិការៈនៃមាស ត្រាច់ចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេកាស់ដោយបំណែក ដែលចែក (ស្មើគ្នា) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង៤ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះកើតឡើងដល់នាងផង តើដោយហេតុអ្វី

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
ទិស្វាន ភិក្ខុំ តសិតំ កិលន្តំ
ឧដ្ឋាយ ទាតុំ ឧទកំ អទាសឹ

យោ វេ កិលន្តស្ស បិបាសិតស្ស
ឧដ្ឋាយ ទាតុំ ឧទកំ ទទាតិ
សីតោទកា តស្ស ភវន្តិ នជ្ជោ
បហូតមល្យា ពហុបុណ្ឌរីកា

តំ អាបគា អនុបរិយន្តិ សព្វទា
សីតោទកា វាលុកសន្ថតា នទី
អម្ពា ច សាលា តិលកា ច ជម្ពុយោ
ឧទ្ទាលកា ទាដលិយោ ច ផុល្លា

ម្នាលទេវតា មានអានុភាពច្រើន អាត្មាសូមសួរនាង

នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី

នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ

របស់នាង ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ

ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំ កាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្សអំពីជាតិមុន

ក្នុងមនុស្សលោក បានឃើញភិក្ខុស្រេកទឹក លំបាក ក៏សង្វាត

ប្រគេនទឹកឆាន់ ជនណាមួយ សង្វាតឲ្យទឹកផឹក ដល់អ្នក

លំបាក អ្នកស្រេកឃ្លាន ស្ទឹងទាំងឡាយ ដែលមានទឹកត្រជាក់

មានសួនច្បារច្រើន មានឈូក-សច្រើន រមែងកើតមានដល់

ជននោះ ស្ទឹងទាំងឡាយដែលមានទឹកត្រជាក់ ក្រាលដោយ

ដីខ្សាច់ព័ទ្ធជុំវិញទីនោះ សព្វកាល ស្វាយក្តី រាំងក្តី ច្បារក្តី

ព្រីងក្តី រាជព្រឹក្សក្តី ប្រនៀងក្តី ក៏មានផ្ការីកស្គុះស្គាយ

តំ ភូមិភាគេហិ ឧបេតរូបំ
វិមានសេដ្ឋំ ភុសសោភមានំ
តស្សេវ កម្មស្ស អយំ វិបាកោ
ឯតាទិសំ បុញ្ញកតា លភន្តិ

តេន មេ តាទិសោ វណ្ណោ តេន មេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា

អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមកាសិ បុញ្ញំ
តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

នាវាវិមានំ សត្តមំ ។

## អដ្ឋមំ នាវាវិមានំ

(៨) សុវណ្ណច្ឆទនំ នាវំ នារិ អារុយ្ហ តិដ្ឋសិ
ឱគាឡ្ហសិ បោក្ខរណឹ បទុមំ ឆិន្ទសិ បាណិនា
កូដាគារា និវេសា តេ វិភត្តា ភាគសោ មិតា
ទទ្ទល្លមានា អាភន្តិ សមន្តា ចតុរោ ទិសា

អ្នកធ្វើបុណ្យតែងបាននូវវិមានដ៏ប្រសើរ ល្អក្រៃពេក មានសភាព
ដ៏សមរម្យតាមភូមិភាគទាំងឡាយនោះ នេះជាវិបាកនៃកម្មនោះ
ឯង ពួកជនដែលបានធ្វើបុណ្យ តែងបានអានិសង្សបែបនេះ
ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ
ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយ
ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ នាវាវិមាន ទី ៧ ។

## នាវាវិមាន ទី ៨

(៨) (ព្រះសម្ពុទ្ធត្រាស់សួរថា) ម្នាលនារី នាងឡើង ឋិតនៅ
លើទូក មានដម្បូល ជាវិការៈនៃមាស ត្រាច់ចុះកាន់
ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ
ជាលំនៅ របស់នាង ដូចជាគេកស់ ដោយចំណែក ដែល
ចែក (ស្មើគ្នា) ភ្លឺរុងរឿង ជុំវិញ ក្នុងទិស ទាំង ៤

កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា សម្ពុទ្ធេនេវ បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
ទិស្វាន ភិក្ខូ តសិតេ កិលន្តេ
ឧដ្ឋាយ បាតុំ ឧទកំ អទាសិំ
យោ វេ កិលន្តាន បិបាសិតានំ
ឧដ្ឋាយ បាតុំ ឧទកំ ទទាតិ
សីតោទកា តស្ស ភវន្តិ នជ្ជោ
បហូតមល្យា ពហុបុណ្ឌរីកា
តំ អាបគា អនុបរិយន្តិ សព្វទា
សីតោទកា វាលុកសន្ថតា នទី

នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង
ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត
ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវតា មានអានុភាពច្រើន តថាគតសូមសួរនាង
នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាពដ៏រុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះសម្ពុទ្ធត្រាស់សួរហើយ មានចិត្តត្រេកអរ
លុះព្រះសម្ពុទ្ធសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំម្ចាស់កាលដែលកើតជាមនុស្សក្នុងពួកមនុស្ស អំពីជាតិមុន
ក្នុងមនុស្សលោក បានឃើញពួកភិក្ខុ ស្រេកទឹក លំបាក
ក៏សង្វាតប្រគេនទឹកឆាន់ ជនណាមួយ សង្វាតឲ្យទឹក
ផឹកដល់អ្នកលំបាក អ្នកស្រេកឃ្លាន ស្ទឹងមានទឹកត្រជាក់
មានសួនច្បារច្រើន មានឈូក-សច្រើន រមែងកើតឡើង
ដល់ជននោះ ស្ទឹងទាំងឡាយ មានទឹកត្រជាក់ ក្រាល
ដោយដីខ្សាច់ តែងព័ទ្ធជុំវិញទីនោះ សព្វកាល

វិមានវត្ថុស្មិំ បឋមស្ស បីឋវគ្គស្ស នវមំ បទីបវិមានំ

អម្ពា ច សាលា តិលកា ច ជម្ពុយោ
ឧទ្ទាលកា បាដលិយោ ច ផុល្លា
តំ ភូមិភាគេហិ ឧបេតរូបំ
វិមានសេដ្ឋំ សុសោភមានំ
តស្សៈ កម្មស្ស អយំ វិបាកោ
ឯតាទិសំ បុញ្ញកតា លភន្តិ
កូដាគារ និវេសា មេ វិភត្តា ភាគសោ មិតា
ទទ្ទល្លមានា អាភន្តិ សមន្តា ចតុរោ ទិសា
តេន មេ តាទិសោ វណ្ណោ តេន មេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា
តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។
ឯតស្ស កម្មស្ស អយំ វិបាកោ
ឧដ្ឋាយ ពុទ្ធោ ឧទកំ អទាសីតិ ។

នាវាវិមានំ អដ្ឋមំ ។

## នវមំ បទីបវិមានំ

(៩) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា

ស្វាយក្តី ពំងក្តី ច្បារក្តី ព្រីងក្តី ពជព្រឹក្សក្តី
ប្រទៀងក្តី ក៏មានផ្ការីកស្គុះស្គាយ អ្នកធ្វើបុណ្យ
តែងបានវិមានដ៏ប្រសើ ល្អក្រៃពេក មានសភាព
ដ៏សមរម្យ តាមភូមិភាគ ទាំងឡាយនោះ
នេះជាវិបាក របស់កម្មនោះឯង ពួកជនដែល
បានធ្វើបុណ្យ រមែងបាន អានិសង្សបែបនេះ

ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់ខ្ញុំម្ចាស់ ដូចជាគេកាត់ជាយ ចំណែកដែលចែក (ស្មើគ្នា) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ ព្រោះហេតុនោះបានជា ខ្ញុំម្ចាស់មានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំម្ចាស់ក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំម្ចាស់ផង ខ្ញុំម្ចាស់មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំម្ចាស់ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ៗ នេះជាវិបាកនៃកម្មនុ៎ះ ព្រះពុទ្ធទ្រង់ក្រោកឡើងហើយ ទ្រង់សោយទឹក ៗ

ចប់ នាភិវិមានទី ៨ ។

## បទីបវិមាន ទី ៩

(៩) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមាន
សម្បុរល្អ តាំងនៅ ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

កេន តេ តាទិសោ វណ្ណោ   កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា   យេ កេចិ មនសោ បិយា
កេន ត្វំ វិមលោភាសា   អតិរោចសិ ទេវតេ
កេន តេ សព្វគត្តេហិ   សព្វា ឱភាសរេ(១) ទិសា

បុដ្ឋាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា   មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ   យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
តមន្ធការម្ហិ តិមីសិកាយំ
បទីបកាលម្ហិ អទំ បទីបំ(២)
យោ អន្ធការម្ហិ តិមីសិកាយំ
បទីបកាលម្ហិ ទទាតិ ទីបំ
ឧប្បជ្ជតិ ជោតិរសំ វិមានំ
បហូតមល្យំ ពហុបុណ្ឌរីកំ

---

១ ម. ឱភាសតេ ។ ២ ម. ទទាសឹ ទីបំ ។

នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយ ណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី ម្នាលទេវធីតា នាងមានពន្លឺប្រាសចាកមន្ទិល រុងរឿងក្រៃលែង ដោយហេតុអ្វី ទិសទាំងពួងភ្លឺអំពីអវយវៈទាំងអស់របស់នាង ដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិ
មុន ក្នុងមនុស្សលោក បានឲ្យប្រទីប ក្នុងទីងងឹតខ្លាំង
ក្នុងទីអ័ព្ទផ្សែង ក្នុងកាលគួរអុជប្រទីប ជនណាឲ្យ
ប្រទីប ក្នុងទីងងឹតខ្លាំង ក្នុងទីអ័ព្ទផ្សែង ក្នុងកាលគួរអុជ
ប្រទីបហើយ វិមានក៏មានរស្មីរុងរឿង មានសួនច្បារ
ច្រើន មានឈូក-សច្រើន រមែងកើតឡើងដល់ជននោះ

តេន មេតាទិសោ វណ្ណោ តេន មេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា
តេណាហំ វិមលោភាសា អតិរោចាមិ ទេវតា
តេន មេ សព្វគត្តេហិ សព្វា ឱភាសរេ ទិសា
អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមកាសិ បុញ្ញំ
តេនម្ហិ ឯវំ ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

បីឋវិមានំ នវមំ ។

# ទសមំ តិលទក្ខិណាវិមានំ

(១០) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេតាទិសោ វណ្ណោ កេន តេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា
បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង ព្រោះហេតុនោះបានជាខ្ញុំមានពន្លឺប្រាសចាកមន្ទិល រុងរឿងកន្លងទេវតាទាំងឡាយ ព្រោះហេតុនោះ ទិសទាំងពួង តែងភ្លឺអំពីពពងកាយទាំងអស់របស់ខ្ញុំ

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ បទីបវិមាន ទី ៩ ។

## តិលទក្ខិណាវិមាន ទី ១០

[១០] (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងដែលមានសម្បុរល្អ តាំងនៅ ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី

កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ

អទ្ទសំ វិរជំ ពុទ្ធំ វិប្បសន្នមនាវិលំ
អាសជ្ជ ទានំ អទាសិំ អកាមា តិលទក្ខិណំ
ទក្ខិណេយ្យស្ស ពុទ្ធស្ស បសន្នា សេហិ បាណិហិ
តេន មេ តាទិសោ វណ្ណោ តេន មេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា

អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមកាសិ បុញ្ញំ
តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

តិលទក្ខិណវិមានំ ទសមំ ។

នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។
ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា
ខ្ញុំ កាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស អំពី
ជាតិមុន ក្នុងមនុស្សលោក បានឃើញព្រះពុទ្ធ ទ្រង់
ប្រាសចាកធូលីគឺកិលេស មានព្រះទ័យថ្លា មិនល្អក់
ខ្ញុំមិនមានប្រាជ្ញាគឺមិនបានប្រុងទុក ជ្រះថ្លាហើយ បានប្រមូលល្
ថ្វាយជាទាន ដល់ព្រះពុទ្ធជាទក្ខិណេយ្យបុគ្គល ដោយដៃរបស់ខ្លួន
ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ
ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយ ណា
នីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង
បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំ មានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ តិលទក្ខិណាវិមាន ទី ១០ ។

# ឯកាទសមំ បតិព្វតាវិមានំ

(១១) កោញ្ចា មយុរា ទិវិយា ច ហំសា
វគ្គុស្សរា កោកិលា សម្បតន្តិ
បុប្ផាភិកិណ្ណំ រម្មមិទំ វិមានំ
អនេកចិត្តំ នរនារិសេវិតំ
តត្ថច្ឆសិ ទេវិ មហានុភាវេ
ឥទ្ធី វិកុព្វន្តិ អនេករូបា
ឥមា ច តេ អច្ឆរាយោ សមន្តតោ
នច្ចន្តិ គាយន្តិ បមោទយន្តិ
ទេវិទ្ធិបត្តាសិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
បតិព្វតា អនញ្ញមនា អហោសឹ
មាតាវ បុត្តំ អនុរក្ខមានា

# បតិព្វតាវិមាន ទី ១១

[១១] (ព្រះមោគ្គល្លានសួរថា) ពួកក្រៀល ក្ងោក ហង្ស ទីងតាមើ មានអានុភាពជាទិព្វ មានសម្លេងពីរោះ មកប្រជុំគ្នា វិមាននេះជាទីត្រេកអរ ដេរដាសដោយផ្កា វិចិត្រវចនាយ៉ាងច្រើន ដែលជនប្រុសស្រីសេពគប់ហើយ ម្នាលទេវធីតា មានអានុភាពច្រើន នាងនៅក្នុងវិមាននោះ ពួកស្រីអប្សរទាំងប៉ុន្មាន មានឫទ្ធិនិម្មិតរូបច្រើន រាំច្រៀង រីករាយ ដោយជុំវិញ ម្នាលទេវធីតា មានអានុភាពច្រើន នាងបានដល់នូវឫទ្ធិយ៉ាងនេះ នាងកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំ កាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស
មានសេចក្តីគោរពប្តី មិនមានចិត្តកើតឡើង
ក្នុងបុរសដទៃ ខំរក្សាប្តី ដូចជាមាតារក្សាកូន

កុទ្ធាបិហំ នប្ផរុសំ អវោចំ
សច្ចេ ឋិតា មោសវជ្ជំ បហាយ
ទានេ រតា សង្គហិតត្តភាវា
អន្នញ្ច បានញ្ច បសន្នចិត្តា
សក្កច្ច ទានំ វិបុលំ អទាសឹ
តេន មេតាទិសោ វណ្ណោ តេន មេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា
អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមកាសិ បុញ្ញំ
តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

បតិព្វតាវិមានំ ឯកាទសមំ ។

## ទ្វាទសមំ ទុតិយបតិព្វតាវិមានំ

(១២) វេឡុរិយថម្ភំ រុចិរំ បភស្សរំ
វិមានមារុយ្ហ អនេកចិត្តំ
តត្ថច្ឆសិ ទេវិ មហានុភាវេ

ខ្ញុំ ទុកណាជាមានសេចក្ដីក្រោធ ក៏មិនបានពោលពាក្យអាក្រក់ (ចំពោះប្ដី) ខ្ញុំបានតាំងនៅក្នុងពាក្យសច្ចៈ បានលះបង់ពាក្យកុហក ជាអ្នកត្រេកអរក្នុងទាន មានអធ្យាស្រ័យគ្រោះ (ដោយសង្គហវត្ថុទាំងឡាយ) មានចិត្តជ្រះថ្លា បានឲ្យបាយ ទឹក ឲ្យទានដ៏ធំទូលាយ ដោយសេចក្ដីគោរព ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណាមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង ៗ

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់
ខ្ញុំក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ៗ

ចប់ បតិព្វតាវិមាន ទី ១១ ។

# ទុតិយបតិព្វតាវិមាន ទី ១២

(១៦) (ព្រះមោគ្គល្លានសួរថា) នាងឡើងកាន់វិមាន
មានសសរ ជាវិការៈនៃកែវពិទូរ្យ ដ៏រុងរឿង
ភ្លឺផ្លេក មានវិចិត្រដ៏ច្រើន ម្នាលទេវធីតា
មានអានុភាពច្រើន នាងបាននៅក្នុងវិមាននោះ

វិមានវត្ថុស្មឹ បឋមស្ស បីឋវគ្គស្ស ទ្វាទសមំ បតិព្វតាវិមានំ

ឧច្ចាវចា ឥទ្ធិវិកុព្វមានា
ឥមា ច តេ អច្ឆរាយោ សមន្តតោ
នច្ចន្តិ គាយន្តិ បមោទយន្តិ
ទេវិទ្ធិបត្តាសិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
ឧបាសិកា ចក្ខុមតោ អហោសឹ
បាណាតិបាតា វិរតា អហោសឹ
លោកេ អទិន្នំ បរិវជ្ជយិស្សំ
អមជ្ជបា នាបិ(១) មុសា អភាណឹ
សកេន សាមិនា អហោសឹ តុដ្ឋា
អន្នញ្ច បានញ្ច បសន្នចិត្តា
សក្កច្ច ទានំ វិបុលំ អទាសឹ

---

១ ម. អមជ្ជបោ នោច ។

វិមានវត្ថុ បីឋវគ្គ ទី ១ ទុតិយបតិព្វតាវិមាន ទី ១២

ពួកស្រីអប្សរ ទាំងអម្បាលនេះ ដែលខ្ពស់ទឹងទាប មានឫទ្ធិ និម្មិតផ្សេងៗ កំច្រៀងរីករាយដោយជុំវិញ ម្នាលទេវធីតា មានអានុភាពច្រើន នាងបានដល់នូវឫទ្ធិ នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា ខ្ញុំកាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាឧបាសិកា (របស់ព្រះគោតម មានបញ្ញាចក្ខុ) វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន ក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយកុហក ជាអ្នកត្រេកអរនឹងប្ដីរបស់ខ្លួន មានចិត្តជ្រះថ្លា បានឲ្យបាយ ទឹក ឲ្យទានដ៏ធំទូលាយ ដោយសេចក្ដីគោរព

កេន មេ តាទិសោ វណ្ណោ កេន មេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា
អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមហំ អកាសឹ
តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទុតិយបតិព្វតាវិមានំ ចុទ្ទសមំ ។

## តេរសមំ សុណិសាវិមានំ

(១៣) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា
បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេច ដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណាមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ ទុតិយបតិព្វតាវិមាន ទី ១២ ។

## សុណិសាវិមាន ទី ១៣

(១៣) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវធីតា នាងមានសម្បុរល្អ បំផុតនៅហើយ ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេច ដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណាមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ
អហំ មនុស្សេសុ មនុស្សភូតា
សុណិសា អហោសឹ សសុរស្ស ឃរេ
អទ្ទសំ វិរជំ ភិក្ខុំ វិប្បសន្នមនាវិលំ
តស្ស អទាសិហំ បូវំ បសន្នា សេហិ បាណិហិ
ភាគឌ្ឍភាគំ ទត្វាន មោទាមិ នន្ទនេ វនេ
តេន មេ តាទិសោ វណ្ណោ តេន មេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា
តេនម្ហិ ឯវំជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

សុណិសាវិមានំ តេរសមំ ។

## ចុទ្ទសមំ សុណិសាវិមានំ

(១៤) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស ជា
កូនប្រសា ក្នុងផ្ទះ នៃឪពុកក្មេក បានឃើញភិក្ខុ
ប្រាសចាកធូលីគឺកិលេស មានចិត្តថ្លា មិនល្អក់

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំ ដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន
លុះប្រគេននំជាចំណែកពាក់កណ្តាលហើយ ក៏រីករាយ ក្នុងនន្ទនវ័ន
ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ
ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណា ទីមួយ
ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ សុណិសាវិមាន ទី ១៣ ។

# សុណិសាវិមាន ទី ១៤

(១៤) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវធីតា នាងមានសម្បុរ
ល្អ ឋិតនៅហើយ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក
នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង
ក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយដែលជាទីគាប់ចិត្ត
ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

ពុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
សុណិសា អហោសឹ សសុរស្ស ឃរេ

អទ្ទសំ វិរជំ ភិក្ខុំ វិប្បសន្នមនាវិលំ
តស្ស អទាសហំ ភាគំ បសន្នា សេហិ បាណិហិ
កុម្មាសបិណ្ឌំ ទត្វាន មោទាមិ នន្ទនេ វនេ
តេន មេតាទិសោ វណ្ណោ តេន មេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា

តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

សុណិសាវិមានំ ចុទ្ទសមំ ។

ម្នាលទេវតា មានអានុភាពច្រើន អាត្មាសូមសួរ
នាង នាងកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យ
អ្វី នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំ កាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស ជា
កូនប្រសាក្នុងផ្ទះ នៃឪពុកក្មេក បានឃើញភិក្ខុ
ដែលប្រាសចាកកិលេស មានចិត្តថ្លា មិនល្អក់

ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យបំណែក (នំកុម្មាស)ដល់ភិក្ខុនោះ ដោយដៃ
របស់ខ្លួន លុះឲ្យដុំនៃនំកុម្មាសរួចហើយ ក៏រីករាយ ក្នុងនន្ទនវ័ន
ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ
ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណា
នីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

ចប់ ទុតិយសុណិសាវិមាន ទី ១៤ ។

# បណ្ណរសមំ ឧត្តរាវិមានំ

(១៥) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

ឥស្សា ច មច្ឆរិយមថោ[1] បលាសោ
នាហោសិ មយ្ហំ ឃរមាវសន្តិយា
អក្កោធនា ភត្តុ វសានុវត្តិនី
ឧបោសថេ . . . និច្ចប្បមត្តា[2]

១ ឱ. មច្ឆរិយមថោ ។ ម. មច្ឆេរមថោ ។ ២ ម. និច្ចមប្បមត្តា ។

# ឧត្តរាវិមាន ទី ១៥

(១៥) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាងទិសទាំងពួង ឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាង ក៏ភ្លឺច្បាស់ សព្វទិស ដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ដោះស្រាយនូវផលនៃកម្មនេះថា

សេចក្ដីច្រណែនក្ដី សេចក្ដីកំណាញ់ក្ដី មានះក្ដី ការលើក
ខ្លួនផ្ទឹមក្ដី មិនមានដល់ខ្ញុំ កាលដែលនៅគ្រប់គ្រងផ្ទះ
ខ្ញុំមិនមានសេចក្ដីក្រោធ ជាអ្នកប្រព្រឹត្តតាមអំណាចកស្ដា
មិនមានសេចក្ដីប្រមាទ ជានិច្ច ក្នុងការរក្សាឧបោសថ

ចាតុទ្ទសឹ បញ្ចទសឹ  យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច  អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសឹ  សទា សីលេសុ សំវុតា
សញ្ញមា សំវិភាគា ច  វិមានំ អាវសាមហំ (១)
បាណាតិបាតា វិរតា  មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច  មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា  អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ  គោតមស្ស យសស្សិនោ
សាហំ សកេន សីលេន  យសសា ច យសស្សិនី
អនុភោមិ សកំ បុញ្ញំ  សុខិតា ចម្ហិ អនាមយា (២)
តេន មេតាទិសោ វណ្ណោ  តេន មេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច មេ ភោគា  យេ កេចិ មនសោ បិយា

អក្ខាមិ តេ ភិក្ខុ មហានុភាវ
មនុស្សភូតា យមហំ អកាសិ
តេនម្ហិ ឯវញ្ជលិតានុភាវា
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

---

១ ម អាវសាមិមំ ។ ២ ម. ចម្ហិ នាមយា ។

ខ្ញុំបានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីល គ្រប់កាល ជាអ្នកមានសេចក្តីសង្រួម មានការចែករំលែកទាន នៅគ្រប់គ្រងវិមាន ជាអ្នកវៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ចាកការលួច ចាកការប្រព្រឹត្តកន្លង ជាអ្នកឆ្ងាយ ចាកការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង៥ ឈ្លាសវៃ ក្នុងអរិយសច្ច ជាឧបាសិកា របស់ព្រះគោតម ដែលមានបញ្ញាចក្ខុ មានយស ខ្ញុំមានយស ដោយសីល ជារបស់ខ្លួនផង ដោយយសផង រមែងសោយនូវបុណ្យ ជារបស់នៃខ្លួនខ្ញុំ ដល់នូវសេចក្តីសុខ មិនមានរោគ ព្រោះហេតុនោះ បានជាខ្ញុំ មានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេច ដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណា នីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយផលបុណ្យនោះ ។

មម ច ភន្តេ វចនេន ភគវតោ បាទេ សិរសា វន្ទេយ្យាសិ ឧត្តរា នាម ភន្តេ ឧបាសិកា ភគវតោ បាទេ សិរសា វន្ទតីតិ ។ អនច្ឆរិយំ ខោ បនេតំ ភន្តេ យំ មំ ភគវា អញ្ញតរស្មឹ សាមញ្ញផលេ ព្យាករេយ្យ ។ តំ ភគវា សកទាគាមិផលេ ព្យាកាសីតិ ។

ឧត្តរាវិមានំ បណ្ណរសមំ ។

## សោឡសមំ សិរីមាវិមានំ

(១៦) យុត្តា ច តេ បរមអលង្កតា ហយា
អធោមុខា អឃសិគមា ពលី ជវា
អភិនិម្មិតា បញ្ចរថា សតា ច តេ
អន្វេន្តិ តំ សារថិចោទិតា ហយា
សា តិដ្ឋសិ រថវរេ អលង្កតា
ឱភាសយំ ជលមិវ ជោតិបាវកោ
បុច្ឆាមិ តំ វរតនុ អនោមទស្សនេ[១]
កស្មា កាយា អនធិវរំ ឧបាគមិ ។

១ ម. វរតនុ អនុមទស្សនេ ។

បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ ថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគ ដោយសិរ្ស: តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចំរើន ឧបាសិកាឈ្មោះឧត្តរា សូមថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរ្ស: ។ បពិត្រលោកម្ចាស់ ព្រះមានព្រះភាគ គប្បីព្យាករខ្ញុំក្នុងសាមញ្ញផលណាមួយ ដោយហេតុណា ហេតុនុ៎ះ ជារបស់អស្ចារ្យលម្អទេ ។ ព្រះមានព្រះភាគ ទ្រង់ព្យាករចំពោះនាងឧត្តរានោះ ក្នុងសកទាគាមិផល ។

បប់ ឧត្តរាវិមាន ទី ១៥ ។

# សិរីមាវិមាន ទី ១៦

(១៦) (ព្រះវង្គីសត្ថេរសួរថា) សេះទាំងឡាយ ដែលនាងទឹមហើយ ប្រដាប់ដោយគ្រឿងអលង្ការដ៏ឧត្តម មានមុខសំយុងចុះ មានកម្លាំង មានសន្ទុះដ៏លឿន ទៅក្នុងអាកាសបាន រថទាំងឡាយ៥០០ កើតឡើងដល់នាង សេះទាំងឡាយ ដូចជានាយសារថី ដាស់តឿនហើយ តាមហែនាង នាងមានខ្លួនប្រដាប់ហើយ ឋិតនៅលើរថដ៏ប្រសើរ ញាំងពន្លឺឲ្យរុងរឿង ដូចជាភ្លើង ភ្លឺព្រោងព្រាយ នាងមានរូបដ៏ប្រសើរ មានរូបគួរមើល មិនថយថោក អាត្មាសូមសួរនាង នាងមកអំពីពួកណា បូលមកគាល់ ព្រះសម្មាសម្ពុទ្ធ ដ៏ប្រសើរបំផុត ។

កាមគ្គបត្តានំ យមាហុ(១) អនុត្តរា

និម្មាយ និម្មាយ រមន្តិ ទេវតា

តស្មា កាយា អច្ឆរាកាមវណ្ណិនី(២)

ឥធាគតា អនធិវរំ នមស្សិតុំ ។

កឹ ត្វំ បុរេ សុចរិតមាចរី ឥធ

កេនាសិ ត្វំ អមិតយសា សុខេធិតា

ឥទ្ធី ច តេ អនធិវរា វិហង្គមា

វណ្ណោ ច តេ ទស ទិសា វិរោចតិ

ទេវេហិ ត្វំ បរិវុតា សក្កតា ចសិ

កុតោ ចុតា សុគតិគតាសិ ទេវតេ

កស្ស វា ត្វំ វចនករានុសាសនឹ

អាចិក្ខ មេ ត្វំ យទិ ពុទ្ធសាវិកា(តិ) ។

នគន្តរេ នគរវរេ សុមាបិតេ

បរិចារិកា រាជវរស្ស សិរីមតោ

នច្ចេហិ គីតេហិ បរមសុសិក្ខិតា អហុំ(៣)

---

១ ឱ. យមាហុ ។ ២ ម. អច្ឆរាកាមវណ្ណិនិ ។ ៣ ឱ. ម. អហុំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ វិមានវត្ថុ

(ទេវតាតបថា) អ្នកប្រាជ្ញទាំងឡាយ សរសើរទេវ-និកាយណាថា ប្រសើរ ជាងពួកទេវតា ជាន់បរនិម្មិតវសវត្តី ដែលដល់នូវការប្រសើរដោយកាម (ព្រោះ) ទេវតាទាំងឡាយ (ក្នុងទេវនិកាយនោះ) និម្មិតដោយខ្លួនឯង ហើយត្រេកអរ ខ្ញុំជាស្រីអប្សរ ទ្រទ្រង់នូវរូបតាមប្រាថ្នា ចុះអំពីពួកនិម្មានរតី-ទេវតានោះ មកកាន់មនុស្សលោកនេះ ដើម្បីថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ព្រះអង្គមិនមានអ្នកដទៃប្រសើរលើស ។

(ព្រះវង្គីសត្ថេរសួរថា) ក្នុងកាលមុន នាងបានប្រព្រឹត្តសុចរិតដូចម្តេច នាងមានយសធំ ចំរើនដោយសេចក្តីសុខ នាងមានឫទ្ធិ មិនមានអ្នកដទៃប្រសើរលើស ទៅកាន់អាកាសបាន ទាំងសម្បុររបស់នាង ក៏រុងរឿងទៅក្នុងទិសទាំង ១០ នាងមានទេវតាហោមរោមធ្វើសក្ការៈ ម្នាលទេវតា នាងច្យុតអំពីឋានណា មកកាន់សុគតិនេះ នាងធ្វើតាមពាក្យប្រដៅអ្នកណា ចូរនាងប្រាប់ដល់អាត្មា បើនាងជាពុទ្ធសាវិកា ។

(ទេវតាតបថា) ខ្ញុំជាស្ត្រីបំរើ របស់ស្តេចដ៏ប្រសើរ (ព្រះបាទពិម្ពិសារៈ) មានសិរី ក្នុងនគរដ៏ឧត្តម ដែលគេសាងដោយល្អ ក្នុងចន្លោះនៃភ្នំ (ទាំង ៥ មានភ្នំឈ្មោះវេភារៈជាដើម) បានសិក្សាស្ទាត់ ដោយរបាំ និងចម្រៀង

សិរីមាតិ មំ រាជគហេ អវេទិសុ
ពុទ្ធោ ច មេ ឥសិនិសភោ វិនាយកោ
អទេសយិ សមុទយទុក្ខនិច្ចតំ
អសង្ខតំ ទុក្ខនិរោធំ សស្សតំ
មគ្គញ្ចិមំ អកុដិលំ អញ្ជសំ សិវំ
សុត្វានហំ អមតបទំ អសង្ខតំ
តថាគតស្ស អនធិវរស្ស សាសនំ
សីលេស្វាហំ បរមសុសំវុតា អហុំ
ធម្មេ ឋិតា នរវរពុទ្ធទេសិតេ
ញត្វាន តំ វិរជំ បទំ អសង្ខតំ
តថាគតេន អនធិវរេន ទេសិតំ
តត្ថេវហំ សមថសមាធិមាផុសិំ
សាយេវ មេ បរមនិយាមតា អហុ
លទ្ធានហំ អមតវរំ វិសេសនំ
ឯកំសិកា អភិសមយេ វិសេសិយ
អសំសយា ពហុជនបូជិតា អហំ
ខិឌ្ឌំ(១) រតឹ បច្ចនុភោមនប្បកំ

---

១ ម. ខិឌ្ឌា ។

វិមានវត្ថុ បីឋវគ្គ ទី ១ សិរីមាវិមាន ទី ១៦

ពួកជនក្នុងនគររាជគ្រឹះ បានស្គាល់ខ្ញុំថាសិរិមា ឯព្រះពុទ្ធជាបុគ្គល ស្វែងរកនូវគុណ មានសីលគុណជាដើម ដូចគោឈ្មោះនិសភៈ គឺគោប្រសើរជាងគោទាំងពួង ជាបុគ្គលដឹកនាំនូវសត្វទាំងឡាយ បានសម្តែងនូវសមុទយសច្ច និងទុក្ខសច្ច ថាជារបស់មិនទៀង នូវទុក្ខនិរោធសច្ចដែលមិនមានបច្ច័យតាក់តែង ថាជារបស់ទៀង និងមគ្គសច្ចនេះ ជាផ្លូវមិនវៀច ជាគន្លងដ៏ក្សេម ដល់ខ្ញុំ លុះខ្ញុំបាន ស្តាប់នូវអច្ចុតបទនៃអមតនិព្វាន ដែលមិនមានបច្ច័យប្រជុំតាក់តែង ជាពាក្យប្រដៅរបស់ព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង ហើយ ខ្ញុំបានសង្រួមដ៏ឧត្តមប្រពៃ ក្នុងសីលទាំងឡាយ តាំងនៅ ក្នុងធម៌ដែលព្រះពុទ្ធប្រសើរជាងជនទ្រង់សម្តែងហើយ លុះដឹងអច្ចុត-បទដែលប្រាសចាករាគៈ មិនមានបច្ច័យប្រជុំតាក់តែងនោះ ដែល ព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង ទ្រង់សម្តែងហើយ ខ្ញុំបាននូវសមាធិ ដែលកើតអំពីសមថៈ ក្នុងអត្តភាពនោះឯង ការ បាននូវសមាធិរបស់ខ្ញុំនោះឯង ជាមគ្គនិយាមដ៏ឧត្តម ខ្ញុំបាននូវអមត·និព្វានដ៏ប្រសើរវិសេស មានសេចក្តីជឿដ៏ពិត បានដល់នូវគុណ-វិសេសក្នុងការត្រាស់ដឹង(នូវសច្ចៈ) មិនមានសង្ស័យ មានពួកជន ច្រើនបូជាហើយ សោយនូវការលេង និងសេចក្តីត្រេកអរដ៏ច្រើន

យំ អហំ អមតទសម្ហិ ទេវតា

តថាគតស្ស អនធិវរស្ស សាវិកា

ធម្មដ្ឋា បឋមផលេ បតិដ្ឋិតា

សោតាបន្នា ន ច បុនមត្ថិ ទុគ្គតិ

សា វន្ទិតុំ អនធិវរំ ឧបាគមឹ

បាសាទិកេ កុសលរតេ ច ភិក្ខវោ

នមស្សិតុំ សមណសមាគមំ សិវំ

សគារវា សិរិមតោ ធម្មរាជិនោ

ទិស្វា មុនឹ មុទិតមនម្ហិ បីណិតា

តថាគតំ នរវរធម្មសារថឹ[១]

តណ្ហច្ឆិទំ កុសលរតំ វិនាយកំ

វន្ទាមហំ បរមហិតានុកម្បកន្តិ ។

សិរីមាវិមានំ សោឡសមំ ។

## សត្តរសមំ បេសការិយវិមានំ

(១៧) ឥទំ វិមានំ រុចិរំ បភស្សរំ

វេឡុរិយថម្ភំ សតតំ សុនិម្មិតំ[២]

សុវណ្ណរុក្ខេហិ សមន្តមោត្ថតំ

---

១ នរវរទម្មសារថឹតិ អដ្ឋកថាយំ ។ ២ ឱ.ម. សុនិម្មិតំ ។

ខ្ញុំជាទេវតាបានឃើញនូវអមតធម៌យ៉ាងនេះហើយ ជាសាវិកានៃព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង បានឃើញធម៌ តាំងនៅក្នុងផលជាបឋម ដល់នូវសោតៈ ទុគ្គតិក៏មិនមានដល់ខ្ញុំទៀត ខ្ញុំបានចូលមក ដើម្បីថ្វាយបង្គំព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃប្រសើរជាងផង ដើម្បីនមស្ការនូវពួកភិក្ខុ ដែលនាំមកនូវសេចក្តីជ្រះថ្លា ជាអ្នកត្រេកអរក្នុងកុសល (មក) កាន់ទីប្រជុំនៃសមណៈដ៏ក្សេមផង ខ្ញុំមានសេចក្តីគោរព ចំពោះព្រះពុទ្ធជាស្តេចហេតុធម៌ ដ៏មានសិរី បានឃើញព្រះពុទ្ធជាអ្នកប្រាជ្ញ ក៏មានចិត្តរីករាយ ត្រេកអរ ខ្ញុំថ្វាយបង្គំព្រះតថាគត ជាធម្មសារថី ដ៏ប្រសើរជាងជន ផ្តាច់បង់តណ្ហា ត្រេកអរក្នុងកុសល ជាអ្នកទូន្មានសត្វ មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដ៏ឧត្តម ។

ចប់ សិរីមាវិមាន ទី ១៦ ។

## បេសការិយវិមាន ទី ១៧

(១៧) (សក្កទេវរាជសួរថា) វិមាន មានសសរជាវិការៈនៃកែវពិទូរ្យនេះ ដ៏រុងរឿងភ្លឺផ្លេកសព្វកាល ឥតមានមន្ទិល គ្របដោយដើមឈើ ជាវិការៈនៃមាស ដោយជុំវិញ

វិមានវត្ថុស្មឹ បឋមស្ស បីឋវគ្គស្ស សត្តរសមំ បេសការិយវិមានំ

ឋានំ មម កម្មវិបាកសម្ភវំ
តត្រូបបន្នា បុរិមច្ឆរា ឥមា
សតំ សហស្សានិ សកេន កម្មុនា
តុវំសិ អជ្ឈុបគតា យសស្សិនី
ឱភាសយំ តិដ្ឋសិ បុព្វទេវតា
សសី អធិគ្គយ្ហ យថា វិរោចតិ
នក្ខត្តរាជារិវ តារកាគណំ
តថេវ ត្វំ អច្ឆរាសង្គណំ ឥមំ
ទទ្ទល្លមានា យសសា វិរោចសិ
កុតោ នុ អាគម្ម អនោមទស្សនេ
ឧបបន្នា ត្វំ ភវនំ មមំ ឥទំ[1]
ព្រហ្មំវ ទេវា តិទសា សហិន្ទកា
សព្វេ ន តប្បាមសេ ទស្សនេន តន្តិ ។
យមេតំ សក្ក អនុបុច្ឆសេ មមំ
កុតោ ចុតា ឥធ អាគតា តុវំ[2]
ពារាណសី នាម បុរត្ថិ កាសិនំ
តត្ថ បុរេ អហោសឹ បេសការិកា[3]

---

១ ម. ឥមំ ។ ២ ម. អាគច្ឆិតិ ភវ ។ ៣ ឱ. ម. ពេសការិកា ។

ឋានរបស់យើង កើតឡើងព្រម ដោយអំណាចផលនៃកម្ម ពួកស្រ្តីអប្សរពីកាលមុនដែលកើតក្នុងវិមាននោះចំនួន ១សែន នាក់ នាងជាអ្នកមានយស កើតឡើងដោយកម្មជារបស់ខ្លួន នាងជាបុត្រទេវតា ញុំាងរស្មីឲ្យភ្លឺតាំងនៅ ដូចព្រះចន្ទជាស្ដេចនៃផ្កាយ រមែងរុងរឿងគ្របសង្កត់ពួកផ្កាយ នាងថ្កើងរុងរឿង ដោយយស ជាងពួក នៃស្រ្តីអប្សរនេះ យ៉ាងនោះដែរ ម្នាលនាង មានរូបគួរមើល មិនថោកថយ នាងមកពីភពណាហ្ន៎ បានមកកើតក្នុងភពរបស់យើងនេះ ពួកទេវតានៅឋានត្រៃត្រិង្សទាំងអស់ ព្រមទាំងព្រះឥន្ទ្រ មិនឆ្អែតស្កប់ស្កល់ ដោយការមើលនូវនាង ដូចជាពួកទេវតា នៅក្នុងឋានត្រៃត្រិង្ស ព្រមទាំងព្រះឥន្ទ្រ មិនឆ្អែតស្កប់ស្កល់ ដោយការឃើញនូវព្រហ្ម ដូច្នោះដែរ ។

(ទេវធីតាតបថា) បពិត្រសក្កៈ ព្រះអង្គទ្រង់សួរប្រស្នានេះ នឹងខ្ញុំព្រះអង្គថា នាងច្យុតមក អំពីភពណា បានមកកើត ក្នុងទីនេះ ខ្ញុំឈ្មោះ បេសការិកា កើតក្នុងបុរី ឈ្មោះពារាណសី របស់អ្នកដែនកាសីនោះ

ពុទ្ធេ ច ធម្មេ ច បសន្នមានសា
សង្ឃេ ច ឯកគ្គិគតា[១] អសំសយា
អខណ្ឌសិក្ខាបទា អាគតប្ផលា
សម្ពោធិធម្មេ និយតា អនាមយាតិ ។
តត្រាភិនន្ទាមសេ ស្វាគតញ្ច តេ
ធម្មេន ច ត្វំ យសសា វិរោចសិ
ពុទ្ធេ ច ធម្មេ ច បសន្នមានសេ
សង្ឃេ ច ឯកគ្គិគតេ អសំសយេ
អខណ្ឌសិក្ខាបទេ អាគតប្ផលេ
សម្ពោធិធម្មេ និយតេ អនាមយេតិ ។

បេសការិយវិមានំ[២] សត្តមំ ។

## ឧទ្ទានំ

បញ្ចបីឋា តយោ នាវា ទីបា តិលទក្ខិណា
ទ្វេ បតី ទ្វេ សុណិសា ឧត្តរា សិរិមា បេសការិកា[៣]
វគ្គោ តេន បវុច្ចតីតិ ។

ឥត្ថីវិមានេ វគ្គោ បឋមោ ។

---

១ ឯកគ្គតាតិបិ បាឋោ ។ ២ ឱ. ពេសការិយ ។ ម. ពេសការីវិមានំ ។ ៣ ឱ. ម. ពេសការិកា ។

ជាអ្នកមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជឿស៊ប់ មិនមានសេចក្តីសង្ស័យ មានសិក្ខាបទមិនបានដាច់ សម្រេចនូវផលទៀង ក្នុងធម៌ជាគ្រឿងត្រាស់ដឹង មិនមានសេចក្តីទុក្ខ ។

សក្កទេវរាជត្រាស់ថា ម្នាលនាងមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជឿស៊ប់មិនមានសេចក្តីសង្ស័យ មានសិក្ខាបទមិនបានដាច់ បានសម្រេចនូវផលទៀង ក្នុងធម៌ជាគ្រឿងត្រាស់ដឹង មិនមានសេចក្តីទុក្ខ យើងត្រេកអរនូវសម្បត្តិរបស់នាងផង នូវដំណើរមកដោយប្រពៃរបស់នាងផង នាងរុងរឿងដោយធម៌គឺបុញ្ញាសម្បត្តិផង ដោយយសគឺទិព្វសម្បត្តិផង ។

ចប់ បេសការិយវិមាន ទី ១៧ ។

## ឧទ្ទាន (នៃបីឋវគ្គនោះ) គឺ

និយាយអំពីបីឋវិមាន ៤ នាវាវិមាន ៣ បទីបវិមាន ១ តិលទក្ខិណាវិមាន ១ បតិព្វតាវិមាន ២ សុណិសាវិមាន ២ ឧត្តរាវិមាន ១ សិរិមាវិមាន ១ បេសការិយវិមាន ១ លោកហៅថាវគ្គបឋមៈឯង ។

ចប់ វគ្គទី ១ ក្នុងឥត្ថីវិមាន ។

---

# ទុតិយោ បិត្តលតាវគ្គោ

## បឋមំ ទាសីវិមានំ

(១៨) អបិ សក្កោវ ទេវិន្ទោ រម្មេ ចិត្តលតាវនេ
សមន្តា អនុបរិយាសិ នារីគណបុរក្ខតា
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា
ទាសី អហោសឹ បរបេស្សិយា កុលេ

ឧបាសិកា ចក្ខុមតោ គោតមស្ស យសស្សិនោ
តស្សា មេ និក្កមោ អាសិ សាសនេ តស្ស តាទិនោ

# បិត្តលតាវគ្គ ទី ២

## ទាសីវិមាន ទី ១

(១៨) (ព្រះមោគ្គល្លានសួរថា) ចុះនាងដែលមានពួកនារីហោមរោម ហែហម ដើរក្រឡឹងជុំវិញ ក្នុងបិត្តលតាវ័ន ជាទីត្រេកអរ ដូចព្រះឥន្ទ្រជាធំជាងទេវតា ញុំាងទិសទាំងពួង ឲ្យភ្លឺដូចជាផ្កាយព្រឹក តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់នាងក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ទេវធីតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំ កាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស
ជាទាសី បំរើអ្នកដទៃ ក្នុងត្រកូល

ជាឧបាសិកានៃព្រះគោតម មានបញ្ញាចក្ខុ មានយស ឯសេចក្តីព្យាយាម ក្នុងសាសនានៃព្រះពុទ្ធ ប្រកបដោយគាំទគុណនោះ តែងមានដល់ខ្ញុំ

កាមំ ភិជ្ជតុយំ កាយោ នេវ អត្ថេត្ថ សន្ថនំ
សិក្ខាបទានំ បញ្ចន្នំ មគ្គោ សោវត្ថិកោ សិវោ
អកណ្ដកោ អគហណោ ឧជុ សព្ភិបវេទិតោ
និក្កមស្ស ផលំ បស្ស យថិទំ បាបុណិត្តិកា
អាមន្តណិកា រញ្ញោម្ហិ សក្កស្ស វសវត្តិនោ
សដ្ឋី តុរិយសហស្សានិ បដិពោធំ ករោន្តិ មេ
អាលម្ពោ គគ្គមោ ភីមោ សាធុវាទិ បសំសិយោ
បោក្ខរោ ច សុផស្សោ ច វីណា[១] មោក្ខា ច នារិយោ
នន្ទា ចេវ សុនន្ទា ច សោណទិន្នា សុចិម្ហិតា[២]
អលម្ពុសា មិស្សកេសី បុណ្ឌរីកាតិ ទារុណី
ឯណីផស្សា សុផស្សា ច សុភទ្ទា មុទុកាវទី[៣]
ឯតា អញ្ញា ច សេយ្យាសេ អច្ឆរានំ បពោធិកា
តា មំ កាលេនុបាគន្ត្វា អភិភាសន្តិ ទេវតា
ហន្ទ នច្ចាម គាយាម ហន្ទ តំ រមយាមសេ
នយិទំ អកតបុញ្ញានំ កតបុញ្ញានមេវិទំ
អសោកំ នន្ទនំ រម្មំ តិទសានំ មហាវនំ

---

១ ម. វីណោ ។ ២ ម. សុចិម្ហិតា ។ ៣ ម. មុទុការី ប ។

ពោះបើកាយនេះចង់បែកធ្លាយទៅក៏ដោយ ក៏ការបញ្ឈប់នូវសេចក្ដី
ព្យាយាមក្នុងកម្មដ្ឋានទុះមិនមានឡើយ ផ្លូវនៃសិក្ខាបទទាំង ៤
ជារបស់មានសួស្ដី ជាទីក្សេម មិនមានឧបទ្ទា មិនសាំញាំ ជាផ្លូវត្រង់
ដែលសប្បុរសប្រាប់ហើយ ខ្ញុំជាស្ត្រីដល់នូវផលនេះ ដោយសេចក្ដី
ព្យាយាមណា លោកចូរឃើញនូវផល នៃសេចក្ដីព្យាយាមនោះចុះ ខ្ញុំ
ជាមហេសីជាទីស្រឡាញ់នៃសក្កទេវរាជ អ្នកញុំាងអំណាចឲ្យប្រព្រឹត្ត
ទៅក្នុងទេវលោកទាំងពីរ ពួកតូរ្យតន្ត្រី ៦ ហ្មឺន តែងធ្វើនូវការសម្រើប
ចិត្តនៃខ្ញុំ ពួកទេវបុត្តឈ្មោះអាលម្ពៈ ១ គគ្គមៈ ១ ភីមៈ ១ សាធុវាទី ១
សំសិយៈ ១ បោក្ខរៈ ១ សុផស្សៈ ១ ទាំងពួកនារីឈ្មោះ
វីណា ១ មោក្ខា ១ នន្ទា ១ សុនន្ទា ១ សោណទិន្នា ១ សុចិម្ហិកា ១
អាលម្ពុសា ១ មិស្សកេសី ១ បុណ្ឌរីកាតិ ១ ទារុណី ១ ឯនិបស្សា ១
សុបស្សា ១ សុភទ្ទា ១ មុទុកាវទី ១ ទាំងពួកនារីដទៃ ជាអ្នក
ជាស់តឿននេះ ប្រសើរជាងពួកស្ត្រីអប្សរ ពួកទេវធីតាទាំងនោះ
តែងចូលមកជិតខ្ញុំ តាមកាល ហើយពោលពាក្យជាទីត្រេកអរថា
មក យើងទាំងឡាយ នាំគ្នា រាំច្រៀង មក យើងទាំងឡាយ ញុំាង
ទេវធីតានោះឲ្យរីករាយ នេះមិនមែនរបស់ពួកអ្នកមិនធ្វើបុណ្យទេ
នេះរបស់ពួកអ្នកបានធ្វើបុណ្យ ឧទ្យានធំជាទីមិនសោយសោក ជាទី
ត្រេកអររីករាយ រមែងមានដល់ពួកទេវតា នៅក្នុងឋានត្រៃត្រិង្ស

វិមានវត្ថុស្មឹ ទុតិយស្ស ចិត្តលតាវគ្គស្ស ទុតិយំ លខុមាវិមានំ

ទុក្ខំ អកតបុញ្ញានំ ឥធ ចេវ បរត្ថ ច
សុខញ្ច កតបុញ្ញានំ ឥធ ចេវ បរត្ថ ច
តេសំ សហព្យកាមានំ កត្តព្វំ កុសលំ ពហុំ
កតបុញ្ញា ហិ មោទន្តិ សគ្គេ ភោគសមង្គិនោតិ ។

ទាសីវិមានំ បឋមំ ។

## ទុតិយំ លខុមាវិមានំ

(១៩) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ
កេវដ្ដទ្វារា និក្ខម្ម អហុ មយ្ហំ និវេសនំ
តត្ថ សំសរមានានំ សាវកានំ មហេសិនំ
ឱទនំ កុម្មាសំ ឌាកំ លោណសោវីរកញ្ចហំ(១)
អទាសឹ ឧជុភូតេសុ វិប្បសន្នេន ចេតសា

---

១ លោណសោចិរកន្តិ អដ្ឋកថាយំ ទិស្សតិ ។

សេចក្ដីសុខ នៃពួកជនដែលមិនបានធ្វើបុណ្យ មិនមានក្នុងលោកនេះផង ក្នុងលោកខាងមុខផង សេចក្ដីសុខនៃពួកជនដែលបានធ្វើបុណ្យ រមែងមានក្នុងលោកនេះផង ក្នុងលោកខាងមុខផង ពួកបុគ្គល អ្នកប្រាថ្នាឲ្យបានកើត ជាមួយនឹងពួកទេវតាទាំងនោះ គប្បីធ្វើកុសលឲ្យច្រើនចុះ ព្រោះថាបុគ្គលបានធ្វើបុណ្យ ជាអ្នកបានបរិបូណ៌ដោយភោគៈ តែងរីករាយ ក្នុងស្ថានសួគ៌ ។

ចប់ ទាសីវិមាន ទី ១ ។

## លខុមាវិមាន ទី ២

(១៩) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។ បេ ។ បានជានាងមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា លំនៅរបស់ខ្ញុំ តាំងនៅជិតទីជាទីចេញអំពីកេវដ្ដទ្វារ ខ្ញុំមានចិត្តជ្រះថ្លា ក្នុងលោកអ្នកមានចិត្តត្រង់ទាំងឡាយ បានប្រគេនបាយទឹកម្ជូរ នឹងបន្លែជ្រក់ ទឹកដែលផ្សំដោយសម្ភារៈច្រើន ដល់ពួកសាវកអ្នកស្វែងរកគុណធំ ដែលត្រាច់ទៅ ក្នុងទីលំនៅនៃខ្ញុំនោះ

ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសឹ សទា សីលេសុ សំវុតា
សញ្ញមា សំវិភាគា ច វិមានំ អាវសាមហំ
បាណាតិបាតា វិរតា មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ គោតមស្ស យសស្សិនោ
តេន មេតាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

មម ច ភន្តេ វចនេន ភគវតោ បាទេ សិរសា វន្ទេយ្យាសិ លខុមា នាម ភន្តេ ឧបាសិកា ភគវតោ បាទេ សិរសា វន្ទតីតិ ។ អនច្ឆរិយំ ខោ បនេតំ ភន្តេ យំ មំ ភគវា អញ្ញតរស្មឹ សាមញ្ញផលេ ព្យាករេយ្យ ។ តំ ភគវា សកទាគាមិផលេ ព្យាកាសីតិ ។

លខុមាវិមានំ ទុតិយំ ។

ខ្ញុំបានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤
ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង
ខ្ញុំជាអ្នកសង្រួម ក្នុងសីលទាំងឡាយ សព្វកាល មានសេចក្តី
សង្រួម មានការចែកទ្រព្យទាន នៅគ្រប់គ្រងវិមាន ជាអ្នកវៀរចាក
បាណាតិបាត សង្រួមចាកមុសាវាទ វៀរចាកការលួច ចាក
ការប្រព្រឹត្តកន្លងចិត្តស្វាមី ជាអ្នកឆ្ងាយចាកការផឹកទឹកស្រវឹង
ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិកា
របស់ព្រះគោតម ដែលមានបញ្ញាចក្ខុ មានយស ព្រោះ
ហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។ បេ ។
បានជាខ្ញុំ មានសម្បុរភ្លឺច្បាស់ សព្វទិស ។

បពិត្រព្រះថេរៈដ៏ចំរើន សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចំរើន ឧបាសិកាឈ្មោះ លខុមា សូមថ្វាយបង្គំ ព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរ្សៈ ។ បពិត្រលោកដ៏ចំរើន ហេតុនោះ ជាការអស្ចារ្យល្មមទេ ត្រង់ពាក្យថា ព្រះមានព្រះភាគទ្រង់ព្យាករខ្ញុំ ក្នុងសាមញ្ញផលណាមួយ ។ ព្រះមានព្រះភាគទ្រង់ព្យាករនូវនាងលខុមានោះ ក្នុងសកទាគាមិផល ។

ចប់ លខុមាវិមាន ទី ២ ។

# តតិយំ អាចាមទាយិកាវិមានំ

(២០) បិណ្ឌាយ តេ ចរន្តស្ស តុណ្ហីភូតស្ស តិដ្ឋតោ
ទលិទ្ទា កបណា នារី បរាគារំ អវស្សិតា
យា តេ អទាសិ អាចាមំ បសន្នា សេហិ បាណិហិ
សា ហិត្វា មានុសំ ទេហំ កំ នុ សា ទិសតំ គតាតិ ។
បិណ្ឌាយ មេ ចរន្តស្ស តុណ្ហីភូតស្ស តិដ្ឋតោ
ទលិទ្ទា កបណា នារី បរាគារំ អវស្សិតា
យា មេ អទាសិ អាចាមំ បសន្នា សេហិ បាណិហិ
សា ហិត្វា មានុសំ ទេហំ វិប្បមុត្តា ឥតោ ចុតា
និម្មានរតិនោ នាម សន្តិ ទេវា មហិទ្ធិកា
តត្ថ សា សុខិតា នារី មោទតាចាមទាយិកា ។
អហោ ទានំ វរាកិយា កស្សបេ សុប្បតិដ្ឋិតំ
បរាភតេន ទានេន ឥជ្ឈិត្ថ វត ទក្ខិណា
យា មហេសិត្តំ ការេយ្យ ចក្កវត្តិស្ស រាជិនោ
នារី សព្វង្គកល្យាណី ភត្តុ ចានោមទស្សិកា
ឯតស្សាចាមទានស្ស កលំ នាគ្ឃតិ(១) សោឡសិំ

---

១ ម. នគ្ឃតិ ។

# អាចាមទាយិកាវិមាន ទី ៣

(៦០) (ព្រះឥន្ទ្រសួរព្រះកស្សបថា) កាលដែលលោកម្ចាស់ត្រាច់ទៅបិណ្ឌបាត ឈរនៅស្ងៀម មាននារីម្នាក់ កំសត់ កំព្រា អាស្រ័យនៅផ្ទះ នៃបុគ្គលដទៃ ជ្រះថ្លា បានប្រគេនបាយក្តាំង ដល់លោកម្ចាស់ដោយដៃរបស់ខ្លួន នាងនោះ លះបង់ ពង់កាយជារបស់មនុស្សហើយ ទៅកាន់ទិសណាហ្ន៎ ។

(ព្រះថេរៈតបថា) កាលដែលអាត្មាត្រាច់ទៅបិណ្ឌបាត ឈរស្ងៀម មាននារីកំសត់ កំព្រា អាស្រ័យនៅផ្ទះនៃបុគ្គលដទៃ ជ្រះថ្លា បានប្រគេនបាយក្តាំង ដល់អាត្មាដោយដៃរបស់ខ្លួន នាងនោះលះបង់ ពង់កាយជារបស់មនុស្ស រួចផុតស្រឡះ ចាកអំពីមនុស្សលោកនេះទៅហើយ ពួកទេវតាដែលមានឫទ្ធិច្រើន មាននៅក្នុងឋាននិម្មានរតីណា នារីដែលជាអ្នកប្រគេនបាយក្តាំង ក៏ដល់នូវសេចក្តីសុខរីករាយ ក្នុងពួកទេវតា ជាន់និម្មានរតីនោះ ៗ ឱហ្ន៎ ទានរបស់ស្រីកំព្រាដែលបានតាំងទុកល្អ ក្នុងព្រះថេរៈព្រះនាមកស្សបៈ ឱហ្ន៎ ទក្ខិណាសម្រេចហើយដោយទានដែលនាំមក អំពីផ្ទះនៃបុគ្គលដទៃ នារីណាមានអវយវៈល្អទាំងអស់ ជាទីរមិលមើល មិនបានទោកថយនៃភស្តា គប្បីធ្វើនូវភាពនៃខ្លួនជាមហេសី នៃស្តេចចក្រពត្តិ ក៏មិនដល់មួយចំណិតនៃចំណែក ១៦ ។ ដង នៃការឲ្យនូវបាយក្តាំងនោះឡើយ

សតំ និក្ខា សតំ អស្សា  សតំ អស្សតរី រថា
សតំ កញ្ញាសហស្សានិ  អាមុត្តមណិកុណ្ឌលា
ឯកស្សា ចាមទានស្ស  កលំ នាគ្ឃន្តិ សោឡសឹ
សតំ ហេមវតា នាគា  ឦសាទន្តា ឧរូឡ្ហវា
សុវណ្ណកច្ឆា មាតង្គា  ហេមកប្បនិវាសសា
ឯកស្សា ចាមទានស្ស  កលំ នាគ្ឃន្តិ សោឡសឹ
ចតុន្នំ មហាទីបានំ  ឥស្សរំ យោច ការយេ
ឯកស្សា ចាមទានស្ស  កលំ នាគ្ឃតិ សោឡសិន្តិ[១] ។

អាចាមទាយិកាវិមានំ តតិយំ ។

## ចតុត្ថំ ចណ្ឌាលីវិមានំ

(២១) ចណ្ឌាលិ វន្ទ បាទានិ  គោតមស្ស យសស្សិនោ
តមេវ អនុកម្បាយ  អដ្ឋាសិ ឥសិសត្តមោ
អភិប្បសាទេហិ មនំ  អរហន្តម្ហិ តាទិនេ[២]
ខិប្បំ បញ្ជលិកា[៣] វន្ទ  បរិត្តំ តវ ជីវិតន្តិ ។

---

១ ម. តិសទ្ទោ នត្ថិ ។ ២ ឱ. តាទិនិ ។ អដ្ឋកថាយំ តាទិសេតិ ទិស្សតិ ។
៣ ឱ. ម. ខិប្បំ បញ្ជលិកា ។

មាសផ្ដោរ ១០០ សេះ ១០០ រថទឹមអស្សតរ ១០០ កញ្ញា ១សែន មានកុណ្ឌលជាវិការៈនៃកែវមណី ប្រដាប់ហើយ ក៏មិនដល់មួយចំណិតនៃចំណែក ១៦ ។ ដង នៃការឲ្យនូវបាយក្ដាំងនោះឡើយ ដំរីទាំងឡាយដ៏ប្រសើរ ១០០ នៅក្នុងព្រៃហេមពាន្ត មានភ្លុកដូចជាចន្ទោលនង្គ័ល មានកម្លាំងខ្លាំង មានខ្សែជង្គង់មាស ជាតួងមាតង្គៈ មានគ្រឿងប្រដាប់វិចិត្រហើយ ដោយមាស ក៏មិនដល់មួយចំណិត នៃចំណែក ១៦ ។ ដង នៃការឲ្យនូវបាយក្ដាំងនោះឡើយ បុគ្គលណា គប្បីធ្វើនូវភាព នៃខ្លួនជាធំក្នុងទ្វីបទាំង ៤ ក្នុងលោកនេះ ក៏នៅមិនទាន់ដល់មួយចំណិត នៃចំណែក ១៦ ។ ដង នៃការឲ្យនូវបាយក្ដាំងនោះឡើយ ។

ចប់ អាចាមទាយិកាវិមាន ទី ៣ ។

# ចណ្ឌាលីវិមាន ទី ៤

(៦១) (ព្រះមោគ្គល្លានប្រាប់ថា) នែនាងចណ្ឌាលី នាងចូរថ្វាយបង្គំព្រះបាទនៃព្រះគោតម ដ៏មានយស ព្រះពុទ្ធព្រះអង្គជាឥសីទ័ព ទ្រង់ប្រថាប់នៅដើម្បីអនុគ្រោះនាង ចូរនាងញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះពុទ្ធ ជាព្រះអរហន្តប្រកបដោយតាទិគុណចុះ នាងចូរផ្គងអញ្ជលីឲ្យរហ័ស ថ្វាយបង្គំចុះ ព្រោះថា ជីវិតរបស់នាងតិចណាស់ ។

វិមានវត្ថុស្មិំ ទុតិយស្ស ចិត្តលតាវគ្គស្ស ចតុត្ថំ ចណ្ឌាលីវិមានំ

ចោទិតា ភាវិតត្តេន សរីរន្តិមធារិនា
ចណ្ឌាលី វន្ទិ បាទានិ គោតមស្ស យសស្សិនោ
តមេនំ អវធិ គាវី ចណ្ឌាលី បញ្ជលី ឋិតំ
នមស្សមានំ សម្ពុទ្ធំ អន្ធការេ បភង្ករំ

ខីណាសវំ វិគតរជំ អនេញ្ជំ(១)
ទេវិទ្ធិបត្តា ឧបសង្កមិត្វា
វន្ទាម តំ វីរ មហានុភាវ ។
សុវណ្ណវណ្ណា ជលិតា មហាយសា
វិមានមោរុយ្ហ អនេកចិត្តា
បរិវារិតា អច្ឆរាសង្គណេន
កា ត្វំ សុភេ ទេវតេ វន្ទសេ មមំ(២) (ឥតិ)។

អហំ ភទន្តេ ចណ្ឌាលី តយា(៣) វីរេន(៤) បេសិតា
វន្ទិំ អរហតោ បាទេ គោតមស្ស យសស្សិនោ
សាហំ វន្ទិត្វា(៥) បាទានិ ចុតា ចណ្ឌាលិយោនិយា
វិមានំ សព្វសោ ភទ្ទំ ឧបបន្នម្ហិ នន្ទនេ
អច្ឆរានំ សហស្សានិ បុរក្ខិត្វា មំ តិដ្ឋន្តិ

---

១ ឱ. វិគតរជំ អនេជំ ឯកំ អរញ្ញម្ហិ រហោ និសិន្នំ ។ ម. វិគតរជំ នេជំ ឯកំ អរញ្ញម្ហិ រហោ និសិន្នំ ។ ២ ម. មម ។ ៣ ឱ. តយោ ។ ៤ ម. បេវេន ។ ៥ ឱ. ម. វន្ទិត្វា ។

វិមានវត្ថុ ចិត្តលតាវគ្គ ទី ២ បណ្ឌាលីវិមាន ទី ៤

នាងបណ្ឌាលី ដែលព្រះមហាមោគ្គល្លាន មានខ្លួនអប់រំហើយ ទ្រទ្រង់នូវសរីរៈជាទីបំផុត បានដាស់តឿនហើយ ក៏ថ្វាយបង្គំព្រះបាទាព្រះគោតមដ៏មានយស ក៏ស្រាប់តែមោគោរុះនាងបណ្ឌាលី ដែលកំពុងផ្គងអញ្ជលីថ្វាយបង្គំ នូវព្រះសម្ពុទ្ធ អ្នកធ្វើនូវពន្លឺក្នុងទីងងឹតនោះ

នាងបណ្ឌាលី បានដល់នូវឫទ្ធិនៃទេវតា ចូលមកគាល់
(នូវព្រះមហាមោគ្គល្លាន) ជាព្រះខីណាស្រព ប្រាសចាកធូលី
មិនមានតណ្ហា (ហើយនិយាយថា) បពិត្រលោកមានព្យាយាម
មានអានុភាពច្រើន យើងខ្ញុំសូមថ្វាយបង្គំលោក ។

(ព្រះថេរៈសួរថា) ម្នាលទេវធីតា មានគុណល្អ
នាងជាអ្វី មានសម្បុរដូចជាមាស មានសរីៈដ៏ក្វី មាន
យសធំ ចុះមកអំពីវិមាន ប្រកបដោយវិចិត្រ ដ៏ច្រើន
មានពួកស្រីអប្សរហោមរោម មកថ្វាយបង្គំអាត្មាដូច្នេះ ។

(នាងបណ្ឌាលីទេវធីតាតបថា) បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំឈ្មោះបណ្ឌាលី ដែលលោកម្ចាស់មានសេចក្ដីព្យាយាម បញ្ជូនទៅឲ្យថ្វាយបង្គំព្រះបាទា នៃព្រះគោតម ជាព្រះអរហន្តដ៏មានយស លុះខ្ញុំថ្វាយបង្គំព្រះបាទាហើយ ក៏ច្យុតអំពីកំណើត នៃនាងបណ្ឌាលីមកកាន់វិមាន ដ៏ប្រសើរ ដោយប្រការទាំងពួង កើតឡើងក្នុងនន្ទនឧទ្យាន មានស្រ្តីអប្សរ ១ ពាន់ ហោមរោម

តាសាហំ បវរា សេដ្ឋា វណ្ណេន យសសាយុតា
បហូតកតកល្យាណា សម្បជានា បតិស្សតា
មុនឹ ការុណិកំ លោកេ ភន្តេ វន្ទិតុមាគតាតិ ។
ឥទំ វត្វាន ចណ្ឌាលី កតញ្ញូ កតវេទិនី
វន្ទិត្វា អរហតោ បាទេ តត្ថេវន្តរធាយតីតិ ។

ចណ្ឌាលិវិមានំ ចតុត្ថំ ។

## បញ្ចមំ ភទ្ទិត្ថិកាវិមានំ

(៥២)នីលា បីតា ចកាឡាច មញ្ជិដ្ឋា អថ លោហិតា
ឧច្ចាវចានំ វណ្ណានំ កិញ្ជក្ខបរិវារិតា
មន្ទារវានំ បុប្ផានំ មាលំ ធារេសិ មុទ្ធនិ
នាមេ(១) អញ្ញេសុ កាយេសុ រុក្ខា សន្តិ សុមេធសេ
កេន កាយំ ឧបបន្នា តាវតឹសំ យសស្សិនី(២)
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលំ(ន្តិ)។
ភទ្ទិត្ថិកាតិ មំ អញ្ញឹសុ កិម្ពិលាយំ(៣) ឧបាសិកា
សទ្ធា សីលេន សម្បន្នា សំវិភាគរតា សទា

---

១ ឱ. នមេ ។ ម. នយិមេ ។ ២ ម. យសស្សិនី ។ ៣ ម. អញ្ញំសុ កិមិលាយំ ។

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំជាទេវតា ប្រសើរវិសេស ជាងស្រីអប្សរទាំងនោះ ដោយសម្បុរ ដោយយសនិងអាយុ ជាទេវតាមានកុសលដ៏ច្រើនបានធ្វើហើយ ដឹងខ្លួន មានស្មារតី មកដើម្បីថ្វាយបង្គំនូវព្រះមុនី ព្រះអង្គប្រកបដោយសេចក្តីករុណា ក្នុងលោក ។ លុះនាងចណ្ឌាលី ជាស្ត្រីមានកតញ្ញូកតវេទិនី ពោលពាក្យនេះ ដូច្នេះហើយ ក៏ថ្វាយបង្គំព្រះបាទា នៃព្រះអរហន្តហើយ ក៏បាត់ពីទីនោះទៅ ។

ចប់ ចណ្ឌាលីវិមាន ទី ៤ ។

## ភទ្ទិត្ថិកាវិមាន ទី ៥

(២២) (ព្រះមានព្រះភាគ ត្រាស់សួរថា) នាងមានសម្បុរខៀវផង លឿងផង ខ្មៅផង ហង្សបាទផង ក្រហមផង ពោមពេមដោយលំអងនៃផ្កា មានពណ៌ផ្សេងៗ ទ្រទ្រង់នូវកម្រងផ្កាមន្ទារពុស្សនៅលើក្បាល ម្នាលនាងមានប្រាជ្ញាល្អ ដើមឈើនេះ ក្នុងពួកទេវតាដទៃគ្មានទេ ម្នាលនាងមានយស នាងកើតក្នុងពួកទេវតានៅក្នុងស្ថានត្រៃត្រិង្ស ដោយបុណ្យអ្វី ម្នាលទេវធីតា តថាគតសួរហើយ នាងចូរប្រាប់មក ផលនៃកម្មនេះ ដូចម្តេច ។

(ទេវតានោះតបថា) ជនទាំងឡាយស្គាល់ខ្ញុំថា ភទ្ទិត្ថិកា ខ្ញុំជាឧបាសិកា នៅក្នុងកិម្ពិលានគរ បរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរ ក្នុងការចែករំលែកនូវទាន សព្វកាល

## វិមានវត្ថុស្មឹ ទុតិយស្ស ចិត្តលតាវគ្គស្ស បញ្ចមំ ភទ្ទិត្ថិកាវិមានំ

អច្ឆាទនញ្ច ភត្តញ្ច សេនាសនំ បទីបិយំ
អទាសឹ ឧជុភូតេសុ វិប្បសន្នេន ចេតសា
ចាតុទ្ទសឹ បញ្ចទសឹ យា ច(១) បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសឹ(២) សទា សីលេសុ សំវុតា
បាណាតិបាតា វិរតា មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ អប្បមាទវិហារិនី

កតាវកាសា កតកុសលា តតោ ចុតា
សយម្បភា អនុវិចរាមិ នន្ទនំ
ភិក្ខូ ចាហំ បរមហិតានុកម្បកេ
អភោជយឹ តបស្សិយុគំ មហាមុនឹ
កតាវកាសា កតកុសលា តតោ ចុតា
សយម្បភា អនុវិចរាមិ នន្ទនំ
អដ្ឋង្គិកំ អបរិមិតំ សុខាវហំ
ឧបោសថំ សតតមុបាវសឹ អហំ

---
១ ឱ. យោវ ។ ២ ម. ឧបវសិស្សំ ។

វិមានវត្ថុ ចិត្តលតាវគ្គ ទី ២ ភទ្ទិត្ថិកាវិមាន ទី ៥

ខ្ញុំមានចិត្តជ្រះថ្លាហើយ ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប ខ្ញុំរក្សានូវឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃ ទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមល្អក្នុងសីលទាំងឡាយ សព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង (ចិត្តស្វាមី) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានការនៅដោយសេចក្តីមិនធ្វេសប្រហែស

មានឱកាសនៃសេចក្តីសុចរិតធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ខ្ញុំបានញុំាងពួកភិក្ខុ អ្នកអនុគ្រោះដោយប្រយោជន៍ដ៏ក្រៃលែង និងគូនៃសាវ័កដែលមានតបៈ និងព្រះមហាមុនីឲ្យសោយអាហារ ខ្ញុំមានឱកាសធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ខ្ញុំរក្សានូវឧបោសថប្រកបដោយអង្គ ៨ រកប្រមាណមិនបាន នាំមកនូវសេចក្តីសុខសព្វកាល

កតាវកាសា កតកុសលា តតោ ចុតា

សយម្បភា អនុវិចរាមិ នន្ទនន្តិ ។

ភទ្ទិត្ថិកាវិមានំ បញ្ចមំ ។

## ឆដ្ឋំ សោណទិន្នាវិមានំ

(២៣) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា
បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ
សោណទិន្នាតិ មំ អញ្ញំសុ នាលន្ទាយំ ឧបាសិកា
សទ្ធា សីលេន សម្បន្នា សំវិភាគរតា សទា
អច្ឆាទនញ្ច ភត្តញ្ច សេនាសនំ បទីបិយំ
អទាសឹ ឧជុភូតេសុ វិប្បសន្នេន ចេតសា

ខ្ញុំមានឱកាសធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទី
នោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ។

ចប់ ភទ្ទិត្ថិកាវិមាន ទី ៥ ។

## សោណទិន្នាវិមាន ទី ៦

(៤៣) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរល្អ ញាំងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាង កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី
នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់
នាង ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា ជនទាំងឡាយស្គាល់នូវខ្ញុំថា សោណទិន្នា ខ្ញុំជាឧបាសិកា នៅក្នុងស្រុកនាលន្ទា ជាស្ត្រីបរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន សព្វកាល មានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ភត្ត សេនាសនៈ និងគ្រឿងប្រទីប

ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសឹ សទា សីលេសុ សំវុតា
បាណាតិបាតា វិរតា មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ គោតមស្ស យសស្សិនោ
តេន មេ តាទិសោ វណ្ណោ ។បេ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

សោណទិន្នាវិមានំ ឆដ្ឋំ ។

## សត្តមំ ឧបោសថវិមានំ

(២៩) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។បេ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។បេ។ យស្ស កម្មស្សិទំ ផលំ
ឧបោសថាតិ មំ អញ្ញឹសុ សាកេតាយំ ឧបាសិកា

ខ្ញុំបានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និង ទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង បានសង្រួមក្នុងសីល ទាំងឡាយសព្វកាល ជាអ្នកវៀរចាកបាណាតិបាត សង្រួមចាក មុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង (ចិត្តស្វាមី) និង ការផឹកនូវទឹកស្រវឹង ត្រេកអរ ក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុង អរិយសច្ច ជាឧបាសិកា របស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះបានជាខ្ញុំមានសម្បុរបែបនោះ ។ បេ ។ បានជាខ្ញុំមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

ចប់ សោណទិន្នាវិមាន ទី ៦ ។

## ឧបោសថវិមាន ទី ៧

(២៤) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងដែលមាន សម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ ដោយហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។ បេ ។ បានជា នាងមានសម្បុរភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផល នៃកម្មនេះថា ជនទាំងឡាយ បានស្គាល់ នូវខ្ញុំថា ឧបោសថា ខ្ញុំជាឧបាសិកា នៅក្នុងសាកេតនគរ

សទ្ធា សីលេន សម្បន្នា សំវិភាគរតា សទា
អច្ឆាទនញ្ច ភត្តញ្ច សេនាសនំ បទីបិយំ
អទាសឹ ឧជុភូតេសុ វិប្បសន្នេន ចេតសា
ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសឹ សទា សីលេសុ សំវុតា
បាណាតិបាតា វិរតា មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ គោតមស្ស យសស្សិនោ
តេន មេ តាទិសោ វណ្ណោ ។បេ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អភិក្កន្តំ នន្ទនំ សុត្វា ឆន្ទោ មេ ឧបបជ្ជថ
តត្ថ ចិត្តំ បណិធាយ ឧបបន្នម្ហិ នន្ទនំ
នាកាសឹ សត្ថុ វចនំ ពុទ្ធស្សាទិច្ចពន្ធុនោ
ហីនេ ចិត្តំ បណិធាយ សាម្ហិ បច្ឆានុតាបិនី ។

## សុត្តន្តបិដក ខុទ្ទកនិកាយ វិមានវត្ថុ

បរិបូណ៌ដោយសទ្ធានិងសីល មានចិត្តត្រេកអរ ក្នុងការចែករំលែកនូវទាន សព្វកាល មានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលទាំងឡាយ សព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង (ចិត្តស្វាមី) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិកា របស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជា ខ្ញុំមានសម្បុរបែបនោះ ។ បេ ។ បានជាខ្ញុំមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

សេចក្តីពេញចិត្ត កើតឡើងដល់ខ្ញុំ ព្រោះបានឮនូវនន្ទនវ័នជារឿយ ៗ ខ្ញុំបានដំកល់នូវចិត្ត ក្នុងនន្ទនវ័ន ក្នុងតាវត្តិង្សនោះ ហើយចូលទៅកាន់នន្ទនវ័ន ខ្ញុំពុំបានធ្វើតាមព្រះពុទ្ធដីកា របស់ព្រះសាស្តា ជាព្រះពុទ្ធ ជាផៅពង្សនៃព្រះអាទិត្យទេ ខ្ញុំមានសេចក្តីក្តៅក្រហាយ ក្នុងកាលខាងក្រោយ ព្រោះដំកល់នូវចិត្ត ក្នុងធម៌ដ៏ថោកទាប ។

កីវ ចិរំ វិមានស្មឹ ឥធ វស្សសុ ពោសជេ
ទេវតេ បុច្ឆិតាចិក្ខ យទិ ជានាសិ អាយុនោ (ឥតិ) ។
សដ្ឋីវស្សសហស្សានិ (១) ឥធ ឋត្វា មហាមុនិ
ឥតោ ចុតា គមិស្សាមិ មនុស្សានំ សហព្យតន្តិ ។
មា ត្វំ ឧពោសជេ ភយំ សម្ពុទ្ធេនាសិ ព្យាកតា
សោតាបន្នា វិសេសយិ បហីនា តវ ទុគ្គតីតិ ។

ឧបោសថវិមានំ សត្តមំ ។

# អដ្ឋមំ សុនិទ្ទាវិមានំ

(២៨) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។បេ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។បេ។ យស្ស កម្មស្សិទំ ផលំ
សុនិទ្ទាតិ មំ អញ្ញិសុ (២) រាជគហស្មឹ ឧបាសិកា
សទ្ធាសីលេន សម្បន្នា សំវិភាគរតា សទា

---

១ ឱ ម. ឯត្តកេ តិស្សោ ច វស្សកោដិយោតិ អត្ថិ ។ ២ ម. និទ្ទាតិ មមំ អញ្ញិសុ ។

(ព្រះថេរៈសួរថា) ម្នាលនាងឧបោសថា នាងនៅក្នុងវិមាននេះ អស់កាលយូរប៉ុន្មាន ម្នាលទេវធីតា អាត្មាសួរនាងហើយ នាងចូរប្រាប់មក បើនាងដឹងប្រមាណអាយុ ។

(ទេវតាតបថា) បពិត្រព្រះថេរៈជាអ្នកប្រាជ្ញធំ ខ្ញុំឋិតនៅក្នុងវិមាននេះ ៦ម៉ឺនឆ្នាំ ច្យុតអំពីវិមាននេះហើយនឹងទៅកើតជាមួយនឹងពួកមនុស្ស ។

(ព្រះថេរៈពោលថា) ម្នាលនាងឧបោសថា នាងកុំខ្លាចឡើយ នាងគឺព្រះសម្ពុទ្ធទ្រង់ព្យាករហើយ ថាជាស្ត្រីបានដល់សោតៈ សម្រេចគុណវិសេសហើយ ទុគ្គតិ នាងបានលះបង់ហើយ ។

ចប់ ឧបោសថវិមាន ទី ៧ ។

## សុនិទ្ធាវិមាន ទី ៨

(២៥) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរល្អ ញុំាងទិសទាំងពួង ឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជា នាងមានសម្បុរបែបនោះ ។ បេ ។ បានជានាងមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃកម្មនេះថា ជនទាំងឡាយបានស្គាល់នូវខ្ញុំថា សុនិទ្ធា ខ្ញុំជាឧបាសិកា នៅក្នុងក្រុងរាជគ្រឹះ បរិបូណ៌ដោយ សទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន សព្វកាល

អច្ឆាទនញ្ច ភត្តញ្ច សេនាសនំ បទីបិយំ
អទាសិំ ឧជុភូតេសុ វិប្បសន្នេន ចេតសា
ចាតុទ្ទសិំ បញ្ចទសិំ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសិំ សទា សីលេសុ សំវុតា
បាណាតិបាតា វិរតា មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ គោតមស្ស យសស្សិនោ
តេន មេតាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

សុនិទ្ទាវិមានំ អដ្ឋមំ ។

## នវមំ សុទិន្នាវិមានំ

(៤៦) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

ខ្ញុំមានចិត្តជ្រះថ្លាក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួម ក្នុងសីលទាំងឡាយសព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ការប្រព្រឹត្តិកន្លង (ចិត្តស្វាមី) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃ ក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។ បេ ។ បានជាខ្ញុំ មានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

ចប់ សុនិទ្ធាវិមានទី ៨ ។

## សុទិន្នាវិមាន ទី ៩

(២៦) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរល្អ ញុំាងទិសទាំងពួង ឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជា នាងមានសម្បុរបែបនោះ ។ បេ ។ បានជានាងមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

វិមានវត្ថុស្មិំ ទុតិយស្ស ចិត្តលតាវគ្គស្ស នវមំ សុទិន្នាវិមានំ

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
សុទិន្នាតិ មំ អញ្ញាសុ រាជគហស្មិំ ឧបាសិកា
សទ្ធា សីលេន សម្បន្នា សំវិភាគរតា សទា
អច្ឆាទនញ្ច ភត្តញ្ច សេនាសនំ បទីបិយំ
អទាសឹ ឧជុភូតេសុ វិប្បសន្នេន ចេតសា
ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសឹ សទា សីលេសុ សំវុតា
បាណាតិបាតា វិរតា មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ គោតមស្ស យសស្សិនោ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

សុទិន្នាវិមានំ នវមំ ។

វិមានវត្ថុ បិត្តលតាវគ្គ ទី ២ សុទិន្នាវិមានទី ៩

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ល។ នូវផលនៃកម្មនេះ ថាជនទាំងឡាយបានស្គាល់នូវខ្ញុំថា សុទិន្នា ខ្ញុំជាឧបាសិកា នៅក្នុងក្រុងរាជគ្រឹះ បរិបូណ៌ដោយ សទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន សព្វកាល ខ្ញុំមានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿង ស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សា ឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃ ទី ១៤ ទី១៥ និង ទី ៨ នៃ បក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលទាំងឡាយ សព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយ ចាកការលួច ចាកការប្រព្រឹត្តិកន្លង(បិត្តស្វាមី) និងការផឹកនូវទឹក ស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង៥ ឈ្លាសវៃ ក្នុងអរិយសច្ច ជាឧបាសិកា នៃព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំ មានសម្បុរបែបនោះ ។ល។ បានជាខ្ញុំ មានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

ចប់ សុទិន្នាវិមាន ទី ៩ ។

## ទសមំ ភិក្ខុទាយិកាវិមានំ

(២៧) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
អទ្ទសំ វិរជំ ពុទ្ធំ វិប្បសន្នមនាវិលំ
តស្ស អទាសិហំ (១) ភិក្ខំ បសន្នា សកេហិ បាណិហិ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ភិក្ខុទាយិកាវិមានំ ទសមំ ។

## ឯកាទសមំ ទុតិយភិក្ខុទាយិកាវិមានំ

(២៨) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។

---

១ ឱ.ម. អទាសហំ ។

# ភិក្ខុទាយិកាវិមាន ទី ១០

(៤៧) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចជាផ្កាយព្រឹក បិតនៅ ព្រោះហេតុអ្វី បានជា នាងមានសម្បុរបែបនោះ ។ បេ ។ បានជានាងមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃកម្មនេះថា ខ្ញុំកាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក បានឃើញ ព្រះពុទ្ធប្រាសចាកធូលីគឺកិលេស មានព្រះហឫទ័យថ្លា មិនល្អក់ មានចិត្តជ្រះថ្លា បានថ្វាយបង្អែមដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។ បេ ។ បានជាខ្ញុំ មានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

ចប់ ភិក្ខុទាយិកាវិមាន ទី ១០ ។

# ទុតិយភិក្ខុទាយិកាវិមាន ទី ១១

(៤៨) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរល្អ ញុំាងទិសទាំងពួង ឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក បិតនៅ ព្រោះហេតុអ្វី បានជានាង មានសម្បុរបែបនោះ ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតា

បុរិមាយ ជាតិយា មនុស្សលោកេ

អទ្ទសំ វិរជំ ពុទ្ធំ វិប្បសន្នមនាវិលំ

តស្ស អទាសិហំ ភិក្ខំ បសន្នា សកេហិ បាណិហិ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទុតិយភិក្ខាទាយិកាវិមានំ ឯកាទសមំ ។

## ឧទ្ទានំ

ទាសី ចេវ លខុមា ច អថ អាចាមទាយិកា

ចណ្ឌាលី ភទ្ទិត្ថិកា ចេវ សោណទិន្នា ឧបោសថា

និទ្ទា ចេវ សុទិន្នា ច ទ្វេ ច ភិក្ខាយ ទាយិកា

វគ្គោ តេន បវុច្ចតីតិ ។

ឥត្ថិវិមានេ ទុតិយោ វគ្គោ ។

ភាណវារំ បឋមំ ។

បានជានាង មានសម្បុរភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃកម្មនេះថា

ខ្ញុំ កាលដែលកើត ជាមនុស្ស ក្នុងពួក
មនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក

បានឃើញព្រះពុទ្ធ មានធូលីគឺរាគៈ ទៅប្រាសហើយ ព្រះអង្គមានព្រះហឫទ័យថ្លា មិនល្អក់ ក៏មានចិត្តជ្រះថ្លា បានថ្វាយបង្ហាន់ ដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។ បេ ។ បានជាខ្ញុំ មានសម្បុរភ្លឺច្បាស់ សព្វទិស ។

ចប់ ទុតិយភិក្ខាទាយិកាវិមាន ទី ១១ ។

## ឧទ្ទាន (នៃចិត្តលតាវគ្គ ទី២ នោះ) គឺ

និយាយអំពីទាសីវិមាន ១ លខុមាវិមាន ១ អាចាមទាយិកា-វិមាន ១ ចណ្ឌាលីវិមាន ១ ភទ្ទិត្ថិកាវិមាន ១ សោណទិន្នា-វិមាន ១ ឧបោសថវិមាន ១ សុនិទ្ទាវិមាន ១ សុទិន្នាវិមាន១ ភិក្ខាទាយិកាវិមាន ២ លើក លោកហៅថា វគ្គដូច្នេះឯង ។

ចប់វគ្គ ទី ២ ក្នុងឥត្ថីវិមាន ។

ចប់ភាណវារៈ ទី ១ ។

# តតិយោ បារិច្ឆត្តកវគ្គោ

## បឋមំ ឧឡារវិមានំ

(២៩) ឧឡារោ តេ យសោ វណ្ណោ សព្វា ឱភាសតេ ទិសា

នារិយោ នច្ចន្តិ គាយន្តិ ទេវបុត្តា អលង្កតា
មោទេន្តិ បរិវារេន្តិ តវ បូជាយ ទេវតេ
សោវណ្ណានិ វិមានានិ តវិមានិ សុទស្សនេ
តុវំសិ ឥស្សរា តេសំ សព្វកាមសមិទ្ធិនី
អភិជាតា មហន្តាសិ ទេវកាយេ បមោទសិ
ទេវតេ បុច្ឆិតាចិក្ខ យស្ស[១] កម្មស្សិទំ ផលន្តិ[២] ។

អហំ មនុស្សេសុ មនុស្សភូតា
ទុស្សីលេ កុលេ សុណិសា អហោសឹ

អស្សទ្ធេសុ កទរិយេសុ សទ្ធាសីលេន សម្បន្នា
បិណ្ឌាយ ចរមានស្ស អបូវំ តេ អទាសហំ
តស្ស អទាសហំ បូវំ បសន្នា សេហិ បាណិហិ
ឥតិស្សា សស្សុ បរិភាសិ អវិនីតា តុវំ វធូ
ន មំ សម្បុច្ឆិតុំ ឥច្ឆិ សមណស្ស ទទាមហំ
តតោ មេ សស្សុ កុបិតា បហាសិ មុសលេន មំ

---

១ ម. កិស្ស ។ ២ ម. តិសទ្ទោ នត្ថិ ។

# បារិច្ឆត្តកវគ្គ ទី ៣

## ឧឡារវិមាន ទី ១

(៤៩) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានយសនឹងសម្បុរដ៏ឧត្តម ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ពួកនារីនឹងពួកទេវបុត្ត បានប្រដាប់គ្រឿងអលង្ការ រាំ ច្រៀង រីករាយ ដោមរោម ដើម្បីបូជា ដល់នាង ម្នាលនាងសុទស្សនា វិមានទាំងឡាយជាវិការៈនៃមាសនេះ ជារបស់នាង បំណែកនាងសោត ជាឥស្សរៈលើវិមានទាំងនោះ ញុំាងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេច នាងមានជាតិល្អ ជាអ្នកធំ រីករាយ ក្នុងពួកទេវតា ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ ផលនៃកម្មនេះ តើដូចម្តេច ។

(ទេវតានោះតបថា) ខ្ញុំកាលកើត ជាមនុស្ស ក្នុង
ពួកមនុស្ស ជាកូនប្រសា ក្នុងត្រកូលទ្រុស្តសីល

ជាអ្នកមិនមានសទ្ធា ជាមនុស្សកំណាញ់ ប៉ុន្តែខ្ញុំជាអ្នកបរិបូណ៌ដោយសទ្ធា នឹងសីល បានប្រគេននំ ដល់លោកម្ចាស់ ដែលត្រាច់ទៅបិណ្ឌបាត ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំ ដល់លោកម្ចាស់ដោយដៃរបស់ខ្លួន មាតាក្មេករបស់ខ្ញុំនោះ បានប្រទេចផ្តាសាថា ហឹងជាស្ត្រីមានគូស្រករ គេប្រដៅមិនបាន មិនប្រាថ្នានឹងទទួលពាក្យអញ ក្នុងកាលនោះ មាតាក្មេកខ្ញុំខឹង ក៏សំពងខ្ញុំនឹងអង្រែ

កុជ្ឈន្តិញ្ញា អវធិ មំ ឆាសត្តី ជីវិតំ ពរំ
សាហំ កាយស្ស ភេទា ច វិប្បមុត្តា តតោ ចុតា
តាវតឹសានំ ទេវានំ ឧបបន្នា សហព្យតំ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ឧឡារវិមានំ បឋមំ ។

## ទុតិយំ ឧច្ឆុវិមានំ

(៣០) ឱភាសយិត្វា បឋវឹ សទេវកំ
អតិរោចសិ ចន្ទិមសុរិយា វិយ
សិរិយា ច វណ្ណេន យសេន តេជសា
ព្រហ្មាវ ទេវេ តិទសេ សហិន្ទកេ
បុច្ឆាមិ តំ ឧប្បលមាលធារិនិ
អាវេឡិនិ កញ្ចនសន្និភត្តចេ
អលង្កតេ ឧត្តមវត្ថធារិនិ
កា ត្វំ សុភេ ទេវតេ វន្ទសេ មមំ
កឹ ត្វំ បុរេ កម្មំ អកាសិ អត្តនា
មនុស្សភូតា បុរិមាយ ជាតិយា
ទានំ សុចិណ្ណំ អថ សីលសញ្ញមំ

ត្រូវត្រង់ចង្កួយស្មាខ្ញុំ ខ្ញុំមិនអាច ដើម្បីរស់នៅយូរបាន ខ្ញុំក៏បែកធ្លាយរាងកាយ ផុតស្រឡះ ច្យុតចាកអត្តភាពនោះ បានមកកើតជាមួយនឹងពួកទេវតា ជាន់តាវត្តិង្ស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរល្អ បែបនោះ ។ បេ ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់ សព្វទិស ។

ចប់ ឧឡារវិមាន ទី ១ ។

## ឧច្ឆុវិមាន ទី ២

(៣០) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងរុងរឿងក្រពេក ដោយសិរីផង វណ្ណៈផង យសផង តេជៈផង ដូចព្រះចន្ទនឹងព្រះអាទិត្យ ញុំាងផែនដីព្រមទាំងទេវលោកឲ្យភ្លឺច្បាស់ ឬដូចព្រហ្មរុងរឿងជាងពួកទេវតាព្រមទាំងព្រះឥន្ទ្រ ក្នុងឋានត្រៃត្រឹង្ស ម្នាលទេវតាអ្នកមានគុណល្អ ទ្រទ្រង់កម្រងផ្កាឧប្បល មានគ្រឿងប្រដាប់ត្រចៀក មានសម្បុរស្បែកដូចមាស មានខ្លួនប្រដាប់ហើយ ទ្រទ្រង់សំពត់ដ៏ឧត្តម អាត្មាសូមសួរនាង នាងជាអ្វី មកថ្វាយបង្គំអាត្មា នាងកាលកើតជាមនុស្ស ក្នុងជាតិមុន បានធ្វើអំពើអ្វី ដោយខ្លួនឯងក្នុងកាលមុន បានសន្សំទាន ឬបានសង្រួមក្នុងសីល

កេនូបបន្នា សុគតឹ យសស្សិនី

ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលន្តិ ។

ឥទានិ ភន្តេ ឥមមេវ គាមេ

បិណ្ឌាយ អម្ហាកំ ឃរំ ឧបាគមិ

តតោ តេ ឧច្ឆុស្ស[១] អទាសិ ខណ្ឌិកំ

បសន្នចិត្តា អតុលាយ បីតិយា

សស្សុ ច បច្ឆា អនុយុញ្ជតេ មមំ

កហន្នុ ឧច្ឆុំ វធុកេ[២] អវាករិ

ន ឆឌ្ឌិតំ ន ច ខាទិតំ មយា

សន្តស្ស ភិក្ខុស្ស សយំ អទាសិហំ

តុយ្ហំ ឥទំ ឥស្សរិយំ អថោ មមំ

ឥតិស្សា សស្សុ បរិភាសតេ មមំ

បីឋំ គហេត្វា បហារំ អទាសិ មេ

តតោ ចុតា កាលកតម្ហិ ទេវតា

តទេវ កម្មំ កុសលំ កតំ មយា

សុខញ្ច កម្មំ អនុភោមិ អត្តនា

---

១ ឱ. តតោ ឧច្ឆុ អស្ស ។ ២ ម. វធុតេ ។

នាងជាស្ត្រីមានយស បានមកកើតក្នុងសុគតិភព ដោយហេតុអ្វី ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ផលនៃកម្មនេះតើដូចម្តេច ។

(ទេវតានោះតបថា) បពិត្រលោកម្ចាស់ដ៏ចំរើន ក្នុងកាលអម្បាញ់មិញ លោកម្ចាស់ បានចូលទៅកាន់ផ្ទះរបស់ខ្ញុំនេះឯង ដើម្បីបិណ្ឌបាតក្នុងស្រុក ក្នុងកាលនោះ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅ មួយកំណាត់ ដល់លោកម្ចាស់ ដោយបីតិថ្លឹងមិនបាន ក្រោយមក ម្តាយក្មេកខ្ញុំសួរដេញដោលថា ម្នាលស្ត្រីជាកូនចិញ្ចឹម នាងយកអំពៅទៅណាបាត់ ខ្ញុំមិនបានចោល មិនបានទំពាស៊ីទេ ខ្ញុំបានឲ្យដល់ភិក្ខុអ្នកមានចិត្តរម្ងាប់ ដោយខ្លួនឯងទៅហើយ (បើដូច្នោះ) ផ្ទះនេះធំស្រេចនឹងនាង ឬស្រេចនឹងយើង ម្តាយក្មេក ប្រទេចផ្តាសាខ្ញុំដូច្នេះហើយ ក៏ចាប់យកកាំងមកប្រហារខ្ញុំ ខ្ញុំធ្វើមរណកាល ច្យុតចាកអត្តភាពនោះបានមកកើត ជាទេវតា អំពើជាកុសលនោះឯង ដែលខ្ញុំបានធ្វើហើយ ខ្ញុំបានទទួលផលជាសុខ ដោយខ្លួនឯង

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស ទុតិយំ ឧច្ឆុវិមានំ

ទេវេហិ សទ្ធឹ បរិចារិយាមហំ
មោទាមហំ កាមគុណេហិ បញ្ចហិ
តទេវ កម្មំ កុសលំ កតំ មយា
សុខញ្ច កម្មំ អនុភោមិ អត្តនា
ទេវិន្ទគុត្តា តិទសេហិ រក្ខិតា
សមប្បិតា កាមគុណេហិ បញ្ចហិ
ឯតាទិសំ បុញ្ញផលំ អនប្បកំ
មហាវិភាគា មម ឧច្ឆុទក្ខិណា
ទេវេហិ សទ្ធឹ បរិចារិយាមហំ
មោទាមហំ កាមគុណេហិ បញ្ចហិ
ឯតាទិសំ បុញ្ញផលំ អនប្បកំ
មហាជុតិកា មម ឧច្ឆុទក្ខិណា
ទេវិន្ទគុត្តា តិទសេហិ រក្ខិតា
សហស្សនេត្តោរិវ(១) នន្ទនេ វនេ
តុវញ្ច ភទ្ទេ អនុកម្បកំ វិទុំ
ឧបេច្ច វន្ទឹ កុសលញ្ច បុច្ឆិយា(២)

១ ម. សហស្សនេត្តារិវ ។ ២ ម. បុច្ឆិសំ ។

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ ឧច្ឆុវិមាន ទី ២

ខ្ញុំគប់ប្រសព្វផល មួយអន្ទើដោយពួកទេវតា ខ្ញុំរីករាយ ដោយកាមគុណ ៥ អំពើជាកុសលនោះ ខ្ញុំបានធ្វើ ហើយ ខ្ញុំបានទទួលផលអំពើជាសុខ ដោយខ្លួនឯង ខ្ញុំមានព្រះឥន្ទ្រ ជាធំជាងទេវតា គ្រប់គ្រង មានពួក ទេវតា ក្នុងឋានតាវត្តឹង្សក្រោ ឆ្អែតស្កប់ស្កល់ដោយ កាមគុណ ៥ ផលនៃបុណ្យបែបនេះ មានប្រមាណ ច្រើន ឧច្ឆុទក្ខិណាទានរបស់ខ្ញុំមានផលច្រើន ខ្ញុំគប់ ប្រសព្វផល មួយអន្ទើដោយពួកទេវតា ខ្ញុំរីករាយ ដោយកាមគុណ ៥ ផលនៃបុណ្យបែបនេះ មានប្រមាណ ច្រើន ឧច្ឆុទក្ខិណាទានរបស់ខ្ញុំ មានសេចក្តីចំរើន ច្រើន ខ្ញុំមានព្រះឥន្ទ្រជាធំជាងទេវតាគ្រប់គ្រង មាន ពួកទេវតាក្នុងឋានតាវត្តឹង្សក្រោ ដូចជាសហស្សនេត្រ ក្នុងនន្ទនវ័ន បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំចូលមក ថ្វាយបង្គំចំពោះលោកម្ចាស់ អ្នកប្រកបដោយសេចក្តី ករុណា ជាអ្នកប្រាជ្ញផង ទូលសួរនូវអាការមិនមានរោគផង

តតោ តេ ឧជ្ជុស្ស អទាសឹ ខណ្ឌិកំ
បសន្នចិត្តា អតុលាយ បីតិយាតិ ។

ឧជ្ជុវិមានំ ទុតិយំ ។

## តតិយំ បល្លង្កវិមានំ

(៣១) បល្លង្កសេដ្ឋេ មណិសោវណ្ណចិត្តេ
បុប្ផាភិកិណ្ណេ សយនេ ឧឡារេ
តត្ថច្ឆសិ ទេវិ មហានុភាវេ
ឧច្ចាវចា ឥទ្ធិវិកុព្ពមានា
ឥមា ច តេ អច្ឆរាយោ សមន្តតោ
នច្ចន្តិ គាយន្តិ បមោទយន្តិ
ទេវិទ្ធិបត្តាសិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
អហំ មនុស្សេសុ មនុស្សភូតា
អឌ្ឍេ កុលេ សុណិសា អហោសឹ
អក្កោធនា ភត្តុវសានុវត្តិនី
អប្បមត្តា ឧបោសថេ

ព្រោះខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅ១កំណាត់

ដល់លោកម្ចាស់ ដោយបីតិ ដ៏ថ្លៃថ្លាមិនបាន ។

ចប់ ឧច្ឆុវិមាន ទី ២ ។

## បល្លង្កវិមាន ទី ៣

(៣១) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា មានអានុភាពច្រើន នាងនៅលើបល្លង្ក ដ៏ប្រសើរ វិចិត្រដោយកែវមណីនិងមាស ដេរដាសដោយផ្កា មានទីដេកដ៏ឧឡារិកនោះ ទាំងពួកស្រីអប្សរ របស់នាងទាំងនេះ ផ្សេងវិទ្ធផ្សេង ៗ ក៏ ច្រៀង ឲ្យត្រេកអរ ដោយជុំវិញ ម្នាលនាង មានអានុភាពច្រើន នាងបានដល់នូវឫទ្ធិនៃទេវតា នាងកាលកើត ជាមនុស្ស តើបានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

(ទេវតានោះតបថា) ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូនប្រសាក្នុងត្រកូលស្តុកស្តម្ភ មិនមានសេចក្តីក្រោធ ប្រព្រឹត្តតាមអំណាចរបស់ប្តី មិនប្រមាទក្នុងឧបោសថ

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស តតិយំ បល្លង្កវិមានំ

មនុស្សភូតា ទហរា អបាបិកា
បសន្នចិត្តា បតិមាភិរាធយឹ
ទិវា ច រត្តោ ច មនាបចារិនី
អហំ បុរេ សីលវតី អហោសឹ
បាណាតិបាតា វិរតា អចោរិយា[១]
សំសុទ្ធកាយា សុចិព្រហ្មចារិនី
អមជ្ជបានា ច មុសា អភាណឹ
សិក្ខាបទេសុ បរិបូរការិនី
ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច បសន្នមានសា អហំ[២]
អដ្ឋង្គុបេតំ អនុធម្មចារិនី
ឧបោសថំ បីតិមនា ឧបាវសឹ
ឥមញ្ច អរិយំ អដ្ឋង្គវរេហុបេតំ
សមាទិយិត្វា កុសលំ សុខុទ្រយំ
បតិម្ហិ កល្យាណីវសានុវត្តិនី
អហោសឹ បុព្វេ សុគតស្ស សាវិកា

---

១ ម. អចោរិកា ។ ២ ម. អភិបសន្នមានសាតិ ទិស្សតិ ។

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ បល្លង្កវិមាន ទី ៣

ខ្ញុំកាលកើតជាមនុស្ស នៅក្មេងមិនទាន់ចាស់ មានចិត្តជ្រះថ្លា បានធ្វើប្តីឲ្យប្រាសក្រាណ បានប្រព្រឹត្តតាមសេចក្តីពេញចិត្ត (របស់ប្តី) ទាំងថ្ងៃទាំងយប់ ខ្ញុំជាស្ត្រីមានសីល ក្នុងកាលមុន បានវៀរចាកបាណាតិបាត មិនប្រព្រឹត្តលួច មានកាយបរិសុទ្ធ ប្រព្រឹត្តព្រហ្មចរិយៈធម៌ដ៏ស្អាត ទាំងមិនផឹកទឹកស្រវឹង មិនពោះបាក្យកុហក បានធ្វើការបំពេញ ក្នុងសិក្ខាបទទាំងឡាយ ខ្ញុំមានចិត្តជ្រះថ្លា ជាអ្នកប្រព្រឹត្តធម៌ដ៏សមគួរ មានចិត្តត្រេកអរ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង លុះសមាទានឧបោសថធម៌ដ៏ប្រសើរនេះ ដែលមានសេចក្តីសុខជាកម្រៃប្រកបដោយអង្គ ៨ ហើយ បានប្រព្រឹត្តតាមអំណាចដ៏ល្អចំពោះប្តី ជាសាវិកាបស់ព្រះសុគត ក្នុងកាលមុន

ឯតាទិសំ កុសលំ ជីវលោកេ
កម្មំ ករិត្វាន វិសេសភាគិនី
កាយស្ស ភេទា អភិសម្បរាយំ
ទេវិទ្ធិបត្តា សុគតិម្ហិ អាគតា
វិមានបាសាទវរេ មនោរមេ
បរិវារិតា អច្ឆរាសង្គណេន
សយម្បភា ទេវគណា រមន្តិ មំ
ទីឃាយុកី ទេវវិមានមាគតន្តិ ។

បល្លង្កវិមានំ តតិយំ ។

## ចតុត្ថំ លតាវិមានំ

[៣២] លតា ច សជ្ជា បវរា ច ទេវតា
អច្ឆិមុតី រាជវរស្ស សិរីមតោ
សុតា ច រញ្ញោ វេស្សវណស្ស ធីតា
រាជី មតី ធម្មគុណេហិ សោភិតា[១]
បញ្ចេត្ថ នារិយោ អគមំសុ ន្ហាយិតុំ
សីតោទកំ ឧប្បលិនី សិវំ នទី
តា តត្ថ ន្ហាយិត្វា រមិត្វា ទេវតា

---

១ ម. សោភថ ។

លុះបានធ្វើអំពើ ជាកុសលប្រាកដដូច្នេះ ក្នុងជីវលោកហើយ ទើបបានចំណែកនៃគត ប្រកបដោយសម្បត្តិទិព្វវិសេស ដល់បែកធ្លាយរាងកាយស្លាប់ទៅ ក្នុងបរលោក បានដល់នូវឫទ្ធិនៃទេវតា មកកើតក្នុងសុគតិ មានវិមានប្រាសាទដ៏ប្រសើរ ជាទីរីករាយនៃចិត្ត មានពួកស្រីអប្សរហែហម ពួកទេវតាដែលមានឥទ្ធិខ្លួនឯង រមែងត្រេកអរទីងទុំ ដែលមានអាយុវែង មកកាន់ទេវវិមាន ។

ចប់ បល្លង្កវិមាន ទី ៣ ។

## លតាវិមាន ទី ៤

(៣២) ពួកទេវតា ឈ្មោះលតា ១ សជ្ជា ១ បវរា ១ អច្ចិមុតី ១ សុតា ១ ជាធីតានៃស្តេចវេស្សវ័ណ ជាស្តេចប្រសើរ មានសិរី ជាធីតាដ៏រុងរឿង មានប្រាជ្ញា ល្អដោយគុណធម៌ទាំងឡាយ ពួកនារីទាំង៥នាក់ បានទៅកាន់ស្ទឹង ដែលមានទឹកត្រជាក់ មានផ្កាឧប្បល ជាទីក្សេម ដើម្បីងូត ក្នុងហិមវន្តប្រទេសនេះ លុះពួកទេវតាទាំងនោះ បានងូតទឹកក្នុងស្ទឹងនោះរួចហើយ ក៏រីករាយ

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស ចតុត្ថំ លតាវិមានំ

ឆន្ទិត្វា ឋាយិត្វា សុតាលតិ ព្រវិ

បុច្ឆាមិ តំ ឧប្បលមាលធារិនិ

អាវេឡិនិ កញ្ចនសន្និភត្តចេ

បីតរត្តាម្ពត្ថិ ធរេ សោភនេ

ទីឃាយុតី(១) កេន កតោ យសោ តវ

កេនាសិ ភទ្ទេ បតិនោ បិយតរា

វិសិដ្ឋកល្យាណិតរស្សុ រូបតោ

បទក្ខិណា នច្ចគីតវាទិតេ

អាចិក្ខ នោ ត្វំ នរនារិ បុច្ឆិតាតិ ។

អហំ មនុស្សេសុ មនុស្សភូតា

ឧឡារភោគេ កុលេ សុណិសា អហោសឹ

អក្កោធនា ភត្តុ វសានុវត្តិនី

អប្បមត្តា ឧបោសថេ

មនុស្សភូតា ទហរា អបាបិកា

បសន្នចិត្តា បតិមាភិរាធយឹ

សទេវរំ សស្សុរំ សទាសកំ

អភិរាធយឹ តម្ហិ កតោ យសោ មម

សាហំ តេន កុសលេន កម្មុនា

---

១ ម. ទីឃាយុកា ។

កាំប្រៀនសប្បាយ ហើយនាងសុតា បាននិយាយ នឹងនាងលតាថា ខ្ញុំសួរនាង ម្នាលនាងអ្នកទ្រទ្រង់កម្រងផ្កាឧប្បល ទ្រទ្រង់ប្រដាប់ត្រចៀក មានសម្បុរស្បែកល្អ ដូចមាស មានភ្នែក ប្រកបដោយស្នាមក្រហមលឿង ល្អដូចអាកាស (ដែលផុតចាកពពក) ជាស្ត្រីមានអាយុវែង យសរបស់នាង តើបុណ្យអ្វីតាក់តែងឲ្យ ម្នាលនាងដ៏ចំរើន នាងជាទីស្រឡាញ់បំផុតរបស់ប្តី នាងល្អឆើតឆាយដោយរូប ជាស្ត្រីឈ្លាស ក្នុងការរាំ ច្រៀង ប្រគំ តើដោយបុណ្យដូចម្តេច ម្នាលនារី នាងដែលយើងសួរហើយ ចូរប្រាប់យើង ។

(នាងលតាឆ្លើយថា) ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូនប្រសា ក្នុងត្រកូលមានភោគៈដ៏លើសលុប ខ្ញុំមិនមានសេចក្តីក្រោធ ប្រព្រឹត្តតាមអំណាចស្វាមី មិនប្រមាទ ក្នុងឧបោសថ ជាមនុស្សនៅក្មេង មិនទាន់ចាស់ មានចិត្តជ្រះថ្លា បានញុំាងប្តីឲ្យប្រោសប្រាណ បានញុំាងទេវតាដ៏ប្រសើរ គឺឪពុកក្មេក ម្តាយក្មេក (ទាំងបងប្អូនខាងប្តី) ព្រមទាំងខ្ញុំប្រុស ខ្ញុំស្រី ឲ្យត្រេកអរ យសរបស់ខ្ញុំ ខ្ញុំបានធ្វើហើយក្នុងកាលនោះ ខ្ញុំនោះបានដល់នូវសេចក្តីវិសេស ក្នុងហេតុ ៤ យ៉ាងគឺ

ចតូហិ ឋានេហិ វិសេសមជ្ឈគា
អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច
ខិឌ្ឌំ រតឹ(១) បច្ចនុភោមនប្បកំ ។
សុតំ ឥទំ ភាសតិ យំ អយំ លតា
យំ នោ អបុច្ឆិម្ហ អកិត្តយី នោ
បតិនោ កិរម្ហាកំ(២) វិសិដ្ឋា នារីនំ
គតី ច នេសំ បវរា ច ទេវតា
បតីសុ ធម្មំ បរិចរាម(៣) សព្វា
បតិព្វតា យថាករន្តិ ឥត្ថិយោ
បតីសុ ធម្មំ បរិចរាម(៤) សព្វា
លច្ឆាមសេ ភាសតិ យំ អយំ លតា
សីហោ យថា បព្វតសានុគោចរោ
មហិន្ធរំ បព្វតមាវសិត្វា
បសយ្ហ ហន្ត្វា ឥតរេ ចតុប្បទេ
ខុទ្ទេ មិគេ ខាទតិ មំសភោជនោ
តថេវ សទ្ធា ឥធ អរិយសាវិកា
ភត្តារំ និស្សាយ បតឹ អនុព្វតា

១ ម. ខិឌ្ឌារតី ។ ២ ម. កិរស្មាកន្តិបត្តិ ។ ៣ ឱ.ម. បចុរាម ។ ៤ ឱ.បចរិត្វា ។ ម. បចរិត្វាន ។

អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ ដោយកុសលកម្មនោះ ខ្ញុំបានគប់ប្រសប់ នូវវិល្បនៃជាទីគាប់ ដ៏ច្រើន ៗ នាងលតានេះ ពោលពាក្យណា ពាក្យនោះ(យើងទាំងឡាយ) ឮហើយ ឬយើងទាំងឡាយ សួរនូវហេតុណា នាងលតា បានប្រាប់ (ហេតុនោះ) ដល់យើងថា ធម្មតាប្ដីទាំងឡាយ ជាអ្នកស្កុតត្រូវ ចំពោះយើងទាំងឡាយផង ជាគតិរបស់ នារីទាំងឡាយផង ជាទេវតាដ៏ប្រសើរ របស់នារី ទាំងឡាយនោះផង ពួកយើងទាំងអស់ នឹងប្រព្រឹត្តនូវធម៌ ចំពោះប្ដីទាំងឡាយ ពួកស្ត្រីប្រតិបត្តិប្ដី យ៉ាងណា ពួកយើង ទាំងអស់គ្នា នឹងប្រព្រឹត្តនូវធម៌ចំពោះប្ដីទាំងឡាយ(យ៉ាងនោះ) នាងលតានេះ គាបបាន នូវសម្បត្តិណាហើយពោល យើងទាំងឡាយ រមែងបាននូវ (សម្បត្តិនោះ) សត្វសីហៈ ជាសត្វស៊ីសាច់ ត្រាច់ទៅតាមជង្គំ អាស្រ័យនៅក្នុងភ្នំ ឈ្មោះមហិន្ទរ (ភ្នំប្រទ្រង់ផែនដី) ស្ទុះទៅសង្គ្រុបចាប់ស៊ី នូវពួកម្រឹគតូចៗ ដែលមានជើងបួនក្រៅនេះ យ៉ាងណាមិញ នាងលតានោះ ជាស្ត្រីមានសទ្ធា ជាអរិយសាវិកា ក្នុងសាសនានេះ អាស្រ័យនូវប្ដី ហើយប្រតិបត្តិប្ដី

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស បញ្ចមំ គុត្តិលវិមានំ

គោឌំ វចិត្វា អនុក្កយ្យ មជ្ឈេ

សត្តតិ សា មោទតិ សម្មុចារិនីតិ ។

លតាវិមានំ បទុត្តំ ។

# បញ្ចមំ គុត្តិលវិមានំ

(៣៣) សត្តតន្តឹ សុមធុរំ រាមណេយ្យំ អវាចយឹ

សោ មំ រង្គម្ហិ អវ្ហេតិ សរណំ មេ ហោហិ កោសិយាតិ ។

អហំ តេ សរណំ ហោមិ អហមាចរិយបូជកោ

ន តំ ជយិស្សតិ សិស្សោ សិស្សមាចរិយ ជេស្សសីតិ ។

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ

ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា

កេន តេតាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ

ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ(១) មហានុភាវេ

មនុស្សភូតា កិមកាសិ បុញ្ញំ

១ ឱ. ទេវ ។

បានសម្រាប់សេចក្តីក្រោធ គ្រប់សង្កត់នូវសេចក្តីកំណាញ់
ប្រព្រឹត្តធម៌ ហើយរីករាយក្នុងឋានសួគ៌ ក៏យ៉ាងនោះដែរ ។

ចប់ លតាវិមាន ទី ៤ ។

# គុត្តិលវិមានទី ៥

(៣៣) (មហាសត្វឈ្មោះគុត្តិលៈពោលថា) ខ្ញុំបង្រៀននូវពិណាមានខ្សែ ៧ មានសំឡេងពីរោះជាទីសប្បាយរីករាយ (សិស្សឈ្មោះមុសលៈ) នោះ ចង់ប្រឡងរិទ្ធីនឹងខ្ញុំ ក្នុងទីស្នាមសម្រាប់លេង បពិត្រកោសិយៈ សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ ។

(សក្កទេវរាជពោលថា) ខ្ញុំជាទីពឹងរបស់លោកបាន ខ្ញុំជាអ្នកបូជាអាចារ្យ សិស្សទឹងមិនឈ្នះលោកទេ បពិត្រអាចារ្យ[១] លោកនឹងឈ្នះសិស្ស ។

(ព្រះមហាមោគ្គល្លានសួរទេវតាថា)ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក សម្បុររបស់នាងបែបនោះ តើសម្រេចដោយបុណ្យដូចម្តេច ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយ ណាមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុដូចម្តេច

ម្នាលទេវតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលកើត ជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច

---

១ ក្នុងកាលមុន មហាសត្វធ្លាប់ធ្វើជាអាចារ្យរបស់សក្កទេវរាជ ។

កេនាសិ ឯវញ្ជលិតានុភាវា

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា

បញ្ហំ បុដ្ឋា វិយាកាសិ យស្ស កម្មស្សិទំ ផលំ

វត្ថុត្តមទាយិកា នារី

បវរា ហោតិ នរេសុ នារីសុ

ឯវំ បិយរូបទាយិកា មនាបំ

ទិព្វំ សា លភតេ ឧបេច្ច ឋានំ

តស្សា មេ បស្ស វិមានំ

អច្ឆរា កាមវណ្ណិនីហមស្មិ

អច្ឆរាសហស្សាហំ(១) បវរា

បស្ស បុញ្ញានំ វិបាកំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ឥតរំ ចតុវិមានំ យថា វត្ថទាយិកាវិមានំ តថា វិត្ថារេតព្វំ ។

អភិក្កន្តេន វណ្ណេន ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

---

១ ម. អច្ឆរាសហស្សស្សាហំ ។

នាងមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់
នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យដូចម្តេច ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

នារីឲ្យនូវសំពត់ដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុស
ស្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាព
ជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជាដើម
បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោក
រមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ
មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំង
មួយពាន់ សូមលោកមើលនូវផល នៃបុណ្យទាំងឡាយ
ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

វត្ថាយិកាវិមាន បណ្ឌិតសំដែងឲ្យពិស្តារយ៉ាងណា ចតុរវិមាន
ក្រៅនេះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារ យ៉ាងនោះផងចុះ ។

(នាង) មានសម្បុរ ដ៏រុងរឿង ។បេ។
ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

វិមានវត្ថុស្មិំ តតិយស្ស បារិច្ឆត្តកវគ្គស្ស បញ្ចមំ គុត្តិលវិមានំ

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
វត្ថុត្តមទាយិកា នារី
បវរា ហោតិ នរេសុ នារីសុ
ឯវំ បិយរូបទាយិកា មនាបំ
ទិព្វំ សា លភតេ ឧបេច្ច ឋានំ
តស្សា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា
បស្ស បុញ្ញានំ វិបាកំ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។
អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
។ បេ ។ ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ
ៗ បេ ៗ ផលនៃកម្មនេះថា

នារីឲ្យនូវផ្កាដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រី
ទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទី
ស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជាដើម បាន
នូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិល
មើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរមាន
សម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំង
មួយពាន់ សូមលោកមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ៗ បេ ៗ
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ៗ

ម្នាលទេវតា នាងមានសម្បុររុងរឿង ៗ បេ ៗ ដូចផ្កាយព្រឹក
សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្ដេច ៗ បេ ៗ
ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ៗ

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ
ៗ បេ ៗ ផលនៃកម្មនេះថា

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

គន្ធុត្តមទាយិកា នារី
បវរា ហោតិ នរេសុ នារីសុ
ឯវំ បិយរូបទាយិកា មនាបំ
ទិព្វំ សា លភតេ ឧបេច្ច ឋានំ
តស្សា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា
បស្ស បុញ្ញានំ វិបាកំ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
ផលុត្តមទាយិកា នារី
បវរា ហោតិ នរេសុ នារីសុ

នារីឲ្យនូវគ្រឿងក្រអូបដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្ត្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាព ជាទីស្រឡាញ់ ទើបទៅកាន់បាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក
សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។បេ។
ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារី អ្នកឲ្យ នូវផ្លែឈើ ដ៏ឧត្តម
ជាស្ត្រីប្រសើរ ជាងជនប្រុសស្រីទាំងឡាយ

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស បញ្ចមំ គុត្តិលវិមានំ

ឯវំ បិយរូបទាយិកា មនាបំ
ទិព្វំ សា លភតេ ឧបេច្ច ឋានំ
តស្សា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា
បស្ស បុញ្ញានំ វិបាកំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ

វត្ថុត្តមទាយិកា នារី
បវរា ហោតិ នរេសុ នារីសុ
ឯវំ បិយរូបទាយិកា មនាបំ
ទិព្វំ សា លភតេ ឧបេច្ច ឋានំ

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ គុត្តិលវិមាន ទី ៥

នារីនោះ ជាស្ត្រីឲ្យនូវវត្ថ មានសភាពជាទីស្រឡាញ់
ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ
ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើល នូវវិមាន
របស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរ
ជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរ ជាងស្ត្រីអប្សរទាំង
មួយពាន់ សូមលោកមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺដូច
ផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច
។ បេ ។ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ
។ បេ ។ ផលនៃកម្មនេះថា

នារី ឲ្យនូវវត្ថមានរសដ៏ឧត្តម ជាស្រីប្រសើរជាង
ជនប្រុសស្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថ
មានសភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មាន
វិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ

តស្មា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា
បស្ស បុញ្ញានំ វិបាកំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
។ បេ ។ ឱសធី វិយ តារកា

កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ

គន្ធបញ្ចង្គុលិកំ អហមទាសឹ
កស្សបស្ស ភគវតោ ថូបស្មឹ
តស្មា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា
បស្ស បុញ្ញានំ វិបាកំ

សូមលោកមើលមើល នូវវិមានរបស់ខ្ញុំនោះចុះ
ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជា
ស្ត្រីប្រសើរ ជាងស្ត្រីអប្សរ ទាំងមួយពាន់
សូមលោកមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ម្នាលទេវតា នាងមានសម្បុររុងរឿង ។ បេ ។ ដូចផ្កាយព្រឹក
សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។ បេ ។
ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ
។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំបានឱ្យនូវគ្រឿងប្រស់ព្រំ មានក្លិនក្រអូប លើស្តូបនៃ
ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប សូមលោកមើល
មើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរ
ជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរ ជាងស្ត្រីអប្សរ ទាំង
មួយពាន់ សូមលោកមើល នូវផលនៃបុណ្យទាំងឡាយ

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស បញ្ចមំ គុត្តិលវិមានំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ឥតរំចតុវិមានំ យថា គន្ធបញ្ចង្គុលិកំ វិមានំ តថា វិត្ថារេតព្វំ ។

អភិក្កន្តេន វណ្ណេន ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ភិក្ខូ ចាហំ ភិក្ខុនិយោ ច

អទ្ទសាមិ បន្ថបដិបន្នេ

តេសាហំ ធម្មំ សុត្វាន

ឯកូបោសថំ ឧបវសិស្សំ

តស្សា មេ បស្ស វិមានំ

អច្ឆរា កាមវណ្ណិនីហមស្មិ

អច្ឆរាសហស្សាហំ បវរា

បស្ស បុញ្ញានំ វិបាកំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន ។ បេ ។

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ គុត្តិលវិមាន ទី ៨

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។

ទាំងសម្បុរ របស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

វិមាន ៤ ក្រៅនេះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារ ដូចគន្ធបញ្ចង្គុលិកវិមាន

ផងចុះ ។

មានសម្បុរ ដំរុងរឿង ។ បេ ។

ទាំងសម្បុរ របស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំបានឃើញនូវពួកភិក្ខុ និងពួកភិក្ខុនី ដើរទៅកាន់ផ្លូវ

ខ្ញុំបានស្តាប់ធម៌ របស់ភិក្ខុនឹងភិក្ខុនីទាំងនោះ ហើយ

រក្សា នូវឧបោសថអស់ ១ ថ្ងៃ សូមលោកមើល នូវ

វិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទី

ប្រាថ្នា ខ្ញុំជាប្រធានប្រសើរ ជាងស្ត្រីអប្សរទាំងមួយពាន់

សូមលោក មើលមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។

ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

មានសម្បុរ ដំរុងរឿង ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ឧទកេ ឋិតា ឧទកំ អទាសឹ

ភិក្ខុនោ ចិត្តេន វិប្បសន្នេន

តស្សា មេ បស្ស វិមានំ

អច្ឆរា កាមវណ្ណិនីហមស្មិ

អច្ឆរាសហស្សស្សាហំ បវរា

បស្ស បុញ្ញានំ វិបាកំ

តេន មេតាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

សស្សុញ្ចាហំ សស្សុរេ ច

ចណ្ឌិកេ កោធនេ ច ផរុសេ ច

អនុស្សុយ្យិកា ឧបដ្ឋាសឹ

ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។បេ។ ផលនៃកម្មនេះថា

ខ្ញុំឈរក្នុងទឹក មានចិត្តជ្រះថ្លា បានប្រគេនទឹកដល់ភិក្ខុ

សូមលោកមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្រ្តីអប្សរ

មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្រ្តីអប្សរទាំង

មួយពាន់ សូមលោករមិលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។

ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

មានសម្បុរ ដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។បេ។ ផលនៃកម្មនេះថា

ខ្ញុំមិនមានសេចក្តីច្រណែន បានបំរើម្តាយក្មេក នឹងឪពុក

ក្មេក ដែលកាចផង ខឹងច្រើនផង អាក្រក់ផង

វិមានវត្ថុម្ហិ តតិយស្ស បារិច្ឆត្តកវគ្គស្ស បញ្ចមំ គុត្តិលវិមានំ

អប្បមត្តា សកេន សីលេន
តស្សា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា
បស្ស បុញ្ញានំ វិបាកំ
តេន មេតាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។
អភិក្កន្តេន វណ្ណេន ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
បរកម្មការី អាសី
អត្ថេនាតន្ទិតា ទាសី
អក្កោធនា អនតិមានី
សំវិភាគិនី សក្កស្ស ភាគស្ស(១)
តស្សា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា

១ ម. ភាគស្ស ។

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ គុត្តិលវិមាន ទី ៤

ខ្ញុំមិនមានសេចក្ដីប្រមាទ ក្នុងសីល របស់ខ្លួន
សូមលោកមើល នូវវិមាន របស់ខ្ញុំនោះចុះ
ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រី
ប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោក
មើលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ ខ្ញុំប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។
មានសម្បុរ ដ៏រុងរឿង ។ បេ ។
ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។
ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។ បេ ។ ផលនៃកម្មនេះជា

ខ្ញុំជាទាសី ធ្វើការបម្រើនៃជនដទៃ មិនខ្ជិលប្រអូសដោយកិច្ចការ
(ទាំងតូច) ជាស្ត្រីមិនមានសេចក្ដីក្រោធ មិនមើលងាយគេ
ជាអ្នកចែករំលែកនូវចំណែករបស់ខ្លួន (ដល់ជនអ្នកត្រូវការ)
សូមលោកមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មាន
សម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់

បស្ស បុញ្ញានំ វិបាកំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ

។ បេ ។ ឱសធី វិយ តារកា

កេន តេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ទីភេឧឧមហំ អទាសឹ

ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស

តស្សា មេ បស្ស វិមានំ

អច្ឆរា កាមវណ្ណិនីហមស្មិ

អច្ឆរាសហស្សាហំ បវរា

បស្ស បុញ្ញានំ វិបាកំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

សូមលោករមើលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។

ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។ បេ ។ ដូចផ្កាយព្រឹក

សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។ បេ ។

ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំបានឲ្យនូវបាយលាយដោយទឹកដោះស្រស់ ដល់

ភិក្ខុត្រាច់ទៅបិណ្ឌបាត សូមលោកមើល នូវវិមាន

របស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទី

ប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់

សូមលោករមិលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។

ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

តេសុ បញ្ចសតិវិមានំ យថា ទីភេជនធាយិកាវិមានំ

តថា វិត្ថារេតព្វំ ។

អភិក្កន្តេន វណ្ណេន ។ បេ ។

វណ្ណោ ច តេ សព្វទិសា បកាសតីតិ ។

សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

១– ផាណិតំ អហមទាសឹ

២– តិម្ពរុសកំ ។ បេ ។

៣– ឧច្ឆុខណ្ឌិកំ

៤– កក្ការុកំ (១)

៥– ឯឡាលុកំ

៦– វល្លិបក្កំ (២)

៧– ផារុសកំ

៨– ហត្ថប្បតាបកំ

៩– សាកមុដ្ឋឹ

១០– បុប្ផកមុដ្ឋឹ

១១– មូលកំ

១២– និម្ពមុដ្ឋឹ

---

១ ឱ. កក្ការិកំ ។ ២ ឱ. ម. វល្លិផលំ ។

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ គុត្តិលវិមាន ទី ៥

បណ្ដាវិមានទាំងនោះ វិមាន ២៥ បណ្ឌិតគប្បីសំដែងឲ្យពិស្ដារ ដូចវីកេខនទាយិកាវិមាន ផងចុះ ។

មានសម្បុរ ដ៏រុងរឿង ។ បេ ។

សម្បុរបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។ បេ ។ ផលនៃកម្មនេះថា

១ ខ្ញុំបានឲ្យ ស្ករអំពៅ

២ ។ បេ ។ ផ្លែទន្លាប់

៣ អំពៅ ១ កំណាត់

៤ ផ្លែត្រសក់

៥ ផ្លែល្ពៅ

៦ ផ្លែត្រសក់ស្រូវ

៧ ផ្លែមាក់ប្រាង

៨ បង្ក្រានសម្រាប់កំដៅដៃ

៩ អន្លក់ ១ ក្ដាប់

១០ ផ្កា ១ ក្ដាប់

១១ មើមដំឡូង

១២ ស្លឹកស្ដៅ ១ ក្ដាប់

១៣– អម្ពកញ្ជិកំ

១៤– ទោណិនិម្មជ្ជំ (១)

១៥– កាយពន្ធំ

១៦– អំសពទ្ធកំ (២)

១៧– អយោគបដ្ដំ

១៨– វិធូបនំ

១៩– តាលបណ្ណំ (៣)

២០– មោរហត្ថំ

២១– ឆត្តំ

២២– ឧបាហនំ

២៣– បូវំ

២៤– មោទកំ

២៥– សក្ខលិំ (៤) អហាមទាសិំ

ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស

តស្សា មេ បស្ស វិមានំ

អច្ឆរា កាមវណ្ណិនីហមស្មិ

អច្ឆរាសហស្សាហំ (៥) បវរា

---

១ ម. ទោណិនិម្មជ្ជនិំ ។ ២ ឱ. អំសវដ្ដកំ ។ ៣ ឱ. តាលវណ្ដំ ។ ៤ ម. សក្ខលិកំ ។ ៥ ឱ. អច្ឆរាសហស្សស្ស ។ ម. អច្ឆរាសហស្សស្សាហំ ។

១៣ ជ្រក់ស្វាយ

១៤ គ្រាប់ល្ងបុក

១៥ វត្ថុពន្លបង្កេះ

១៦ យោគបាត្រ

១៧ សំពត់អយោគ

១៨ ផ្តិតមានជ្រុង ៤

១៩ ផ្តិតស្លឹកត្នោត

២០ ផ្តិតកន្ទុយក្ងោក

២១ ឆត្រ

២២ ស្បែកជើង

២៣ នំ

២៤ ត្រប៉ែ

២៥ ខ្ញុំបានប្រគេន នំក្រៀប

ដល់ភិក្ខុ ដែលត្រាច់ទៅដើម្បីបិណ្ឌបាត

សូមលោកមើល នូវវិមានរបស់ខ្ញុំនោះចុះ

ខ្ញុំជាស្ត្រីអប្សរ មានសម្បុរ ជាទីប្រាថ្នា

ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់

បស្ស បុញ្ញានំ វិបាកំ

កេន មេ តាទិសោ វណ្ណោ ។បេ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ស្វាគតំ វត មេ អជ្ជ សុប្បភាតំ សុហុដ្ឋិតំ
យំ អទ្ទសំ ទេវតាយោ អច្ឆរា កាមវណ្ណិនិយោ
តាសាហំ(១) ធម្មំ សុត្វាន កាហាមិ កុសលំ ពហុំ
ទានេន សមចរិយាយ សំយមេន ទមេន ច
សាហំ តត្ថ គមិស្សាមិ(២) យត្ថ គន្ត្វា ន សោចរេតិ ។

គុត្តិលវិមានំ បញ្ចមំ ។

## ឆដ្ឋំ ទទ្ទល្លវិមានំ

(៣៤) ទទ្ទល្លមានា(៣) វណ្ណេន យសសា ច យសស្សិនី
សព្វេ ទេវេ តាវតឹសេ វណ្ណេន អតិរោចសិ(៤)
ទស្សនំ នាភិជានាមិ ឥទំ បឋមទស្សនំ
កស្មា កាយា នុ អាគម្ម នាមេន ភាសសេ មមន្តិ ។

---

១ ម. ឥមាសាហំ ។ ២ម. ស្វាហំ តត្ថ គច្ឆាមិ ។ ៣ ឱ. ទទ្ទល្លមានោ ។ ម. ទទ្ទល្លមាន។
៤ ម. អតិរោចសី ។

សូមលោករមិលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ល។

ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

+ ឧហ្ន ដំណើរមកនៃអញក្នុងថ្ងៃនេះ ជាការល្អណាស់តើ ថ្ងៃនេះភ្លឺល្អណាស់ ការក្រោកឡើង អំពីដំណេកល្អណាស់ ព្រោះអញបានឃើញពួកទេវតា ជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា អាត្មាអញនោះ បានស្តាប់ធម៌របស់ពួកទេវតាទាំងនោះ ទើបបានធ្វើកុសលច្រើន ដោយការឲ្យទានផង ដោយការប្រព្រឹត្តិស្មើផង ដោយការសង្រួមផង ដោយការទូន្មានផង អ្នកផង ទៅកន្លែងណា ហើយមិនសោយសោក អាត្មាអញនោះ ទើងទៅកន្លែងនោះដែរ ។

ចប់ គុត្តិលវិមានទី ៥ ។

## ទទ្ទល្លវិមាន ទី ៦

(៣៤) (នាងភទ្ទាសួរថា) នាងមានសម្បុរដ៏រុងរឿង មានយសកន្លងនូវពួកទេវតា ជាន់តាវត្តិង្សទាំងអស់ ដោយយសផង ដោយសម្បុរផង ខ្ញុំមិនដែលឃើញ(នាង)សោះ ឃើញម្តងនេះឈ្មោះថាឃើញជាដំបូង នាងមកអំពីពួកទេវតាជាន់ណា បានជាមកហៅចំឈ្មោះរបស់ខ្ញុំ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

អហំ ភទ្ទេ សុភទ្ទាសិំ បុព្វេ មានុសកេ ភវេ
សហាភរិយា ច តេ អាសឹ ភគិនី ច កនិដ្ឋកា
សាហំ កាយស្ស ភេទាយ វិប្បមុត្តា តតោ ចុតា
និម្មានរតីទេវានំ ឧបបន្នា សហព្យតំ ។
បហូតកតកល្យាណា តេ ទេវេ យន្តិ បាណិនោ
យេសំ ត្វំ កិត្តយិស្សសិ សុភទ្ទេ ជាតិមត្តនោ
កថំ(១) ត្វំ កេន វណ្ណេន កេន វា អនុសាសិតា
កីទិសេនេវ ទានេន សុព្វតេន យសស្សិនី
យសំ ឯតាទិសំ បត្តា វិសេសំ វិបុលមជ្ឈគា
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលំ(ឥតិ)។
អដ្ឋេវ បិណ្ឌបាតានិ យំ ទានំ អទទំ បុរេ
ទក្ខិណេយ្យស្ស សង្ឃស្ស បសន្នា សកេហិ បាណិហិ
តេន មេតាទិសោ វណ្ណោ ។បេ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

---

១ ម. អបិ ។

(នាងសុភទ្ទាឆ្លើយថា) ម្នាលនាងភទ្ទា ខ្ញុំជាស្រីឈ្មោះសុភទ្ទា ខ្ញុំជាភរិយារួម(ប្តី) ជាមួយនឹងនាងផង ហើយត្រូវជាប្អូននាងផង ក្នុងភពជារបស់មនុស្ស ក្នុងកាលមុន ខ្ញុំនោះ លុះបែកធ្លាយរាងកាយ ផុតស្រឡះ ច្យុតចាកមនុស្សលោកនោះ បានមកកើតជាមួយនឹងពួកទេវតា ជាន់និម្មានរតី ។

(នាងភទ្ទាសួរថា) ម្នាលនាងសុភទ្ទា នាងបានថ្ងៃនូវជាតិរបស់ខ្លួន ក្នុងពួកទេវតាជាន់និម្មានរតីណា ពួកសត្វមានកម្មជាកុសលធ្វើហើយ ដ៏ច្រើន រមែងទៅកាន់ពួកទេវតាជាន់និម្មានរតីនោះ នាងអ្នកណាប្រៀនប្រដៅ ដោយហេតុដូចម្តេច ដោយប្រការដូចម្តេច នាងជាស្ត្រីមានយស ដល់នូវយសបែបនេះ បាននូវគុណ-វិសេស ដ៏ធំទូលាយ តើដោយទានដូចម្តេច ដោយវត្តល្អដូចម្តេច ម្នាលទេវតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(នាងសុភទ្ទាឆ្លើយថា) ក្នុងកាលមុន ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទានណា ដោយដៃរបស់ខ្លួន ទាននោះគឺបិណ្ឌបាត[១] ៨ (ដែលខ្ញុំឲ្យហើយ) ដល់សង្ឃ ជាទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ សម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

---

១ បិណ្ឌបាតដែលបុគ្គលឲ្យដល់ភិក្ខុ ៨ រូប ។ អដ្ឋកថា ។

វិមានវត្ថុស្មិំ តតិយស្ស បារិច្ឆត្តកវគ្គស្ស ឆដ្ឋំ ទទ្ទល្លវិមានំ

អហំ តយា ពហុតរេ ភិក្ខូ សញ្ញតេ ព្រហ្មចារិនោ[1]
តប្បេសិំ អន្នបានេន បសន្នា សកេហិ បាណិហិ
តយា ពហុតរំ ទត្វា ហីនកាយូបគា អហំ
កថំ ត្វំ អប្បតរំ ទត្វា វិសេសំ វិបុលមជ្ឈគា
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលំ(តំតិ)។
មនោភាវនិយោ ភិក្ខុ សន្ទិដ្ឋោ មេ បុរេ អហុ
តាហំ[2] ភត្តេន និមន្តេសិំ រេវតំ អត្តនដ្ឋមំ
សោ មេ អត្ថបុរេក្ខារោ អនុកម្បាយ រេវតោ
សង្ឃេ ទេហីតិ មំ អវោច តស្សាហំ វចនំ ករិំ
សា ទក្ខិណា សង្ឃគតា អប្បមេយ្យា បតិដ្ឋិតា
បុគ្គលេសុ តយា ទិន្នំ ន តំ តវ មហប្ផលន្តិ ។
ឥទានេវាហំ ជានាមិ សង្ឃេ ទិន្នំ មហប្ផលំ
សាហំ គន្ត្វា មនុស្សត្តំ វទញ្ញូ វីតមច្ឆរា
សង្ឃេ ទានំ ទស្សាមិហំ[3] អប្បមត្តា បុនប្បុនន្តិ ។

---

១ ម. ព្រហ្មចរិយេ ។ ២ ម. តាសំ ភត្តេ និមន្តេសិ ។ ៣ ឱ. ទានំ ទស្សាមហំ ។ ម. ទានានិ ទស្សាមិ ។

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ ទទ្ទល្លវិមាន ទី ៦

(នាងភទ្ទាសួរថា) ខ្ញុំបានញ៉ាំងភិក្ខុទាំងឡាយ ដែលមានសេចក្តីសង្រួមប្រព្រឹត្តធម៌ដ៏ប្រសើរ ច្រើនលើសជាងនាង ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទានដោយដៃរបស់ខ្លួនច្រើនលើសជាងនាង ហើយចូលទៅកាន់កាយដោកពាប នាងឲ្យទានតិចជាងខ្ញុំទេ ប៉ុន្តែបាននូវគុណវិសេសដ៏ធំទូលាយ តើដោយហេតុដូចម្តេច ម្នាលទេវតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(នាងសុភទ្ទាឆ្លើយថា) ភិក្ខុអ្នកញ៉ាំងចិត្តឲ្យចំរើន ខ្ញុំបានឃើញក្នុងកាលមុន ខ្ញុំបាននិមន្តព្រះរេវតត្ថេរនោះ មានខ្លួនជាគំរប់៨ដោយភត្ត ព្រះរេវតត្ថេរនោះ ធ្វើនូវប្រយោជន៍ធំ ដល់ខ្ញុំ ដោយសេចក្តីអនុគ្រោះ បានប្រាប់ខ្ញុំថា នាងចូរឲ្យ(ទាន) ចំពោះសង្ឃ ខ្ញុំក៏បានធ្វើតាមពាក្យលោក សង្ឃគតាទក្ខិណានោះ ជាទានមានផលប្រមាណមិនបាន ខ្ញុំបានដឹកល់ទុកល្អហើយ ឯទានដែលនាងឲ្យហើយចំពោះបុគ្គលទាំងឡាយ ទានរបស់នាងនោះ មិនមានផលច្រើនឡើយ ។

(នាងភទ្ទាឆ្លើយថា)ឥឡូវនេះ ខ្ញុំបានដឹងច្បាស់ហើយថា ទានដែលបុគ្គលបានឲ្យចំពោះសង្ឃ ជាទានមានផលច្រើន ខ្ញុំនោះបើបានទៅកាន់អត្តភាពជាមនុស្ស ដឹងក្តីកាលណា ប្រាសចាកសេចក្តីកំណាញ់ មិនធ្វេសប្រហែស នឹងឲ្យទានចំពោះសង្ឃរឿយ ១ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

កា ឯសា ទេវតា ភទ្ទេ តយា មន្តយតេ សហ
សព្វេ ទេវេ តាវតឹសេ វណ្ណេន អតិរោចតិ (ឥតិ) ។
មនុស្សភូតា ទេវិន្ទ បុព្វេ មានុសកេ ភវេ
សហាយិកា ច មេ អាសិ ភគិនី ច កនិដ្ឋកា
សង្ឃេ ទានានិ ទត្វាន កតបុញ្ញា វិរោចតិ(ឥតិ) ។
ធម្មេន បុព្វេ ភគិនី តយា ភទ្ទេ វិរោចសិ
យំ សង្ឃស្មិំ អប្បមេយ្យេ(១) បតិដ្ឋាបេសិ ទក្ខិណំ
បុច្ឆិតោ ហិ មយា ពុទ្ធោ គិជ្ឈកូដស្មិំ បព្វតេ
វិបាកំ សំវិភាគស្ស យត្ថ ទិន្នំ មហប្ផលំ
យជមានានំ មនុស្សានំ បុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ យត្ថ ទិន្នំ មហប្ផលំ
តំ មេ ពុទ្ធោ វិយាកាសិ ជានំ កម្មផលំ សកំ
វិបាកំ(២) សំវិភាគស្ស យត្ថ ទិន្នំ មហប្ផលំ
ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ

---

១ ម. សង្ឃម្ហិ អប្បមេយ្យំ ។ ២ ម. វិភាគំ ។

(ព្រះឥន្ទសួរថា) ម្នាលនាងភទ្ទា ទេវតានេះ ត្រូវជាអ្វីនឹងនាង ក៏មកប្រឹក្សាជាមួយនាង ទាំងសម្បូររុងរឿងកន្លងពួកទេវតា ជាន់តាវត្តឹង្ស ។

(នាងភទ្ទាឆ្លើយថា) បពិត្រព្រះអង្គជាធំជាងទេវតា កាលពីដើម ទេវតានោះកើតជាមនុស្ស ក្នុងភពនៃមនុស្ស បានជាភរិយារបស់ព្រះអង្គ ជាមួយនឹងខ្ញុំផង ហើយត្រូវជាប្អូនខ្ញុំព្រះអង្គផង បានឲ្យទានទាំងឡាយចំពោះសង្ឃ មានបុណ្យធ្វើហើយ ទើបបានរុងរឿងដូច្នេះ ។

(ព្រះឥន្ទពោលថា) ម្នាលនាងភទ្ទា កាលពីដើម ប្អូនស្រីរុងរឿងដោយធម៌ជាងនាង ព្រោះបានញុំាងទក្ខិណាទាន ឲ្យដំកល់នៅស៊ប់ចំពោះសង្ឃ មានផលរាប់មិនបាន ដ្បិតព្រះពុទ្ធគង់លើភ្នំគិជ្ឈកូដ ខ្ញុំបានសួរនូវផលនៃការចែករំលែក ចំពោះបុគ្គលដែលគេឲ្យទានទៅមានផលច្រើន ខ្ញុំបានសួរព្រះពុទ្ធអំពីបុណ្យ ដែលឲ្យផលក្នុងបច្ចុប្បន្នរបស់មនុស្សទាំងឡាយ អ្នកឲ្យទាន ជាសត្វប្រាថ្នាបុណ្យ ចំពោះពួកបុគ្គល ដែលគេឲ្យទានទៅមានផលច្រើន កាលព្រះពុទ្ធជ្រាបច្បាស់នូវផលនៃកម្ម គឺវិបាកនៃការចែករំលែកចំពោះពួកបុគ្គលដែលគេឲ្យទានទៅមានផលច្រើន ដោយព្រះអង្គឯង ហើយព្យាករបញ្ហានោះដល់ខ្ញុំ បុគ្គល ៤ ពួកអ្នកដល់នូវមគ្គ នឹងបុគ្គល ៤ ពួកតាំងនៅក្នុងផល នេះឯងហៅថាសង្ឃ លោកប្រតិបត្តិត្រង់ប្រកបដោយប្រាជ្ញានឹងសីល

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស ឆដ្ឋំ ទទ្ទល្លវិមានំ

យជមានានំ មនុស្សានំ បុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ សង្ឃេ ទិន្នំ មហប្ផលំ
ឯសោ ហិ សង្ឃោ វិបុលោ មហគ្គតោ
ឯសប្បមេយ្យោ ឧទធីវ សាគរោ
ឯតេ ហិ សេដ្ឋា នរវីរិយសាវកា(១)
បភង្ករា ធម្មកថំ ឧទីរយន្តិ
តេសំ សុទិន្នំ សុហុតំ សុយិដ្ឋំ
យេ សង្ឃមុទ្ទិស្ស ទទន្តិ ទានំ
សា ទក្ខិណា សង្ឃគតា បតិដ្ឋិតា
មហប្ផលា លោកវិទូហិ វណ្ណិតា
ឯតាទិសំ បុញ្ញមនុស្សរន្តា
យេ វេទជាតា វិចរន្តិ លោកេ
វិនេយ្យ មច្ឆេរមលំ សមូលំ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

ទទ្ទល្លវិមានំ ឆដ្ឋំ ។

---

១ ម. នរវីរសាវកា ។

វិមានវត្ថុ បារិច្ឆត្តកវគ្គ ទី ៣ ទទ្ទល្លវិមាន ទី ៦

ព្រះពុទ្ធបានសំដែង នូវបុណ្យ ដែលឲ្យផល ក្នុងបច្ចុប្បន្ន របស់មនុស្សទាំងឡាយ អ្នកឲ្យទាន ជាសត្វប្រាថ្នា នូវបុណ្យ កាលធ្វើ ចំពោះសង្ឃ ដែលគេឲ្យទានទៅ មានផលច្រើន ព្រោះថា សង្ឃនុ៎ះ ជាសង្ឃមានគុណដ៏ធំទូលាយ សង្ឃនុ៎ះ ដូចជាសាគរដែលទ្រទ្រង់នូវទឹក មានដប្រៀបរាប់មិនបាន ពួកសាវ័កអ្នកមានសេចក្តីព្យាយាមដាង៍ទរ:ទាំងនេះ ជាអ្នកប្រសើរមែនពិត អ្នកធ្វើនូវពុទ្ធិគិញាណ(ដល់សត្វលោក)ហើយសំដែងនូវធម្មកថា ពួកសត្វណា បានឲ្យទានឧទ្ទិស ចំពោះសង្ឃ (ទាននោះ) ឈ្មោះថា ពួកសត្វទាំងនោះ បានឲ្យល្អហើយ បូជាតូចល្អហើយ បូជាធំល្អហើយ សង្ឃគតាទក្ខិណាទាននោះ ឈ្មោះថា បុគ្គលដំកល់ទុកល្អហើយ ជាទានមានផលច្រើន ព្រះសម្មាសម្ពុទ្ធទាំងឡាយ ជ្រាបច្បាស់នូវលោក ទ្រង់សរសើរហើយថា ជនទាំងឡាយណា កាលរឭកនូវបុណ្យ ដែលខ្លួនបានធ្វើ ឧទ្ទិសចំពោះសង្ឃប្រាកដដូច្នោះ ហើយកើតមានសេចក្តីត្រេកអរ រមែងត្រាច់ទៅក្នុងលោក ជនទាំងឡាយនោះ ឈ្មោះថា កំចាត់បង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫស មិនមានគេតិះដៀល រមែងទៅកាន់ឋានសួគ៌ ។

ចប់ ទទ្ទល្លវិមាន ទី ៦ ។

# សត្តមំ សេសវតីវិមានំ

(៣៨) ផលិករជតហេមជាលច្ឆន្នំ
វិវិធចិត្រតលមទ្ទសំ សុរម្មំ
ព្យម្ហំ សុនិម្មិតំ តោរណូបបន្នំ
រុចកូបកិណ្ណមិទំ[១] សុភំ វិមានំ
ភាតិ ច ទស ទិសា នភេវ សុរិយោ
សរទេ តមោនុទោ សហស្សរំសី
តថា តបតិ មិទំ តវ វិមានំ
ជលមិវ ធូមសិខោ និសេ នភគ្គេ
មុសតីវ នយនំ សតេរតាវ
អាកាសេ ឋបិតមិទំ មនុញ្ញំ
វីណាមុរជសម្មតាឡឃុដ្ឋំ
ឥទ្ធំ ឥន្ទបុរំ យថា តវ មិទំ
បទុមកុមុទុប្បលកុវលយំ
យោធិកា ភណ្ឌិកា នោជកា ច សន្តិ
សាលកុសុមិតបុប្ផិតា អសោកា
វិវិធទុមគ្គសុគន្ធសេវិតមិទំ

---

១ ម. រូបកូបកិណ្ណមិទំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ វិមានវត្ថុ

## សេសវតីវិមាន ទី ៧

(៣៤) (ព្រះវង្គីសត្ថេរពោលថា) អាត្មាបានឃើញវិមាននេះល្អ ដែលប្រក់ដោយសំណាញ់ ជាវិការៈនៃកែវផលិកនឹងប្រាក់នឹងមាស មានដែងវិចិត្រដោយកែវផ្សេង ៗ គួរឲ្យរីករាយ ដោយប្រពៃ ជាទីនៅដែលបុញ្ញកម្មនិម្មិតល្អហើយ ប្រកប ដោយក្លោងទ្វារ ពេយកាយដោយខ្សាច់មាស ជាវិមានដ៏ល្អ ព្រះអាទិត្យឰដ៏អាកាស មានរស្មី ១ ពាន់ កំចាត់បង់នូវងងឹត ក្នុងសរទកាល ញុំាងទិសទាំង ១០ ឲ្យភ្លឺ (យ៉ាងណាមិញ) វិមានរបស់នាងនេះ ក៏រុងរឿង យ៉ាងនោះដែរ វិមាននេះជាទីគាប់ចិត្ត តាំងនៅឰដ៏អាកាស ហាក់ដូចជាអណ្តាតភ្លើង រុងរឿងក្នុងវេលាយប់ ឬដូចផ្លេកបន្ទោរ ក្នុងទីបំផុតនៃពពក កន្រំពងដោយសំឡេងពិណ សំភោរ ស្គរ រតាំង វិមានរបស់នាងនេះ ដូចជាបុររបស់ព្រះឥន្ទ្រ ដ៏ស្តុកស្តម្ភ ទាំងឈូក.ស កុមុទ ឧប្បលក្រហម ឧប្បលខៀវ មានទាំងផ្កាយូថិកា ផ្កាបារ ផ្កានទោង ផ្កាសាលព្រឹក្ស ផ្កាអសោក សឹងរីកស្គុះស្គាយ វិមាននេះ ប្រសព្រុំ ដោយក្លិនក្រអូប នៃឈើដ៏ឧត្តមផ្សេង ៗ

វិមានវត្ថុស្មិំ តតិយស្ស បារិច្ឆត្តកវគ្គស្ស សត្តមំ បេសវតីវិមានំ

សលឡលពុជសុជកសំយុត្តា
កុសុកសុផុល្លិតលតាវលម្ពិនីហិ
មណិជាលសទិសា យសស្សិនី
រម្មា ពោក្ខរណី ឧបដ្ឋិតា តេ
ឧទករុហា ច យេត្ថ បុប្ផជាតា
ថលជា យេវ សន្តិ រុក្ខជាតា
មានុស្សកា អមានុស្សកា ច ទិព្វា
សេត្ត[១] តុម្ហំ និវេសនម្ហិ ជាតា
កិស្ស សមទមស្ស អយំ[២] វិបាកោ
កេនាសិ កម្មផលេនិធូបបន្នា
យថា ច តេ អធិគតមិទំ វិមានំ
តទនុបទំ អវចាសិ អឡារបម្ហេតិ[៣] ។
យថា ច មេ អធិគតមិទំ វិមានំ
កោញ្ចមយូរចកោរសង្ឃចរិតំ
ទិព្យបិលវហំ សរាជចិណ្ណំ
ទិជការណ្ឌវកោកិលាភិនាទិតំ

---

១ ម. សព្វេ ។ ២ ម. សំយមទមស្សយំ ។ ៣ ម អវចាសិឡារបម្ហេតិ ។

ម្នាលនាងមានយស ស្រះបោក្ខរណីប្រកបដោយឈើស្រស់ ខ្នុរសម្បូរនិងសុជកព្រឹក្ស(១) ប្រកបដោយឈើមានខ្លឹមខាងក្រៅ (មានត្នោតនិងដូងជាដើម) និងវល្លិ រីកស្គុះស្គាយ សំយុងចុះ ប្រាកដស្មើដោយបណ្ដាញនៃកែវមណី ជាទីរីករាយ តាំងឡើង(ក្នុងទីជិតនៃវិមាន) របស់នាង បុប្ផជាតទាំងឡាយណា ដែលដុះក្នុងទឹកក្ដី រុក្ខជាតិទាំងឡាយណា ដែលដុះលើគោកក្ដី ជារបស់មនុស្សក្ដី ជារបស់អមនុស្សក្ដី ដ៏ជាទិព្វ (បុប្ផជាតនិងរុក្ខជាតទាំងនោះ) បានដុះឡើង ជិតលំនៅរបស់នាង ក្នុងឋានសួគ៌នេះ តើជាផលនៃការស្ងប់និងការទូន្មានដូចម្ដេច នាងបានមកកើតក្នុងវិមាននេះ តើដោយផលនៃកម្មដូចម្ដេច ម្យ៉ាងទៀត វិមាននេះ នាងបានដោយកម្មណា ម្នាលនាងមានពេមភ្នែក-ង នាងគប្បីសំដែងកម្មនោះតាមលំដាប់បទ ។

(ទេវតាពោលថា) វិមាននេះហ្វូងក្រៀល ក្ងោក មាន់ទោរត្រាច់ទៅ មានហ្វូងបក្សីទឹក និងរាជហង្សត្រាច់ទៅ គឺកកងដោយសត្វចក្រៀលខ្យង តាវៅ និងសត្វស្វាប(ឯទៀតៗជាច្រើន)

---

១ សុជកព្រឹក្សនេះ មានតែក្នុងទេវលោកនិងភ្នំគន្ធមាទ ក្នុងទីដទៃមិនមាន ។ អដ្ឋកថា ។

នានាសណ្ឋានកប្បុប្ផរុក្ខវិវិធា
បាតលិជម្ពុអសោករុក្ខវន្តំ
យថា ច មេ អធិគតមិទំ វិមានំ
តន្តេ បវេទិស្សាមិ សុណោហិ ភន្តេ
មគធវរបុរត្ថិមេ
នាឡកគាមកោ នាម អត្ថិ ភន្តេ
តត្ថ អហោសឹ បុរេ សុណិសា
សេសវតីតិ តត្ថ ជានិំសុ មមំ
សាហំ អបចឹ តត្ថ កម្មកុសលំ
ទេវមនុស្សបូជិតំ មហន្តំ
ឧបតិស្សំ និព្វុតំ អប្បមេយ្យំ
មុទិតមនា កុសុមេហិ អព្ភោកិរឹ
បរមគតិគតញ្ច បូជយិត្វា
អន្តិមទេហធរំ ឥសឹ ឧឡារំ
បហាយ មានុសកំ សមុស្សយំ
តិទសាគតា ឥធ មាវសាមិ ឋានន្តិ ។

សេសវតីវិមានំ(១) សត្តមំ ។

១ ម. សេវតីវិមានំ ។

មានដើមប្រទៀង ដើមព្រីង ដើមអសោក មានឈើប្រកប ដោយផ្កាជាបណ្ដាញមានប្រការផ្សេងៗ ដែលខ្ញុំបានហើយ ដោយកម្មណាផង វិមាននេះដែលខ្ញុំបានហើយ ដោយកម្មណាផង ខ្ញុំនឹងសំដែង កម្មនោះៗ ដល់លោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ ចាំស្ដាប់ចុះ បពិត្រលោកម្ចាស់ដ៏ចំរើន មានស្រុកមួយឈ្មោះនាឡកៈ នៅក្នុងដែនមគធៈដ៏ប្រសើរ ទិសខាងកើត កាលពីដើម ខ្ញុំព្រះករុណាជាកូនប្រសា (ក្នុងគហបតិត្រកូល) ក្នុងស្រុកនាឡកៈនោះ ពួកជនក្នុងស្រុក ស្គាល់ខ្ញុំថា នាងសេសវតី ខ្ញុំនោះបានសន្សំ នូវកុសលកម្ម ក្នុងស្រុកនោះ ខ្ញុំមានចិត្តរីករាយ បានបូជាផ្កាដល់ព្រះឧបតិស្សត្ថេរ ដែលទេវតានិងមនុស្សបូជាហើយ លោកមានគុណដ៏ធំ បរិនិព្វានហើយ មានគុណប្រមាណមិនបាន លុះខ្ញុំបានបូជាលោកអ្នកស្វែងរកនូវគុណដ៏លើសលុប ទ្រទ្រង់រាងកាយជាទីបំផុត បានដល់គតិយ៉ាងក្រៃលែង ហើយខ្ញុំលះបង់កាយជារបស់មនុស្ស បានមកកាន់ទេវនិកាយជាន់តាវត្តិង្ស នាងនៅលោកនេះ ។

ចប់ សេសវតីវិមានទី ៧ ។

# អដ្ឋមំ មល្លិកាវិមានំ

(៣៦) បីតវត្ថេ បីតធជេ បីតាលង្ការភូសិតេ
បីតន្តរាហិ វគ្គូហិ អបិលន្ធាវ សោភសិ
កា កម្ពុកាយុរធរេ[1] កញ្ចនាវេឡភូសិតេ
ហេមជាលកសញ្ឆន្នេ នានារតនមាលិនី

សោវណ្ណមយា លោហិតង្គមយា ច
មុត្តាមយា វេឡុរិយាមយា ច
មសារគល្លា សហលោហិតកា[2]
បារេវតក្ខីហិ មណីហិ ចិត្តតា
កោចិ កោចិ ឯត្ថ មយូរសុស្សរោ
ហំសស្ស រញ្ញោ ករវីកសុស្សរោ
តេសំ សរោ សុយ្យតិ វគ្គុរូបោ
បញ្ចង្គិកំ តុរិយមិវប្បវាទិតំ

រថោ ច តេ សុកតោ វគ្គុ នានារតនចិត្តតោ
នានាវណ្ណេហិ[3] ធាតូហិ សុវិភត្តោវ សោភតិ

---

១ ម. កាកម្ពុកាយុរធរេ ។ ២ ឧ. សហលោហិតង្គា ។ ៣ ឱ. នានាវណ្ណាហិ ។

# មល្លិកាវិមានទី ៨

(៣៦)(នាងទេវតាសួរថា) ម្នាលនាងមានសំពត់លឿង មានទង់លឿង ស្អិតស្អាង ដោយគ្រឿងអលង្ការលឿង នាងបើទុកជាមិនប្រដាប់ ដោយសំពត់ស្បៀកមានពណ៌លឿងទាំងឡាយ មានសាច់ដ៏ល្អិតក៏ដោយ ក៏នៅតែល្អ ម្នាលនាងអ្នកទ្រទ្រង់នូវគ្រឿងប្រដាប់ដៃជាវិការៈនៃមាស ស្អិតស្អាងដោយក្រវិលជាវិការៈនៃមាស ពាសពេញដោយបណ្ដាញ ជាវិការៈនៃមាស នាងជាអ្វី នាងមានកម្រងកែវផ្សេងៗ

កម្រងជាវិការៈនៃមាសផង ជាវិការៈនៃកែវមណីមានពណ៌
ក្រហមផង ជាវិការៈនៃកែវមុក្តាផង ជាវិការៈនៃកែវ
ពិទូរ្យផង កែវពព្រុសផង មួយអន្លើដោយកែវមានពណ៌
ក្រហមផង ដ៏វិចិត្រដោយកែវទាំងឡាយ ប្រាកដស្មើដោយ
ក្អែកព្រាប បណ្ដាកម្រងទាំងនុ៎ះ កម្រងមួយៗ មាន
សូរពីរោះដូចសម្លេងក្ងោក ដូចសម្លេងរាជហង្ស(ឬ)ពីរោះដូច
សម្លេងករវិក សូរកម្រងទាំងនោះ មានភាពពីរោះ ឮហាក់
ដូចជាតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលគេប្រគំហើយ

ទាំងរថ របស់នាង ក៏មានសភាព ស្អាតល្អ មានអវយវៈ ដ៏វិចិត្រហើយ ដោយកែវផ្សេងៗ ដែលដាំ ចាក់ចែងហើយ ដោយធាតុ[១] ទាំងឡាយ មានពណ៌ផ្សេងៗ សមល្អ

---

១ ដោយសម្ភារៈមានទ្រពងនិងបង្គោលជាដើម ។ អដ្ឋកថា ។

តស្មឹ រថេ កញ្ចនពិម្ពវណ្ណា
យត្ថ(១) ឋិតា ភាសសិមំ បទេសំ
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលន្តិ ។
សោវណ្ណជាលំ មណិសោវណ្ណចិត្តំ(២)
មុត្តាចិត្តំ ហេមជាលេន ឆន្នំ(៣)
បរិនិព្វុតេ គោតមេ អប្បមេយ្យេ
បសន្នចិត្តា អហមាភិរោបយឹ
តាហំ កម្មំ ករិត្វាន កុសលំ ពុទ្ធវណ្ណិតំ
អបេតសោកា សុខិតា សម្បមោទាមនាមយាតិ ។

មល្លិកាវិមានំ អដ្ឋមំ ។

## នវមំ វិសាលក្ខិវិមានំ

(៣៧) កា នាម ត្វំ វិសាលក្ខី រម្មេ ចិត្តលតាវនេ
សមន្តា អនុបរិយាសិ នារីគណបុរក្ខតា
យទា ទេវា តាវតឹសា បវិសន្តិ ឥមំ វនំ
សយោគ្គា សរថា សព្វេ ចិត្រា ហោន្តិ ឥធាគតា
តុយ្ហញ្ច ឥធ បត្តាយ ឧយ្យានេ វិចរន្តិយា
កាយេន ទិស្សតិ ចិត្តំ កេន រូបំ តវេទិសំ

---

១ ឱ.ម. យា ត្វំ ។ ២ ម. មណិសោវណ្ណចិត្តិតំ ។ ៣ ម. សញ្ឆន្នំ ។

នាងឋិតនៅលើរថនោះ មានពណ៌មានរូបប្រៀប

ដោយមាស ញុំាងប្រទេសនេះ ឲ្យភ្លឺរុងរឿង

ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវធីតាឆ្លើយថា) ខ្ញុំមានចិត្តជ្រះថ្លា ចំពោះព្រះគោតម

ព្រះអង្គមានគុណប្រមាណមិនបាន ដែលទ្រង់បរិនិព្វាន

ហើយ បានបូជាបណ្ដាញមាសដ៏វិចិត្រ ដោយកែវមណី

និងមាសរំលេចដោយកែវមុក្តា បាំងដោយសំណាញ់មាស

ខ្ញុំបានធ្វើកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ ប្រាស

ចាកសេចក្ដីសោក ដល់នូវសេចក្ដីសុខ មានចិត្តត្រេកអរព្រម ។

ចប់ មល្លិកាវិមានទី ៨ ។

## វិសាលក្ខិវិមាន ទី៩

(៣៧) (សក្កទេវរាជសួរថា) ម្នាលនាងមានភ្នែកធំទូលាយ នាង

ឈ្មោះអ្វី បានជា មានពួកនារីហោមរោម ហើយដើរត្រេចរឿង ជុំវិញ

ព្រៃចិត្តលតា ជាទីរីករាយ ពួកទេវតាដាន់តាវត្តិង្ស ចូលទៅកាន់

ព្រៃនេះ ក្នុងកាលណា (កាលនោះ) ពួកទេវតាទាំងអស់ ព្រម

ទាំងយាន ព្រមទាំងរថ ដ៏វិចិត្រ ក៏មកក្នុងទីនុ៎ះ នាងកាលមក

ដល់ក្នុងទីនេះ ហើយត្រាច់ទៅក្នុងឧទ្យាន ចិត្តរមែងប្រាកដដោយ

កាយ រូបរបស់នាង ក៏ប្រាកដដូច្នេះ តើដោយហេតុដូចម្ដេច

វិមានវត្ថុស្មឹ តតិយស្ស បារិច្ឆត្តកវគ្គស្ស នវមំ វិសាលក្ខិវិមានំ

ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលំ(តិ)។
យេន កម្មេន ទេវិន្ទ រូបំ មជ្ឈំ គតី ច មេ
ឥទ្ធី ច អានុភាវោ ច តំ សុណោហិ បុរិន្ទទ
អហំ រាជគហេ រម្មេ សុនន្ទា នាម ឧបាសិកា
សទ្ធា សីលេន សម្បន្នា សំវិភាគរតា សទា
អច្ឆាទនញ្ច ភត្តញ្ច សេនាសនំ បទីបិយំ
អទាសឹ ឧជុភូតេសុ វិប្បសន្នេន ចេតសា
ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសឹ សទា សីលេសុ សំវុតា
បាណាតិបាតា វិរតា មុសាវាទា ច សញ្ញតា
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារកា
បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា
ឧបាសិកា ចក្ខុមតោ គោតមស្ស យសស្សិនោ
តស្សា មេ ញាតិកុលំ អាសិ សទា មាលាភិហារតិ
តាហំ ភគវតោ ថូបេ សព្វមេវាភិរោបយឹ

ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ គតិ រិទ្ធិ និងអានុភាពរបស់ខ្ញុំ (កើតឡើង) ដោយកម្មណា បពិត្រព្រះអង្គទ្រង់ព្រះនាមបុរិន្ទទៈ សូមព្រះអង្គស្តាប់ នូវកម្មនោះចុះ ខ្ញុំជាឧបាសិកា ឈ្មោះសុនន្ទា នៅក្នុងក្រុងរាជគ្រឹះជាទីត្រេកអរ ជាស្ត្រីបរិបូណ៌ ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន មានចិត្តជ្រះថ្លា បានឲ្យសំពត់សម្រាប់ស្លៀកដណ្តប់ផង ភត្តផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះពួកព្រះអរិយបុគ្គល អ្នកមានចិត្តត្រង់ សព្វៗ កាល ខ្ញុំបានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង បានសង្រួមក្នុងសីលទាំងឡាយផង វៀរចាកបាណាតិបាតផង សង្រួមចាកមុសាវាទផង ឆ្ងាយចាកការលួចផង ចាកការប្រព្រឹត្តកន្លង (ចិត្តស្វាមី)ផង ចាកការផឹកទឹកស្រវឹងផង សព្វៗកាល ហើយត្រេកអរ ក្នុងសិក្ខាបទទាំង ៥ ឈ្លាសក្នុងអរិយសច្ចទាំងឡាយ ជាឧបាសិកានៃព្រះគោតមព្រះអង្គមានបញ្ញាចក្ខុ មានយស ឯត្រកូលនៃញាតិរបស់ខ្ញុំនោះតែងយកកម្រងផ្កា មកឲ្យខ្ញុំ សព្វៗ កាល ខ្ញុំបានបូជាកម្រងផ្កានោះទាំងអស់ ចំពោះព្រះស្តូប នៃព្រះមានព្រះភាគ

ឧបោសថេចហំ គន្ត្វា មាលាគន្ធវិលេបនំ
ថូបស្មឹ អភិរោបេសឹ បសន្នា សេហិ បាណិហិ
តេន កម្មេន ទេវិន្ទ រូបំ មយ្ហំ គតី ច មេ
ឥទ្ធី ច អានុភាវោ ច យញ្ច មាលាភិបូជយឹ
យញ្ច សីលវតី អាសឹ ន តំ តាវ វិបច្ចតិ
អាសា ច បន មេ ទេវិន្ទ សកទាគាមិនី សិយន្តិ ។

វិសាលក្ខិវិមានំ នវមំ ។

## ទសមំ បារិច្ឆត្តកវិមានំ

(៣៨) បារិច្ឆត្តកេ កោវិឡារេ រមណីយេ មនោរមេ
ទិព្វមាលំ គន្ថមានា គាយន្តី សម្បមោទសិ
តស្សា តេ នច្ចមានាយ អង្គមង្គេហិ សព្វសោ
ទិព្វា សទ្ទា និច្ឆរន្តិ សវនីយា មនោរមា
តស្សា តេ នច្ចមានាយ អង្គមង្គេហិ សព្វសោ
ទិព្វា គន្ធា បវាយន្តិ សុចិគន្ធា មនោរមា
វិវត្តមានា កាយេន យា វេណីសុ បិលន្ធនា

ខ្ញុំមានចិត្តជ្រះថ្លា បានទៅក្នុងថ្ងៃឧបោសថ ហើយបូជាកម្រងផ្កា គ្រឿងក្រអូបគ្រឿងលាប ចំពោះព្រះស្តូប ដោយដៃរបស់ខ្លួន បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ គតិ ឫទ្ធិ និងអានុភាព របស់ខ្ញុំ (កើតឡើង) ដោយកម្មនោះ ដែលខ្ញុំបានបូជាកម្រងផ្កាក្តី ដែលខ្ញុំជាស្ត្រីមានសីលក្តី ការបូជានូវកម្រងផ្កា និងការរក្សាសីល របស់ខ្ញុំនោះ មិនទាន់ឲ្យផលនៅឡើយ បពិត្រព្រះអង្គជាធំជាងទេវតា តែសេចក្តីប្រាថ្នារបស់ខ្ញុំថា សូមឲ្យខ្ញុំបានជាសកទាគាមិនី ។

ចប់ វិសាលក្ខីវិមាន ទី ៩ ។

## បារិច្ឆត្តកវិមាន ទី ១០

(៣៨) (ព្រះមោគ្គល្លានសួរថា) កាលនាងកាន់ផ្កាល្អស្អុងទាំងឡាយ ឈ្មោះបារិច្ឆត្តកព្រឹក្ស គួររីករាយ គួរត្រេកអរនៃចិត្ត ហើយគ្រងជាកម្រងទិព្វ ច្រៀង រីករាយ សប្បាយ កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួរជាទីរីករាយនៃចិត្ត រមែងលាន់ឮ អំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ កាលដែលនាង កំពុងរាំនោះ ក្លិនទិព្វទាំងឡាយ មានក្លិនក្រអូបគួរជាទីរីករាយនៃចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ នាងរាកកាយ គ្រឿងប្រដាប់ ទាំងឡាយណា ឮដំផ្សងសក់ របស់នាង

វិមានវត្ថុម្ហិ តតិយស្ស បារិច្ឆត្តកវគ្គស្ស ឧទ្ទានំ

តេសំ សុយ្យតិ និគ្ឃោសោ តុរិយេ បញ្ចង្គិកេ យថា
វដំសកា វាតធូតា វាតេន សម្បកម្បិតា
តេសំ សុយ្យតិ និគ្ឃោសោ តុរិយេ បញ្ចង្គិកេ យថា
យាបិ(១) តេ សិរស្មិំ មាលា សុចិគន្ធា មនោរមា
វាតិ គន្ធោ ទិសា សព្វា រុក្ខោ មញ្ជូសកោ យថា
ឃាយសេ តំ សុចិគន្ធំ រូបំ បស្សសិ អមានុសំ
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលំ(តិ)។
បភស្សរំ អច្ឆិមន្តំ(២) វណ្ណគន្ធេន សញ្ញុតំ
អសោកបុប្ផមាលាហំ ពុទ្ធស្ស ឧបនាមយឹ
តាហំ កម្មំ ករិត្វាន កុសលំ ពុទ្ធវណ្ណិតំ
អបេតសោកា សុខិតា សម្បមោទាមនាមយាតិ ។

បារិច្ឆត្តកវិមានំ ទសមំ ។

## ឧទ្ទានំ

ឧឡារំ ឧច្ឆុបល្លង្កំ លតា ច គុត្តិលេន ច
ទទ្ទល្ល សេសវតី មល្លិ(៣) វិសាលក្ខិ បារិច្ឆត្តកោ
វគ្គោ តេន បវុច្ចតីតិ ។

បារិច្ឆត្តកវគ្គោ តតិយោ ។

---

១ ម, តស្សា ។ ២ ឱ, ម. អច្ចិមន្តំ ។ ៣ ម. ទទ្ទល្ល បេសមល្លិកា ។

សំឡេងគឹកកង នៃគ្រឿងប្រដាប់តាំងឡាយនោះ ឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះ ក៏កម្រើកដោយខ្យល់ សូរនៃគ្រឿងប្រដាប់ត្រចៀកតាំងនោះ ឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ៥ កម្រងផ្កាណា ឯជំសិរ្សៈរបស់នាង មានក្លិនក្រអូបឈ្ងុយឈ្ងប់ ជាទីរីករាយនៃចិត្ត (ក្លិនកម្រងផ្កានោះ) រមែងផ្សាយទៅសព្វទិស ហាក់ដូចដើមឧឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូប ដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) ខ្ញុំបានបង្អោននូវកម្រងផ្កាអសោក មានរស្មីភ្លឺផ្លេក ប្រកបដោយពណ៌និងក្លិន ចំពោះព្រះពុទ្ធ ខ្ញុំបានធ្វើនូវកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ បានប្រាសចាកសេចក្តីសោក បានដល់នូវសេចក្តីសុខ មានចិត្តត្រេកអរព្រម ។

ចប់ បារិច្ឆត្តកវិមាន ទី ១០ ។

## ឧទ្ទាន

និយាយអំពីឧឡារវិមាន ១ ឧច្ឆុវិមាន ១ បល្លង្កវិមាន ១ លតាវិមាន១ គុត្តិលវិមាន ១ ទទ្ទល្លវិមាន ១ សេសវតីវិមាន ១ មល្លិកាវិមាន ១ វិសាលក្ខីវិមាន ១ បារិច្ឆត្តកវិមាន ១ ព្រោះហេតុនោះ ទើបហៅថាវគ្គ ។

ចប់ បារិច្ឆត្តកវគ្គ ទី ៣ ។

# ចតុត្ថោ មញ្ជិដ្ឋកវគ្គោ

## បឋមំ មញ្ជិដ្ឋកវិមានំ

(៣៩) មញ្ជិដ្ឋកេ[1] វិមានស្មឹ សោវណ្ណវាលុកសន្ថតេ
បញ្ចង្គិកេន តុរិយេន រមសិ សុប្បវាទិតេ
តម្ហា វិមានា ឱរុយ្ហ និម្មិតា រតនាមយា
ឱគាហសិ សាលវនំ បុប្ផិតំ សព្ពកាលិកំ
យស្ស យស្សេវ សាលស្ស មូលេ តិដ្ឋសិ ទេវតេ
សោ សោ មុញ្ចតិ បុប្ផានិ ឱនមិត្វា ទុមុត្តមោ
វាតេរិតំ សាលវនំ អាធុតំ ទិជសេវិតំ
វាតិ គន្ធោ ទិសា សព្វា រុក្ខា មញ្ជុសកោ[2] យថា
ឃាយសេ តំ សុចិគន្ធំ រូបំ បស្សសិ អមានុសំ
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលន្តិ ។
អហំ មនុស្សេសុ មនុស្សភូតា
ទាសី អយ្យិរកុលេ[3] អហុំ
ពុទ្ធំ និសិន្នំ ទិស្វាន សាលបុប្ផេហិ ឱកិរឹ
វដំសកញ្ច សុកតំ សាលបុប្ផមយំ អហំ
ពុទ្ធស្ស ឧបនាមេសឹ បសន្នា សកេហិ បាណិហិ

១ ឱ. មញ្ជេដ្ឋកេ ។ ២ ឱ. មញ្ជូសកោ ។ ៣ ឱ. អយ្យរកុលេ ។

# មញ្ជិដ្ឋកវគ្គទី ៤

## មញ្ជិដ្ឋកវិមានទី ១

(៣៩) (ព្រះមោគ្គល្លានសួរថា) នាងត្រេកអរ ដោយតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ដែលគេប្រគំពីរោះ ក្នុងវិមានកែវផលិក ពណ៌ហង្សបាទ ក្រាលខ្សាច់មាស នាងចុះចាកវិមាននោះ ដែលបុញ្ញកម្មនិម្មិតហើយ ជាវិការៈនៃកែវ ហើយចូលទៅកាន់ ព្រៃសាលព្រឹក្សមានផ្កាកើតសព្វកាល ម្នាលទេវតា នាងឋិតនៅជិត គល់សាលព្រឹក្សណាៗ ដើមសាលព្រឹក្សនោះៗ ជាឈើដ៏ឧត្តម រមែងឱនទន់ទោរ ជម្រុះផ្កាចុះមក ព្រៃសាលព្រឹក្សក៏ជួយដោយខ្យល់ ត្រូវខ្យល់បក់មកកំរើកៗ មានពួកសត្វបក្សីនៅអាស្រ័យ ក្លិនក៏ ផ្សាយទៅ សព្វទិស ដូចដើមឪឡោក នាងតែងដុំក្លិនក្រអូបនោះ តែងឃើញរូប ដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មា សួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) ខ្ញុំកាលកើត ជាមនុស្ស

ក្នុងពួកមនុស្ស ជាទាសី ក្នុងផ្ទះចៅហ្វាយ

ខ្ញុំបានឃើញព្រះពុទ្ធ កំពុងគង់ បានរោយរាយផ្កាសាលព្រឹក្ស ខ្ញុំមាន ចិត្តជ្រះថ្លា បានបូជាគ្រឿងប្រដាប់ត្រចៀក ដែលល្អហើយ ជាវិការៈនៃផ្កាសាលព្រឹក្ស ចំពោះព្រះសម្ពុទ្ធ ដោយដៃរបស់ខ្លួន

តាហំ កម្មំ ករិត្វាន កុសលំ ពុទ្ធវណ្ណិតំ
អបេតសោកា សុខិតា សម្បមោទាមនាមយាតិ ។

មញ្ជិដ្ឋកវិមានំ[១] បឋមំ ។

## ទុតិយំ បភស្សរវិមានំ

[៤០] បភស្សរវរវណ្ណនិភេ
សុរត្តវត្ថនិវាសនេ
មហិទ្ធិកេ ចន្ទនរុចិរគត្តេ
កា ត្វំ សុភេ ទេវតេ វន្ទសេ មមំ
បល្លង្កោ ច តេ មហគ្ឃោ
នានារតនចិត្តិតោ រុចិរោ
យត្ថ ត្វំ និសិន្នា វិរោចសិ
ទេវរាជារិវ នន្ទនេ វនេ
កិំ ត្វំ បុរេ សុចរិតមាចរី ភទ្ទេ
កិស្ស កម្មស្ស វិបាកំ អនុភោសិ
ទេវលោកស្មិំ ទេវតេ បុច្ឆិតាចិក្ខ
កិស្ស កម្មស្សិទំ ផលន្តិ ។
បិណ្ឌាយ តេ ចរន្តស្ស
មាលំ ផាណិតញ្ច អទទំ ភន្តេ

១ ឱ. មញ្ជេដ្ឋកវិមានំ ។

ខ្ញុំបានធ្វើកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ បានប្រាសចាក សេចក្តីសោក ដល់នូវសេចក្តីសុខ មិនមានរោគ មានចិត្តត្រេកអរព្រម ។

ចប់ មញ្ជិដ្ឋកវិមាន ទី ១ ។

## បភស្សរវិមាន ទី ២

(៤០)(ព្រះមោគ្គល្លានសួរថា) ម្នាលទេវតាល្អ មានពន្លឺ មានពណ៌ប្រសើរក្លៃផ្ទេក ស្លៀកសំពត់ពណ៌ក្រហម ស្រស់ មានរិទ្ធិច្រើន មានខ្លួនរុងរឿងហាក់ដូចប្រស់ព្រំ ដោយខ្លឹមចន្ទន៍ នាងជាអ្វី មកថ្វាយបង្គំអាត្មា មួយទៀត បល្លង្ករបស់នាងមានតម្លៃច្រើន សឹងវិចិត្រ ដោយកែវផ្សេងៗ ដ៏រុងរឿង នាងអង្គុយលើបល្លង្ក ដ៏រុងរឿង ដូចទេវរាជ (បិតនៅ) ក្នុងនន្ទនវ័ន ម្នាលនាងដ៏ចំរើន ក្នុងកាលមុន នាងបានប្រព្រឹត្តសុចរិតដូចម្តេច នាងសោយផលកម្មដូចម្តេច ក្នុងទេវលោក ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) បពិត្រព្រះថេរៈ ដ៏ចំរើន ខ្ញុំព្រះករុណា បានប្រគេន នូវផ្កាម្លិះ និងស្ករអំពៅ ដល់លោកម្ចាស់ កាលនិមន្តទៅ ដើម្បីបិណ្ឌបាត

តស្ស កម្មស្សិទំ វិបាកំ
អនុភោមិ ទេវលោកស្មឹ
ហោតិ ច មេ អនុតាបោ
អបរធំ ទុក្ខិតញ្ច មេ ភន្តេ
សាហំ ធម្មំ នាស្សោសឹ
សុទេសិតំ ធម្មរាជេន
តំ តំ វទាមិ ភទ្ទន្តេ
យស្ស មេ អនុកម្បិយោ
កោចិ ធម្មេសុ តំ សមាទបេថ
សុទេសិតេ ធម្មរាជេន
យេសំ អត្ថិ សទ្ធា ពុទ្ធេ
ធម្មេ ច សង្ឃរតនេ ច
តេ មំ អតិវិរោចន្តិ
អាយុនា យសសា សិរិយា
បតាបេន វណ្ណេន ឧត្តរិតរា
អញ្ញេ មហិទ្ធិកតរា មយា ទេវាតិ ។

បភស្សរវិមានំ ទុតិយំ ។

ខ្ញុំទើបទទួលនូវផលនេះ នៃកម្មនោះ គួរទេវលោក បពិត្រព្រះថេរៈដ៏ចំរើន តែសេចក្តីក្តៅក្រហាយមាន ដល់ខ្ញុំ ទាំងទោសកំហុស ដែលដល់នូវសេចក្តីទុក្ខ (កំកើតឡើង) ដល់ខ្ញុំ (ព្រោះ)ខ្ញុំនោះ មិនបានស្តាប់ធម៌ ដែលព្រះពុទ្ធ ជាធម្មរាជ ទ្រង់សំដែងល្អហើយ បពិត្រព្រះថេរៈដ៏ចំរើន ព្រោះហេតុនោះ បានជាខ្ញុំ និយាយនឹងលោកម្ចាស់ថា បុគ្គលណាមួយ ដែលខ្ញុំ គួរអនុគ្រោះ លោកម្ចាស់បានដឹកនាំបុគ្គលនោះ ក្នុង ធម៌ទាំងឡាយ ដែលព្រះពុទ្ធ ជាធម្មរាជ ទ្រង់សំដែង ល្អហើយ សេចក្តីជឿចំពោះពុទ្ធរតនៈ ធម្មរតនៈនឹង សង្ឃរតនៈ មានដល់ទេវតាទាំងឡាយណា ទេវតា ទាំងឡាយដទៃនោះ ច្រើនលើសលុប ដែលមានឫទ្ធិ ច្រើនជាងខ្ញុំ រមែងរុងរឿង ក្រៃលែងនូវខ្ញុំ ដោយអាយុ ដោយយស ដោយសិរី ដោយតេជះ ដោយវណ្ណៈ ។

ចប់ បភស្សរវិមាន ទី ២ ។

# តតិយំ នាគវិមានំ

(៤១) អលង្កតា កនកកញ្ចនាចិតំ[១]
សុវណ្ណជាលចិត្តំ មហន្តំ
អភិរុយ្ហ គជវំ សុកប្បិតំ
ឥធាគមា វេហាសយំ អន្តលិក្ខេ
នាគស្ស ទន្តេសុ ទុវេសុ និម្មិតា
អច្ឆោទកា បទុមិនិយោ សុផុល្លា
បទុមេសុ តុរិយគណា បវជ្ជរេ
ឥមា ច នច្ចន្តិ មនោហរាយោ
ទេវិទ្ធិបត្តាសិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
ពារាណសិយំ ឧបសង្កមិត្វា
ពុទ្ធស្សហំ វត្ថយុគំ អទាសិំ
បាទានិ វន្ទិត្វា ឆមា និសីទឹ
ចិត្តាវតំ[២] អញ្ជលិកំ អកាសិំ[៣]

---

១ ឱ. មណិកនកកញ្ចនាចិតំ ។ ម. មណិកញ្ចនាចិតំ ។ ២ ឱ. វិត្តាវតំ ។ ម. វិត្តាហំ ។ ៣ ម. អទាសឹ ។

# នាគវិមាន ទី ៣

(៤១) (ព្រះវង្គីសត្ថេរដ៏មានអាយុសួរថា) នាងប្រដាប់ខ្លួន ហើយ ឡើងជិះដំរីប្រសើរ វិចិត្រដោយកែវមណីនឹងមាស បិទបាំងដោយបណ្តាញមាស ជាដំរីមាឌធំ ដែលបុញ្ញកម្ម សម្រេចល្អហើយ (អង្គុយ) លើខ្នងដំរី ជាទីកែកាយ មកឰដ៏អាកាស ក្នុងទីនេះ ស្រះទាំងឡាយ មានទឹកថ្លា មានគុម្ពឈូក មានផ្កាកែស្គុះស្គាយ ដែលបុញ្ញកម្មនិម្មិត ហើយ ត្រង់ក្ដុកដំរីទាំងគូ ពួកតូរ្យតន្ត្រី ប្រគំ លើផ្កាឈូកទាំងឡាយ មានពួកស្រីកែវមនោហរទាំងនេះ ក៏រាំ (លើផ្កាឈូកទាំងនោះ) ម្នាលនាង មានអានុភាព ច្រើន នាងដល់នូវរិទ្ធិនៃទេវតា នាងកាលកើត ជាមនុស្ស តើបានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាងនេះ ផង ទាំងសម្បុររបស់នាង ក៏អាចញុំាងទិសទាំងពួងឲ្យភ្លឺ បានផង តើដោយបុណ្យដូចម្តេច ។

(ទេវតាឆ្លើយថា) ខ្ញុំបានចូលទៅក្នុងក្រុងពារាណសី បានថ្វាយ សំពត់មួយគូដល់ព្រះពុទ្ធ ហើយថ្វាយបង្គំព្រះបាទា អង្គុយលើ ផែនដី មានចិត្តត្រេកអរ បានធ្វើនូវអញ្ជលិកម្ម ចំពោះព្រះអង្គ

ពុទ្ធោ ច មេ កញ្ចនសន្និភត្តចោ
អទេសយិ សមុទយទុក្ខនិច្ចតំ
អសង្ខតំ ទុក្ខនិរោធសច្ចំ[១]
មគ្គំ អទេសយិ យតោ វិជានិស្សំ[២]
អប្បាយុកី កាលកតា តតោ ចុតា
ឧបបន្នា តិទសានំ[៣] យសស្សិនី
សក្កស្សហំ អញ្ញតរា បជាបតិ
យសុត្តរា នាម ទិសាសុ វិស្សុតាតិ ។

នាគវិមានំ តតិយំ ។

## ចតុត្ថំ អលោមវិមានំ

(៦២) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ

---

១ ម. ទុក្ខនិរោធសស្សតំ ។ ២ ម. វិជានិយំ ។ ៣ ម. ឧប្បន្នា តិទសគណា ។

បំណែកព្រះពុទ្ធ ព្រះអង្គមានព្រះបញ្ញាដ៏ភ្លឺ ប្រាកដស្មើដោយមាស ព្រះអង្គបានសំដែងសមុទយសច្ចនឹងទុក្ខសច្ច ជារបស់មិនទៀងផង បានសំដែងទុក្ខនិរោធសច្ច ជាអសង្ខតធម៌ផង មគ្គសច្ចផង ដល់ខ្ញុំ ជាហេតុឲ្យខ្ញុំបានត្រាស់ដឹង ខ្ញុំជាស្រីមានអាយុតិច ធ្វើមរណកាល ច្យុតមកកើត ក្នុងពួកទេវតា ជាន់តាវត្តិង្ស ជាស្រីមានយស ជាបជាបតីគឺប្រពន្ធមួយ របស់សក្កទេវរាជ ឈ្មោះនាង យសុត្តរា ល្បីពេញសព្វទិសទាំងឡាយ ។

ចប់ នាគវិមាន ទី ៣ ។

# អលោមវិមាន ទី ៤

(៤៦) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើ (សម្រេច) ដោយបុណ្យដូចម្តេច ។ បេ ។ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

អហញ្ច ពារាណសិយំ ពុទ្ធស្សាទិច្ចពន្ធុនោ
អទាសឹ សុក្ខកុម្មាសំ បសន្នា សកេហិ បាណិហិ
សុក្ខាយ អលោណិកាយ ច បស្ស ផលំ[១] កុម្មាសបិណ្ឌិយា
អលោមំ សុខិតំ ទិស្វា កោ បុញ្ញំ ន ករិស្សតិ[២]
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អលោមវិមានំ ចតុត្ថំ ។

## បញ្ចមំ កញ្ជិកទាយិកាវិមានំ

(៨៣) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
។ បេ ។ ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
អហំ អន្ធកវិន្ទស្មឹ ពុទ្ធស្សាទិច្ចពន្ធុនោ
អទាសឹ កោលសម្បាកំ កញ្ជិកំ តេលធូបិតំ

---
១ ម. ផុស្ស ផលំ ។ ២ ម. ករិស្សតីតិ ។

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំកុម្មាសក្រៀម ដល់ព្រះពុទ្ធជាអាទិច្ចពន្ធុ ទៀបក្រុងពារាណសី ដោយដៃរបស់ខ្លួន សូមលោកម្ចាស់មើលនូវផលនៃនំកុម្មាសក្រៀមផង សាបផងចុះ អ្នកណាឃើញនាងអនោមា ជាស្រីដល់នូវសេចក្តីសុខហើយ នឹងមិនធ្វើនូវបុណ្យកើត ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ អនោមវិមាន ទី ៤ ។

# កញ្ជិកទាយិកាវិមាន ទី ៥

(៤៣) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។ បេ ។ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ តើសម្រេចដោយបុណ្យ ដូចម្តេច ។ បេ ។ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេន នូវទឹកបបរ ដែលបំអិនលាយ ដោយផ្លែពុទ្រាអប់ដោយប្រេង ដល់ព្រះពុទ្ធជាអាទិច្ចពន្ធុ ក្នុងស្រុកឈ្មោះអន្ធកវិន្ទៈ

បិប្ផល្យាលសុណេន ច　　មិស្សំ លាមញ្ជកេន ច
អទាសឹ ឧជុភូតស្មឹ　　វិប្បសន្នេន ចេតសា
យា មហេសិតំ ការេយ្យ　　ចក្កវត្តិស្ស រាជិនោ
នារី សព្វង្គកល្យាណី　　ភត្តុ ចានោមទស្សិកា
ឯតស្ស[១] កញ្ជិកទានស្ស　　កលំ នាគ្ឃតិ សោឡសឹ
សតំ និក្ខា សតំ អស្សា　　សតំ អស្សតរីរថា
សតំ កញ្ញាសហស្សានិ　　អាមុត្តមណិកុណ្ឌលា
ឯតស្ស កញ្ជិកទានស្ស　　កលំ នាគ្ឃន្តិ សោឡសឹ
សតំ ហេមវតា នាគា　　ឦសាទន្តា ឧរូឡ្ហវា
សុវណ្ណកច្ឆា មាតង្គា　　ហេមកប្បនិវាសសា
ឯតស្ស កញ្ជិកទានស្ស　　កលំ នាគ្ឃន្តិ សោឡសឹ
ចតុន្នំបិ ច ទីបានំ　　ឥស្សរំ យោធ ការយេ
ឯតស្ស កញ្ជិកទានស្ស　　កលំ នាគ្ឃតិ សោឡសិន្តិ ។

កញ្ជិកទាយិកាវិមានំ បញ្ចមំ ។

---

១ ម. ឯកស្ស ។

ខ្ញុំមានចិត្តជ្រះថ្លា ចំពោះព្រះពុទ្ធអង្គទៀងត្រង់ បានប្រគេនវត្ថុណាយ ប្រឡំដោយដីប្ដី ខ្ញុំមមើម នឹងវត្ថុមានក្លិនប្រហើរ នារីណាមាន អវយវៈល្អសព្វ មានរូបមិនថោកថយ គួរមើលរបស់កស្ដា គប្បីធ្វើ ជាអគ្គមហេសីនៃស្ដេចចក្រពត្តិ នារីនោះមិនដល់ចំណិតទី ១ នៃ ចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរ នេះឡើយ មាសក្ដារ ១០០ សេះ ១០០ រថទឹមដោយមេសេះអស្សតរ ១០០ កញ្ញា ១ សែន ដែលពាក់កុណ្ឌលកែវមណី ក៏មិនដល់ ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃ ការឲ្យទឹកបបរនេះឡើយ ពួកដំរីដែលកើតក្នុងប្រទេសឈ្មោះហិមវន្ត ចំនួន ១០០ មានភ្លុក-ដូចចន្ទោលរថ ចំរើនដោយកំឡាំងនឹងសន្ទុះ នឹងការប្រើប្រែង មានខ្សែដង្គត់ជាវិការៈនៃមាស មានគ្រឿងប្រដាប់ សម្រេចដោយមាស ក៏មិនដល់ចំណិតទី ១ នៃចំណែកដែល គេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ បុគ្គលណា ក្នុងលោកនេះ គប្បីធ្វើនូវភាពនៃខ្លួនជាធំ ក្នុងទ្វីបទាំង ៤ បុគ្គលនោះ ក៏នៅតែមិនទាន់ដល់ចំណិតទី ១ នៃចំណែកដែល គេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ ។

ចប់ កញ្ជិកទាយិកាវិមាន ទី ៤ ។

# ឆដ្ឋំ វិហារវិមានំ

(៤៤) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ៗ បេ ៗ ឱសធី វិយ តារកា
តស្សា តេ នច្ចមានាយ អង្គមង្គេហិ សព្វសោ
ទិព្វា សទ្ទា និច្ឆរន្តិ សវនីយា មនោរមា
តស្សា តេ នច្ចមានាយ អង្គមង្គេហិ សព្វសោ
ទិព្វា គន្ធា បវាយន្តិ សុចិគន្ធា មនោរមា
វិវត្តមានា កាយេន យា វេណីសុ បិឡន្ធនា
តេសំ សុយ្យតិ និគ្ឃោសោ តុរិយេ បញ្ចង្គិកេ យថា
វដំសកា វាតធុតា វាតេន សម្បកម្បិតា
តេសំ សុយ្យតិ និគ្ឃោសោ តុរិយេ បញ្ចង្គិកេ យថា
យាបិ តេ សិរសិ មាលា សុចិគន្ធា មនោរមា
វាតិ គន្ធោ ទិសា សព្វា រុក្ខោ មញ្ជូសកោ យថា
ឃាយសេ តំ សុចិគន្ធំ រូបំ បស្សសិ អមានុសំ
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលន្តិ ៗ

សាវត្ថិយំ មយ្ហំ សខី ភទន្តេ
សង្ឃស្ស ការេសិ មហាវិហារំ
តត្ថ បសន្នា អហមានុមោទឹ

# វិហារវិមាន ទី៦

(៤៤) (ព្រះអនុរុទ្ធត្ថេរសួរថា) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។ បេ ។ ដូចផ្កាយព្រឹក កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួរពេញចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំដោយសព្វគ្រប់ កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយ មានក្លិនក្រអូប ជាទីពេញចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំ ដោយសព្វគ្រប់ កាលនាងរាំកាយ គ្រឿងប្រដាប់ទាំងឡាយឮដ៏ផងសក់ ក៏ឮសូរគឹកកង ដូចតូរ្យតន្ត្រីប្រកបដោយអង្គ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះក៏កើតដោយខ្យល់ ឮសូរគឹកកងដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ផ្កាកម្រងណា ឮដ៏សិរ្សៈរបស់នាង មានក្លិនក្រអូប ជាទីពេញចិត្ត (ក្លិនថៃផ្កាកម្រងនោះ) រមែងផ្សាយទៅសព្វទិស ដូចដើមទុំឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូប ដែលមិនមែនជារបស់មនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) បពិត្រព្រះអនុរុទ្ធដ៏ចំរើន (នាងវិសាខា) ជាសំឡាញ់របស់ខ្ញុំ បានឲ្យធ្វើមហាវិហារទៀបក្រុងសាវត្ថី ឧទ្ទិសចំពោះព្រះសង្ឃ ខ្ញុំជ្រះថ្លា ពេញពាយ ចំពោះវិហារនោះ

ទិស្វា អគារញ្ច បិយញ្ច មេតំ
តាយេវ មេ សុទ្ធមនោបសាទាយ
លទ្ធំ វិមានព្ភុតទស្សនេយ្យំ
សមន្តតោ សោឡសយោជនានិ
វេហាសយំ គច្ឆតិ ឥទ្ធិយា មម

កូដាគារា និវេសា មេ វិភត្តា ភាគសោ មិតា
ទទ្ទល្លមានា អាភន្តិ សមន្តា សតយោជនំ
បោក្ខរញ្ញោ ច មេ ឯត្ថ បុថុលោមនិសេវិតា
អច្ឆោទកា វិប្បសន្នា សោវណ្ណវាលុកសន្ថតា(១)
នានាបទុមសញ្ឆន្នា បុណ្ឌរីកសមោតតា
សុរភី សម្បវាយន្តិ មនុញ្ញមាលុតេរិតា(២)
ជម្ពុយោ បនសា តាលា នាឡិកេរ វនានិ ច
អន្តោ និវេសនេ ជាតា នានារុក្ខា អរោបិតា(៣)
នានាតុរិយសង្ឃុដ្ឋំ អច្ឆរាគណឃោសិតំ
យោបិ មំ សុបិនេ បស្សេ សោបិ វិត្តោ សិយា នរោ
ឯតាទិសំ អព្ភុតទស្សនេយ្យំ វិមានំ សព្វសោ បភំ
មម កម្មេហិ និព្វត្តំ អលំ បុញ្ញានិ កាតវេ ។

---

១ ឱ. សោណ្ណវាលុកសន្ថតា ។ ២ ម. មនុញ្ញវាលុតេរិតា ។ ៣ ឱ.ម. អរោបិមា ។

ព្រោះឃើញនូវផ្ទះគឺវិហារ ជាទីស្រឡាញ់នេះ ទើបវិមានដែលខ្ញុំបានហើយ ដោយអនុមោទនា ដ៏បរិសុទ្ធនោះឯង ជាវត្ថុអស្ចារ្យ គួររមិលមើល កំពស់ទៅក្នុងអាកាស អស់ ១៦ យោជន៍ជុំវិញ ដោយបុញ្ញរិទ្ធិនៃខ្ញុំ ផ្ទះកំពូល ជាលំនៅរបស់ខ្ញុំ ដូចជាចែកដោយចំណែកស្មើគ្នា រុងរឿងក្លៃទៅ អស់ ១០០ យោជន៍ជុំវិញ ឯស្រះបោក្ខរណីទាំងឡាយរបស់ខ្ញុំ ក្នុងទីនេះ ដែលពួកត្រីទិព្វនៅអាស្រ័យហើយ មានទឹកថ្លាក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ត្រួតដោយឈូក-សទាំងឡាយ មានក្លិនក្រអូប ជាទីគាប់ចិត្ត ដែលខ្យល់បក់ផ្សាយទៅ ដើមព្រីង ខ្នុរ ត្នោត ដូង ព្រៃទឹងឈើផ្សេងៗ ទាំងឡាយដុះជិតលំនៅខាងក្នុង មិនបាច់ដាំឡើយ (វិមាននោះ) សឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឹកកងដោយពួកស្រីអប្សរ ទោះជនណាឃើញខ្ញុំក្នុងការយល់សប្តិ ជននោះឯង គង់ត្រេកអរ វិមានបែបនេះ ជាទីអស្ចារ្យ គួររមិលមើល ភ្លឺព្រោងព្រាត ដោយសព្វគ្រប់ កើតឡើងដោយបុញ្ញកម្មទាំងឡាយរបស់ខ្ញុំ បុគ្គលគួរធ្វើនូវបុណ្យទាំងឡាយ ។

វិមានវត្ថុស្មឹ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស ឆដ្ឋំ វិហារវិមានំ

តាយេវ តេ សុទ្ធនុមោទនាយ
លទ្ធំ វិមានព្ភុតទស្សនេយ្យំ
យា ចេវ សា ទានមទាសិ នារី
តស្សា គតឹ ព្រូហិ កុហឹ ឧប្បន្នា សាតិ ។
យា សា អហុ មយ្ហ សខី ភទន្តេ
សង្ឃស្ស ការេសិ មហាវិហារំ
វិញ្ញាតធម្មា សា អទាសិ ទានំ
ឧប្បន្នា និម្មានរតីសុ ទេវេសុ[១]
បជាបតី តស្ស សុនិម្មិតស្ស
អចិន្តិយា កម្មវិបាក តស្សា[២]
យមេតំ បុច្ឆសិ កុហឹ ឧប្បន្នា សាតិ ។
តន្តេ វិយាកាសឹ អនញ្ញថា អហំ
តេន ហញ្ញេបិ[៣] សមាទបេថ
សង្ឃស្ស ទានានិ ទទាថ វិត្តា
ធម្មញ្ច សុណាថ បសន្នមានសា
សុទុល្លភោ លទ្ធោ មនុស្សលាភោ
យំ មគ្គំ មគ្គាធិបតី អទេសយិ
ព្រហ្មសរោ កញ្ចនសន្និភត្តចោ

---

១ ឱ. ទេវេ ។ ២ ម. តស្ស ។ ៣ ឱ. ហិ អញ្ញេបិ ។

## វិមានវត្ថុ មញ្ជិដ្ឋកវគ្គ ទី ៤ វិហារវិមាន ទី ៦

(ព្រះអនុរុទ្ធត្ថេរសួរថា) វិមានដែលនាងបានហើយ ដោយអនុមោទនា ដ៏បរិសុទ្ធនោះឯង ជាទីអស្ចារ្យ គួររមិលមើល ម្យ៉ាងទៀត នារីណា បានឲ្យនូវទាន នាងចូរប្រាប់នូវគតិ របស់នារីនោះ តើទៅកើតក្នុងទីណា ។

(ទេវតាឆ្លើយថា) បពិត្រលោកដ៏ចំរើន ស្រីសំឡាញ់របស់ខ្ញុំណាបានឲ្យជាងធ្វើមហាវិហារដើម្បីសង្ឃ ស្រីសំឡាញ់នោះ (គឺនាងវិសាខា) ជាស្ត្រីមានធម៌ ដឹងច្បាស់ បានឲ្យទានហើយ បានទៅកើតក្នុងទេវលោក ជាទន្និម្មានរតី បានជាបជាបតីនៃទេវបុត្រឈ្មោះសុនិម្មិត លោកម្ចាស់សួរកេ នូវនារីណាថា នារីនោះទៅកើតក្នុងទីណា ផលនៃកម្មរបស់នារីនោះ មិនគប្បីគិតឡើយ ។ បពិត្រលោកដ៏ចំរើន ខ្ញុំបានដោះស្រាយតាមសេចក្តីពិត មិនប្រែប្រួល ព្រោះហេតុនោះ លោកម្ចាស់ចូរបបួលពួកជនដទៃថា អ្នកទាំងឡាយ ចូរគេកអរឲ្យទានចំពោះសង្ឃផង អ្នកទាំងឡាយចូរមានចិត្តជ្រះថ្លា ស្តាប់ធម៌ផង ការបានអត្តភាពជាមនុស្ស ដែលគេកម្របានដោយលំបាក អ្នកទាំងឡាយ ក៏បានហើយ ព្រះពុទ្ធ មានសំឡេងដូចព្រហ្ម មានព្រះចម្មាដូចមាស ជាអធិបតីក្នុងផ្លូវ បានសំដែងនូវទានជាផ្លូវណា

សង្ឃស្ស ទានានិ ទទាថ វិត្តា
មហប្ផលា យត្ថ ភវន្តិ ទក្ខិណា
យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា
ចត្តារិ ឯតានិ(១) យុគានិ ហោន្តិ
តេ ទក្ខិណេយ្យា សុគតស្ស សាវកា
ឯតេសុ ទិន្នានិ មហប្ផលានិ
ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ
យជមានានំ មនុស្សានំ បុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ សង្ឃេ ទិន្នំ មហប្ផលំ
ឯសោ ហិ សង្ឃោ វិបុលោ មហគ្គតោ(២)
ឯសប្បមេយ្យោ ឧទធីវ សាគរោ
ឯតេហិ សេដ្ឋា នរីយសាវកា(៣)
បភង្ករា ធម្មមុទីរយន្តិ
តេសំ សុទិន្នំ សុហុតំ សុយិដ្ឋំ
យេ សង្ឃមុទ្ទិស្ស ទទន្តិ ទានំ

---

១ ឱ. យេតានិ ។ ២ ឱ. ម. មហគ្គតោ ។ ៣ ឱ. ម. នរវីរសាវកា ។

ទក្ខិណាទាន(ដែលបុគ្គលឲ្យហើយ)ចំពោះសង្ឃណា ជាទានមានផលច្រើន អ្នកទាំងឡាយ ចូរត្រេកអរឲ្យទានទាំងឡាយ(នោះ)ចំពោះសង្ឃ (នោះ)ចុះ បុគ្គលទាំងឡាយណា ៨ ពួក ដែលសប្បុរសទាំងឡាយ សរសើរហើយ បើរាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវ័កនៃព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយ ដែលបុគ្គលឲ្យហើយចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយនុ៎ះ ជាទានមានផលច្រើន បុគ្គល ៤ ពួក តាំងនៅក្នុងមគ្គ បុគ្គល ៤ ពួកតាំងនៅក្នុងផល នេះឈ្មោះថាព្រះសង្ឃ លោកប្រតិបត្តិត្រង់ ប្រកបដោយបញ្ញានឹងសីល បុណ្យឲ្យផល ក្នុងបច្ចុប្បន្ន ដែលពួកសត្វជាមនុស្សប្រាថ្នានូវបុណ្យ កាលបូជាកាលធ្វើ បានឲ្យហើយចំពោះសង្ឃ ជាទានមានផលច្រើន ព្រោះថា ព្រះសង្ឃនុ៎ះ ជាព្រះសង្ឃមានគុណ ធំទូលាយ ព្រះសង្ឃនុ៎ះ ដូចជាសាគរ ដែលទ្រទ្រង់នូវទឹក មានជម្រៅរាប់មិនបាន ពួកសាវ័កអ្នកមានសេចក្តីព្យាយាម ប្រសើរជាងនរៈទាំងនេះ ជាអ្នកប្រសើរមែនពិត ជាអ្នកធ្វើនូវពន្លឺ គឺញាណ សំដែងនូវធម៌ ពួកសត្វណា បានឲ្យទាន ទុកឧទ្ទិសចំពោះព្រះសង្ឃ (ទាននោះ) ឈ្មោះថា ពួកសត្វទាំងនោះបានឲ្យល្អហើយ បូជាតូច ល្អហើយ បូជាធំ ល្អហើយ

សា ទក្ខិណា សង្ឃគតា បតិដ្ឋិតា
មហប្ផលា លោកវិទូហិ វណ្ណិតា
ឯតាទិសំ បុញ្ញមនុស្សរន្តា (១)
យេ វេទជាតា វិចរន្តិ លោកេ
វិនេយ្យ មច្ឆេរមលំ សមូលំ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

វិហារវិមានំ ឆដ្ឋំ ។

ភាណវារំ ទុតិយំ ។

## សត្តមំ ចតុរិត្ថិវិមានំ

(៤៨) អភិក្កន្តេន វណ្ណេន ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
ឥន្ទីវរានំ ហត្ថកំ អហមទាសឹ
ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស
ឯសិកានំ ឧណ្ណតស្មឹ នគរេ (២)
វរេ បណ្ណកតេ (៣) រម្មេ

---

១ ម. សញ្ញមនុស្សរន្តា ។ ២ ម. នគរ ។ ៣ ឱ. បេណ្ណកតេ ។

សង្ឃគតាទក្ខិណាទាននោះ ដែលបុគ្គលដំកល់ទុកល្អហើយ ជាទានមានផលច្រើន ដែលព្រះពុទ្ធទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ត្រាស់សរសើរហើយថា ជនទាំងឡាយណា កាលរឭកឃើញនូវបុណ្យ ប្រាកដដូច្នោះ រមែងកើតសេចក្ដីត្រេកអរ ត្រាច់រង្គាត់ទៅ ក្នុងលោក ជនទាំងនោះកំចាត់បង់ នូវមន្ទិល គឺសេចក្ដីកំណាញ់ ព្រមទាំងឫសជាអ្នកមិនមានគេតិះដៀលបាន រមែងទៅកាន់ឋានសួគ៌ ។

ចប់ វិហារវិមាន ទី ៦ ។

ចប់ ភាណវារៈទី ២ ។

## ចតុរិត្ថីវិមាន ទី ៧

(៤៨) (ព្រះមោគ្គល្លានសួរថា) មានសម្បុរដ៏រុងរឿង ។ បេ ។
ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេននូវផ្កាកជព្រឹក្សមួយបាច់ ដល់ភិក្ខុកាលនិមន្តទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានដែនដីខ្ពស់ ឈ្មោះបណ្ណកតៈ ជាគ្រឿងគួរត្រេកអរ នៃពួកជនអ្នកនៅក្នុងដែនឯសិកៈ

តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។
អភិក្កន្តេន វណ្ណេន ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
នីលុប្បលហត្ថកំ អហមទាសឹ
ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស
ឯសិកានំ ឧណ្ណតស្មិំ នគរេ
វរេ បណ្ណកតេ[១] រម្មេ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។
អភិក្កន្តេន វណ្ណេន ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
ឱទាតមូលកំ ហរិតបត្តំ
ឧទកស្មិំ សរេ ជាតំ អហមទាសឹ

ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

(ព្រះមោគ្គល្លានសួរថា) មានសម្បុរដ៏រុងរឿង ។ បេ ។
ទាំងសម្បុរបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេន នូវផ្កាឧប្បលខៀវមួយបាច់ ដល់ភិក្ខុ កាលនិមន្តទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកតៈ ជាក្រុងគួរត្រេកអរ នៃពួកជនអ្នកនៅក្នុងដែនឯសិកៈ

ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

(ព្រះមោគ្គល្លានសួរថា) មានសម្បុរដ៏រុងរឿង ។ បេ ។
ទាំងសម្បុរបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេន នូវផ្កាឈូកមួយបាច់ ដែលមាន
ក្រអូប មានស្លឹកខៀវ ដុះក្នុងស្រះ មានទឹក

វិមានវត្ថុស្មឹ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស សត្តមំ ចតុរិត្ថិវិមានំ

ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស
ឯសិកានំ ឧណ្ណតស្មឹ នគរេ
វរេ បណ្ណកតេ រម្មេ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។
អភិក្កន្តេន វណ្ណេន ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
អហំ សុមនា សុមនស្ស សុមនមកុលានិ
ទន្តវណ្ណានិ អហមទាសឹ
ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស
ឯសិកានំ ឧណ្ណតស្មឹ នគរេ
វរេ បណ្ណកតេ រម្មេ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ចតុរិត្ថិវិមានំ សត្តមំ ។

វិមានវត្ថុ មញ្ជិដ្ឋកវគ្គ ទី ៤ ចតុរិត្ថីវិមាន ទី ៧

ដល់ភិក្ខុ កាលនិមន្តទៅបិណ្ឌបាត ក្នុងនគរ
ដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកតៈ
គួរត្រេកអរ នៃពួកជនអ្នកនៅក្នុងដែនឯសិកៈ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

(ព្រះមោគ្គល្លានសួរថា) មានសម្បុរដ៏រុងរឿង ។ បេ ។
ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំឈ្មោះសុមនា បានប្រគេនផ្កាម្លិះក្រពុំ មានពណ៌ប្រាកដ
ស្មើ ដោយក្លុកដំរី ដល់ភិក្ខុអ្នកមានចិត្តល្អ កាលនិមន្ត
ទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះ
បណ្ណកតៈ គួរត្រេកអរ នៃពួកជនអ្នកនៅក្នុងដែនឯសិកៈ
ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ចតុរិត្ថីវិមាន ទី ៧ ។

# អដ្ឋមំ អម្ពវិមានំ

(៤៦) ទិព្វន្តេ អម្ពវនំ រម្មំ បាសាទេត្ថ មហល្លកោ
នានាតុរិយសង្ឃុដ្ឋា[១] អច្ឆរាគណឃោសិតោ
បទីបោ ចេត្ថ ជលតិ និច្ចំ សោវណ្ណយោ មហា
ទុស្សផលេហិ រុក្ខេហិ សមន្តា បរិវារិតោ
កេន តេ អម្ពវនំ រម្មំ បាសាទេត្ថ មហល្លកោ
កេន តេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
វិហារំ សង្ឃស្ស ការេសឹ អម្ពេហិ បរិវារិតំ
បរិយោសិតេ វិហារេ ការេន្តេ និដ្ឋិតេ មហេ
អម្ពេ អច្ឆាទយិត្វាន[២] កត្វា ទុស្សមយេ ផលេ
បទីបំ តត្ថ ជាលេត្វា ភោជយិត្វា គណុត្តមំ
និយ្យាទេសឹ តំ សង្ឃស្ស បសន្នា សកេហិ បាណិហិ

---

១ ឱ. នានាតុរិយសង្ឃុដ្ឋោ ។ ២ ម. អម្ពេហិ ឆាទយិត្វាន ។

## អម្ពវិមាន ទី ៨

(៤៦) (ព្រះមោគ្គល្លានសួរថា) ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ ក្នុងព្រៃស្វាយនុ៎ះ សឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឺកងរំដោយពួកស្រីអប្សរ ទាំងប្រទីបជ្វាលាដ៏ធំ ជាវិការៈនៃមាស មានពួកឈើ ដែលផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ក៏ភ្លឺរុងរឿងក្នុងប្រាសាទនោះជានិច្ច ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ តើសម្រេចដោយបុណ្យដូចម្ដេច សម្បុររបស់នាង ប្រាកដដូច្នោះ តើសម្រេច ដោយបុណ្យដូចម្ដេច ៗ បេ ៗ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ៗ ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ៗ បេ ៗ ផលនៃកម្មនេះថា

ខ្ញុំកាលជាតិមុន កើត ជាមនុស្ស
ក្នុងពួកមនុស្ស នាមនុស្សលោក

បានឲ្យជាងធ្វើវិហារ ឧទ្ទិសចំពោះសង្ឃ មានដើមស្វាយព័ទ្ធជុំវិញ កាលធ្វើវិហាររួចស្រេចហើយ បានធ្វើបុណ្យឆ្លង ខ្ញុំបានដណ្ដាំ ដើមស្វាយទាំងឡាយ ធ្វើផ្លែទាំងឡាយជាវិការៈនៃសំពត់ អុជប្រទីបភ្លឺរុងរឿង ក្នុងព្រៃស្វាយនោះ បានញ៉ាំងព្រះសង្ឃដ៏ឧត្តមជាងគណៈឲ្យឆាន់ ក៏មានចិត្តជ្រះថ្លា បានវេរវិហារនោះចំពោះសង្ឃដោយដៃរបស់ខ្លួន

តេន មេ អម្ពវនំ រម្មំ  បាសាទេត្ថ មហល្លកោ
នានាតុរិយសង្ឃុដ្ឋោ  អច្ឆរាគណឃោសិតោ
បទីបោ ចេត្ថ ជលតិ  និច្ចំ សោវណ្ណយោ មហា
ទុស្សផលេហិ រុក្ខេហិ  សមន្តា បរិវារិតោ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អម្ពវិមានំ អដ្ឋមំ ។

# នវមំ បីតវិមានំ

(៤៧) បីតវត្ថេ បីតធជេ(១)  បីតាលង្ការភូសិតេ
បីតចន្ទនលិត្តង្គេ  បីតុប្បលមធារិនី
បីតប្បាសាទសយនេ  បីតាសនេ បីតភោជនេ(២)
បីតឆត្តេ បីតរថេ  បីតស្សេ បីតវីជនេ(៣)
កឹ កម្មំ អករី ភទ្ទេ  បុព្វេ មានុសកេ ភវេ
ទេវតេ បុច្ឆិតាចិក្ខ  កិស្ស កម្មស្សិទំ ផលំ(ន្តិ)។
កោសាតកី(៤) នាម លតត្ថិ ភន្តេ តិត្តិកា(៥) អនភិជ្ឈិតា

---

១ ឱ. បីតាវត្ថេ បីតាធជេ ។ ២ ម. បីតភាជនេ ។ ៣ ម. បីតពីជនេ ។ ៤ ឱ. កោសាតកិ ។
៥ ម. កត្តិកា ។

ដោយបុញ្ញកម្មនោះ ទើបខ្ញុំមានព្រៃស្វាយ គួរសប្បាយ មានប្រាសាទ ខ្ពស់ធំទូលាយ ក្នុងព្រៃស្វាយនោះ សឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឹកកងដោយពួកស្រីអប្សរ ទាំងប្រទីបផ្កាលាដ៏ធំ ជាវិការៈនៃមាស មានពួកឈើផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ភ្លឺរុងរឿង ក្នុងប្រាសាទនោះជានិច្ច សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ សម្រេចដោយបុណ្យនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ អម្ពវិមាន ទី ៨ ។

## បីតវិមាន ទី ៩

(៤៧) (ទេវរាជសួរថា) ម្នាលនាងដ៏ចំរើន មានសំពត់លឿង មានទង់លឿង ស្អិតស្អាងដោយគ្រឿងប្រដាប់មានពណ៌លឿង មានអវយវៈលាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កាឧប្បលលឿង មានប្រាសាទនឹងទីដេកលឿង មានទីអង្គុយលឿង មានភោជនលឿង មានឆ័ត្រលឿង មានរថលឿង មានសេះលឿង មានផ្លិតលឿង នាងបានធ្វើអំពើដូចម្តេច ក្នុងភពជារបស់មនុស្ស ក្នុងកាលមុន ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវធីតាឆ្លើយថា) បពិត្រព្រះអង្គដ៏ចំរើន វល្លិ៍ឈ្មោះកោសាតកី (វល្លិ៍ននោងព្រៃ) ជាជាតិវល្លិ៍ល្វីង ដែលគេមិនត្រូវការ

តស្សា ចត្តារិ បុប្ផានិ ថូបំ អភិហរឹ អហំ
សត្ថុសរីរំ ឧទ្ទិស្ស វិប្បសន្នេន ចេតសា
នាស្ស មគ្គំ អវេក្ខិស្សំ តទគ្គមនសា សតី(១)
តតោ មំ អវធី គាវី ថូបំ អប្បត្តមានសំ
តញ្ចាហំ អភិសញ្ចេយ្យំ ភិយ្យោ(២) នូន ឥតោ សិយា
តេន កម្មេន ទេវិន្ទ មឃវា ទេវកុញ្ជរ
បហាយ មានុសំ ទេហំ តវ សហព្យតមាគតា(៣) ។
ឥទំ សុត្វា តិទសាធិបតិ មឃវា ទេវកុញ្ជរោ
តាវតឹសេ បសាទេន្តោ មាតលឹ ឯតទព្រវិ
បស្ស មាតលិ អច្ឆេរំ ចិត្តំ កម្មផលំ ឥទំ
អប្បកម្បិ កតំ ទេយ្យំ បុញ្ញំ ហោតិ មហប្ផលំ
នត្ថិ ចិត្តេ បសន្នម្ហិ អប្បកា នាម ទក្ខិណា
តថាគតេ វា សម្ពុទ្ធេ អថ វា តស្ស សាវកេ
ឯហិ មាតលិ អម្ហេបិ ភិយ្យោ ភិយ្យោ មហេម្ហសេ(៤)
តថាគតស្ស ធាតុយោ សុខោ បុញ្ញានមុទ្ទយោ
តិដ្ឋន្តេ និព្វុតេ វាបិ សមេ ចិត្តេ សមំ ផលំ

១ ម. ទតគ្គមនសា សតិ ។ ២ ឱ. ភីយោ ។ ៣ ម. សហព្យមាគតា ។
៤ ឱ. ម. មហេមសេ ។

ខ្ញុំម្ចាស់មានចិត្តជ្រះថ្លា បាននាំយកផ្កាននោងព្រៃនោះ ៤ ទង ទៅបូជាព្រះស្តូប ឧទ្ទិសចំពោះព្រះសរីរធាតុនៃព្រះសាស្តា ខ្ញុំម្ចាស់កំពុងមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះធាតុនៃព្រះមានព្រះភាគនោះ មិនបានក្រឡេកមើលផ្លូវគោនោះ គោនោះមេគោមកដល់ខ្ញុំម្ចាស់ ដែលមានអធ្យាស្រ័យមិនទាន់ដល់ព្រះស្តូប (ស្លាប់ទៅ) បើខ្ញុំម្ចាស់សន្សំបុណ្យនោះសម្រេច ម៉្លេះសមជាមានសម្បត្តិដ៏លើសលុបជាងនេះ បពិត្រព្រះអង្គជាធំជាងទេវតា នាមមឃវៈ ជាទេវកុញ្ជរ ខ្ញុំម្ចាស់បានលះបង់រាងកាយជាមនុស្ស មកកើតជាមួយនឹងព្រះអង្គ ព្រោះកម្មនោះ ។

ព្រះឥន្ទ្រ នាមមឃវៈ ជាទេវកុញ្ជរ ជាធំជាងទេវតាក្នុងជាន់ត្រៃត្រឹង្ស បានស្តាប់ពាក្យនេះហើយ ក៏ញុំាងទេវធីតាឲ្យជ្រះថ្លា ក្នុងភពតាវត្តឹង្ស ហើយ បានពោលពាក្យនេះ នឹងមាតលិទេវបុត្រថា ម្នាលមាតលិ អ្នកចូរមើលសេចក្តីអស្ចារ្យ នេះជាផលនៃកម្មដ៏វិចិត្រ ទេយ្យវត្ថុ សូម្បីបន្តិចបន្តួចដែលគេធ្វើហើយ ជាបុណ្យមានផលច្រើន កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវ័ករបស់ព្រះតថាគតហើយ ទក្ខិណាទានឈ្មោះថាមានផលតិចមិនមែនឡើយ ម្នាលមាតលិ អ្នកចូរមក យើងទាំងឡាយនឹងបូជាព្រះធាតុព្រះតថាគតឲ្យលើសលុបជាងនេះទៅទៀត ការសន្សំនូវបុណ្យទាំងឡាយ រមែងនាំមកនូវសេចក្តីសុខ កាលព្រះតថាគតឋិតនៅក្តី បរិព្វានទៅក្តី បើតាំងចិត្តស្មើ ផលក៏ស្មើ

ចេតោបណិធិហេតូ ហិ សត្តា គច្ឆន្តិ សុគ្គតឹ
ពាហុន្នំ វត អត្ថាយ ឧប្បជ្ជន្តិ តថាគតា
យត្ថ ការំ ករិត្វាន សគ្គំ គច្ឆន្តិ ទាយកាតិ ។

បីតវិមានំ នវមំ ។

## ទសមំ ឧច្ឆុវិមានំ

(៤៨) ឱភាសយិត្វា បឋវឹ សទេវកំ
អតិរោចសិ ចន្ទិមសុរិយា វិយ
សិរិយា ច វណ្ណេន យសេន តេជសា
ព្រហ្មាវ ទេវេ តិទសេ សហិន្ទកេ
បុច្ឆាមិ តំ ឧប្បលមាលធារិនេ
អាវេឡិនេ កញ្ចនសន្និភត្តចេ
អលង្កតេ ឧត្តមវត្ថធារិនេ
កា ត្វំ សុភេ ទេវតេ វន្ទសេ មមំ[១]
ទានំ សុចិណ្ណំ អថ សីលសញ្ញមោ[២]
កេនូបបន្នា សុគតឹ យសស្សិនី
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលំ (ឥតិ) ។

---

១ ឱ. មម ។ ២ ម. សីលសញ្ញមំ ។

ដ្បិតថាសត្វទាំងឡាយ មានការជ្រះថ្លាចិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន ទាយកទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជា ចំពោះព្រះតថាគតទាំងឡាយណា ព្រះតថាគតទាំងនោះ បានកើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ៗ

ចប់ បីតវិមាន ទី ៩ ។

## ឧប្បលវិមានទី ១០

(៤៨) (ព្រះមោគ្គល្លានសួរថា) នាងរុងរឿងក្នុងពួកទេវតា ដោយសិរីផង ដោយសម្បុរផង ដោយយសផង ដោយតេជៈផង ដូចជាព្រះចន្ទ្រ និងព្រះអាទិត្យ ញុំាងផែនដីព្រមទាំងទេវលោកឲ្យភ្លឺរុងរឿង ឬដូចជាព្រហ្មរុងរឿងក្នុងពួកទេវតាក្នុងជាន់ត្រៃត្រិង្ស ព្រមទាំងព្រះឥន្ទ្រ ម្នាលទេវតា អ្នកទ្រទ្រង់កម្រងផ្កាឧប្បល មានក្លួងផ្កាសម្រាប់ប្រដាប់ក្បាល មានសម្បុរស្បែកក៏ដូចមាស តាក់តែងគ្រឿងអលង្ការ ទ្រទ្រង់សំពត់ដ៏ឧត្តម អាត្មាសូមសួរនាង ម្នាលទេវតា ល្អស្រស់នាងជាអ្វី មកថ្វាយបង្គំអាត្មា នាងបានសន្សំទានល្អហើយ ឬក៏នាងបានសង្រួម ក្នុងសីល បានមកកើត ក្នុងសុគតិជាស្ត្រីមានយស តើដោយហេតុដូចម្តេច ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

ឥធទ្ទេ ភទ្ទេ ឥធមេវ[១] តាមិំ
បិណ្ឌាយ អម្ហាក យំ ឧបាគមី
តតោ តេ ឧច្ឆុស្ស អទាសិ ខណ្ឌិកំ
បសន្នចិត្តា អតុលាយ បីតិយា
សស្សុ ច បន អនុយុញ្ជតេ មមំ
កហំ នុ ឧច្ឆុំ[២] វធុ តេ អវាករិ
ន ឆឌ្ឌិតំ ន បន ខាទិតំ មយា
សន្តស្ស ភិក្ខុស្ស សយំ អទាសិហំ
តុយ្ហញ្ចិទំ ឥស្សរិយំ អថោ មម
ឥតិស្ស សស្សុ បរិភាសតេ មមំ
លេឌ្ឌុំ គហេត្វា បហារំ អទាសិ មេ
តតោ ចុតា កាលកតម្ហិ ទេវតា
តទេវ កម្មំ កុសលំ កតំ មយា
សុខញ្ច កម្មំ អនុភោមិ អត្តនា
ទេវេហិ សទ្ធិំ បរិចារយាមហំ
មោទាមហំ កាមគុណេហិ បញ្ចហិ
តទេវ កម្មំ កុសលំ កតំ មយា
សុខញ្ច កម្មំ អនុភោមិ អត្តនា

---

១ ម. ឥធ តេ ភទ្ទេ ឥធមេវ ។ ២ ឱ. ឧច្ឆុ ។

(ទេវតាឆ្លើយថា) បពិត្រព្រះថេរៈដ៏ចំរើន រឿងនេះ លោកម្ចាស់ (ជ្រាបស្រាប់ហើយ) លោកម្ចាស់បានចូលទៅកាន់ផ្ទះរបស់ខ្ញុំ ដើម្បីបិណ្ឌបាត ក្នុងស្រុកឯណោះ គ្រានោះ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅ ១ កំណាត់ដល់លោកម្ចាស់ ដោយបីតិថ្លឹងមិនបាន លុះកាលខាងក្រោយមក ម្ដាយក្មេក បានសួរដេញដោលខ្ញុំថា ម្នាលមេ នាងបំផ្លាញអំពៅទៅណា (ខ្ញុំឆ្លើយថា) ខ្ញុំមិនបានបោលទេ មិនបានស៊ីទេ ខ្ញុំបានប្រគេនដល់ភិក្ខុ អ្នកមានចិត្តស្ងប់ ដោយខ្លួនឯង ម្ដាយក្មេក ក៏ប្រទេចផ្ដាសាខ្ញុំថា ហងឯង ឬអញ ជាធំក្នុងផ្ទះនេះ ហើយក៏យកដុំដីប្រហារខ្ញុំ ខ្ញុំធ្វើមរណកាល ច្យុតចាកមនុស្សលោកនោះបានមកកើតជាទេវតា កុសលកម្មនោះឯង ដែលខ្ញុំបានធ្វើហើយ ខ្ញុំក៏បានទទួលផលនៃកម្មជាសុខ ដោយខ្លួនឯង បានញុំាងស្ត្រីឲ្យបម្រើ ជាមួយនឹងទេវតាទាំងឡាយ ខ្ញុំរមែងរីករាយដោយកាមគុណទាំង ៥ កុសលកម្មនោះឯង ដែលខ្ញុំបានធ្វើហើយ ខ្ញុំក៏បានទទួលផលនៃកម្មជាសុខ ដោយខ្លួនឯង

ទេវិន្ទគុត្តា តិទសេហិ រក្ខិតា
សមប្បិតា កាមគុណេហិ បញ្ចហិ
ឯតាទិសំ បុញ្ញផលំ អនប្បកំ
មហាវិបាកា មម ឧច្ឆុទក្ខិណា
ទេវេហិ សទ្ធឹ បរិចារិយាមហំ
មោទាមហំ កាមគុណេហិ បញ្ចហិ
ឯតាទិសំ បុញ្ញផលំ អនប្បកំ
មហាជុតិកា មម ឧច្ឆុទក្ខិណា
ទេវិន្ទគុត្តា តិទសេហិ រក្ខិតា
សហស្សនេត្តោរិវ នន្ទនេ វនេ
តុវញ្ច ភទ្ទេ អនុកម្បកំ វិទុ
ឧបេច្ច វន្ទី កុសលញ្ច បុច្ឆិ មំ[១]
តតោ តេ ឧច្ឆុស្ស អទាសិ ខណ្ឌិកំ
បសន្នចិត្តា អតុលាយ បីតិយាតិ ។

ឧច្ឆុវិមានំ ទសមំ ។

## ឯកាទសមំ វន្ទនវិមានំ

(៤៩) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា

១ ម. បុច្ឆិស្សំ ។

ព្រះឥន្ទ្រជាធំជាងទេវតាបានគ្រប់គ្រងហើយ ពួកទេវតាជាន់ត្រៃត្រិង្ស ក៏បានរក្សាហើយដែរ ស្កប់ស្កល់ដោយកាមគុណ ៥ ផលបុណ្យប្រាកដដូច្នេះ មិនមែនតិចតួចឡើយ ទក្ខិណាទាន (ការឲ្យអំពៅ) របស់ខ្ញុំ ជាទានមានផលច្រើន ខ្ញុំបានញ៉ាំងស្រ្តីឲ្យបម្រើ ជាមួយនឹងទេវតាទាំងឡាយ ខ្ញុំរមែងរីករាយ ដោយកាមគុណ ៥ ផលបុណ្យប្រាកដដូច្នេះ មិនមែនតិចតួចឡើយ ទក្ខិណាទាន របស់ខ្ញុំ មានតេជះច្រើន ព្រះឥន្ទ្រជាធំជាងទេវតា បានគ្រប់គ្រងហើយ ពួកទេវតាជាន់ត្រៃត្រិង្ស ក៏បានរក្សាហើយដែរ ដូចជាព្រះសហស្សនេត្រក្នុងព្រៃនន្ទនវ័ន បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំបានទៅថ្វាយបង្គំលោកម្ចាស់ ជាអ្នកបេះដឹង ជាអ្នកអនុគ្រោះ លោកម្ចាស់បានសួរនូវកុសលចំពោះខ្ញុំ លំដាប់នោះខ្ញុំ មានចិត្តជ្រះថ្លា បានប្រគេនអំពៅមួយកំណាត់ ដល់លោកម្ចាស់ដោយបីតិថ្លឹងមិនបាន ។

ចប់ ឧច្ឆុវិមាន ទី ១០ ។

## វន្ទនវិមាន ទី ១១

(៤៩) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញ៉ាំងទិសទាំងពួង ឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក

តេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា ទេវតា អត្តមនា មោគ្គល្លានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
អហំ មនុស្សេសុ មនុស្សភូតា
ទិស្វាន សមណេ សីលវន្តេ
បាទានិ វន្ទិត្វា មនំ បសាទយឹ
វិត្តា ចហំ អញ្ជលិកំ អកាសឹ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

វន្ទនវិមានំ ឯកាទសមំ ។

## ទ្វាទសមំ រជ្ជុមាលាវិមានំ

(៨០) អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ហត្ថេ បាទេ ច វិគ្គយ្ហ នច្ចសិ សុប្បវាទិតេ
តស្សា តេ នច្ចមាណាយ(១) អង្គមង្គេហិ សព្វសោ
ទិព្វា សទ្ទា និច្ឆរន្តិ សវនីយា មនោរមា
តស្សា តេ នច្ចមាណាយ អង្គមង្គេហិ សព្វសោ
ទិព្វា គន្ធា បវាយន្តិ សុចិគន្ធា មនោរមា

---

១ ឱ. នច្ចមានាយ ។

សម្បុរបស់នាងប្រាកដដូច្នោះ តើសម្រេចដោយបុណ្យដូចម្តេច ។ បេ ។ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញពួកសមណៈ អ្នកមានសីល ក៏ថ្វាយបង្គំបាទា ហើយញុំាងចិត្តឲ្យជ្រះថ្លា ត្រេកអរ បានធ្វើអញ្ជលិកម្ម (ចំពោះសមណៈទាំងនោះ) ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ វន្ទនវិមាន ទី ១១ ។

## រជ្ជុមាលាវិមាន ទី ១២

(៤០) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង (កាលបើត្បូងត្រូវ) ដែលគេប្រគំល្អហើយ នាងរាំ ដៃរាំ ជើងរាំ កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួរគាប់ចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយ ដ៏ក្រអូប គួរគាប់ចិត្ត រមែងផ្សាយចេញ អំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់

វិមានវត្ថុស្មឹ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស ទ្វាទសមំ រជ្ជុមាលាវិមានំ

វិត្តមានា កាយេន យា វេណីសុ បិឡន្ធនា
តេសំ សុយ្យតិ និគ្ឃោសោ តុរិយេ បញ្ចង្គិកេ យថា
វដំសកា វាតធូតា វាតេន សម្បកម្បិតា
តេសំ សុយ្យតិ និគ្ឃោសោ តុរិយេ បញ្ចង្គិកេ យថា
យាបិ តេ សិរសិ មាលា សុចិគន្ធា មនោរមា
វាតិ គន្ធោ ទិសា សព្វា រុក្ខោ មញ្ជូសកោ យថា
ឃាយសេ តំ សុចិគន្ធំ រូបំ បស្សសិ អមានុសំ
ទេវតេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលំ(ន្តិ)។
ទាសី អហំ បុរេ អាសឹ គយាយំ ព្រាហ្មណស្សហំ
អប្បបុញ្ញា អលក្ខិកា រជ្ជុមាលាតិ មំ វិទូ
អក្កោសានំ វធានញ្ច តជ្ជនាយ(១) ច ឧក្កតា
កុដំ គហេត្វា និក្ខម្ម អាគច្ឆឹ ឧទកហារិយា
វិបថេ កុដំ និក្ខិបិត្វា វនសណ្ឌំ ឧបាគមឹ
ឥធេវាហំ មរិស្សាមិ កឹវត្ថោបិ ជីវិតេន មេ
ទឡ្ហបាសំ ករិត្វាន អាលម្ពិត្វាន បាទបេ
តតោ ទិសា វិលោកេសឹ កោ នុ ខោ វនមស្សិតោ

---

១ ឱ. តជ្ជនយា ។

កាលនាងអាកកាយ ស្លឹកកងនៃគ្រឿងប្រដាប់ទាំងឡាយ ឮដំ ក្នុងសក់នោះ ឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ស្លឹកកង នៃគ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះ កម្រើកដោយខ្យល់ នោះ ឮដូចជាតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ កម្រងផ្កាណា ឮដំសិរ្សៈរបស់នាង មានក្លិនក្រអូបឈ្ងុយឈ្ងប់ ជាទីរីករាយចិត្ត ក្លិនកម្រងផ្កានោះ រមែងផ្សាយទៅ សព្វទិស ដូចឈើឪឡោក នាងតែងធុំក្លិនក្រអូបនុ៎ះ តែងឃើញរូប ដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) ក្នុងកាលពីដើម ខ្ញុំជាទាសីនៃព្រាហ្មណ៍ ក្នុងស្រុកឈ្មោះគយា ជាស្ត្រីមានបុណ្យតិច មិនមានសិរី ពួកជន ស្គាល់ខ្ញុំថា ជាស្ត្រីឈ្មោះរជ្ជុមាលា ខ្ញុំធុញទ្រាន់ ដោយការ គម្រាមរបស់ពួកជនអ្នកជេរ វាយ ហើយក៏កាន់ក្អម ដើរចេញ ទៅដងទឹក ត្រឡប់មកវិញ ដាក់ក្អមទៅក្រៅផ្លូវ ដើរចូលទៅ កាន់ដងព្រៃ ដោយគិតថា អញនឹងស្លាប់ ក្នុងទីនេះតែម្តងទៅចុះ ប្រយោជន៍អ្វី ដោយការរស់នៅរបស់អញ ហើយក៏ធ្វើអន្ទាក់យ៉ាង មាំ ចងសំយុងចុះ ត្រង់ប្រគាបឈើ លំដាប់នោះ ខ្ញុំក៏រមិលមើល នូវទិសទាំងឡាយថា អ្នកណាហ្ន៎ ដែលអាត្មាអញ ត្រូវនមស្ការ

តត្ថទ្ទសាសឹ(១) សម្ពុទ្ធំ សព្វលោកហិតំ មុនឹ

និសិន្នំ រុក្ខមូលស្មឹ ឈាយន្តំ អកុតោភយំ

តស្ស មេ អហុ សំវេគោ អព្ភុតោ លោមហំសនោ

កោ នុ ខោវ ទមស្សិតោ មនុស្សោ ឧទាហុ ទេវតា

បាសាទិកំ បសាទនីយំ វនា(២) និព្វនមាគតំ

ទិស្វា មនោ មេ បសីទិ នាយំ យាទិសកីទិសោ

គុត្តិន្ទ្រិយោ ឈានរតោ អពហិគតមានសោ

ហិតោ សព្វស្ស លោកស្ស ពុទ្ធោ អយំ ភវិស្សតិ

ភយភេរវេ ទុរាសទោ សីហោវ គុហានិស្សិតោ

ទុល្លភាយំ ទស្សនាយ បុប្ផំ ឧទុម្ពរំ យថា

សោ មំ មុទូហិ វាចាហិ អាលបិត្វា តថាគតោ

រដ្ឋុមាលេតិ មំ អវោច សរណំ គច្ឆ តថាគតំ

តាហំ គិរំ សុណិត្វាន នេលំ អត្ថវតឹ សុចឹ

សណ្ហំ មុទុញ្ច វគ្គុញ្ច សព្វសោកាបនូទនំ

---

១ ឱ. ម. តត្ថទ្ទសាមិ ។ ២ ម. វេតា ។

ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គមានប្រយោជន៍ ដល់សត្វលោកទាំងពួង ទ្រង់ជាអ្នកប្រាជ្ញ កំពុងគង់ចំរើនឈាន ទៀបគល់ឈើនោះ ព្រះអង្គមិនមានភ័យ អំពីទីណាមួយ សេចក្តីសង្វេគ សេចក្តីអស្ចារ្យ និងការត្រេកអរ ក៏កើតឡើងដល់ខ្ញុំនោះ (ដោយគិតថា) បុគ្គលណាហ្ន៎ មនុស្ស ឬទេវតា ដែលអាត្មាអញត្រូវនមស្ការ ហើយចិត្តខ្ញុំក៏ជ្រះថ្លា ព្រោះបានឃើញព្រះសម្ពុទ្ធ អ្នកនាំមកនូវសេចក្តីជ្រះថ្លា គួរជាទីជ្រះថ្លា ព្រះអង្គចេញអំពីព្រៃ គឺកិលេស មកកាន់ព្រះនិព្វាន ដែលមិនមានតណ្ហា ព្រះសម្ពុទ្ធនេះ មិនមែនជាបុគ្គលផ្តេសផ្តាសទេ ព្រះអង្គមានឥន្ទ្រិយគ្រប់គ្រងហើយ ត្រេកអរក្នុងឈាន មានចិត្តមិនបានប្រព្រឹត្តទៅក្នុងអារម្មណ៍ខាងក្រៅ ព្រះអង្គជាប្រយោជន៍ដល់សត្វលោកទាំងពួង នេះប្រាកដជាព្រះពុទ្ធ ដូចជាសីហៈដែលគួរខ្លាចដ៏ពន្លឹក មិនគួរហ៊ានចូលទៅកេអាស្រ័យនៅក្នុងគុហា ព្រះពុទ្ធនេះ បុគ្គលកម្របានចួបប្រទះ ដូចជាផ្កាឧទុម្ពរ (ដែលគេឃើញបានដោយក្រ) ព្រះតថាគតនោះ បានហៅខ្ញុំដោយវាចាផ្អែមល្ហែមថា ម្នាលនាងវជ្ជមាលា ហើយទ្រង់ត្រាស់នឹងខ្ញុំថា នាងចូរដល់នូវព្រះតថាគតជាទីពឹងចុះ លុះខ្ញុំបានស្តាប់ព្រះវាចានោះ ជាវាចាឥតទោស ប្រកបដោយប្រយោជន៍ ជាវាចាស្អាតពីរោះ ផ្អែមល្ហែមគួរចង់ស្តាប់ បន្ទោបង់នូវសេចក្តីសោកទាំងពួង (ហើយមានចិត្តជ្រះថ្លា)

## វិមានវត្ថុស្មឹ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស ទ្វាទសមំ រជ្ជុមាលាវិមានំ

កាលុចិត្តញ្ច មំ ញត្វា   បសន្នំ សុទ្ធមានសំ
ហិតោ សព្វស្ស លោកស្ស   អនុសាសិ តថាគតោ
ឥទំ ទុក្ខន្តិ មំ អវេច   អយំ ទុក្ខស្ស សម្ភវេ
អយំ ទុក្ខនិរោធោ ច   អញ្ជសោ អមតោគធោ
អនុកម្បកស្ស កុសលស្ស   ឱវាទម្ហិ អហំ ឋិតា
អជ្ឈគា អមតំ សន្តឹ   និព្វានំ បទមច្ចុតំ
សាហំ អវដ្ឋិតា បេមា   ធម្មេ អវិកម្បិនី
មូលជាតាយ សទ្ធាយ   ធីតា ពុទ្ធស្ស ឱរសា
សាហំ រមាមិ កីឡាមិ   មោទាមិ អកុតោភយា
ទិព្វមាលំ ធារយាមិ   បិវាមិ មធុមទ្ទវំ[១]
សដ្ឋិតុរិយសហស្សានិ   បដិពោធំ ករោន្តិ មេ
អាឡម្ពោ គគ្គរោ ភីមោ[២]   សាធុវាទី ច សំសយោ
ពោក្ខរោ ច សុផស្សោ ច   វីណា[៣] មោក្ខា ច នារិយោ
នន្ទា ចេវ សុនន្ទា ច   សោណទិន្នា សុចិម្ហិតា
អលម្ពុសា មិស្សកេសី ច   បុណ្ឌរីកាតិទារុណី
ឯណីបស្សា សុបស្សា ច   សុភទ្ទា មុទុកាវទី[៤]
ឯតា ចញ្ញា ច សេយ្យាសេ   អច្ឆរានំ បពោធិយោ

---

១ ម. មធុមទ្ទុវំ ។ ២ ម. ភគ្គរោ ភិម្មោ ។ ៣ ម. វិណា ។ ៤ ម. សំភទ្ទា មុទុតាបរិ ។

ព្រះតថាគតបានជ្រាបច្បាស់នូវខ្ញុំ ថាជាស្រីមានចិត្តគួរដល់ការនាកម្ម កំពុងជ្រះថ្លា មានចិត្តបរិសុទ្ធ ព្រះអង្គជាប្រយោជន៍ ដល់សត្វលោកទាំងពួង ទ្រង់ប្រៀនប្រដៅ (សត្វលោកទាំងពួង) បានទ្រង់ត្រាស់ទឹងខ្ញុំថា នេះជាទុក្ខ នេះជាដែនកើតនៃទុក្ខ នេះជាហេតុរលត់ទុក្ខ នេះជាផ្លូវទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ខ្ញុំជាស្ត្រីឋិតនៅ ក្នុងឱវាទ នៃព្រះតថាគត ព្រះអង្គជាបុគ្គលឈ្លាសវៃ ជាអ្នកអនុគ្រោះ ហើយបានដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ជាទីស្ងប់រម្ងាប់ ជាបទមិនឃៀនឃាត ខ្ញុំនោះ ជាស្ត្រីមានសេចក្តីស្រឡាញ់ ខ្ជាប់ខ្ជួនមិនញាប់ញ័រ ក្នុងទស្សនញ្ញាណ ដោយសទ្ធាជាមូល ជាធីតាកើតអំពីឧរា នៃព្រះពុទ្ធជាម្ចាស់ ខ្ញុំនោះ រមែងត្រេកអរ រីករាយមិនមានភ័យ ពីហេតុអ្វីមួយឡើយ ទ្រទ្រង់នូវកម្រងផ្កាទិព្វ ផឹកនូវទឹកឃ្មុំដ៏ផ្អែម តូរ្យតន្ត្រីទាំង ៦ ម៉ឺន រមែងធ្វើនូវការភ្ញាក់រលឹក ដល់ខ្ញុំ ទេវបុត្រឈ្មោះ អាឡម្ពៈ ១ គគ្គរៈ ១ ភីមៈ ១ សាធុវាទី ១ សំសយៈ ១ បោក្ខរៈ ១ សុផស្សៈ ១ នារីទាំងឡាយ គឺនារីឈ្មោះវិណា ១ មោក្ខា ១ នន្ទា ១ សុនន្ទា ១ សោណទិន្នា ១ សុចិម្ហិតា ១ អលម្ពុសា ១ មិស្សកេសី ១ បុណ្ឌរីកាតិទារុណី ១ ឯណិបស្សា ១ សុបស្សា ១ សុភទ្ទា ១ មុទុកាវទី ១ ទេវតាទាំងនេះផង ដទៃផង ប្រសើរជាងស្រីអប្សរទាំងឡាយ ជាអ្នកធ្វើ ឲ្យភ្ញាក់រលឹក

តា មំ កាលេនុបាគន្ត្វា អភិភាសន្តិ ទេវតា

ហន្ទ នច្ចាម គាយាម ហន្ទ តំ រមយាមសេ

នយិទំ អកតបុញ្ញានំ កតបុញ្ញានមេវិទំ

អសោកំ នន្ទនំ រម្មំ តិទសានំ មហាវនំ

សុខំ អកតបុញ្ញានំ ឥធ នត្ថិ បរត្ថ ច

សុខញ្ច កតបុញ្ញានំ ឥធ ចេវ បរត្ថ ច

តេសំ សហព្យកាមានំ កាតព្វំ កុសលំ ពហុំ

កតបុញ្ញា ហិ មោទន្តិ សគ្គេ ភោគសមង្គិនោ

ពហូនំ វត អត្ថាយ ឧប្បជ្ជន្តិ តថាគតា

ទក្ខិណេយ្យា មនុស្សានំ បុញ្ញក្ខេត្តានមាករា

យត្ថ ការំ ករិត្វាន សគ្គេ មោទន្តិ ទាយកាតិ ។

វដ្ដមាលាវិមានំ ទុតិយំ ។

ពួកទេវតាទាំងនោះ ចូលទៅរកខ្ញុំ តាមកាលគួរ ហើយពោលថា ហាំយើងទាំងឡាយ នឹងកំប្រៀង ហាំយើងទាំងឡាយ នឹងត្រេកអរ ចំពោះមហាវិមាននោះ មហាវិមាននេះ មិនមែនជាទីរបស់បុគ្គលទាំងឡាយ អ្នកមិនបានធ្វើបុណ្យទេ មហាវិមាននេះ ជាទីរបស់បុគ្គលទាំងឡាយ អ្នកធ្វើបុណ្យប៉ុណ្ណោះ មហាវិមាននេះ ជាព្រៃគ្មានសេចក្តីសោក ជាព្រៃគួររីករាយ គួរត្រេកអរ នៃទេវតាទាំងឡាយ ជាន់តាវត្តឹង្ស សេចក្តីសុខ រមែងមិនមានដល់បុគ្គលទាំងឡាយ ដែលមិនបានធ្វើបុណ្យ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង សេចក្តីសុខរមែងមាន ដល់បុគ្គលទាំងឡាយ អ្នកបានធ្វើបុណ្យ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ពួកជនអ្នកប្រាថ្នាទៅកើត ជាទេវតានោះ គួរធ្វើកុសលឲ្យច្រើន ព្រោះថា ជនទាំងឡាយអ្នកបានធ្វើបុណ្យ ជាអ្នកបរិបូណ៌ ដោយភោគៈ រមែងរីករាយក្នុងឋានសួគ៌ ពួកទាយកធ្វើការបូជា ចំពោះព្រះតថាគតទាំងឡាយណា ហើយរីករាយ ក្នុងឋានសួគ៌ ព្រះតថាគតទាំងនោះ ជាទក្ខិណេយ្យបុគ្គល ជាមណ្ឌលជាទីកើតនៃព្រះអរិយបុគ្គល ដែលជាបុញ្ញក្ខេត្ត របស់មនុស្សទាំងឡាយ រមែងកើតឡើង ដើម្បីប្រយោជន៍ ដល់ជនមានប្រមាណច្រើន ។

ចប់ រជ្ជុមាលាវិមាន ទី ១២ ។

វិមានវត្ថុស្មឹ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស ឧទ្ទានំ

## ឧទ្ទានំ

មញ្ជិដ្ឋា បភស្សរា នាគា
អលោមា កញ្ជិកទាយិកា
វិហារចតុរិត្ថម្ពា បីតា
ឧច្ឆុវន្ទនរជ្ជុមាលា ច
វគ្គោ តេន បវុច្ចតីតិ ។

ឥត្ថីវិមានេ វគ្គោ ចតុត្ថោ ។

---

# ឧទ្ទាន

និយាយអំពីមញ្ជិដ្ឋវិមាន ១ បភស្សរវិមាន ១ នាគវិមាន ១ អលោមវិមាន ១ កញ្ជិកទាយិកាវិមាន ១ វិហារវិមាន ១ ចតុរិត្ថិវិមាន ១ អម្ពវិមាន ១ បីតវិមាន ១ ឧច្ឆុវិមាន ១ វន្ទនវិមាន ១ រជ្ជុមាលាវិមាន ១ ហេតុនោះបានជា ហៅថា វគ្គ ។

ចប់ វគ្គ ទី ៤ ក្នុងឥត្ថីវិមាន ។

---

# បញ្ចមោ មហារថវគ្គោ

## បឋមំ មណ្ឌូកទេវបុត្តវិមានំ

(៥១) កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ

អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា ។

មណ្ឌូកោហំ បុរេ អាសឹ ឧទកេ វារិគោចរោ

តវ ធម្មំ សុណន្តស្ស អវធិ វច្ឆបាលកោ

មុហុត្តំ ចិត្តបសាទស្ស ឥទ្ធឹ បស្ស យសញ្ច មេ

អានុភាវញ្ច មេ បស្ស វណ្ណំ បស្ស ជុតិញ្ច មេ

យេ ច តេ ទីឃមទ្ធានំ ធម្មំ អស្សោសុំ គោតម

បត្តា តេ អចលដ្ឋានំ យត្ថ គន្ត្វា ន សោចរេ ។

មណ្ឌូកទេវបុត្តវិមានំ បឋមំ ។

# មហារថវគ្គ ទី ៥

## មណ្ឌូកទេវបុត្តវិមាន ទី ១

(៤១) (ព្រះមានព្រះភាគត្រាស់សួរថា) អ្នកណាហ្ន៎ រុងរឿង ដោយឫទ្ធិ ដោយយស មានសម្បុរដ៏ល្អ ញុំាងទិសទាំងពួង ឲ្យភ្លឺ មកថ្វាយបង្គំបាទា នៃតថាគត ។

(មណ្ឌូកទេវបុត្តក្រាបទូលថា) ក្នុងកាលមុន ខ្ញុំព្រះអង្គជាកង្កែប នៅក្នុងទឹក មានវារិជាតិជាអាហារ កាលខ្ញុំព្រះអង្គកំពុងតែស្តាប់ ធម៌របស់ព្រះអង្គ នាយគោបាល បានសម្លាប់ខ្ញុំ សូមព្រះអង្គ ទ្រង់ទតនូវឫទ្ធិ នឹងយសរបស់ខ្ញុំ ទ្រង់ទតនូវអានុភាព របស់ខ្ញុំ ទ្រង់ទតនូវសម្បុរ នឹងពន្លឺរបស់ខ្ញុំ អ្នកមានចិត្តជ្រះថ្លា តែមួយ រំពេចបុះ បពិត្រព្រះគោតម ពួកជនណា បានស្តាប់ធម៌របស់ ព្រះអង្គអស់កាលជាអង្វែង ពួកជននោះ រមែងដល់នូវអចលដ្ឋាន (ទីមិនកំរើក) ដែលជាទីទៅហើយ រមែងមិនសោយសោក ។

ចប់ មណ្ឌូកទេវបុត្តវិមាន ទី ១ ។

## ទុតិយំ រេវតីវិមានំ

(៨២) ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ
តថេវ កតបុញ្ញំបិ អស្មា លោកា បរំ គតំ
បុញ្ញានិ បដិគណ្ហន្តិ បិយំ ញាតីវ(១) អាគតំ

ឧដ្ឋេហិ រេវតេ សុបាបធម្មេ
អបារុតំ ទ្វារំ អទានសីលេ
នេស្សាម តំ យត្ថ ថុនន្តិ ទុគ្គតា
សមប្បិតា នេរយិកា ទុក្ខេនាតិ(២)
ឥច្ចេវំ វត្វាន យមស្ស ទូតា
តេ ទ្វេ យក្ខា លោហិតក្ខា ព្រហន្តា
បច្ចេកពាហាសុ គហេត្វា រេវតឹ
បក្កាមយឹសុ(៣) ទេវគណស្ស សន្តិកេ
អាទិច្ចវណ្ណំ រុចិរំ បភស្សរំ
ពយម្ហំ(៤) សុភំ កញ្ចនជាលឆន្នំ
កស្សេតំ អាកិណ្ណជនំ វិមានំ
សុរិយស្ស រំសីរិវ ជោតមានំ

---

១ ឱ. ម. ញាតីវ ។ ២ ម. តិសរេទុក្ខត្តិ ។ ៣ ម. បក្កាមយុំ ។ ៤ ឱ. វ្យម្ហំ ។ ម. ព្យម្ហំ ។

# រេវតីវិមាន ទី ២

(៥២) ពួកញាតិមិត្តនិងសំឡាញ់ តែងត្រេកអរសាទរ ចំពោះបុរស ដែលព្រាត់ប្រាសអស់កាលយូរ ហើយវិលមកអំពីទីឆ្ងាយ ដោយសួស្តី ថា មកហើយ ដូច្នេះយ៉ាងណា បុណ្យទាំងឡាយ រមែងទទួលបុគ្គល ដែលបានធ្វើបុណ្យហើយ ចេញចាកលោកនេះ ទៅកាន់លោកខាងមុខ ដូចពួកញាតិទទួលញាតិ ជាទីស្រឡាញ់មកដល់ យ៉ាងនោះដែរ

(យក្ខទាំងពីរនាក់និយាយថា) នែនាងរេវតី មានធម៌ដ៏លាមកពន់ពេក ជាស្រីឥតទាន ឥតសីល នាងចូរក្រោកឡើង ទ្វារនរកបើកហើយ ពួកសត្វនរក ជាសត្វទុគ្គតប្រកបដោយទុក្ខ យំថ្ងូរនៅក្នុងទីណា ពួកយើងនឹងនាំនាងទៅ ក្នុងទីនោះ លុះយក្ខមានភ្នែកក្រហម ធំសំបើមទាំងពីរ ជាទូតនៃយមរាជ បានពោល យ៉ាងនេះហើយ ក៏ចាប់នាងរេវតី ត្រង់ដើមដៃម្ខាងម្នាក់ ហើយនាំចូលទៅ ក្នុងសំណាក់នៃពួកទេវតា

(នាងរេវតីសួរថា) វិមានដែលមានសម្បុរ ដូចព្រះអាទិត្យ ដ៏រុងរឿង ភ្លឺផ្លេក សំបើមល្អ បិទបាំង ដោយបណ្ដាញមាស មានជនកុះករ ភ្លឺដូចស្មើព្រះអាទិត្យទុំ តើជាវិមានអ្នកណា

នារីគណា ចន្ទនសារានុលិត្តា (១)
ឧភតោ វិមានំ ឧបសោភយន្តិ
តន្តិស្សតិ សុរិយសមានវណ្ណំ
កោ មោទតិ សគ្គប្បត្តោ វិមានេតិ ។
ពារាណសិយំ នន្ទិយោ នាមាសិ ឧបាសកោ
អមច្ឆរី ទានបតី វទញ្ញូ
តស្សេតំ អាកិណ្ណជនំ វិមានំ
សុរិយស្ស រំសីរិវ ជោតមានំ
នារីគណា ចន្ទនសារានុលិត្តា
ឧភតោ វិមានំ ឧបសោភយន្តិ
តន្តិស្សតិ សុរិយសមានវណ្ណំ
សោ មោទតិ សគ្គប្បត្តោ វិមានេ
នន្ទិយស្សាហំ ភរិយា
អគារិនី សព្វកុលស្ស ឥស្សរា
ភត្តុវិមានេ រមិស្សាមិ ទានិហំ
ន បត្ថយេ និរយំ (២) ទស្សនាយ ។
ឯសេវ តេ និរយោ សុជាបជេម្ម
បុញ្ញំ តយោ អកតំ ជីវលោកេ

---

១ ឱ. ចន្ទនសារលិត្តា ។ ២ ឱ. និរយេ ។

ពួកនារីទាំងឡាយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ ហើយចូលទៅ ញុំាងវិមាននោះឲ្យល្អរុងរឿងទាំងពីរខាង វិមាននោះមានសម្បុរប្រាកដស្មើ ដោយសម្បុរព្រះអាទិត្យ បុគ្គលណាហ្ន៎ បានដល់នូវឋានសួគ៌ ហើយរីករាយ ក្នុងវិមាន ។

(យក្ខទាំងពីរនោះប្រាប់ថា) ក្នុងក្រុងពារាណសី មានឧបាសកម្នាក់ឈ្មោះនន្ទិយៈ ជាអ្នកមិនកំណាញ់ ជាម្ចាស់ទានអ្នកដឹងនូវពាក្យពេចន៍ វិមានដែលមានជនកុះករ ដ៏រុងរឿងដូចស្មើព្រះអាទិត្យនុ៎ះ ជាវិមានរបស់ឧបាសកឈ្មោះនន្ទិយៈនោះពួកនារីទាំងឡាយ មានខ្លួនលាបហើយ ដោយលំអិតខ្លឹមចន្ទន៍ហើយចូលទៅញុំាងវិមាននោះឲ្យល្អរុងរឿងទាំងពីរខាង វិមាននោះ មានសម្បុរស្មើដោយសម្បុរព្រះអាទិត្យ នន្ទិយឧបាសកនោះ បានដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន(នោះ) ។

(នាងរេវតីនិយាយថា) ខ្លួនខ្ញុំ ជាប្រពន្ធរបស់នន្ទិយឧបាសកជាម្ចាស់ផ្ទះ ជាធំរបស់ត្រកូលទាំងអស់ ខ្ញុំនឹងត្រេកអរ ក្នុងវិមានរបស់ប្តី ក្នុងកាលឥឡូវនេះ ខ្ញុំមិនចង់ឃើញនរក

(យក្ខទាំងពីរនោះតបថា) ម្នាលស្រីមានធម៌ ដ៏លាមកពន់ពេក នរកនុ៎ះ ជានរក សម្រាប់នាងហើយនាងឯង មិនបានធ្វើបុណ្យ ក្នុងមនុស្សលោកសោះ

វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស ទុតិយំ រេវតីវិមានំ

ន ហិ មច្ឆរិយោ រោសកោ បាបធម្មោ
សគ្គូបគានំ លភតិ សហព្យតំ ។

កឹ នុ គូថញ្ច មុត្តញ្ច អសុចិ[1] បដិទិស្សតិ
ទុគ្គន្ធំ កិមិទំ មិឡ្ហំ កិមេតំ ឧបវាយតិ ។

ឯស សំសវកោ នាម (និរយោ) គម្ភីរោ សតបោរិសោ
យត្ថ វស្សសហស្សានិ តុវំ បច្ចសិ រេវតេ ។

កឹ នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កេន សំសវកោ លទ្ធោ (និរយោ) គម្ពីរោ សតបោរិសោ (ឥតិ) ។

សមណេ ព្រាហ្មណេ ចាបិ អញ្ញេ ចាបិ[2] វណិព្វកេ
មុសាវាទេន វញ្ចេសិ តំ បាបំ បកតំ តយា
តេន សំសវកោ លទ្ធោ (និរយោ) គម្ភីរោ សតបោរិសោ
តត្ថ វស្សសហស្សានិ តុវំ បច្ចសិ រេវតេ

ហត្ថេបិ ឆិន្ទន្តិ អថោបិ បាទេ
កណ្ណេបិ ឆិន្ទន្តិ អថោបិ នាសំ
អថោបិ កាកោលគណា សមេច្ច
សង្គម្ម ខាទន្តិ វិផន្ទមានន្តិ ។

---

១ ម. អសុចឹ ។ ២ ឱ. ម. វាបិ ។

ដ្បិតថា បុគ្គលមានសេចក្តីកំណាញ់ ជាអ្នកជេរ
ប្រទេចគេ មានធម៌លាមក រមែងមិនបានកើតរួម
ជាមួយនឹងពួកអ្នកដែលទៅកើត ក្នុងឋានសួគ៌ទេ ។

(នាងបេតីសួរថា) អ្វីនេះហ្ន៎ ជាគូថនឹងមូត្រមិនស្អាត ជាក់ស្តែង
ម្ល៉េះ អ្វីនេះហ្ន៎ ជាលាមកមានក្លិនអាក្រក់ម្ល៉េះ អ្វីនុ៎ះហ្ន៎ ផ្សាយក្លិនមក ។

(ពួកនិរយបាលពោលថា) នុ៎ះនរកឈ្មោះសំសវកៈ ជំជ្រៅចំនួន
មួយរយជួរបុរស ម្នាលនាងបេតី នាងនឹងឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំ ។

(នាងបេតីតបថា) អំពើអាក្រក់ដូចម្តេច ដែលខ្ញុំបានធ្វើដោយ
កាយ វាចា ចិត្ត នរកឈ្មោះសំសវកៈ ជំជ្រៅ ចំនួនមួយរយជួរបុរស
ខ្ញុំបាន ដោយហេតុដូចម្តេច ។

(ពួកនិរយបាលពោលថា) នាងបាននិយាយបញ្ឆោតពួកសមណៈ
ពួកព្រាហ្មណ៍ នឹងពួកវណិព្វកៈដទៃ ៗ ដោយមុសាវាទ បាបនោះ
នាងបានធ្វើហើយ យ៉ាងនេះ នរកឈ្មោះសំសវកៈ ជំជ្រៅចំនួន
មួយរយជួរបុរស នាងបាន ព្រោះបាបនោះឯង ម្នាលនាងបេតី
នាងនឹងឆេះក្នុងនរកនោះ រាប់ពាន់ឆ្នាំ

ពួកនិរយបាល កាត់ដៃក៏មាន កាត់ជើងក៏មាន កាត់ស្លឹក
ត្រចៀកក៏មាន កាត់ច្រមុះក៏មាន មួយទៀត ពួកសត្វក្អែក
មកប្រជុំជញ្ជែងចឹក នូវសត្វនរក ដែលកំពុងតែញាប់ញ័រ ។

សាធុ ខោ មំ បដិវេថ   កាហាមិ កុសលំ ពហុំ
ទានេន សមចរិយាយ   សញ្ញមេន ទមេន ច
យំ កត្វា សុខិតា ហោន្តិ   ន ច បច្ឆានុតប្បរេតិ ។
បុរេ តុវំ បមជ្ជិត្វា   ឥទានិ បរិទេវសិ
សយំ កតានំ កម្មានំ   វិបាកំ អនុភោស្សសិ ។

កោ ទេវលោកតោ មនុស្សលោកំ
គន្ត្វាន បុដ្ឋោ មេ ឯវំ វទេយ្យ
និក្ខិត្តទណ្ឌេសុ ទទាថ ទានំ
អច្ឆាទនំ សយនមថន្នបានំ
ន ហិ មច្ឆរិយោ (១) រោសកោ បាបធម្មោ
សគ្គូបគានំ លភតិ សហព្យតំ (ឥតិ) ។

សាហំ នូន ឥតោ គន្ត្វា   យោនឹ លទ្ធាន មានុសឹ
វទញ្ញូ សីលសម្បន្នា   កាហាមិ កុសលំ ពហុំ
ទានេន សមចរិយាយ   សញ្ញមេន ទមេន ច
អារាមានិ ច រោបិស្សំ   ទុគ្គេ សង្កមនានិ ច
បបញ្ច ឧទបានញ្ច   វិប្បសន្នេន ចេតសា

១ ម. មច្ឆរី ។

(នាងពេតីតបថា) ខ្ញុំសូមអង្វរ សូមអ្នកទាំងឡាយ នាំខ្ញុំត្រឡប់ទៅវិញ ពួកសត្វ ជាអ្នកបានសុខ ទាំងមិនក្តៅក្រហាយ ក្នុងកាលខាងក្រោយ ព្រោះបានធ្វើកុសលណា ខ្ញុំនឹងធ្វើកុសលនោះឲ្យច្រើនដោយការឲ្យទាន ការប្រព្រឹត្តស្មើ ការសង្រួម នឹងការទូន្មានឥន្ទ្រិយ ។

(ពួកទេវយានបាលពោលថា) ក្នុងកាលមុននាងប្រមាទហើយ ឥឡូវនេះខ្លួញយំ នាងនឹងទទួលផលនៃកម្មទាំងឡាយ ដែលបានធ្វើដោយខ្លួនឯង។

(នាងពេតីតបថា) បុគ្គលណា ចេញអំពីទេវលោក ទៅកាន់
មនុស្សលោកហើយ ខ្ញុំសួរ តបប្រាប់ខ្ញុំ យ៉ាងនេះថា
អ្នកទាំងឡាយ ចូរឲ្យសំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក
(ទីអង្គុយ) នឹងបាយ ទឹក ជាទាន ចំពោះពួកជនដែលមាន
អាជ្ញាជាក់ចុះហើយ បើពិតថា បុគ្គលមានសេចក្តីកំណាញ់
ជាអ្នកជេរ ប្រទេចគេ មានធម៌ដ៏លាមក រមែងមិនបានទៅ
កើតជាមួយនឹងពួកអ្នកដែលទៅកើត ក្នុងឋានសួគ៌មែន ។

ខ្ញុំនោះ ប្រសិនបើរួចទៅអំពីនេះ ហើយបានទទួលកំណើតជារបស់មនុស្ស នឹងជាអ្នកដឹងក្តី បរិបូណ៌ដោយសីល ធ្វើនូវកុសលឲ្យច្រើនដោយការឲ្យទាន ការប្រព្រឹត្តស្មើ ការសង្រួម នឹងការទូន្មាននូវឥន្ទ្រិយ មួយទៀត ខ្ញុំនឹងដាំឈើសួន សង់ស្ពានសម្រាប់ឆ្លងទៅមក ក្នុងទីដែលលំបាក ជីកអណ្តូង ជីកស្រះ ដោយចិត្តជ្រះថ្លា

ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
ចាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសិស្សំ សទា សីលេសុ សំវុតា
ន ច ទានេ បមជ្ជិស្សំ សាមំ ទិដ្ឋមិទំ មយាតិ(១) ។
ឥច្ចេវំ វិលបន្តិញ្ច(២) ផន្ទមានំ តតោ តតោ
ខិបឹសុ និរយេ ឃោរេ ឧទ្ធបាទំ អវំសិរំ ។

អហំ បុរេ មច្ឆរិនី អហោសឹ
បរិភាសិកា សមណព្រាហ្មណានំ
វិតថេន ច សាមិកំ វញ្ចយិត្វា
បច្ចាមហំ(៣) និរយេ ឃោររូបេតិ ។

រេវតីវិមានំ ទុតិយំ ។

## តតិយំ ឆត្តមាណវកវិមានំ

(៨៣) យោ វទតំ បវរោ មនុជេសុ
សក្យមុនី ភគវា កតកិច្ចោ
បារគតោ ពលវិរិយសមង្គី(៤)
តំ សុគតំ សរណត្ថមុបេហិ

---

១ ម. តិ-សទ្ទោ នត្ថិ ។ ២ ឱ. វិប្បលបន្តី ។ ម. វិប្បលបន្តិ ។ ៣ ម. តប្បាមហំ ។
៤ ម. ពលវីរសមង្គី ។

ខ្ញុំនឹងរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី១៤ ទី១៥ នឹងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ខ្ញុំនឹងជាបុគ្គលសង្រួមក្នុងសីលទាំងឡាយ គ្រប់កាល ខ្ញុំនឹងមិនប្រមាទ ក្នុងទាន ព្រោះខ្ញុំបានឃើញអំពើនេះ (ជាក់ច្បាស់) ដោយខ្លួនឯងហើយ ។

(ពួកនិរយបាល) បោះនាងរេវតីដែលកំពុងយំ បម្រះនទៀលយ៉ាងនេះ ទៅក្នុងនរកដ៏ពទ្លឹក ឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ។

(នាងរេវតីនិយាយថា) ក្នុងកាលមុន ខ្ញុំជាអ្នកមាន
សេចក្តីកំណាញ់ ជាអ្នកជេរ ប្រទេច នូវពួកសមណៈ
នឹងព្រាហ្មណ៍ បោកប្រាសនូវស្វាមី ដោយពាក្យ
មិនពិត ទើបខ្ញុំឆេះ ក្នុងនរក មានសភាពដ៏ពទ្លឹក ។

ចប់ រេវតីវិមាន ទី ២ ។

# ឆត្តមាណវកវិមាន ទី ៣

(៥៣) ព្រះមានព្រះភាគ ជាសក្យមុនីអង្គណា ដ៏ប្រសើរខ្ពស់ ជាងពួកអ្នកប្រាជ្ញ ក្នុងពួកមនុស្ស ទ្រង់បានធ្វើកិច្ចស្រេចហើយ ដល់នូវត្រើយគឺព្រះនិព្វាន ព្រះអង្គប្រកបព្រមដោយកំឡាំង (នឹងញាណ) នឹងសេចក្តីព្យាយាម អ្នកចូរដល់នូវព្រះមានព្រះភាគ ជាព្រះសុគតអង្គនោះ ដើម្បីជាសរណៈចុះ

វិរាគមនេជមសោកំ

ធម្មសង្ខតមប្បដិកូលំ

មធុរមិមំ បគុណំ សុវិភត្តំ

ធម្មមិមំ សរណត្ថមុបេហិ

យត្ថ ច ទិន្នមហប្ផលមាហុ

ចតូសុ សុចីសុ បុរិសយុគេសុ

អដ្ឋ ច បុគ្គលធម្មទសា តេ

សង្ឃមិមំ សរណត្ថមុបេហីតិ ។

ន តថា តបតិ នភស្មឹ សូរិយោ

ចន្ទោ ន ភាសតិ ន ផុស្សោ

យថាតុលមិទំ មហប្បភាសំ

កោ នុ ត្វំ តិទិវា មហិមុបាគមិ

ឆិន្ទតិ ច រំសី បភាករស្ស(១)

សាធិកវីសតិយោជនានិ អាភា

រត្តិម្បិ ច យថា ទិវំ ករោតិ

បរិសុទ្ធំ វិមលំ សុភំ វិមានំ

ពហុបទុមវិចិត្តបុណ្ឌរីកំ

១ ឱ. បភំករស្ស ។ ម. បភង្ករស្ស ។

អ្នកបូជល់នូវធម៌ ដែលប្រាសចាករាគៈ(អរិយមគ្គ) មិនរំភើប មិនមានសោក (អរិយផល) ជាសភាវធម៌ដែលបច្ច័យប្រជុំតាក់តែង មិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែលលោកចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ អ្នកប្រាជ្ញទាំងឡាយ បានពោលនូវទានដែលបុគ្គលឱ្យហើយ ចំពោះគូបុរសដ៏ស្អាត ៤ គូណា ថាជាទានមានផលច្រើន គូនៃបុរសនោះចាត់ជាបុគ្គល ៨ ពួក ជាអ្នកឃើញនូវធម៌ អ្នកបូជល់នូវព្រះសង្ឃនេះជាសរណៈចុះ ។

(ព្រះមានព្រះភាគត្រាស់ថា) វិមានរបស់អ្នកនេះ មានពន្លឺខ្លាំងរកអ្វីប្រៀបគ្មាន យ៉ាងណា ព្រះអាទិត្យ ព្រះចន្ទនិងផ្កាយផុស្សៈ (ផ្កាយប្រចាំខែបុស្ស) ឰដ៏អាកាស ក៏មិនរុងរឿងមិនភ្លឺត្រឹមស្មើយ៉ាងនោះ អ្នកជាអ្វី មកអំពីទេវលោកមកកាន់ផែនដីមួយទៀតស្មើ(វិមានរបស់អ្នកផ្សាយទៅ) អស់ ២៥ យោជន៍ គ្រប់សង្កាត់ស្មើព្រះអាទិត្យ ធ្វើរាត្រីឲ្យដូចជាវេលាថ្ងៃ វិមានដ៏ល្អស្អាត មិនមានមន្ទិល មានផ្កាឈូកក្រហមជាច្រើនបែបនិងមានផ្កាឈូកស

វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស តតិយំ ឆត្តមាណវកវិមានំ

ឱកិណ្ណំ កុសុមេហិ នេកវិចិត្តំ
អរជិរជហេមជាលច្ឆន្នំ
អាកាសេ តបតិ យថាបិ សុរិយោ
រត្តកម្ពលបីតវាសសាហិ[1]
អគលុប្បិយង្គុចន្ទនុស្សទាហិ
កញ្ចនតនុសន្និភត្តចាហិ
បរិបូរន្តគណំវ តារកាហិ
នរនារិយោ ពហុកេត្ថ នេកវណ្ណា
កុសុមវិភូសិតាភរណេត្ថ សុមនា
អនិលបមុញ្ចិតា បវន្តិ[2] សុរភិ
តបនីយវិចិត្តា សុវណ្ណឆន្នា
កិស្ស កម្មស្ស អយំ វិបាកោ
កេនាសិ កម្មផលេនិធូបបន្នា
យថា ច តេ អធិគតមិទំ វិមានំ
តទនុរូបំ អវហាសិ[3] ឥង្ឃ បុដ្ឋាតិ ។
យមិធ បថេ សមេច្ច មាណវេន
សត្ថានុសាសិ អនុកម្បមានោ

១ ឱ. ម. រត្តម្ពរបីតវាសសាហិ ។ ២ ម. បវាយន្តិ ។ ៣ ម. តទនុបមំ អវហាសិ ។

វិមានវត្ថុ មហារថវគ្គ ទី ៥ ឆត្តមាណវកវិមាន ទី ៣

មានពណ៌ដ៏វិចិត្រលាយឡំដោយផ្កាផ្សេងៗ វិចិត្រដោយក្រវិល នឹងក្រងផ្កាជាច្រើនយ៉ាង ជាវិមានមិនមានធូលី ពាំងបិទបាំងដោយបណ្ដាញមាស ប្រាសចាកធូលី រុងរឿងត្រចែត ឮដ៏អាកាស ដូចព្រះអាទិត្យ ដ៏ពាសពេញ ដោយពួកទេវធីតា (ស្លៀកដណ្ដប់) សំពត់កម្ពលក្រហម នឹងសំពត់លឿង មានខ្លួនប្រស់ព្រំ ប្រដាប់ដោយគ្រឿងក្រស្នា ផ្កាបិយង្គុនឹងគ្រឿងចន្ទន៍ មានស្បែកដ៏ស្ដើងក្លៃថ្លា ដូចមាស ដូចជាអាកាសដែលពេញពាសដោយពួកផ្កាយ ក្នុងវិមាននុ៎ះ មាននរនារី ជាច្រើន មានវណ្ណៈប្លែកៗគ្នា មានគ្រឿងអម្ពរ ស្អិតស្អាងដោយផ្កា មានចិត្តរីករាយក្នុងវិមាននុ៎ះ លុះត្រូវខ្យល់បក់ផាត់មកផ្សព្វផ្សាយក្លិនក្រអូប មានគ្រឿងបិទបាំង ជាវិការៈនៃមាស ដ៏វិចិត្រដោយបរិក្ខារដ៏រុងរឿង នេះជាផលនៃបុញ្ញកម្មដូចម្ដេច អ្នកបានមកកើតក្នុងវិមាននេះ តើដោយផលបុញ្ញកម្ម ដូចម្ដេចមួយទៀត អ្នកបាននូវវិមាននេះ ដោយអំពើ យ៉ាងណា អ្នក កាលបើតថាគតសួរហើយ សូមអ្នកប្រាប់ នូវហេតុតាមសមគួរដល់អំពើនោះ យ៉ាងនោះ ។

ព្រះសាស្ដា ទ្រង់អនុគ្រោះ បានជួប នឹងឆត្ត-មាណពនោះ ក្នុងផ្លូវនេះ ហើយព្រះអង្គទ្រង់ប្រៀនប្រដៅ

តវ រតនវរស្ស ធម្មំ សុត្វា
ការិស្សាមីតិ ច ឥតិ ព្រាវិត្តា ធន្តោ
ជិនបវរំ ឧបេមិ សរណំ
ធម្មញ្ចាបិ តថេវ ភិក្ខុសង្ឃំ
ធោតិ បឋមំ អកេចាហំ ភន្តេ
យថា តេ វចនំ តថេវកាសិំ
មា ច បាណវធំ វិវិធំ ចរស្សុ[១]
អសុចិំ ហិ បាណេសុ
អសញ្ញតំ អវណ្ណយិំសុ[២] សប្បញ្ញា
ធោតិ បឋមំ អកេចាហំ ភន្តេ
យថា តេ វចនំ តថេវកាសិំ[៣]
មា ច បរជនស្ស រក្ខិតាយោ
បរភរិយាយោ អគមា អនរិយមេតំ
ធោតិ បឋមំ អកេចាហំ ភន្តេ
យថា តេ វចនំ តថេវកាសិំ

---

១ ម. វិវិធំ បរស្ស ។ ២ ម. អវណ្ណយិំ ។ ៣ ឱ. តតោបរំ: មា ច បរជនស្ស រក្ខិតម្បិ អាទាតព្វំ អសញ្ញតោ អទិន្នំ ធោតិ បឋមំ អកេចាហំ ភន្តេ យថា តេ វចនំ តថេវកាសិន្តិ បាឋោ ទិស្សតិ ។

បំណែកធម៌ត្រាណាត បានស្តាប់ធម៌ របស់ព្រះអង្គ ជាគេនៈដ៏ប្រសើរហើយ ក៏ក្រាបទូលថា ខ្ញុំព្រះអង្គនឹងធ្វើតាម ខ្ញុំព្រះអង្គ សូមដល់ព្រះជិនបវរ ព្រមទាំងព្រះធម៌នឹងព្រះសង្ឃ ជាសរណៈ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន(ដឹងនូវសរណគមន៍)ទេ ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវ តាមព្រះពុទ្ធដីកា របស់ព្រះអង្គហើយ (ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា) អ្នកកុំប្រព្រឹត្តនូវការសម្លាប់សត្វ ជាអំពើមិនស្អាត មានប្រការផ្សេង ៗ ព្រោះថា ពួកជនប្រកបដោយប្រាជ្ញា មិនសរសើរនូវការមិនសង្រួមក្នុងពួកសត្វទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន(ដឹងទេ)ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើត្រឹមត្រូវ តាមព្រះពុទ្ធដីកា របស់ព្រះអង្គហើយ (ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា) អ្នកកុំកាន់យកទ្រព្យ ដែលជនដទៃរក្សា កុំគប់រកភរិយា របស់ជនដទៃ ដ្បិតអំពើនេះមិនប្រសើរទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន (ដឹងទេ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គ បានធ្វើឲ្យត្រឹមត្រូវ តាមព្រះពុទ្ធដីកា របស់ព្រះអង្គហើយ

វិមានវត្ថុម្ហិ បញ្ចមស្ស មហារថវគ្គស្ស តតិយំ ឆត្តមាណវកវិមានំ

មា ច វិតថំ អញ្ញថា អភណិ
ន ហិ មុសាភណិំ អវណ្ណយឹសុ សប្បញ្ញា
ណោតិ បឋមំ អភេចាហំ ភន្តេ
បច្ឆា តេ វចនំ តថេវកាសឹ
យេន ច បុរិសស្ស អបេតិ សញ្ញា
តំ វជ្ជំ[១] បរិវជ្ជយស្សុ សព្វំ
ណោតិ បឋមំ អភេចាហំ ភន្តេ
បច្ឆា តេ វចនំ តថេវកាសឹ
ស្វាហំ ឥធ បញ្ចសិក្ខា ករិត្វា
បដិបជ្ជិត្វា តថាគតស្ស ធម្មេ
ទេ្វ បថមគមាសឹ ចោរមជ្ឈេ
តេ មំ តត្ថ វធឹសុ ភោគហេតុ
ឯត្តកមិទំ អនុស្សរាមិ កុសលំ
តតោ បរំ ន មេ វិជ្ជតិ អញ្ញំ

១ ឱ. ម. មជ្ជំ

ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា អ្នកកុំនិយាយឲ្យឃ្លាតចាក
សេចក្តីពិត ដោយហេតុដទៃឡើយ ព្រោះថាពួកជនដែល
ប្រកបដោយប្រាជ្ញា មិនសរសើរពាក្យកុហកទេ បពិត្រព្រះ
អង្គដ៏ចំរើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គ
មិន(ដឹងទេ)ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវ
តាមព្រះពុទ្ធដីកា របស់ព្រះអង្គហើយ (ព្រះអង្គបានទូន្មាន
ខ្ញុំព្រះអង្គថា)សញ្ញារបស់បុរស រមែងប្រាសទៅ ព្រោះគ្រឿង
ស្រវឹងណា អ្នកចូរលះ ចូរវៀរ នូវគ្រឿងស្រវឹងទាំងអស់
នោះចេញ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានក្រាបទូល ជា
ដំបូងថា ខ្ញុំព្រះអង្គមិន (ដឹងទេ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គ
បានធ្វើឲ្យត្រឹមត្រូវ តាមព្រះពុទ្ធដីកា របស់ព្រះអង្គហើយ
ខ្ញុំព្រះអង្គនោះ បានទទួលយកសិក្ខាបទ ៥ ហើយប្រតិបត្តិ
តាមធម៌របស់ព្រះតថាគត ហើយដើរទៅកាន់ផ្លូវ ត្រង់ចន្លោះ
ព្រៃប្រទល់ស្រុកពីរ ក្នុងចំណោមពួកចោរ ពួកចោរទាំងនោះ
បានសម្លាប់ខ្ញុំព្រះអង្គ ក្នុងទីនោះ ព្រោះហេតុតែភោគសម្បត្តិ
ខ្ញុំព្រះអង្គ តែងរលឹកនូវកុសល មានប្រមាណប៉ុណ្ណោះនេះ
កុសលដទៃ ក្រៅអំពីនោះ របស់ខ្ញុំព្រះអង្គ មនមានឡើយ

តេន សុចរិតេន កម្មុនាហំ
ឧបបន្នា តិទិវេសុ កាមកាមី(១)
បស្ស ខណមុហុត្តសញ្ញមស្ស
អនុធម្មប្បដិបត្តិយា វិបាកំ
ជលមិវ យសសា បេក្ខមានា
ពហុកា បិហយន្តិ ហីនកម្មា(២)
បស្ស កតិបយាយ ទេសនាយ
សុគតិញ្ចម្ហិ គតា សុខញ្ច បត្តា
យេ ច តេ សតតញ្ច សុណន្តិ ធម្មំ
មញ្ញេ តេ អមតំ ផុសន្តិ ខេមំ
អប្បកម្បិ កតំ មហាវិបាកំ
វិបុលំ ហោតិ(៣) តថាគតស្ស ធម្មេ

---

១ ម. ឧប្បត្តិ សុវណ្ណឆន្នា ។ កេន តេ តាទិសោ វណ្ណោ ។ បេ ។ វណ្ណោ ច តេ សព្វទិសា បភាសតីតិ សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ បញ្ហំ បុដ្ឋោ វិយាកាសិ យស្ស កម្មស្សិទំ ផលំ ។ ទិព្វំ មមំ វស្សសហស្សមាយុ វាចាភិគីតំ មនសា បវត្តិតំ ឯត្តាវតា ឋស្សតិ បុញ្ញកម្មោ ទិព្វេហិ កាមេហិ សកាមកាមីតិ ឥមេ បាឋា ទិស្សន្តិ ។
២ ម. ហីនកាមា ។ ៣ ម. វិបុលំ ផលំ ។

ខ្ញុំព្រះអង្គបានទៅកើត ក្នុងទេវលោក ជាអ្នកបានទទួល
កាម តាមសេចក្តីប្រាថ្នា ដោយសារអំពើសុចរិតនោះ
សូមព្រះអង្គទ្រង់ចាំទុកនូវផល នៃការសង្រួមក្នុងខណៈ
មួយរំពេច នឹងការប្រតិបត្តិធម៌ដ៏សមគួរចុះ ពួកជន
ជាច្រើន ដែលមានធម៌ថោកទាប (ជាងខ្ញុំ) កាល
បានឃើញខ្ញុំព្រះអង្គ កំពុងតែរុងរឿង ដោយយស
ក៏រមែងស្រឡាញ់ សូមព្រះអង្គទ្រង់ចាំទុក ខ្ញុំព្រះអង្គ
បានដល់នូវសុគតិផង ដល់នូវសេចក្តីសុខផងដោយ
សារធម្មទេសនាតិចទេ ចំណែកពួកជនណា ស្តាប់
ធម៌របស់ព្រះអង្គរឿយៗ ពួកជននោះ ទំនងជាបាន
នូវអមតនិព្វានជាទីក្សេម មិនខាន បុញ្ញកម្ម សូម្បីមាន
ប្រមាណតិច ដែលបុគ្គលធ្វើហើយ ក្នុងសាសនធម៌
របស់ព្រះតថាគត រមែងមានផលច្រើន ធំទូលាយ

វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស តតិយំ ឆត្តមាណវកវិមានំ

បស្ស កតបុញ្ញតាយ ឆត្តោ
ឱភាសេតិ[១] បឋវឹ យថាបិ សុរិយោ
កិមិទំ កុសលំ កិមាចរេម
ឥច្ចេកោ[២] ហិ សមេច្ច មន្តយន្តិ
តេ មយំ បុនទេវ លទ្ធា មានុស្សត្តំ
បដិបន្នា វិចរេមុ[៣] សីលវន្តោ
ពហុការោ អនុកម្បកោ ច មេ សត្ថា
ឥតិ មេ សតិ អគមា ទិវាទិវស្ស
ស្វាហំ ឧបគតោម្ហិ សច្ចនាមំ
អនុកម្បស្សុ បុនបិ សុណោមិ[៤] ធម្មំ
យេធ បជហន្តិ កាមរាគំ
ភវរាគានុសយញ្ច បហាយ មោហំ
ន ច តេ ឧបេន្តិ[៥] គព្ភសេយ្យំ
បរិនិព្វានគតា ហិ សីតិភូតាតិ[៦] ។

ឆត្តមាណវកវិមានំ តតិយំ ។

---

១ ឱ. ម. ឱភាសតិ ។ ២ ម. ឥច្ចេតេ ។ ៣ ម. វិហរេមុ ។ ៤ ម. សុណោមុ ។
៥ ម. ន តេ បុន មុបេន្តិ ។ ៦ ម. សន្តិភូតាតិ ។

វិមានវត្ថុ មហារថវគ្គ ទី ៥ ឆត្តមាណវកវិមាន ទី ៣

សូមព្រះអង្គទ្រង់ទតចុះ ឆត្តមាណពញុំាងផែនដី ឲ្យរុងរឿង ដូចព្រះអាទិត្យ ព្រោះបានធ្វើបុណ្យទុកហើយ ជនមួយពួកប្រជុំប្រឹក្សាគ្នាថា កុសលនេះដូចម្តេច យើងត្រូវប្រព្រឹត្តអំពើកុសលដូចម្តេច ពួកយើងនោះ លុះបាននូវអត្តភាពជាមនុស្សវិញហើយ គួរជាអ្នកមានសីល ប្រព្រឹត្ត ប្រតិបត្តិ ឯព្រះសាស្តា មានឧបការៈច្រើន ទ្រង់អនុគ្រោះខ្ញុំព្រះអង្គ ព្រោះហេតុនោះ កាលខ្ញុំព្រះអង្គនៅរស់ ព្រះអង្គក៏ស្តេចមកទាំងថ្ងៃ ខ្ញុំព្រះអង្គនោះក៏បានចូលទៅគាល់ព្រះអង្គ មានព្រះនាមជាសប្បុរស សូមព្រះអង្គអនុគ្រោះឲ្យបាន ខ្ញុំព្រះអង្គសូមស្តាប់ធម៌ម្តងទៀត ជនពួកណា ក្នុងសាសនានេះ លះបង់កាមរាគផង លះបង់ភវរាគានុស្ស័យផង លះបង់មោហៈផង ជនពួកនោះ មិនចូលទៅកាន់ដំណេកក្នុងគភ៌ឡើយ ព្រោះបានដល់នូវព្រះនិព្វាន ជាធម៌ត្រជាក់ ។

ចប់ ឆត្តមាណវកវិមាន ទី ៣ ។

# បត្ថំ កក្កដរសទាយកវិមានំ

(៨៤) ឧច្ចមិទំ មណិថូណំ វិមានំ
សមន្តតោ ទ្វាទស យោជនានិ
កូដាគារា សត្តសតា ឧឡារា
វេឡុរិយត្ថម្ភា រុចកត្ថតា សុភា
តត្ថច្ឆសិ បិវសិ ខាទសិ ច
ទិព្វា ច វីណា បវទន្តិ វគ្គូ
ទិព្វា រសា កាមគុណេត្ថ បញ្ច
នារិយោ ច នច្ចន្តិ សុវណ្ណឆន្នា
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា
បុច្ឆាមិ តំ ទេវ មហានុភាវ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
បញ្ហំ បុដ្ឋោ វិយាកាសិ យស្ស កម្មស្សិទំ ផលំ

## កក្កដរសទាយកវិមាន ទី៤

(៤៤) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មាន
សសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍
មានផ្ទះកំពូល ៧០០ ដ៏លើសលប់ ដែលមានសសរជា
វិការៈនៃកែវពិទូរ្យ ក្រាលកម្រាលដ៏ល្អ (ក្ដារមាស)
ជាផ្ទះកំពូលដ៏ល្អ ខ្លួនអ្នកតែងនៅក្រេបផឹកទាំងទំពាស៊ី
ក្នុងវិមាននោះ ពិណទិព្វ មានសំឡេងពីរោះ រមែង
លាន់ឮ កាមគុណ ៨ មានរសជាទិព្វ ទាំងពួកនារី ស្អិត
ស្អាងកាយ ដោយគ្រឿងមាស តែងរាំនៅក្នុងវិមាននុ៎ះ
សម្បត្តិរបស់អ្នកប្រាកដដូច្នោះ តើដោយបុញ្ញកម្មដូចម្ដេច ទិព្វសម្បត្តិ
សម្រេចដល់អ្នកក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយ ជាទីពេញ
ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់អ្នកផង តើដោយបុញ្ញកម្មដូចម្ដេច
ម្នាលទេវតា អ្នកមានអានុភាពច្រើន អាត្មាសូមសួរអ្នក
អ្នកកាលដែលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្ដេច
អ្នកមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បត្តិរបស់
អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្ដេច ។
ទេវបុត្រនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

សតិសមុប្បាទករោ ទ្វារេ កក្កដកោ(១) ឋិតោ

និដ្ឋិតោ ជាតរូបស្ស សោភតិ ទសបាទកោ

តេន មេ តាទិសោ វណ្ណោ តេន មេ ឥធមិជ្ឈតិ

ឧប្បជ្ជន្តិ ច មេ ភោគា យេ កេចិ មនសោ បិយា

តេនម្ហិ ឯវំ ជលិតានុភាវោ

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

កក្កដរសទាយកវិមានំ ចតុត្ថំ ។

ឥតរំ បញ្ចវិមានំ យថា កក្កដវិមានំ តថា វិត្ថារេតព្វំ ។

## បញ្ចមំ ទ្វារបាលកវិមានំ

(៤៨) ឧច្ចមិទំ មណិថូណំ វិមានំ

សមន្តតោ ទ្វាទស យោជនានិ

។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ទិព្វំ មម វស្សសហស្សមាយុ

វាចាភិគីតំ មនសា បវត្តិតំ

១ ឥធ កក្កដកសទ្ទោ កក្កដសទិសោយេវ ។

រូបក្តាមមានជើង ១០ ស្ថិតនៅប្រថទ្វារ សម្រាប់ដាស់ស្មារតី
ដែលសម្រេចដោយមាស រុងរឿងល្អ វណ្ណៈរបស់ខ្ញុំ ដែល
ប្រាកដដូច្នោះ ដោយហេតុបុញ្ញកម្មនោះ ទិព្វសម្បត្តិសម្រេច
ដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណាមួយ ជាទីពេញចិត្ត
ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង ដោយសារបុញ្ញកម្មនោះ
ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ
ក៏ភ្លឺច្បាស់ សព្វទិស ដោយបុញ្ញកម្មនោះឯង ។

ចប់ កក្កដរសទាយកវិមាន ទី ៤ ។

វិមាន៥ ក្រៅពីនេះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារ ដូចកក្កដវិមានផងចុះ ។

# ទ្វារបាលកវិមាន ទី ៥

(៥៥) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មាន
សសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍
។ បេ ។ សម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។
ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ
។ បេ ។ ទូលផលនៃកម្មនេះថា

ខ្ញុំមានអាយុមួយពាន់ឆ្នាំទិព្វ (ព្រោះ) ពាក្យដែល
ខ្ញុំពោលដោយពិត (ដោយសេចក្តីគោរព)
ដែលខ្ញុំ ឲប្រព្រឹត្តទៅហើយ ដោយចិត្ត

ឯត្តាវតា ឋស្សតិ បុញ្ញកម្មោ
ទិព្វេហិ កាមេហិ សមង្គិភូតោ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទ្វារបាលកវិមានំ បញ្ចមំ ។

## ឆដ្ឋំ ករណីយវិមានំ

(៥៦) ឧច្ចមិទំ មណិថូណំ វិមានំ
សមន្តតោ ទ្វាទស យោជនានិ
។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
។ បេ ។ យស្ស កម្មស្សិទំ ផលំ
ករណីយានិ បុញ្ញានិ បណ្ឌិតេន វិជានតា
សមគ្គតេសុ ពុទ្ធេសុ យត្ថ ទិន្នំ មហប្ផលំ
អត្ថាយ វត មេ ពុទ្ធោ អរញ្ញា គាមមាគតោ
តត្ថ ចិត្តំ បសាទេត្វា តាវតឹសូបគោ អហំ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ករណីយវិមានំ ឆដ្ឋំ ។

បុគ្គលមានបុញ្ញកម្ម ដោយហេតុត្រឹមតែការពោលទឹកការជ្រះថ្លា

ប៉ុណ្ណោះ រមែងបរិបូណ៌ដោយកាមជាទិព្វ ស្ថិតនៅ (អស់កាលយូរ)

សម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះ ។ បេ ។

ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ទ្វារបាលកវិមាន ទី ៥ ។

## ករណីយវិមាន ទី ៦

(៩៦) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មាន

សសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍

។ បេ ។ ទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

បណ្ឌិតអ្នកស្គាល់ច្បាស់ (នូវអំពើឥតប្រយោជន៍ មានប្រយោជន៍)

គួរតែធ្វើបុណ្យទាំងឡាយ ទានដែលគេថ្វាយ ចំពោះព្រះពុទ្ធទាំង

ឡាយព្រះអង្គប្រតិបត្តិល្អ រមែងមានផលច្រើន ព្រះពុទ្ធទ្រង់ស្តេច

ចេញអំពីព្រៃមកកាន់ស្រុក ដើម្បីសេចក្តីចំរើនដល់ខ្ញុំជាប្រាកដ ខ្ញុំ

ក៏បានញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះព្រះអង្គនោះ ហើយបានទៅកើត

ក្នុងតាវត្តិង្សទេវលោក សម្បុរបស់ខ្ញុំប្រាកដដូច្នោះ ដោយបុញ្ញកម្ម

នោះ ។ បេ ។ ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ករណីយវិមាន ទី៦ ។

# សត្តមំ ទុតិយករណីយវិមានំ

(៨៧) ឧច្ចមិទំ មណិថូណំ វិមានំ

សមន្តតោ ទ្វាទស យោជនានិ

។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ករណីយានិ បុញ្ញានិ បណ្ឌិតេន វិជានតា

សម្មគ្គតេសុ ភិក្ខូសុ យត្ថ ទិន្នំ មហប្ផលំ

អត្ថាយ វត មេ ភិក្ខុ អរញ្ញា គាមមាគតា

តត្ថ ចិត្តំ បសាទេត្វា តាវត្តឹសូបគោ អហំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទុតិយករណីយវិមានំ សត្តមំ ។

# អដ្ឋមំ សូចិវិមានំ

(៨៨) ឧច្ចមិទំ មណិថូណំ វិមានំ

សមន្តតោ ទ្វាទស យោជនានិ

។ បេ ។

# ទុតិយករណីយវិមាន ទី ៧

(៥៧) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។ បេ ។ ពាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

បណ្ឌិតអ្នកស្គាល់ច្បាស់ (នូវអំពើមានប្រយោជន៍ ឥតប្រយោជន៍) គួរធ្វើបុណ្យពាំងឡាយ ទានដែលគេថ្វាយ ចំពោះភិក្ខុជាអ្នកប្រតិបត្តិល្អ រមែងមានផលច្រើន ពួកភិក្ខុចេញអំពីព្រៃមកកាន់ស្រុក ដើម្បីសេចក្តីចំរើនដល់ខ្ញុំជាប្រាកដ ខ្ញុំបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះពួកភិក្ខុនោះ ហើយបានទៅកើត ក្នុងតាវត្តិង្សទេវលោក សម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះ ។ បេ ។ ពាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ទុតិយករណីយវិមាន ទី ៧ ។

# សូចិវិមាន ទី ៨

(៥៨) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

យំ ទទាតិ ន តំ ហោតិ

យញ្ញេវ ទត្វា តញ្ញេវ សេយ្យោ

សុចិ ទិន្នា សុចិមេវ សេយ្យោ

តេន មេតាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

សុចិវិមានំ អដ្ឋមំ ។

## នវមំ ទុតិយសុចិវិមានំ

(៨៩) ឧច្ចមិទំ មណិថូណំ វិមានំ

សមន្តតោ ទ្វាទស យោជនានិ

។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ

បុរិមាយ ជាតិយា មនុស្សលោកេ

ទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវបុត្រនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

បុគ្គលឡើងនូវទេយ្យធម៌ណា ផលនៃទេយ្យធម៌នោះ

មិនមែនសម្រេចត្រឹមប៉ុណ្ណោះឡើយ គឺបុគ្គលឡើងនូវ

ទេយ្យធម៌ណា ការឡើងនូវទេយ្យធម៌នោះ ប្រសើរបំផុត

ខ្ញុំបានឡើងម្ហូប ម្ហូបនោះឯង ប្រសើរបំផុត

សម្បុរបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។ បេ ។

ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ សូចិវិមាន ទី៨ ។

## ទុតិយសូចិវិមាន ទី ៩

(៩៩) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មានសសរ ធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។ បេ ។

ទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវបុត្រនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

កាលពីជាតិមុន ខ្ញុំបានកើត ជាមនុស្ស

ក្នុងពួកមនុស្ស នាមនុស្សលោក

អទ្ទសំ វិរជំ ភិក្ខុំ វិប្បសន្នមនាវិលំ
តស្ស អទាសិហំ សូចឹ បសន្នា សកេហិ បាណិហិ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទុតិយសូចិវិមានំ នវមំ ។

## ទសមំ នាគវិមានំ

(៦០) សុសុក្កខន្ធំ អភិរុយ្ហ នាគំ
អកាចិនំ ទន្តិ ពលឹ មហាជវំ
អារុយ្ហ គជំ បវរំ សុកប្បិតំ
ឥធាគមា វេហាសយមន្តលិក្ខេ(១)
នាគស្ស ទន្តេសុ ទុវេសុ និម្មិតា
អច្ឆោទកា បទុមិនិយោ សុផុល្លា
បទុមេសុ ច តុរិយគណា បវជ្ជរេ
ឥមា ច នច្ចន្តិ មនោហរាយោ
ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

---

១ ម. វេហាយសមន្តលិក្ខេ ។

បានឃើញភិក្ខុដែលប្រាសចាកធូលីគឺកិលេស មានឥន្ទ្រិយដ៏ជ្រះថ្លា មិនល្អក់ ខ្ញុំក៏ជ្រះថ្លា បានប្រគេនម្ហូបដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ទុតិយសូចិវិមាន ទី ៩ ។

## នាគវិមាន ទី ១០

(៦០) (ព្រះមោគ្គល្លានសួរថា) អ្នកឡើងជិះដំរី ដែលមាន ក-ស-ល្អ ឥតសៅហ្មង មានភ្លុក មានកំឡាំង មានសន្ទុះខ្លាំង គួរឡើងជិះ ជាដំរីដ៏ប្រសើរ ដែលបុញ្ញឫទ្ធិតាក់តែងហើយដោយប្រពៃ រីករាយក្នុងអាកាស មកក្នុងទីនេះ គុម្ពឈូកទាំងឡាយស្ដុតទៅក្នុងទឹកថ្លា មានផ្ការីកស្គុះស្គាយល្អ ដែលបុញ្ញឫទ្ធិនិម្មិតហើយ លើភ្លុកទាំងពីរនៃដំរី ទាំងពួកតូរ្យតន្ត្រីប្រគំ នៅលើផ្កាឈូកទាំងឡាយ ឯពួកទេពអប្សរទាំងនេះ គួររីករាយចិត្ត ក៏(នៅលើផ្កាឈូក) អ្នកបានសម្រេចទេវឫទ្ធិ មានអានុភាពច្រើន កាលអ្នកកើតជាមនុស្សតើបានធ្វើបុណ្យដូចម្ដេច អ្នកមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្ដេច ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អទ្ទសំ មុដ្ឋិបុប្ផានំ[១] កស្សបស្ស ភគវតោ[២]

ថូបស្មិំ អភិរោបយិំ[៣] បសន្នោ សកេហិ បាណិហិ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

នាវាវិមានំ ទសមំ ។

## ឯកាទសមំ ទុតិយនាវាវិមានំ

(៦១) មហន្តំ នាគំ អភិរុយ្ហ សព្វសេតំ គជុត្តមំ

វនា វនំ អនុបរិយាសិ នារីគណបុរក្ខិតោ[៤]

ឱភាសេន្តោ ទិសា សព្វា ឱសធី វិយ តារកា

កេន តេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន[៥] បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

---

១ ឱ. ម. មុត្តបុប្ផានិ ។ ២ ឱ. មហេសិនោ ។ ៣ ឱ. ម. អភិរោបេសិំ ។ ៤ ម. នារីគណបុរក្ខតោ ។ ៥ អដ្ឋកថាយំ វត្តសេនាគំ បាឋោ ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំមានចិត្តជ្រះថ្លា បានបូជានូវផ្កាប្រាំបីក្តាប់ ចំពោះស្តូបរបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប ដោយដៃរបស់ខ្លួន សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ នាគវិមាន ទី ១០ ។

## ទុតិយនាគវិមាន ទី ១១

(៦១) (ព្រះមោគ្គល្លានសួរថា) អ្នកបានឡើងជិះដំរីធំ សសុទ្ធ ជាដំរីឧត្តម ចេញអំពីព្រៃ ទៅកាន់ព្រៃ មានពួកនារី ចោមរោម ញុំាងទិសទាំងពួងឲ្យភ្លឺបាន ដូចផ្កាយព្រឹក សម្បុររបស់អ្នក ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មដូចម្តេច ។ បេ ។ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

អហំ មនុស្សេសុ មនុស្សភូតោ
ឧបាសកោ ចក្ខុមតោ អហោសឹ
បាណាតិបាតា វិរតោ អហោសឹ
លោកេ អទិន្នំ បរិវជ្ជយិស្សំ
អមជ្ជបោ នោ ច មុសា អភាណឹ
សកេន ទារេន ច តុដ្ឋោ អហោសឹ
អន្នញ្ច បានញ្ច បសន្នចិត្តោ
សក្កច្ច ទានំ វិបុលំ អទាសឹ

តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទុតិយនាគវិមានំ ឯកាទសមំ ។

## ទ្វាទសមំ តតិយនាគវិមានំ

(៦២) កោ នុ ទិព្វេន យានេន សព្វសេតេន ហត្ថិនា
តុរិយាឡិតនិគ្ឃោសោ អន្តលិក្ខេ មហិយ្យតិ
ទេវតា នុសិ គន្ធព្វោ អាទុ សក្កោ បុរិន្ទទោ
អជានន្តា តំ បុច្ឆាម កថំ ជានេមុ តំ មយន្តិ ។
នម្ហិ ទេវោ ន គន្ធព្វោ នាតិ(១) សក្កោ បុរិន្ទទោ
សុធម្មា នាម យេ ទេវា តេសំ អញ្ញតរោ អហន្តិ ។

---

១ ម. នាម្ហិ ។

ខ្ញុំបានកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាឧបាសក របស់ព្រះពុទ្ធព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំព្រះអង្គ បានវៀរចាកបាណាតិបាត វៀរទ្រព្យដែលគេមិនបានឲ្យ ក្នុងលោក ជាអ្នកមិនផឹកទឹកស្រវឹង មិននិយាយពាក្យកុហក ជាអ្នកត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន មានចិត្តជ្រះថ្លា បានឲ្យបាយ និងទឹក ដ៏ច្រើន ជាទាន ដោយគោរព សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ទុតិយនាគវិមាន ទី ១១ ។

## តតិយនាគវិមាន ទី ១២

(៦២) (បណ្ឌិតបុរសម្នាក់ បានសួរថា) អ្នកណាហ្ន៎ + មានដំរីទិព្វដ៏សសុទ្ធ ជាយាន មានសំឡេងគឹកកងដោយតូរ្យតន្ត្រី ដែលគេប្រគំថ្វាយ ដែលពួកបរិវារបូជាក្នុងអាកាស អ្នកជាទេវតា ឬគន្ធព្វ ឬមួយជាព្រះឥន្ទ្រអ្នកឲ្យទាន ក្នុងកាលមុន យើងមិនស្គាល់ ទើបសួរអ្នក យើងស្គាល់អ្នក ដោយប្រការដូចម្តេចបាន ។

(ទេវតាឆ្លើយថា) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាព្រះឥន្ទ្រអ្នកឲ្យទាន ក្នុងកាលមុនទេ ពួកទេវតាណា មានឈ្មោះថាសុធម្មៈ ខ្ញុំក៏រាប់ថាជាទេវតាមួយ ក្នុងពួកទេវតានោះដែរ ។

បុច្ឆាម ទេវ សុធម្ម   បុថុំ កត្វាន អញ្ជលឹ
កឹ កត្វា មានុសេ កម្មំ   សុធម្មំ ឧបបជ្ជសីតិ ។
ឧច្ឆាគារំ តិណាគារំ   វត្ថាគារញ្ច យោ ទទេ
តិណ្ណមញ្ញតរំ ទត្វា   សុធម្មំ ឧបបជ្ជតីតិ ។

តតិយនាគវិមានំ ទ្វាទសមំ ។

## តេរសមំ ចូឡរថវិមានំ

(៦៣) ទឡ្ហធម្មនិសារស្ស   ធនុំ ឱលុព្ភ តិដ្ឋសិ
ខត្តិយោ នុសិ រាជញ្ញោ   អទុ លុទ្ទោ វនេចរោតិ ។
អស្សកាធិបតិស្សាហំ(១)   ភន្តេ បុត្តោ វនេ ចរេ
នាមំ មេ ភិក្ខុ តេ ព្រូមិ   សុជាតោ ឥតិ មំ វិទូ
មិគេ គវេសមានោហំ   ឱគាហន្តោ ព្រហាវនំ
មិគំ តញ្ច នាទ្ទក្ខឹ   តញ្ច ទិស្វា អហំ ឋិតោ(ឥតិ)។
ស្វាគតន្តេ មហាបុញ្ញ   អថោ តេ អទុរាគតំ
ឥតោ(២) ឧទកមាទាយ   បាទេ បក្ខាលយស្សុ តេ

---

១ ម. អស្ស កាធិបតិស្សាសុ ។ ២ ឱ. ម. ឯត្តោ ។

(បណ្ឌិតបុរសសួរថា) បពិត្រទេវតា ឈ្មោះសុធម្មៈ យើងសូមធ្វើនូវអញ្ជលីដ៏ច្រើន ហើយសួរ (លោក) ថា លោកបានធ្វើអំពើដូចម្ដេចក្នុងមនុស្សលោក ទើបបានទៅកើតជាទេវតា ឈ្មោះសុធម្មៈ ។

(ទេវតាឆ្លើយថា) បុគ្គលណា ឲ្យផ្ទះដែលធ្វើដោយដើមអំពៅក្តី ផ្ទះដែលធ្វើដោយស្មៅក្តី ផ្ទះដែលធ្វើដោយសំពត់ក្តី បុគ្គលនោះលុះឲ្យផ្ទះទាំង ៣ ណាទីមួយហើយ រមែងទៅកើតជាទេវតា ឈ្មោះសុធម្មៈ ។

ចប់ តតិយនាគវិមាន ទី ១២ ។

## ចូឡរថវិមាន ទី ១៣

(៦៣) (ព្រះមហាកច្ចាយនៈសួរថា) អ្នកឈរប្រកាន់ធ្នូ ដែលធ្វើអំពីឈើខ្លឹមយ៉ាងមាំ អ្នកជាខត្តិយរាជកុមារ ឬជាព្រានថ្មើរព្រៃ ។

(ព្រះរាជកុមារតបថា) បពិត្រលោកដ៏ចំរើន ខ្ញុំជាកូនរបស់ស្ដេចជាធំក្នុងដែនអស្សកៈ ជាអ្នកៈថ្មើរព្រៃ បពិត្រភិក្ខុ ខ្ញុំសូមប្រាប់ឈ្មោះរបស់ខ្ញុំ ដល់លោក ពួកជនអ្នកចេះដឹង ស្គាល់ខ្ញុំថា សុជាតៈ កាលខ្ញុំស្វែងរកម្រឹគ ចូលទៅក្នុងព្រៃធំ ទៅតាមហើយ តែមិនឃើញម្រឹគ ខ្ញុំក៏បានជួបប្រទះនឹងលោកហើយ ឋិតនៅ ។

(ព្រះកច្ចាយនៈពោលថា) បពិត្រព្រះអង្គមានបុណ្យច្រើន ព្រះអង្គស្ដេចមកស្រួលហើយឬ មួយទៀត ព្រះអង្គស្ដេចមកអំពីទីមិនឆ្ងាយទេឬ សូមព្រះអង្គជូនទឹកអំពីនេះ លាងព្រះបាទរបស់ព្រះអង្គចុះ

ឥទំបិ បានីយំ សីតំ អាភតំ តិរិតព្ភក

រាជបុត្ត តតោ បិត្វា សន្ថតស្មឹ ឧបាវិសាតិ ។

កល្យាណីវត តេ គាថា សវណីយា មហាមុនិ

ឯលា[១] អត្ថវតី វគ្គុ មន្តា អត្ថញ្ច ភាសសិ

កា តេ រតិ វនេ វិហរតោ[២]

ឥសិនិសភ វទេហិ បុដ្ឋោ

តវ[៣] វចនបថំ និសាមយិត្វា

អត្ថធម្មបទំ សមាចរេមសេតិ ។

អហឹសា សព្វបាណីនំ កុមារម្ហាក រុច្ចតិ

ថេយ្យា ច អតិចារា ច មជ្ជបានា ច អារតិ

អរតិ សមចរិយា ច ពាហុសច្ចំ កតញ្ញុតា

ទិដ្ឋេវ ធម្មេ បសំសា ធម្មា ឯតេ បសំសិយាតិ

សន្តិកោ មរណំ តុយ្ហំ ឱរំ មាសេហិ បញ្ចហិ

រាជបុត្ត វិជានាហិ អត្តានំ បរិមោចយាតិ ។

---

១ ឱ នេឡា ។ ២ ម. កោ នុ ត្វំ វនេ វិហរសិ ។ ៣ ម. តភិតិ នត្ថិ ។

នេះជាទឹកសម្រាប់ផឹក ដ៏ត្រជាក់ ដែលជនយកមក អំពីជ្រោះភ្នំ បពិត្រព្រះរាជបុត្រ សូមព្រះអង្គទទួលយកទឹក អំពីនោះមកសោយ ហើយចូរគង់លើកម្រាលដែលក្រាលចុះ ។

(ព្រះរាជកុមារពោលថា) បពិត្រព្រះមហាមុនី វាចារបស់លោកពីរោះណាស់ គួរស្តាប់ ជាវាចាឥតទោស មានប្រយោជន៍ ជាវាចាត្រឹមត្រូវ ទាំងលោកម្ចាស់ក៏ពោលពាក្យនាំមកនូវប្រយោជន៍ ដោយឧបាយនៃប្រាជ្ញា

បពិត្រឥសីទិសកៈ សេចក្តីត្រេកអរ ដូចម្តេច របស់លោក
កាលនៅក្នុងព្រៃ ខ្ញុំសួរហើយ សូមលោកប្រាប់ ខ្ញុំ
នឹងផ្ទៀងស្តាប់ គន្លងពាក្យរបស់លោក ហើយប្រតិបត្តិ
តាមនូវចំណែកធម៌ ដែលនាំមកនូវប្រយោជន៍ ។

(ព្រះកច្ចាយនៈពោលថា) បពិត្រព្រះរាជកុមារ ការមិនបៀតបៀនពួកសត្វទាំងពួង រមែងពេញចិត្តដល់យើង ការវៀរចាកកិរិយាលួចក្តី ចាកការប្រព្រឹត្តិឥតក្តី ចាកការផឹកទឹកស្រវឹងក្តី ការមិនត្រេកអរ (ក្នុងអកុសល) ក្តី ការប្រព្រឹត្តិស្មើក្តី ភាពជាអ្នកចេះដឹងច្រើនក្តី ភាពជាអ្នកដឹងឧបការៈ ដែលគេធ្វើហើយក្តី ធម៌ទាំងនុ៎ះ ជាធម៌គួរប្រាជ្ញ ជាធម៌គួរសរសើរ ក្នុងបច្ចុប្បន្ន បពិត្រព្រះរាជបុត្រ សេចក្តីស្លាប់ របស់ព្រះអង្គ មានក្នុងទីជិត ខាងអាយអំពី ៥ ខែ សូមព្រះអង្គទ្រង់ជ្រាប សូមព្រះអង្គទ្រង់ដោះខ្លួន (ចាកអបាយទុក្ខ) ។

កាតំ ស្វាហំ ជនបទំ គន្ត្វា តាំ កម្មំ កតញ្ញុំ តោសិំ

កាយ ភា បន វិជ្ជាយ កវេយ្យំ អជរាមរោតិ ។

ន វិជ្ជតេ សោ បនេសោ កម្មំ វិជ្ជា ច តោសិំ

យត្ថ គន្ត្វា កវេ មទ្ទោ រាជបុត្តាជរាមរោ

មហទ្ធនា មហាភោគា រដ្ឋវន្តោបិ ខត្តិយា

បហូតធនធញ្ញាសេ ន តេបិ អជរាមរា

យទិ តេ សុតា អន្ធកវេណ្ហុបុត្តា[1]

សូរា វីរា វិក្កន្តប្បហារិនោ

តេបិ អាយុក្ខយំ បត្តា

វិទ្ធស្តា សស្សតី សមា

ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា

ឯតេ ចញ្ញេ ច ជាតិយា តេបិ ន អជរាមរា

យេ មន្តំ បរិវត្តេន្តិ ឆឡង្គំ ព្រហ្មចិន្តិតំ

ឯតេ ចញ្ញេ ច វិជ្ជាយ[2] តេបិ ន អជរាមរា

---

១ ម. អន្ធកវេណ្ឌុបុត្តា ។ ២ ម. វិជ្ជាប ។

(ព្រះរាជកុមារសួរថា) ខ្ញុំនោះនឹងទៅកាន់ជនបទណា ធ្វើអំពើដូចម្ដេច កិច្ចការដូចម្ដេច ជាកិច្ចរបស់បុរស មួយទៀត ខ្ញុំត្រូវប្រកបដោយវិជ្ជាដូចម្ដេច ទើបជាអ្នកមិនចាស់ មិនស្លាប់ ។

(ព្រះកច្ចាយនៈឆ្លើយថា) បពិត្រព្រះរាជបុត្ត សត្វដែលមិនចាស់ មិនស្លាប់ ទៅកាន់ប្រទេសណា ប្រទេសនឹងកិច្ចការ វិជ្ជា ជាកិច្ចរបស់បុរសនោះ មិនមានទេ ទោះបីពួកក្សត្រដែលមានផែន មានទ្រព្យច្រើន មានភោគៈច្រើន មានទ្រព្យនិងធញ្ញាហារ ដ៏គ្រប់គ្រាន់ ពួកក្សត្រទាំងនោះ នឹងថា លែងចាស់ លែងស្លាប់ក៏ទេ

ទោះបីព្រះអង្គក៏ធ្លាប់ឮដែរហើយ ពួកអន្ធកវេណ្ហុបុត្ត ជាអ្នកក្លៀវក្លា ខ្មីឃ្មាត ជាអ្នកអាចប្រហារ នូវសត្រូវបាន ពួកអន្ធកវេណ្ហុបុត្តទាំងនោះ ស្មើដោយសស្សតិវត្ថុ[1] គង់ដល់នូវការអស់ទៅនៃអាយុ វិនាសអស់ហើយ(គង់នៅតែវង្សត្រកូល) ។

ពួកជនទាំងនោះគឺក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាល និងបុក្កុសៈក្ដី ពួកជនឯទៀតដែលមានជាតិក្រៅពីនេះក្ដី ពួកជនទាំងនោះ មិនមែនជា មិនចាស់ មិនស្លាប់ ពួកជនណា រាយមន្តប្រកបដោយអង្គ ៦ ដែលពួកព្រហ្មបានគិតឃើញហើយក្ដី ពួកជនឯទៀតដែលមានវិជ្ជាក្ដី ជនទាំងនោះ ក៏មិនមែនជាមិនចាស់ មិនស្លាប់ឡើយ

---

១ វត្ថុដែលទៀងទាត់ ។

វិមានវត្ថុស្មិំ បញ្ចមស្ស មហារថវគ្គស្ស តេរសមំ ចូឡរថវិមានំ

ឥសយោ ចាបិ យេ សន្តា សញ្ញតត្តា តបស្សិនោ

សរីរំ តេបិ កាលេន វិជហន្តិ តបស្សិនោ

ការិតត្តាបិ អរហន្តោ កតកិច្ចា អនាសវា

និក្ខិបន្តិ ឥមំ ទេហំ បុញ្ញាបាបបរិក្ខយា (ឥតិ)ៗ

សុភាសិតា អត្ថវតី គាថាយោ តេ មហាមុនិ

និជ្ឈត្តោម្ហិ សុភដ្ឋេន ត្វញ្ច មេ សរណំ ភវាតិ ៗ

មា មំ ត្វំ សរណំ គច្ឆ តមេវ សរណំ វជ

សក្យបុត្តំ មហាវីរំ យមហំ សរណំ គតោតិ ៗ

កតរស្មិំ សោ ជនបទេ សត្ថា តុម្ហាក មារិស

អហម្បិ ទដ្ឋុំ គច្ឆិស្សំ ជិនំ អប្បដិបុគ្គលន្តិ ៗ

បុរត្ថិមស្មិំ ជនបទេ ឱក្កាកកុលសម្ភវោ

សត្ថាបិ បុរិសាជញ្ញោ សោ ច ខោ បរិនិព្វុតោតិ ៗ

ពោះជាពួកឥសីណា ជាអ្នកស្ងប់រម្ងាប់ បានសង្រួមចិត្ត មានព្យាយាមដុតបំផ្លាញកិលេស ឥសីទាំងនោះ ក៏លះបោលទូវសរីរៈតាមកាលគួរ ពួកព្រះអរហន្ត មានចិត្តអប់រំហើយ បានធ្វើកិច្ចស្រេចហើយ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃបុណ្យនិងបាប ក៏គង់ដាក់បង់នូវរាងកាយនេះដែរ ។

(ព្រះរាជកុមារពោលថា) បពិត្រព្រះមហាមុនី គាថាទាំងឡាយរបស់លោក ជាសុភាសិតមានប្រយោជន៍ ខ្ញុំកាលបើលោកពន្យល់ដោយសេចក្ដីល្អហើយ សូមលោកជាទីពឹងរបស់ខ្ញុំ ។

(ព្រះថេរៈពោលថា) សូមព្រះអង្គកុំដល់នូវអាត្មាជាសរណៈឡើយ អាត្មាបានដល់ នូវព្រះពុទ្ធជាសក្យបុត្ត ដែលមានព្យាយាមធំណាជាសរណៈ សូមព្រះអង្គទ្រង់ដល់ នូវព្រះពុទ្ធនោះជាសរណៈចុះ ។

(ព្រះរាជកុមារសួរថា) បពិត្រលោកនិទ្ទុក្ខ ព្រះជាគ្រូរបស់លោកនោះ (គង់នៅ) ក្នុងជនបទណា ខ្ញុំនឹងទៅកាន់ជនបទនោះ ដើម្បីឃើញព្រះអង្គទ្រង់ឈ្នះមារ មិនមានបុគ្គលប្រៀបបាន ។

(ព្រះកច្ចាយនៈឆ្លើយថា) ព្រះសាស្ដា ជាបុរសអាជានីយទ្រង់សម្ភព ក្នុងត្រកូលនៃព្រះបាទឧក្កាករាជ ក្នុងជនបទខាងកើតព្រះសាស្ដាអង្គនោះ ទ្រង់បរិនិព្វានហើយ ។

សចេ ហិ ពុទ្ធោ តិដ្ឋេយ្យ សត្ថា តុម្ហាក មារិស
យោជនានិ សហស្សានិ គច្ឆេ(១) បយិរុបាសិតុំ
យតោ ច ខោ បរិនិព្វុតោ សត្ថា តុម្ហាក មារិស
បរិនិព្វុតំ មហាវីរំ គច្ឆាមិ សរណំ អហំ
ឧបេមិ សរណំ ពុទ្ធំ ធម្មញ្ចាបិ អនុត្តរំ
សង្ឃញ្ច នរទេវស្ស គច្ឆាមិ សរណំ អហំ

បាណាតិបាតា វិរមាមិ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយាមិ
អមជ្ជបោ នោ ច មុសា ភណាមិ
សកេន ទារេន ច ហោមិ តុដ្ឋោតិ ។
សហស្សរំសី យថា មហប្បភោ
ទិសំ យថា ភាតិ នភេ អនុក្កមំ
តថប្បការោ តវយំ មហារថោ
សមន្តតោ យោជនសតំ អាយតោ
សុវណ្ណបដ្ដេហិ សមន្តមោនតោ(២)
ឧរស្ស មុត្តាហិ មណីហិ ចិត្តិតោ
លេខា សុវណ្ណស្ស ច រូបិយស្ស ច
សោភន្តិ វេឡុរិយមយា សុនិម្មិតា

---

១ ឆ. គច្ឆេយ្យំ ។ ២ ម. សមន្តមោត្ថតោ ។

(ព្រះរាជកុមារពោលថា) បពិត្រលោកនិទ្ទិក បើព្រះពុទ្ធជាសាស្តា របស់លោកទ្រង់បិតនៅ ខ្ញុំគប្បីទៅអស់ទីមួយពាន់យោជន៍ ដើម្បីចូលទៅគាល់ព្រះអង្គ បពិត្រលោកនិទ្ទិក កាលបើព្រះពុទ្ធ ជាគ្រូរបស់លោក បរិនិព្វានហើយ ខ្ញុំក៏សូមដល់នូវព្រះពុទ្ធ ជាមហាវីរបុរស ដែលបរិនិព្វានហើយ ជាសរណៈ ខ្ញុំសូមដល់ នូវព្រះពុទ្ធ ជាសរណៈផង នូវព្រះធម៌ ជាសរណៈផង សូមដល់ នូវព្រះសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់មនុស្សទាំងទេវតា ជាសរណៈផង

ខ្ញុំសូមវៀរចាកបាណាតិបាតយ៉ាងឆាប់ផង វៀរចាកអទិន្នាទានក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង ជាអ្នកត្រេកអរ ចំពោះតែប្រពន្ធរបស់ខ្លួនផង ។

(ព្រះថេរៈសួរថា) ព្រះអាទិត្យមានរស្មីច្រើន មានពន្លឺធំ ដែលណា ចរទៅក្នុងអាកាស រមែងបំភ្លឺនូវទិសបាន យ៉ាងណា រថធំរបស់អ្នកនេះ មានប្រការដែលនោះដែរ រថជុំវិញខាងបណ្តោយមួយរយយោជន៍ ស្រោបជុំវិញ ដោយផែនមាសតល់បន្ទាល វិចិត្រដោយកែវមុក្តានិងកែវមណី ក្បាច់ជាវិការៈនៃកែវពិទូរ្យ រលេបច្នៃដ៏ផែនមាសនិងប្រាក់ ក្រាំងរថឡើងរឿង

វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស តេរសមំ ចូឡរថវិមានំ

សីសញ្ចិទំ វេឡុរិយស្ស និម្មិតំ
យុគញ្ចិទំ លោហិតកាយ ចិត្តិតំ
យុត្តា សុវណ្ណស្ស ច រូបិយស្ស ច
សោភន្តិ អស្សាបិ ចិមេ មនោជវា
សោ តិដ្ឋសិ ហេមរថេ អធិដ្ឋិតោ
ទេវានមិន្ទោវ សហស្សវាហនោ
បុច្ឆាមិ តាហំ យសវន្តកោវិទំ
កថំ តយា លទ្ធោ អយំ ឧឡារោតិ ។

សុជាតោ នាមហំ ភន្តេ រាជបុត្តោ បុរេ អហុំ
តញ្ច មំ អនុកម្បាយ សញ្ញមស្មឹ និវេសយិ
ខីណាយុកញ្ច មំ ញត្វា សរីរំ បាទាសិ សត្ថុនោ(ឥតិ) ។
ឥមំ សុជាត បូជេហិ តន្តេ អត្ថាយ ហោហីតិ(១)
តាហំ គន្ធេហិ មាលេហិ បូជយិត្វា សមុយ្យុតោ(២)
បហាយ មានុសំ ទេហំ ឧបបន្នោម្ហិ នន្ទនេ
នន្ទនេ បវនេ(៣) រម្មេ នានាទិជគណាយុតេ
រមាមិ នច្ចគីតេហិ អច្ឆរាហិ បុរក្ខតោតិ ។

ចូឡរថវិមានំ តេរសមំ ។

---

១ ឱ. ម. ហេហីតិ ។ ២ ឱ. សមុយ្យុតោ ។ ៣ ឱ. បវនេ ។ ម. បវនេ ។

វិមានវត្ថុ មហារថវគ្គ ទី៥ ចូឡរថវិមាន ទី ១៣

ចុងចន្ទោលរបស់រថសម្រេចដោយកែវពិទូរ្យ ទឹមវិចិត្រដោយកែវទទឹម ចាំងខ្សែក៏ប្រដាប់ដោយមាស ទឹងប្រាក់ សេះចាំងនេះមានសន្ទុះទាន់ចិត្ត រមែងញ៉ាំងរថឲ្យរុងរឿង ព្រះអង្គក៏ចុំប៉ើងគ្រវែតលើរថមាស មានពាហនៈទឹមដោយសេះដ៏ច្រើនដូចព្រះឥន្ទ្រ បពិត្រអ្នកមានយស គាត្មាសូមសួរអ្នកជាបុគ្គលឈ្លាសវៃ តើយសដ៏ប្រសើរលើសលុបនេះ អ្នកបានដោយគុណអ្វី ។

(ទេវបុត្តតបថា) បពិត្រលោកដ៏ចំរើន ក្នុងកាលមុន ខ្ញុំជាព្រះរាជបុត្ត ឈ្មោះសុជាតៈ លោកម្ចាស់បានអនុគ្រោះ ដល់ខ្ញុំនោះបានញ៉ាំងខ្ញុំឲ្យតាំងនៅក្នុងសេចក្តីសង្រួម លោកម្ចាស់បានដឹងនូវខ្ញុំថាអស់អាយុ ហើយបានប្រទានសរីរធាតុព្រះសាស្តា ដល់ខ្ញុំ ។ លោកម្ចាស់បានប្រាប់ថា ម្នាលសុជាតរាជកុមារ ព្រះអង្គចូរបូជានូវព្រះសរីរធាតុនេះចុះ ការបូជានោះ នឹងបានជាប្រយោជន៍ដល់ព្រះអង្គ ខ្ញុំក៏បានប្រឹងប្រែងបូជានូវព្រះសរីរធាតុនោះ ដោយគ្រឿងក្រអូបនិងកម្រងផ្កាទាំងឡាយ លុះលះបង់នូវរាងកាយ ជារបស់មនុស្ស ក៏បានមកកើត ក្នុងទីមនោរម្យដ៏ប្រសើរ គួរត្រេកត្រអាលពន់ពេក ប្រកបដោយពួកទេវតាផ្សេង ៗ ជាដើម ខ្ញុំក៏ត្រេកអរដោយការរាំនិងច្រៀង ដែលពួកទេពអប្សរចោមរោមគ្រៀបគ្រា ។

ចប់ ចូឡរថវិមាន ទី ១៣ ។

## ចុទ្ទសមំ មហារថវិមានំ

(៦៤) សហស្សយុត្តំ ហយវាហនំ សុភំ
អារុយ្ហិមំ សន្ទនំ នេកចិត្តំ
ឧយ្យានភូមឹ អភិតោ អនុក្កមំ
បុរិន្ទទោ ភូតបតីវ វាសវោ
សោវណ្ណមយា តេ រថកុព្ពរា ឧភោ
ផលេហិ អំសេហិ អតីវ សង្គតា
សុជាតគុម្ពា នរវីរនិដ្ឋិតា
វិរោចតិ បណ្ណរសេវ ចន្ទោ
សុវណ្ណជាលាវតតោ រថោ អយំ
ពហូហិ នានារតនេហិ ចិត្តិតោ
សុនន្ទិឃោសោ ច សុភស្សរោ ច
វិរោចតិ ចាមរហត្ថពាហុហិ
ឥមា ច នាភ្យោ មនសាភិនិម្មិតា
រថស្ស បាទន្តរមជ្ឈភូសិតា
ឥមា ច នាភ្យោ សតរាជិចិត្តិតា
សតេរិតា វិជ្ជុរិវប្បភាសរេ

# មហារថវិមាន ទី១៤

(៦៤) (ព្រះមហាមោគ្គល្លានសួរថា) អ្នកបានឡើងជិះរថដ៏ល្អ ជាពាហនៈសេះ ដែលទឹមដោយសេះដ៏ច្រើន មានគ្រឿងវិចិត្រ ដ៏ល្អច្រើនយ៉ាង ហើយទៅជិតទីឧទ្យាន ដូចព្រះឥន្ទ្រ ជាម្ចាស់នៃទេវតា អ្នកបានឲ្យទាន ក្នុងកាលមុន ត្រពង់រថទាំងពីររបស់អ្នក ជាវិការៈនៃមាស ដែលបញ្ចុះដ៏ល្អក្រៃពេក ដោយផែនក្ដារទឹងកំណល់ មេបម្រើង (ខាងក្រៅ) មានសសរបម្រើងជាំហើយដោយល្អ ដែលជនអ្នកមានព្យាយាមឲ្យសម្រេចហើយ រថ (របស់អ្នក) នេះ បិទបាំងដោយបណ្ដាញមាស រុងរឿងដូចព្រះចន្ទ ក្នុងថ្ងៃ ១៥ កើត ជារថដែលវិចិត្រហើយដោយរតនៈផ្សេងៗ ជាច្រើនយ៉ាង មានសូរគឹកកង ជាទីត្រេកអរ ទាំងមានសំឡេងដ៏ពីរោះ រុងរឿងដោយបង្កាន់ដៃ ជាវិការៈនៃផ្ចិតទាំងឡាយ ទាំងដុំនៃរថនេះ ហាក់ដូចជានិម្មិតបានតាមចិត្ត មានខ្នងកង់នឹងកាំប្រដាប់ហើយដោយល្អ មួយទៀត ដុំនៃរថនេះ វិចិត្រដោយក្បាច់ក្បូរជាច្រើន ក្ដីផ្ទុកដោយពណ៌ច្រើនយ៉ាង ដូចជាផ្ទុកបន្ទោរ

វិមានវត្ថុស្មិំ បញ្ចមស្ស មហារថវគ្គស្ស ចុទ្ទសមំ មហារថវិមានំ

អនេកចិត្តាវិតតោ រថោ អយំ
បុថូ ច នេមី ច សហស្សារិយោ[១]
តេសំ សរោ សុយ្យតិ វគ្គុរូបោ
បញ្ចង្គិកំ តុរិយមិវប្បវាទិតំ
សិរស្មិំ ចិត្តំ មណិសន្ទកប្បិតំ[២]
សទា វិសុទ្ធំ រុចិរំ បភស្សរំ
សុវណ្ណរាជីហិ[៣] អតីវ សង្គតំ
វេឡុរិយរាជីហិ[៤] អតីវ សោភតិ
ឥមេ ច វាឡី[៥] មណិសន្ទកប្បិតា
អារោហកម្ពូ សុជវា ព្រហ្មូបមា
ព្រហា មហន្តា ពលិនោ មហាជវា
មនោ តវញ្ញាយ តថេវ សិំសរេ[៦]
ឥមេ ច សព្វេ សហិតា ចតុក្កមា
មនោ តវញ្ញាយ តថេវ សិំសរេ[៧]
សមំ វហន្តិ មុទុកា អនុទ្ធតា
អាមោទមានា[៨] តុរតានមុត្តមា

---

១ ម. សហស្សារសិកោ ។ ២ ម. មណិចន្ទកប្បិតំ ។ ៣ ម. សុវណ្ណរាជីយិ ។
៤ ម. វេឡុរិយរាជិរ ។ ៥ ឧ. ពលី ។ ៦-៧ ម. សព្វរេ ។ ៨ ម. អាមោទនា ។

វិមានវត្ថុ មហារថវគ្គ ទី ៤ មហារថវិមាន ទី ១៤

រថនេះ ជាសពាសដោយគំនូរច្រើនយ៉ាង មានខ្នងកង់ក្រាស់ ទាំងមានស្នីច្រើនពណ៌ សូរសព្ទនៃខ្នងកង់ទាំងនោះ គេឮពីរោះ ដូចជាតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ដែលប្រគំហើយ ក្បាលបន្ទោលរថនេះ ក៏វិចិត្រសម្រេចល្អ ដោយកែវមណី ដូចមណ្ឌលព្រះចន្ទ ជាបន្ទោលបរិសុទ្ធ រុងរឿង ភ្លឺផ្លេកគ្រប់កាល ប្រដាប់ដោយក្បាច់ក្បូរ ជាវិការៈនៃមាស យ៉ាងលើសលុប រុងរឿងដោយក្បាច់ក្បូរ ជាវិការៈនៃកែវពិទូរ្យ យ៉ាងក្រៃពេក ពួកសេះទាំងនេះ សម្រេចដោយរូបព្រះចន្ទ ជាវិការៈ នៃកែវមណី ជាសេះមានកំពស់ទឹងទំហំ(សមរម្យ)មានសន្ទុះលឿនល្អ ឧបមាដូចព្រហ្ម ជាសេះមានអវយវៈប្រសើរ ថ្លៃថ្លា មានអានុភាពច្រើន មានកំឡាំង មានសន្ទុះខ្លាំង ដឹងចិត្តរបស់អ្នកយ៉ាងជាក់ច្បាស់ ហើយប្រព្រឹត្ត ទៅដូចចិត្ត មួយទៀត សេះទាំងអស់នេះ ជាសត្វទៅដោយជើងបួន មានដំណើរព្រមគ្នា ស្គាល់ចិត្តអ្នកយ៉ាងជាក់ច្បាស់ ហើយប្រព្រឹត្តទៅដូចចិត្ត ជាសេះទន់ភ្លន់ មិនរឹងត្អឹង តែងអូសរថទៅស្មើគ្នា ញុំាងជនឲ្យរីករាយ ជាសេះខ្ពង់ខ្ពស់ ជាងសេះទាំងឡាយ

នច្ចន្តិ វត្តន្តិ បវត្តន្តិ អច្ឆរេ
អព្ភុទ្ធន្តា សុកាតេ បិលន្ធនេ
តេសំ សរេ សុយ្យតិ វគ្គុរូបោ[១]
បញ្ចង្គិកំ តុរិយមិវប្បវាទិតំ
រថស្ស ឃោសោ អបិលន្ធនាន ច
ខុរស្ស នាទី អភិសំសនាយ ច
ឃោសោ សុវគ្គូ សមិតស្ស សុយ្យតិ
គន្ធព្វតុរិយានិ វិចិត្រសវនេ
រថេ ឋិតា តា មិគមន្ទលោចនា[២]
អាឡារបម្ហា ហសិតា បិយំវទា
វេឡុរិយជាលា វិនតា តនុច្ឆវា
សទេវ គន្ធព្វសុរគ្គបូជិតា
រត្តា រត្តម្ពរបីតវាសសា
វិសាលនេត្តា អភិរត្តលោចនា
កុលេសុ ជាតា សុតនូ សុចិម្ហិតា
រថេ ឋិតា បញ្ជលិកា ឧបដ្ឋិតា

---
១ ម. វគ្គុរូបេ ។ ២ ម. មិគមន្ទលោចនា ។

រមែងលោស់ (គុម្ពកន្ទុយនឹងសក់) ស្ទុះទៅមុខ លោតទៅ ឰដ៏អាកាស សួយឡើងនូវគ្រឿងប្រដាប់ទាំងឡាយ ដែលបុញ្ញឫទ្ធិតាក់តែងដោយល្អ សំឡេងនៃគ្រឿងប្រដាប់ទាំងនោះ លាន់ឮដ៏ពីរោះ ដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ដែលប្រគំហើយ សំឡេងគឹកកងនៃគ្រឿងប្រដាប់ទាំងឡាយ នៃរថក្តី សូរលាន់ឮ នៃកិរិយាស្ទុះទៅមុខ នៃក្របកសេះក្តី សំឡេងគឹកកងរបស់ទិព្វ ដែលគួររីករាយក្តី ឮសូរពីរោះក្រៃលែង ដូចសូរតូរ្យតន្ត្រី នៃគន្ធព្វទេវតា ក្នុងទីជាទីស្តាប់ដ៏វិចិត្រ ពួកស្រីទេពអប្សរទាំងនោះ ឋិតនៅ លើរថ មានដួងនេត្រាថ្លាយង់ ដូចភ្នែកកូនម្រឹគ មានរោមភ្នែក·ង មានមុខស្រស់ប្រិមប្រិយ មានសំដីគួរពេញចិត្ត មានសរីរកាយ ប៉ំប៉ាំងដោយបណ្តាញកែវពិទូរ្យ មានខ្លួនល្ងន់ល្ហាស មានស្បែកសម្បុរថ្ងៃ ដ៏មដ្ឋ បានបូជាជាមួយនឹងគន្ធព្វ ទាំងទេវតាដ៏ប្រសើរ មានគ្រឿងអម្ពរ ក្រហមស្រុង នឹងគ្រឿងស្លៀកដណ្តប់ពណ៌លឿង មានវង់នេត្រា ដ៏ពេញលេញ មាននេត្រាក្រហមស្រស់ កើតក្នុងទេវត្រកូល មានសរីរៈល្អ មានដំណើរល្អ គួរស្ងើច ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បំរើ

វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស ចុទ្ទសមំ មហារថវិមានំ

កាកម្ពុកា យុរធរា សុវាសសា
សុមជ្ឈិមា ឩរុថនោបបន្នា
វដ្ដង្គុលិយោ សុមុខា(១) សុទស្សនា
រថេ ឋិតា បញ្ជលិកា ឧបដ្ឋិតា
អញ្ញា សុវេណី សុសុមិស្សកេសិយោ
សមំ វិកន្តាហិ បភស្សរាហិ ច
អនុបុព្វតា តា តវ មានសេ រតា
រថេ ឋិតា បញ្ជលិកា ឧបដ្ឋិតា
អាវេឡិនិយោ បទុមុប្បលច្ឆទា
អលង្កតា ចន្ទនសារភោសិតា(២)
អនុបុព្វតា តា តវ មានសេ រតា
រថេ ឋិតា បញ្ជលិកា ឧបដ្ឋិតា
តា មាលិនិយោ បទុមុប្បលច្ឆទា
អលង្កតា ចន្ទនសារភោសិតា
អនុបុព្វតា តា តវ មានសេ រតា
រថេ ឋិតា បញ្ជលិកា ឧបដ្ឋិតា

---
១ ឱ. សុខុមុខា ។ ២ ម. ចន្ទនសារភោបិតា ។

ពួកស្រីទេពអប្សរទាំងនោះ ទ្រទ្រង់នូវសង្វារមាសស្លៀកពាក់សមល្អ ល្វន់ល្វាសយ៉ាងល្មម មានភ្លៅនិងដោះពេញលេញ មានម្រាមដៃមូល មានមុខល្អ គួរមៀងមើល ដ៏ក្រៃលែង ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បំរើ ស្រីទេពអប្សរឯទៀត មានក្ដួងសក់ល្អ នៅក្មេងៗ មានបំណងសក់ លាយដោយ (កម្រងកៃវផាដើម) មានពន្លឺស្មើដែលបុញ្ញកម្មតាក់តែងហើយដ៏ស្មើ ពួកស្រីទេពអប្សរទាំងនោះ សុទ្ធតែមានកិរិយាប្រព្រឹត្តតាម ត្រេកអរហើយ ក្នុងចិត្តរបស់អ្នក ឋិតនៅលើរថ ផ្គងអញ្ជលី គាល់បំរើ មានគ្រឿងប្រដាប់ក្បាល ដ៏ស្រោបដោយផ្កាឈូកនិងផ្កាឧប្បល ប្រដាប់ប្រស់ព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះ មានកិរិយាប្រព្រឹត្តតាម ត្រេកអរហើយ ក្នុងចិត្តរបស់អ្នក ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បំរើ ពួកស្រីទេពអប្សរទាំងនោះ មានគ្រឿងប្រដាប់ដោយកម្រងផ្កា បិទស្រោបដោយផ្កាឈូក និងផ្កាឧប្បល (ស្រីទេពអប្សរពួកខ្លះ) ប្រដាប់ប្រស់ព្រំ ដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះ មានកិរិយាប្រព្រឹត្តតាម ត្រេកអរហើយ ក្នុងចិត្តរបស់អ្នក ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បំរើ

តា មាលិនិយោ បទុមុប្បលច្ឆទា
អលង្កតា ចន្ទនសារវាសិតា
អនុបុព្ពតា តា តវ មានសេ រតា
រថេ ឋិតា បញ្ជលិកា ឧបដ្ឋិតា
កណ្ណេសុ(១) តេ យានិ បិលន្ធនានិ ច
ហត្ថេសុ បាទេសុ តថេវ សីសេ
ឱភាសយន្តិ ទស សព្ពតោ ទិសា
អព្ភុទ្ទយំ សារទិកោវ ភាណុមា
វាតស្ស វេគេន ច សម្បកម្បិតា
ភុជេសុ មាលា អបិលន្ធនានិ ច
មុញ្ចន្តិ ឃោសំ រុចិរំ សុចឹ សុភំ
សព្ពេហិ វិញ្ញូហិ សុសត្តរូបំ
ឧយ្យានភុម្យា ច ទុវដ្ឋិតោ ឋិតា
រថា ច ជាតា តុរិយានិ វា សកេ
តមេវ ទេវិន្ទ បមោទយន្តិ
វីណា យថា ពោក្ខរបត្តពាហុហិ(២)

---

១ ម កណ្ណេសុ ។ ២ ម. ពោក្ខរពាហុភិ ។

ពួកស្រីទេពអប្សរ ទាំងនោះ ប្រដាប់ដោយកម្រងផ្កា បិទស្រោបដោយផ្កាឈូក និងផ្កាឧប្បល ប្រដាប់ប្រស់ព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរ ទាំងនោះ មានកិរិយាប្រព្រឹត្តតាម ត្រេកអរហើយ ក្នុងចិត្តរបស់អ្នក ឋិតនៅលើរថផ្គងអញ្ជលីគាល់បំរើ បណ្តាគ្រឿងប្រដាប់សម្រាប់ស្អិតស្អាងគ្រឿងប្រដាប់ទាំងឡាយណា ត្រង់ដៃទាំងឡាយ ត្រង់ជើងទាំងឡាយ និងត្រង់ក្បាលរបស់អ្នក គ្រឿងប្រដាប់ទាំងនោះញុំាងទិសទាំង ១០ ឲ្យភ្លឺសព្វ ដូចព្រះអាទិត្យរះឡើង ក្នុងសរទកាល(រដូវរំហើយ)កម្រងផ្កានិងគ្រឿងប្រដាប់ទាំងឡាយត្រង់ដើមដៃទាំងឡាយរបស់អ្នក កាលបើត្រូវកំឡាំងនៃខ្យល់បក់មក ក៏ញាប់ញ័រ រមែងបញ្ចេញនូវសូរ ដ៏រងំពីរោះល្អមានសភាពគួរឲ្យអ្នកផង ជាអ្នកចេះដឹង ចង់ស្តាប់ ពួកស្រីទេពអប្សរ ឋិតនៅក្នុងទីឧទ្យាន ជាជួរទាំងសងខាង ស្មូរសព្ទសំឡេង (ក៏កើតឡើងព្រោះអាស្រ័យ) រថផង ដំរីផងតូរ្យតន្ត្រីផង ម្នាលអ្នក ជាធំជាងទេវតា ពួកស្រីទេពអប្សរតែងញុំាងអ្នកឲ្យត្រេកអរកាយ ដូចពិណមានស្នូកនិងសន្ទះដ៏ល្អ

វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស ចុទ្ទសមំ មហារថវិមានំ

ឥមាសុ វីណាសុ ពហូសុ វគ្គុសុ
មនុញ្ញរូបាសុ ហទយេរិតម្បិ តំ
បវជ្ជមានាសុ អតីវ អច្ឆរា
ភមន្តិ កញ្ញា បទុមេសុ សិក្ខិតា
យថា ច គីតានិ ច វាទិតានិ ច
នច្ចានិ ចិមានិ សមេន្តិ ឯកតោ
អថេត្ថ នច្ចន្តិ អថេត្ថ អច្ឆរា
ឱភាសយន្តិ ឧភតោ វ រត្ថិយា
សោ មោទសិ តុរិយគណប្បពោធនោ
មហីយមានោ វជិរាវុធោរិវ
ឥមាសុ វីណាសុ ពហូសុ វគ្គុសុ
មនុញ្ញរូបាសុ ហទយេរិតម្បិ តំ
កឹ ត្វំ បុរេ កម្មមកាសិ អត្តនា
មនុស្សភូតោ បុរិមាយ ជាតិយា
ឧបោសថំ កឹ វ តុវំ(1) ឧបាវសិ
កឹ ធម្មចរិយំ វតមាភិរោចសិ
នយិទំ អប្បស្ស កតស្ស(2) កម្មុនោ
បុព្វេ សុចិណ្ណស្ស ឧបោសថស្ស វា

១ ម. ឧបោសថិកំ ច តុវំ ។ ២ ម. សាវេហិទំ អប្បកតស្ស ។

ទិព្វតសំឡេងនោះប្រព្រឹត្តទៅក្នុងហឫទ័យ បំពោះពិណជាច្រើននេះ មានសំឡេងពីរោះ ដែលមានសភាពគួរចាប់ចិត្ត គួរអ្នកផងសរសើរ ពួកស្រីទេពអប្សរ ជាច្រើនមហិមា រមែងដើរក្រឡឹងជុំវិញ ទេពកញ្ញាដែលបានហាត់ហើយ ក៏បិតនៅលើផ្កាឈូក បំរៀងទាំងឡាយ ប្រគំទាំងឡាយ នឹងរបាំទាំងឡាយ តន្ត្រីទាំងនេះ រមែងព្រមស្មើគ្នាតែមួយ ពួកស្រីទេពអប្សរខ្លះរាំលើវិមានអ្នកនេះ ពួកស្រីទេពអប្សរខ្លះ (ឈរមើលរបាំ) ក៏ព្រោងព្រាតទាំងសងខាង ក្នុងរាត្រី ក្នុងប្រទេសនេះ ខ្លួនអ្នកមានពួកតូរ្យតន្ត្រី សំរាប់ដាស់តឿន ទោះទេវតា បូជាដូចជាដើការុធ (នៃព្រះឥន្ទ្រ) វិកកាយ (ជានិច្ច) ទិព្វតសំឡេងនោះប្រព្រឹត្តទៅក្នុងហឫទ័យ បំពោះពិណជាច្រើននេះ មានសំឡេងពីរោះ ដែលមានសភាព គួរពេញចិត្ត ក្នុងកាលមុន អ្នកកើតជាមនុស្ស ក្នុងជាតិមុនបានធ្វើនូវអំពើដូចម្តេច ដោយខ្លួនឯង អ្នកបានរក្សា ឧបោសថ ឬអ្នកគាប់ចិត្តបំពេញនូវធម្មចរិយាតែ ដូចម្តេច ផលនេះ មិនមែនជាផលនៃកម្ម ដែលអ្នកធ្វើបន្តិចបន្តួចទេ (គឺជាផល) នៃឧបោសថ ដែលអ្នកបានសន្សំ

ឥទ្ធានុភាវោ វិបុលោ អយំ តវ

យំ ទេវសង្ឃំ អភិរោចសេ តុវំ

ទានស្ស តេ ឥទំ ផលំ អថោ សីលស្ស វា បន

អថោ អញ្ជលិកម្មស្ស តម្មេ អក្ខាហិ បុច្ឆិតោ (ឥតិ)។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

បញ្ហំ បុដ្ឋោ វិយាកាសិ យស្ស កម្មស្សិទំ ផលំ

ជិតិន្ទ្រិយំ ពុទ្ធមនោមនិក្កមំ

នរុត្តមំ កស្សបមគ្គបុគ្គលំ

អវាបុរន្តំ អមតស្ស ទ្វារំ

ទេវាតិទេវំ សតបុញ្ញលក្ខណំ

តមទ្ទសំ កុញ្ជរមោឃតិណ្ណំ

សុវណ្ណសិង្គិនទពិម្ពសាទិសំ

ទិស្វាន តំ ខិប្បមហុំ សុចិមនោ

តមេវ ទិស្វាន សុភាសិតទ្ធជំ

តមន្នបានំ អថ វាបិ ចីវរំ

សុចឹ បណីតំ រសសា ឧបេតំ

បុប្ផាភិកិណ្ណម្ហិ សកេ និវេសនេ

បតិដ្ឋបេសឹ ស អសង្គមានសោ

ដោយល្អ ក្នុងកាលមុន ឥទ្ធានុភាពរបស់អ្នកនេះ
ក៏ធំទូលាយ អ្នករុងរឿងលើសលុបគ្រប់ពួកទេវតា

ផលនេះ ជាផលនៃទានរបស់អ្នកឬ ឬជាផលនៃសីល ពុំនោះជាផលនៃអញ្ជលីកម្ម អាត្មាសួរអ្នកហើយ អ្នកចូរប្រាប់សេចក្តីនោះដល់អាត្មា ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសាកសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់ផលនៃបុញ្ញកម្មនេះថា

ខ្ញុំបានឃើញព្រះពុទ្ធកស្សប ទ្រង់ឈ្នះនូវឥន្ទ្រិយ ទ្រង់មាន
ព្យាយាមពេញលេញ ជាអគ្គបុគ្គល ប្រសើរជាងជនទ្រង់បើក
នូវទ្វារនៃអមតៈ ជាទេវតាលើសលុបជាងទេវតា មានបុញ្ញ-
លក្ខណៈច្រើន ជាបុគ្គលប្រសើរ ដូចកុញ្ជរ ចូលចាកអន្លង់គឺ
សង្គ្រាម មានសម្បុរដូចពុម្ពមាសសិង្គីនិងមាសជម្ពូនទ លុះខ្ញុំបាន
ឃើញព្រះមានព្រះភាគនោះហើយ ក៏មានចិត្តស្អាតមួយរំពេច
មួយទៀត លុះខ្ញុំបានឃើញព្រះមានព្រះភាគ ទ្រង់មានសុភាសិត
ជាទង់ជ័យនោះហើយ ក៏បានថ្វាយនូវបាយ និងទឹក ប្រកប
ដោយរស ព្រមទាំងចីវរដ៏ស្អាតប្រសើរ ក្នុងលំនៅរបស់ខ្លួន
ដ៏ជាសពាសដោយកម្រងផ្កា ខ្ញុំឥតមានជាប់ចំពាក់(នឹងអ្វី)ឡើយ

វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស ចុទ្ទសមំ មហារថវិមានំ

តមន្នបានេន ច ចីវរេន ច
ខជ្ជេន ភោជ្ជេន ច សាយនេន ច
សន្តប្បយិត្វា ទិបទានមុត្តមំ
សោ សក្កសោ ទេវបុរេ រមាមហំ
ឯតេនុបាយេន ឥមំ និរគ្គលំ
យញ្ញំ យជិត្វា តិវិធំ វិសុទ្ធំ
បហាយហំ មានុសកំ សមុស្សយំ
ឥន្ទសមោ ទេវបុរេ រមាមហំ
អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច
បណីតរូបំ អភិកង្ខតា មុនិ
អន្នញ្ច បានញ្ច ពហុំ សុសង្ខតំ
បតិដ្ឋបេតព្វមសង្គមានសោ(១)
ឥមស្មឹ លោកេ បរស្មឹ វា បន
ពុទ្ធេន សេដ្ឋោ ច សមោ ន វិជ្ជតិ
អាហុនេយ្យានំ បរមាហុតិំ(២) គតោ
បុញ្ញត្ថិកានំ វិបុលប្ផលេសិនន្តិ ។

មហារថវិមានំ ចុទ្ទសមំ ។

---

១ ម. បតិដ្ឋបេតព្វមសត្តមានសេ ។ ២ ម. យេមាហុនេយ្យានំ បរមាហុតី ។

បានតាក់តែងនិមន្តព្រះពុទ្ធអង្គនោះ អ្នកឧត្តមជាងសត្វជើងពីរ ឲ្យគ្រប់គ្រាន់ដោយបាយ ទឹក ចីវរ ខាទនីយភោជនីយាហារ និងទីដេក ទីអង្គុយ ខ្ញុំនោះរីករាយក្នុងទេវបុរី មានអារម្មណ៍ដ៏ប្រសើរល្អ ខ្ញុំបានបូជាគ្រឿងយញ្ញមហាទាន ឈ្មោះនិរគ្គឡៈ (មិនមានបិទបាំងកកំងស្ទឹម) ជាទានបរិសុទ្ធ ៣ ប្រការគឺ ធ្វើដោយខ្លួនឯង១ ប្រើគេឲ្យធ្វើ១ រលឹកឃើញរឿយៗដោយសប្បាយនេះ១ លុះលះបង់កាយជារបស់មនុស្ស ជាបុគ្គលស្មើនឹងព្រះឥន្ទ្រ ក្នុងទេវបុរី បពិត្រព្រះមុនី បុគ្គលអ្នកប្រាថ្នានូវ អាយុ វណ្ណៈ សុខៈ ពលៈ ដែលមានសភាព ដ៏ថ្លៃថ្នូរ គួរតែតម្កល់បាយទឹកដ៏ច្រើន ដែលខ្លួនបានតាក់តែងយ៉ាងល្អ (ចំពោះព្រះពុទ្ធ) ដោយចិត្តមិនធាប់ចំពាក់ ក្នុងលោកនេះក្តី លោកខាងមុខក្តី មិនមានបុគ្គលណាមួយ ប្រសើរជាង ឬស្មើនឹងព្រះពុទ្ធឡើយ ព្រះពុទ្ធទ្រង់ដល់នូវភាពជាអាហុនេយ្យបុគ្គលដ៏ប្រសើរ ជាងអាហុនេយ្យបុគ្គលទាំងឡាយ របស់ពួកជនអ្នកត្រូវការបុណ្យដែលជាអ្នកស្វែងរកផលយ៉ាងធំទូលាយ ។

ចប់ មហារថវិមាន ទី ១៤ ។

## ឧទ្ទានំ

មណ្ឌូកោ រេវតី ឆត្តោ

កក្កដកោ ទ្វារបាលកោ

ទ្វេ ករណីយា ទ្វេ សូចិ

តយោ នាគា ច ទ្វេ រថា

បុរិសានំ បញ្ចមោ វគ្គោតិ

បឋមោ វគ្គោ បវុច្ចតីតិ ។

ភាណវារំ តតិយំ ។

## ឧទ្ទាន (នៃមហារថវគ្គនោះ) គឺ

និយាយអំពី មណ្ឌូកទេវបុត្តវិមាន ១

រេវតីវិមាន ១ ឆត្តមាណវកវិមាន ១

កក្កដរសទាយកវិមាន ១ ទ្វារបាលកវិមាន ១

ករណីយវិមាន ២ សូចិវិមាន ២ នាគវិមាន ៣

រថវិមាន ២ (វគ្គនេះ) ជាវគ្គ ទី ៥

តែជាវគ្គ ទី ១ បែកខាងបុរស ។

ចប់ ភាណវារៈ ទី ៣ ។

---

# ឆដ្ឋោ បាយាសិកវគ្គោ

## បឋមំ អគារិយវិមានំ

(៦៥) យថា វនំ ចិត្តលតំ បភាសតិ
ឧយ្យានសេដ្ឋំ តិទសានមុត្តមំ
តថូបមំ តុយ្ហមិទំ វិមានំ
ឱភាសយំ តិដ្ឋតិ អន្តលិក្ខេ
ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ បញ្ហំ បុដ្ឋោ វិយាកាសិ យស្ស កម្មស្សិទំ ផលំ

អហញ្ច ភរិយា ច មនុស្សលោកេ
ឱបានភូតា ឃរមាវសិម្ហា
អន្នញ្ច បានញ្ច បសន្នចិត្តា
សក្កច្ច ទានំ វិបុលំ អទម្ហា

តេន មេតាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អគារិយវិមានំ បឋមំ ។

# បាយាសិកវគ្គ ទី ៦

## អគារិយវិមាន ទី ១

(៦៤) (ព្រះមោគ្គល្លានសួរថា) ចិត្តលតាវ័ន ជាឧទ្យានប្រសើរខ្ពង់ខ្ពស់ របស់តាវត្តិង្សទេវតាទាំងឡាយ ភ្លឺរុងរឿងយ៉ាងណា វិមានរបស់អ្នកនេះ ឋិតនៅក្នុងអាកាសក៏ភ្លឺព្រោងព្រាយយ៉ាងនោះដែរ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើត ជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច ។ ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា ខ្លួនខ្ញុំនឹងភរិយារបស់ខ្ញុំ (កាលដែលនៅ) ក្នុងមនុស្សលោក បាននៅគ្រប់គ្រង់ផ្ទះ ជាអ្នកមានចិត្តជ្រះថ្លា មានសភាពដូចជាអណ្តូងទឹក បានឲ្យបាយនិងទឹក ជាទានដ៏ច្រើនដោយគោរព សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ អគារិយវិមាន ទី ១ ។

## ទុតិយំ អគារិយវិមានំ

(៦៦) យថា វនំ ចិត្តលតំ បភាសតិ
ឧយ្យានសេដ្ឋំ តិទសានមុត្តមំ
តថូបមំ តុយ្ហមិទំ វិមានំ
ឱភាសយំ តិដ្ឋតិ អន្តលិក្ខេ
ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
។ បេ ។ យស្ស កម្មស្សិទំ ផលំ
អហញ្ច ភរិយា ច មនុស្សលោកេ
ឱបានភូតា ឃរមាវសិម្ហា
អន្នញ្ច បានញ្ច បសន្នចិត្តា
សក្កច្ច ទានំ វិបុលំ អទម្ហា
តេន មេតាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

អគារិយវិមានំ ទុតិយំ ។

# អគារិយវិមាន ទី ២

(៦៦) (ព្រះមោគ្គល្លានសួរថា) ចិត្តលតាវ័ន ជាឧទ្យានប្រសើរ ខ្ពង់ខ្ពស់របស់តាវត្តិង្សទេវតាទាំងឡាយ ភ្លឺរុងរឿងយ៉ាងណា វិមានរបស់អ្នក ក៏ភ្លឺព្រោងព្រាយ បិតនៅក្នុងអាកាស យ៉ាងនោះដែរ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកទៀត ក៏ភ្លឺច្បាស់ សព្វទិស តើដោយបុញ្ញកម្មដូចម្តេច ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំនិងភរិយា (កាលនៅ) ក្នុងមនុស្សលោក បាននៅគ្រប់គ្រងផ្ទះ ជាអ្នកមានចិត្តជ្រះថ្លា មានសភាពដូចជាអណ្តូងទឹក បានឲ្យបាយ និងទឹក ជាទានដ៏ច្រើន ដោយគោរព សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ អគារិយវិមាន ទី ២ ។

# តតិយំ ផលទាយកវិមានំ

(៦៧) ឧច្ចមិទំ មណិថូណំ វិមានំ
សមន្តតោ ទ្វាទស(១) យោជនានិ
កូដាគារា សត្តសតា ឧឡារា
វេឡុរិយត្ថម្ភា រុចិរត្ថតា សុភា
តត្ថច្ឆសិ បិវសិ ខាទសិ ច
ទិព្វា ច វីណា បវទន្តិ វគ្គុ
អដ្ឋដ្ឋកា សិក្ខិតា សាធុរូបា
ទិព្វា ច កញ្ញា តិទសចរា(២) ឧឡារា
នច្ចន្តិ គាយន្តិ បមោទយន្តិ
ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
បញ្ហំ បុដ្ឋោ វិយាកាសិ យស្ស កម្មស្សិទំ ផលំ

---
១ ឱ. ម. សោឡស ។ ២ ឱ. តិទសាចរា ។

# ផលទាយកវិមានទី៣

(៦៧) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានកំពូល ៧០០ ដ៏ឧឡារិក ដែលមានសសរជាវិការៈនៃកែវពិទូរ្យ ក្រាលដោយគម្រាល ដ៏រុងរឿង ជាផ្ទះដ៏ល្អ ខ្ញុនអ្នកតែងអាស្រ័យនៅ ក្រេបផឹកទំពាស៊ីក្នុងវិមាននោះ ពិណទិព្វ ក៏លាន់ឮពីរោះ មានស្រីទិព្វកញ្ញាចំនួន ៨ នាក់ ៨ ដង (៦៤ នាក់) មានរូបល្អលើសលុប បានហាត់ហើយ ត្រាច់ចរក្នុងឋានត្រៃត្រឹង្សរាំ ច្រៀង សប្បាយរីករាយ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើត ជាមនុស្ស តើបានធ្វើបុញ្ញកម្មដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

ផលទាយី ផលំ វិបុលំ លភតិ
ទទមុជុគតេសុ បសន្នមានសោ[1]
សោ ហិ មោទតិ សគ្គប្បត្តោ តិទិវេ
អនុភោតិ ច បុញ្ញផលំ វិបុលំ
តថេវាហំ មហាមុនិ អទាសឹ ចតុរោ ផលេ
តស្មា ហិ ផលំ អលមេវ ទាតុំ
និច្ចំ មនុស្សេន សុខត្ថិកេន
ទិព្វានិ វា បត្ថយតា សុខានិ
មនុស្សសោភគ្យតមិច្ឆតា វា តិ ។
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ផលទាយកវិមានំ តតិយំ ។

## ចតុត្ថំ ឧបស្សយទាយកវិមានំ

(៦៨) ចន្ទោ យថា វិគតវលាហកេ នភេ
ឱភាសយំ តិដ្ឋតិ[2] អន្តលិក្ខេ
តថូបមំ តុយ្ហមិទំ វិមានំ
ឱភាសយំ តិដ្ឋតិ អន្តលិក្ខេ

---

១ ម. បសន្នមនោ ។ ២ ឱ. ម. គច្ឆតិ ។

បុគ្គលអ្នកឲ្យផ្លែឈើ (មានផ្លែស្វាយជាដើម) រមែងបានផលច្រើន ព្រោះថា បុគ្គលនោះមានចិត្តជ្រះថ្លា ឲ្យទានចំពោះបុគ្គលអ្នកមានចិត្តត្រង់ទាំងឡាយ រមែងដល់នូវឋានសួគ៌ រីករាយ ក្នុងទេវលោក សោយនូវផលបុណ្យដ៏ច្រើន បពិត្រមហាមុនី ខ្ញុំបានឲ្យនូវផលនៃផ្លែស្វាយ ៤ យ៉ាងនេះដែរ ព្រោះហេតុនោះ មនុស្សអ្នកត្រូវការសេចក្ដីសុខជានិច្ច ប្រាថ្នានូវសេចក្ដីសុខទាំងឡាយជាទិព្វ ឬក៏ ប្រាថ្នានូវភាពជាអ្នកមានជាតិល្អ ក្នុងមនុស្ស គួរឲ្យផ្លែឈើ ។

សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុណ្យកម្មនោះឯង ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ផលទាយកវិមាន ទី ៣ ។

## ឧបស្សយទាយកវិមាន ទី ៤

(៦៨) (ព្រះមោគ្គល្លានសួរថា) ព្រះចន្ទរុងរឿង ឋិតនៅក្នុងអាកាស ប្រាសចាកពពកយ៉ាងណា វិមានរបស់អ្នកនេះ ក៏រុងរឿង ឋិតនៅក្នុងអាកាស យ៉ាងនោះដែរ

ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហញ្ច ភរិយា ច មនុស្សលោកេ
ឧបស្សយំ អរហតោ អទម្ហា
អន្នញ្ច បានញ្ច បសន្នចិត្តា
សក្កច្ច ទានំ វិបុលំ អទម្ហា
តេន មេតាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ឧបស្សយទាយកវិមានំ ចតុត្ថំ ។

## បញ្ចមំ ទុតិយឧបស្សយទាយកវិមានំ

(៦៩) សុរិយោ យថា វិគតវលាហកេ នភេ
។ បេ ។
(យថា ហេដ្ឋាវិមានំ តថា វិត្ថារេតព្វំ)
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទុតិយឧបស្សយទាយកវិមានំ បញ្ចមំ ។

អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុញ្ញកម្មដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្ម ដូចម្តេច ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំនឹងភរិយា (កាលនៅ) ក្នុងមនុស្សលោក បានប្រគេនទីសំណាក់ ចំពោះព្រះអរហន្ត ជាអ្នកមានចិត្តជ្រះថ្លា បានប្រគេនបាយនិងទឹក ជាទានដ៏ច្រើន ដោយគោរព សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ឧបស្សយទាយកវិមាន ទី ៤ ។

## ទុតិយឧបស្សយទាយកវិមាន ទី៥

(៦៩) ព្រះអាទិត្យ ភ្លឺរុងរឿង ឰដ៏អាកាស ដែលប្រាសចាកពពក យ៉ាងណា ។ បេ ។

(វិមានខាងក្រោយយ៉ាងណា ឯទុតិយឧបស្សយទាយកវិមាន បណ្ឌិតគប្បីឱ្យពិស្តារ យ៉ាងនោះចុះ)

ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ទុតិយឧបស្សយទាយកវិមាន ទី ៥ ។

# ឆដ្ឋំ ភិក្ខាទាយកវិមានំ

(៧០) ឧច្ចមិទំ មណិថូណំ វិមានំ

សមន្តតោ ទ្វាទស យោជនានិ

កូដាគារា សត្តសតា(១) ឧឡារា

វេឡុរិយត្ថម្ភា រុចិរត្ថតា(២) សុភា

ទេវិទ្ធិបត្តោសិ មហានុភាវោ

។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ

ទិស្វាន ភិក្ខុំ តសិតំ កិលន្តំ

ឯកាហំ ភិក្ខុំ បដិបាទយិស្សំ

សមង្គិភត្តេន តទា អកាសឹ(៣)

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ភិក្ខាទាយកវិមានំ ឆដ្ឋំ ។

---

១ ឱ. សត្តសោ ។ ២ ឱ. រុបិកត្ថតា ។ ៣ ឱ. អកាសី ។

# ភិក្ខាទាយកវិមាន ទី ៦

(៧០) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី មានទំហំជុំវិញ ១៦ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរកែវពិទូរ្យ ក្រាលដោយកម្រាល ដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ អ្នកបានដល់នូវទិព្វនៃទេវតា ជាបុគ្គលមានអានុភាពច្រើន ។ បេ ។ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស បានឃើញភិក្ខុស្រេកឃ្លាន លំបាក ខ្ញុំបានប្រគេនចង្ហាន់ ១ ចំណែក បានធ្វើ (ទាន) ដោយបេសមគ្គិកត្ត(ភត្តនៃបុគ្គលអ្នកមូលមិត្តគ្នា) ក្នុងកាលនោះ ហេតុនោះបានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ភិក្ខាទាយកវិមាន ទី ៦ ។

# សត្តមំ យវបាលកវិមានំ

(៧១) ឧច្ចមិទំ មណិថូណំ វិមានំ

។ បេ ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ

អហោសឹ យវបាលកោ

អទ្ទសំ វិរជំ ភិក្ខុំ វិប្បសន្នមនាវិលំ

តស្ស អទាសហំ ភាគំ(១) បសន្នោ សេហិ បាណិហិ

កុម្មាសបិណ្ឌំ ទត្វាន មោទាមិ នន្ទនេ វនេ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

យវបាលកវិមានំ សត្តមំ ។

# អដ្ឋមំ កុណ្ឌលីវិមានំ

(៧២) អលង្កតោ មាល្យធរោ សុវត្ថោ

សុកុណ្ឌលី កប្បិតកេសមស្សុ

---

១ អដ្ឋកថាយម្បន កុម្មាសន្តិបិ បាឋោ ទិស្សតិ ។

វិមានវត្ថុ ជាយាសិកវគ្គ ទី ៦ កុណ្ឌលីវិមាន ទី ៨

# យវបាលកវិមាន ទី៧

(៧១) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មានសសរ

ធ្វើដោយកែវមណី ។ បេ ។

ពាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។ បេ ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស

ជាអ្នកថែរក្សានូវស្រែ នៃស្រូវដំណើប

ខ្ញុំបានឃើញភិក្ខុដែលមានធូលីគឺកិលេស ទៅប្រាសហើយ មានហឫទ័យ

ថ្លាមិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំមួយចំណែក ដល់ភិក្ខុនោះ

ដោយដៃរបស់ខ្លួន លុះប្រគេនដុំនំរួចហើយ ក៏រីករាយក្នុងនន្ទនវ័ន:

ហេតុនោះបានជា សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។

ពាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ យវបាលកវិមាន ទី ៧ ។

# កុណ្ឌលីវិមាន ទី៨

(៧២) (ព្រះមោគ្គល្លានសួរថា) អ្នកមានខ្លួនប្រដាប់

ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្លៀកដណ្តប់ល្អ មាន

ប្រដាប់ត្រចៀកល្អ មានសក់ និងពុកចង្កា កាត់កោរហើយ

អាមុត្តហត្ថាភរណោ យសស្សី
ទិព្វេ វិមានម្ហិ យថាបិ ចន្ទិមា
ទិព្វា ច វីណា បវទន្តិ វគ្គុ
អដ្ឋដ្ឋកា សិក្ខិតា សាធុរូបា
ទិព្វា ច កញ្ញា តិទសចរា ឧឡារា
នច្ចន្តិ គាយន្តិ បមោទយន្តិ
ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ
ទិស្វាន សមណេ សីលវន្តេ
សម្បន្នវិជ្ជាចរណេ យសស្សី
ពហុស្សុតេ តណ្ហក្ខយូបបន្នេ
អន្នញ្ច បានញ្ច បសន្នចិត្តោ
សក្កច្ច ទានំ វិបុលំ អទាសឹ

មានអាភរណៈសម្រាប់ដៃពាក់ហើយ ជាអ្នកមានយស រុងរឿងក្នុងទិព្វវិមាន ដូចចន្ទទេវបុត្ត ពិណទិព្វ ក៏លាន់ឮពីរោះ ពួកទិព្វកញ្ញា ៨ នាក់ ៨ ជង (៦៤) ជាអ្នកហាត់ហើយ មានរូបល្អ ត្រាច់ចរទៅ ក្នុងឋានតាវត្តិង្ស យ៉ាងឡូរិក រាំ ច្រៀង រីករាយសប្បាយ អ្នកបានដល់នូវឫទ្ធិ នៃទេវតា ជាបុគ្គល មានអានុភាពច្រើន អ្នកកាលកើត ជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស តើដោយបុណ្យអ្វី ។ ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញពួកសមណៈ អ្នកមានសីល បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាអ្នកមានយស ជាពហុស្សុត ដល់នូវការអស់ទៅនៃតណ្ហា ក៏មានចិត្តជ្រះថ្លា បានប្រគេនបាយនឹងទឹក ជាទាន ដ៏ធំទូលាយ ដោយគោរព

វិមានវត្ថុស្មឹ ឆដ្ឋស្ស បាយាសិកវគ្គស្ស នវមំ ទុតិយកុណ្ឌលីវិមានំ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

កុណ្ឌលីវិមានំ អដ្ឋមំ ។

## នវមំ ទុតិយកុណ្ឌលីវិមានំ

(៧៣) អលង្កតោ មាល្យធរោ សុវត្ថោ

សុកុណ្ឌលី កប្បិតកេសមស្សុ

អាមុត្តហត្ថាភរណោ យសស្សី

ទិព្វេ វិមានម្ហិ យថាបិ ចន្ទិមា

ទិព្វា ច វីណា បវទន្តិ វគ្គុ

អដ្ឋដ្ឋកា សិក្ខិតា សាធុរូបា

ទិព្វា ច កញ្ញា តិទសចរា ឧឡារា

នច្ចន្តិ គាយន្តិ បមោទយន្តិ

ទេវិទ្ធិបត្តោសិ មហានុភាវោ

មនុស្សភូតោ កិមកាសិ បុញ្ញំ

កេនាសិ ឯវំជលិតានុភាវោ

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ហេតុនោះបានជា សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។

ពាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ កុណ្ឌលីវិមាន ទី ៨ ។

## ទុតិយកុណ្ឌលីវិមានទី៩

(៧៣) (ព្រះមោគ្គល្លានសួរថា) អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់កម្រងផ្កា ស្លៀកដណ្ដប់ល្អ មានគ្រឿងប្រដាប់ត្រចៀកល្អ មានសក់ទីងពុកបង្កា កាត់កោរហើយ មានអាភរណៈសម្រាប់ដៃពាក់ហើយ ជាអ្នកមានយស រុងរឿងក្នុងទិព្វវិមាន ដូចជាចន្ទទេវបុត្ត ពិណាទិព្វ ក៏លាន់ឮពីរោះ ពួកទិព្វកញ្ញា ៨នាក់៨ជង (៦៤) ជាអ្នកហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានតាវត្តិង្ស យ៉ាង១ឡែក រាំ ច្រៀង រីករាយសប្បាយ អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ពាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

អហំ មនុស្សេសុ មនុស្សភូតោ
ទិស្វាន សមណេ សាធុរូបេ
សម្បន្នវិជ្ជាចរណេ យសស្សី
ពហុស្សុតេ សីលវន្តេ បសន្នេ
អន្នញ្ច បានញ្ច បសន្នចិត្តោ
សក្កច្ច ទានំ វិបុលំ អទាសឹ
តេន មេតាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ទុតិយកុណ្ឌលីវិមានំ នវមំ ។

## ទសមំ ឧត្តរវិមានំ

(៧៨) យា ទេវរាជស្ស សភា សុធម្មា
យត្ថច្ឆសិ ទេវសង្ឃោ សមគ្គោ
តថូបមំ តុយ្ហមិទំ វិមានំ
ឱភាសយំ តិដ្ឋតិ អន្តលិក្ខេ
ទេវិទ្ធិបត្តោសិ មហានុភាវេ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស បានឃើញ សមណៈទាំងឡាយ មានសភាពរម្យទម បរិបូណ៌ដោយ វិជ្ជានិងចរណៈ ជាអ្នកមានយស ជាពហុស្សូត អ្នកមានសីលដ៏ស្អាត ក៏មានចិត្តជ្រះថ្លា បានប្រគេននូវបាយនិងទឹក ជាទានដ៏ធំទូលាយ ដោយគោរព ហេតុនោះបានជា សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ទុតិយកុណ្ឌលីវិមាន ទី ៩ ។

## ឧត្តរវិមាន ទី ១០

(៧៤) (ព្រះមោគ្គល្លានសួរថា) សាលាជាទីប្រជុំឈ្មោះ សុធម្មាណា របស់ទេវរាជ ពួកទេវតាអង្គុយប្រជុំគ្នាក្នុងសាលា ជាទីប្រជុំណា វិមានរបស់អ្នកនេះ ក៏រុងរឿង ឋិតនៅឰដ៏អាកាស មានឧបមេយ្យដូចទេវសភានោះ អ្នកដល់នូវរិទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស តើដោយបុណ្យអ្វី ។

វិមានវត្ថុស្មឹ ឆដ្ឋស្ស បាយាសិកវគ្គស្ស ឧទ្ទានំ

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ

រញ្ញោ បាយាសិស្ស អហោសិំ មាណវោ

លទ្ធា ធនំ សំវិភាគំ អកាសឹ

បិយា ច មេ សីលវន្តោ អហេសុំ

អន្នញ្ច បានញ្ច បសន្នចិត្តោ

សក្កច្ច ទានំ វិបុលំ អទាសឹ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ឧត្តរវិមានំ ទសមំ ។

## ឧទ្ទានំ

ទ្វេ អគារិនោ ផលទាយី ទ្វេ ឧបស្សយទាយី

ភិក្ខាយទាយី យវបាលកោ ចេវ ទ្វេ កុណ្ឌលិនោ បាយាសីតិ ។

វគ្គោ ឆដ្ឋោ ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាមាណព របស់ព្រះបាទបាយាសិ ខ្ញុំបានទ្រព្យហើយ ធ្វើនូវការចែករំលែកផង ពួកអ្នកមានសីល ក៏ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននូវបាយនិងទឹក ជាទានដ៏ធំទូលាយ ដោយគោរព ហេតុនោះបានជា សម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។ ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ឧត្តរវិមាន ទី ១០ ។

## ឧទ្ទាន (នៃបាយាសិកវគ្គនោះ) គឺ

និយាយអំពីអគារវិមាន ២ លើក ផលទាយកវិមាន ១ ឧបស្សយទាយកវិមាន ២ លើក ភិក្ខាទាយកវិមាន ១ យវបាលកវិមាន ១ កុណ្ឌលីវិមាន ២ លើក (ឧត្តរវិមាន) រឿងឧត្តរមាណព អ្នកបម្រើរបស់ព្រះបាទបាយាសិ ១ ។

ចប់បាយាសិកវគ្គ ទី ៦ ។

## សត្តមោ សុនិក្ខិត្តវគ្គោ

## បឋមំ ចិត្តលតាវិមានំ

(៧៩) យថា វនំ ចិត្តលតំ បភាសតិ
ឧយ្យានសេដ្ឋំ តិទសានមុត្តមំ
តថូបមំ តុយ្ហមិទំ វិមានំ
ឱភាសយំ តិដ្ឋតិ អន្តលិក្ខេ
ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ
ទលិទ្ទោ អតាណោ កបណោ កម្មករោ អហោសឹ
ជិណ្ណេ ច មាតាបិតរោ អភរឹ
បិយា ច មេ សីលវន្តោ អហេសុំ
អន្នញ្ច ទានញ្ច បសន្នចិត្តោ
សក្កច្ច ទានំ វិបុលំ អទាសឹ

# សុនិក្ខិត្តវគ្គ ទី ៧

## ចិត្តលតាវិមាន ទី ១

(៧៩) (ព្រះមោគ្គល្លានសួរថា) ព្រៃចិត្តលតា ជាឧទ្យាន ដ៏ប្រសើរឧត្តម របស់ពួកទេវតា រុងរឿង មានឧបមា យ៉ាងណា វិមានរបស់អ្នកនេះ ក៏ភ្លឺរុងរឿង ឋិតនៅនាអាកាស មានឧបមេយ្យយ៉ាងនោះដែរ អ្នកដល់នូវរិទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើត ជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស តើដោយបុណ្យអ្វី ។ ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាអ្នកកំសត់ ឥតទីពឹង កំព្រា ជាកម្មករ (អ្នកធ្វើការឈ្នួល) បានចិញ្ចឹម មាតាបិតា ដែលចាស់ជរាផង អ្នកមានសីលទាំងឡាយ ក៏ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវ បាយនឹងទឹក ដែលជាទាន ដ៏ទូលាយ ដោយគោរព

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

ចិត្តលតាវិមានំ បឋមំ ។

## ទុតិយំ នន្ទនវិមានំ

(៧៦) យថា វនំ(១) ចិត្តលតំ បភាសតិ<br>
ឧយ្យានសេដ្ឋំ តិទសានមុត្តមំ<br>
តថូបមំ តុយ្ហមិទំ វិមានំ<br>
ឱភាសយំ តិដ្ឋតិ អន្តលិក្ខេ<br>
ទេវិទ្ធិបត្តោសិ មហានុភាវោ<br>
មនុស្សភូតោ កិមកាសិ បុញ្ញំ<br>
កេនាសិ ឯវំ ជលិតានុភាវោ<br>
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ<br>
។ បេ ។ យស្ស កម្មស្សិទំ ផលំ<br>
អហំ មនុស្សេសុ មនុស្សភូតោ<br>
ទលិទ្ទោ អតាណោ កបណោ កម្មការោ អហោសឹ<br>
ជិណ្ណេ ច មាតាបិតរោ អភរឹ

---

១ ឱ. ឯត្ថន្តរេ នន្ទនន្តិ អត្ថិ ។

ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។
ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ចិត្តលតាវិមាន ទី ១ ។

## នន្ទនវិមាន ទី ២

(៧៦) (ព្រះមោគ្គល្លានសួរថា) ព្រៃចិត្តលតា ជាឧទ្យានដ៏ប្រសើរឧត្តម របស់ពួកទេវតាជាន់តាវត្តិង្ស រុងរឿងមានឧបមា យ៉ាងណា វិមានរបស់អ្នកនេះ ក៏រុងរឿង ឋិតនៅនាអាកាស ក៏មានឧបមេយ្យដូច្នោះដែរ អ្នកដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើត ជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាមនុស្ស
កំសត់ ឥតទីពឹង កំព្រា ជាកម្មករ (អ្នកធ្វើការ
ឈ្នួល) បានចិញ្ចឹមមាតាបិតា ដែលចាស់ជរាផង

បិយា ច មេ សីលវន្តា អហេសុំ
អន្នញ្ច បានញ្ច បសន្នចិត្តា
សក្កច្ច ទានំ វិបុលំ អទាសឹ
តេន មេ តាទិសោ វណ្ណោ ។បេ។
វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

នន្ទវិមានំ ទុតិយំ ។

## តតិយំ មណិថូណវិមានំ

(៧៧) ឧច្ចមិទំ មណិថូណំ វិមានំ
សមន្តតោ ទ្វាទស យោជនានិ
កូដាគារា សត្តសតា ឧឡារា
វេឡុរិយត្ថម្ភា រុចិរត្ថតា សុភា
តត្ថច្ឆសិ បិវសិ ខាទសិ ច
ទិព្វា ច វីណា បវទន្តិ វគ្គុ
ទិព្វា រសា កាមគុណេត្ថ បញ្ច
នារិយោ ច នច្ចន្តិ សុវណ្ណឆន្នា
កេន តេ តាទិសោ វណ្ណោ ។បេ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

ពួកអ្នកមានសីល ជាទីស្រឡាញ់នៃខ្ញុំផង

ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយ ទឹកទឹក

ដែលជាទាន ដ៏ទូលាយ ដោយគោរព

ហេតុនោះ បានជាសម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។

ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ឧទកទានវិមាន ទី ២ ។

## មណិថូណវិមាន ទី ៣

(៧៧) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ

មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍ មាន

ផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរកែវពិទូរ្យ ដែល

ក្រាលកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ អ្នកបិតនៅ

ផឹក ស៊ី ក្នុងវិមាននោះ ពិណជាទិព្វ លាន់ឮពីរោះ

កាមគុណ ៥ មានរសជាទិព្វ មានក្នុងវិមាននេះផង

ពួកនារីដែលប្រស់ព្រំដោយគ្រឿងមាស ក៏ក្នុងវិមាននេះផង

សម្បុរបស់អ្នក ប្រាកដដូច្នោះ តើសម្រេចដោយបុណ្យអ្វី ។ បេ ។

ទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ

វិវនេ បថេ ចង្កមំ អកាសឹ

អារាមរុក្ខានិ ច រោបយិស្សំ

បិយា ច មេ សីលវន្តោ អហេសុំ

អន្នញ្ច បានញ្ច បសន្នចិត្តោ

សក្កច្ច ទានំ វិបុលំ អទាសឹ

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្វទិសា បភាសតីតិ ។

មណិថូណវិមានំ តតិយំ ។

# ចតុត្ថំ សុវណ្ណវិមានំ

(៧៨) សោវណ្ណមយេ បព្ពតស្មឹ វិមានំ សព្វតោ បភំ

ហេមជាលបដិច្ឆន្នំ កឹកណិកជាលកប្បិតំ

អដ្ឋំសា សុកតា ថម្ភា សព្វេ វេឡុរិយាមយា

ឯកមេកាយ អំសិយា រតនា សត្ត និម្មិតា

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស បានកសាងទីបង្គ្រមត្រង់ផ្លូវក្នុងព្រៃផង ដាំដើមឈើ ជាសួនច្បារផង ពួកអ្នកមានសីលជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយនឹងទឹក ដែលជាទានដ៏ធំទូលាយ ដោយគោរព ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ មណិថូណវិមាន ទី ៣ ។

## សុវណ្ណវិមាន ទី ៤

(៧៨) (ព្រះមោគ្គល្លានសួរថា) វិមានលើភ្នំមាស ភ្លឺសព្វទិស ស្រោបដោយបណ្តាញមាស សម្រេចដោយរំយោល នៃកណ្តឹង សសរទាំងឡាយ មានជ្រុង ៨ ដែលបុញ្ញកម្មធ្វើល្អហើយ ជាវិការៈនៃកែវពិទូរ្យទាំងអស់ កែវ ៧ ប្រការ ដែលបុញ្ញកម្មនិម្មិតហើយ

វេឡុរិយសុវណ្ណស្ស ផលិការូបិយស្ស ច
មសារគល្លមុត្តាហិ លោហិតង្គមណីហិ ច
ចិត្រា មនោរមា ភូមិ ន តត្ថុទ្ធំសតេ រជោ
គោបាណាសេ(១) គណា បីតា កូដំ ធារេន្តិ និម្មិតា
សោបាណានិ ច ចត្តារិ និម្មិតា ចតុរោ ទិសា
នានារតនគព្ភេហិ អាទិច្ចោវ វិរោចតិ
វេទិកា ចតស្សោ តត្ថ វិភត្តា ភាគសោ មិតា
ទទ្ទល្លមានា អាភេន្តិ(២) សមន្តា ចតុរោ ទិសា
តស្មឹ វិមានេ បវរេ ទេវបុត្តា មហាប្បភា(៣)
អតិរោចសិ វណ្ណេន ឧទយន្តោវ ភាណុមា
ទានស្ស តេ ឥទំ ផលំ អថោ សីលស្ស វា បន
អថោ អញ្ជលិកម្មស្ស តំ មេ អក្ខាហិ បុច្ឆិតោ ។
សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
បញ្ហំ បុដ្ឋោ វិយាកាសិ យស្ស កម្មស្សិទំ ផលំ
អហំ អន្ធវនស្មឹ ពុទ្ធស្សាទិច្ចពន្ធុនោ
វិហារំ សត្ថុនោ ការេសឹ បសន្នោ សេហិ បាណិហិ

---

១ ម. គោបាណសី ។ ២ ឱ. ម. ទទ្ទល្លមានា អាភន្តិ ។ ២ ឱ. ម. ទេវបុត្តោ មហប្បភោ ។

គ្រង់ជ្រុងមួយៗ មានជាន់ដ៏វិចិត្រ ដោយកែវពិទូរ្យនឹងមាសផង ដោយកែវផលិកនឹងប្រាក់ផង ដោយកែវពព្រុះនឹងកែវមុក្តាផង ដោយកែវទទឹមនឹងកែវមណីផង ជាទីតម្រេកនៃចិត្ត ធូលីមិនហុយឡើងក្នុងវិមាននោះទេ ទាំងបន្ទប់មានសម្បុរលឿង ដែលបុញ្ញកម្មនិម្មិតហើយ ក៏ទ្រទ្រង់នូវកំពូល ជណ្ដើរទាំង ៤ ក្នុងទិស ៤ ទៀតសោត ក៏បុញ្ញកម្មនិម្មិតហើយដែរ វិមាននោះ រុងរឿងដោយបន្ទប់ទាំងឡាយ ជាវិការៈនៃកែវផ្សេងៗ ដូចព្រះអាទិត្យ បង្កាន់ដៃទាំង ៤ ក្នុងទិសទាំង ៤ នោះ បុញ្ញកម្មតាក់តែងហើយដោយប្រមាណស្មើៗគ្នា ក៏រុងរឿង ញុំាងទិសទាំង ៤ ឲ្យភ្លឺដោយជុំវិញ ពួកទេវបុត្ត អ្នកនៅក្នុងវិមានដ៏ប្រសើរនោះ ជាអ្នកមានពន្លឺច្រើន អ្នករុងរឿង កន្លងដោយសម្បុរ ដូចព្រះអាទិត្យដែលទើបនឹងរះឡើង នេះជាផលនៃទាន នៃសីល ឬនៃអញ្ជលីកម្មរបស់អ្នក អាត្មាសួរហើយ អ្នកចូរប្រាប់នូវហេតុនោះៗ ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ទើបដោះស្រាយនូវផលនៃកម្មនេះថា ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើវិហារដើម្បីព្រះសាស្តា ជាព្រះពុទ្ធអាទិច្ចពន្ធុ ក្នុងស្រុកអន្ធកវិន្ទៈ ដោយដៃរបស់ខ្លួន

តត្ថ គន្ធញ្ច មាលញ្ច បច្ចយញ្ច វិលេបនំ
វិហារំ សត្ថុនោទាសឹ វិប្បសន្នេន ចេតសា
តេន មយ្ហំ ឥទំ លទ្ធំ វសំ វត្តេមិ នន្ទនេ
នន្ទនេ បវរេ(១) រម្មេ នានាទិជគណាយុតេ
រមាមិ នច្ចគីតេហិ អច្ឆរាហិ បុរក្ខិតោតិ ។

សុវណ្ណវិមានំ ចតុត្ថំ ។

## បញ្ចមំ អម្ពវិមានំ

(៧៩) ឧច្ចមិទំ មណិថូណំ វិមានំ
សមន្តតោ ទ្វាទស យោជនានិ
កូដាគារា សត្តសតា ឧឡារា
វេឡុរិយត្ថម្ភា រុចកត្ថតា សុភា
តត្ថច្ឆសិ បិវសិ ខាទសិ ច
ទិព្វា ច វីណា បវទន្តិ វគ្គុំ
ទិព្វា រសា កាមគុណេត្ថ បញ្ច
នារិយោ ច នច្ចន្តិ សុវណ្ណឆន្នា
កេន តេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

១ ម. បវនេ ។

(មិនត្រឹមតែប៉ុណ្ណោះសោត) ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនគ្រឿងក្រអូបផង កម្រងផ្កាផង បច្ច័យផង គ្រឿងលាបផង វិហារផង ដល់ព្រះសាស្តា ក្នុងស្រុកអន្ធកវិន្ទនោះ បានជាខ្ញុំបាននូវផលនៃបុណ្យនេះ ទើបខ្ញុំញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងព្រៃនន្ទនៈ ខ្ញុំរមែងត្រេកអរក្នុងព្រៃនន្ទនៈ ជាទីត្រេកអរដ៏ប្រសើរ ប្រកបដោយហ្វូងបក្សីផ្សេងៗ មានទាំងពួកស្រីអប្សរ អ្នករាំច្រៀងហែហម ។

ចប់ សុវណ្ណវិមាន ទី ៤ ។

## អម្ពវិមាន ទី ៥

(៧៩) (ព្រះមោគ្គល្លានសួរថា) វិមានដ៏ខ្ពស់នេះ មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរ ជាវិការៈនៃកែវពិទូរ្យ ដែលក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះកំពូលល្អ អ្នកឋិតនៅផឹក ស៊ី ក្នុងវិមាននោះផង ពិណជាទិព្វ លាន់ឮពីរោះផង កាមគុណទាំង ៥ មានរសជាទិព្វ ក្នុងវិមាននេះផង ពួកនារីប្រស់ព្រំ ដោយគ្រឿងមាស រាំ (ក្នុងវិមាននេះផង) សម្បុររបស់អ្នកប្រាកដដូច្នោះ តើសម្រេចដោយបុណ្យអ្វី ។បេ។ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស ។

សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
។ បេ ។ យស្ស កម្មស្សិទំ ផលំ
គិម្ហានំ បច្ឆិមេ មាសេ បតាបន្តេ ទិវង្ករេ
បរេសំ ភតកោ បោសោ អម្ពារាមំ អសិញ្ចហំ (១)
អថ តេនាគមា ភិក្ខុ សារីបុត្តោតិ វិស្សុតោ
កិលន្តរូបោ កាយេន អកិលន្តោវ ចេតសា
តញ្ច ទិស្វាន អាយន្តំ អវោច អម្ពសិញ្ចកោ
សាធុ តំ ភន្តេ ន្ហាបេយ្យំ យំ មមស្ស សុខាវហំ
តស្ស មេ អនុកម្បាយ និក្ខិបិ បត្តចីវរំ
និសីទិ រុក្ខមូលស្មឹ ឆាយាយ ឯកចីវរោ
តញ្ច អច្ឆេន វារិនា បសន្នមានសោ នរំ (២)
ន្ហាបយី (៣) រុក្ខមូលស្មឹ ឆាយាយ ឯកចីវរំ
អម្ពោ ច សិត្តោ សមណោ ច ន្ហាបិតោ
មយា ច បុញ្ញំ បសុតំ អនប្បកំ
ឥតិ សោ បីតិយា កាយំ សព្វំ ផរតិ អត្តនោ
តទេវ ឯត្តកំ កម្មំ អកាសឹ តាយ ជាតិយា
បហាយ មានុសំ ទេហំ ឧបបន្នោម្ហិ នន្ទនំ

---

១ ម. អម្ពារាមមសិញ្ចតិ ។ ២ ម. នរោ ។ ៣ ម. ន្ហាបយិ ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃបុញ្ញកម្មនេះថា

ខ្ញុំជាបុរសអ្នកស៊ីឈ្នួលរបស់ពួកជនដទៃ កំពុងតែស្រោចសួនស្វាយ ក្នុងវេលាថ្ងៃដែលកំពុងក្តៅនាខែជាខាងចុងនៃគិម្ហរដូវ (ខែអាសាឍ្ហ:) គ្រានោះ មានភិក្ខុប្រាកដនាមថាព្រះសារីបុត្ត និមន្តមកតាមសួននោះ មានកាយលំបាក តែចិត្តមិនលំបាកទេ ឯខ្ញុំអ្នកស្រោចសួនស្វាយ បានឃើញព្រះសារីបុត្តនោះកំពុងនិមន្តមក ក៏បានទូលថា បពិត្រលោកម្ចាស់ដ៏ចំរើន ខានប្រោសទឹកណាដែលនាំមកនូវសេចក្តីសុខដល់ខ្ញុំ ខ្ញុំសូមនិមន្តលោកម្ចាស់ស្រង់ទឹកនោះ (ព្រះថេរៈ) ដាក់បាត្រនឹងចីវរចុះ ហើយមានចីវរតែមួយ គង់ត្រង់ម្លប់ជិតគល់ឈើ ដោយសេចក្តីអនុគ្រោះដល់ខ្ញុំនោះ ខ្ញុំមានចិត្តជ្រះថ្លា និមន្តព្រះថេរៈនោះ អ្នកមានចីវរតែមួយ (ឲ្យស្រង់ដោយទឹកដ៏ថ្លា) ត្រង់ម្លប់ជិតគល់ឈើ បុរសនោះមានបីតិផ្សាយទៅសព្វកាយរបស់ខ្លួនថា

សួនស្វាយ អាត្មាអញ បានស្រោចហើយ សមណៈក៏
អាត្មាអញ បានឲ្យស្រង់ហើយ បុណ្យដែលអាត្មាអញ
បានខ្វល់ខ្វាយហើយ មិនមែនជាបុណ្យតិចតួចឡើយ

ខ្ញុំបានធ្វើនូវកម្មនោះឯង មានប្រមាណប៉ុណ្ណោះ ក្នុងជាតិនោះ លុះខ្ញុំលះបង់កាយជារបស់នៃមនុស្សហើយ ក៏ចូលទៅកាន់ព្រៃនន្ទនៈ

វិមានវត្ថុស្មឹ សត្តមស្ស សុនិក្ខិត្តវគ្គស្ស ឆដ្ឋំ គោបាលវិមានំ

នន្ទនេ បវរេ រម្មេ នានាទិជគណាយុតេ
រមាមិ នច្ចគីតេហិ អច្ឆរាហិ បុរក្ខិតោតិ ។

អម្ពវិមានំ បញ្ចមំ ។

## ឆដ្ឋំ គោបាលវិមានំ

(៨០) ទិស្វាន ទេវំ បដិបុច្ឆិ ភិក្ខុ
ឧច្ចេ វិមានម្ហិ ចិរដ្ឋិតិកោ
អាមុត្តហត្ថាភរណោ យសស្សី
ទិព្វេ វិមានម្ហិ យថាបិ ចន្ទិមា
ទិព្វា ច វីណា(១) បវទន្តិ វគ្គូ
អដ្ឋដ្ឋកា សិក្ខិតា សាធុរូបា
ទិព្វា ច កញ្ញា តិទសចរា ឧឡារា
នច្ចន្តិ គាយន្តិ បមោទយន្តិ
ទេវិទ្ធិបត្តោសិ មហានុភាវោ
មនុស្សភូតោ កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវោ
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

---

១ ឱ. ម. ឯត្ថ ហេទេ. អលង្កតោ មាលធារី សុវត្ថោ សុកុណ្ឌលី កប្បិត-
កេសមស្សុ ទិព្វេ វិមានម្ហិ យថាបិ ចន្ទិមាតិ អត្ថិ ។

វិមានវត្ថុ សុនិក្ខិត្តវគ្គ ទី ៧ គោបាលវិមាន ទី ៦

ខ្ញុំក្រេកអរក្នុងព្រៃនន្ទនៈ ជាទីរីករាយដ៏ប្រសើរ ប្រកបដោយ
ហ្វូងបក្សីផ្សេងៗ មានពួកស្រីអប្សរ អ្នកច្រៀងរាំហែហម ។

ចប់ អម្ពវិមាន ទី ៥ ។

# គោបាលវិមាន ទី៦

(៨០) (ព្រះមានព្រះភាគត្រាស់ថា) ព្រះមោគ្គល្លាន បាន
ឃើញគោបាលទេវបុត្ត ក្នុងវិមានដ៏ខ្ពស់ តាំងនៅអស់កាល
យូរ ទើបសួរថា អ្នកមានគ្រឿងអាភរណៈសម្រាប់ដៃពាក់
ហើយ ជាអ្នកមានយស រុងរឿងក្នុងទិព្វវិមាន ដូចចន្ទទេវបុត្ត
ពិណជាទិព្វលាន់ឮពីរោះ មានទិព្វកញ្ញា ៨ នាក់ ៨ ជង (៦៤)
បានហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានត្រៃត្រិង្ស
ដ៏ឧឡារិក រាំ ច្រៀង រីករាយសប្បាយ អ្នកដល់នូវរិទ្ធិនៃ
ទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើត ជា
មនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ
ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

សោ ទេវបុត្តោ អត្តមនោ   មោគ្គល្លានេន បុច្ឆិតោ

។ បេ ។   យស្ស កម្មស្សិទំ ផលំ

អហំ មនុស្សេសុ មនុស្សភូតោ

សន្តម្ម រក្ខិស្សំ បរេសំ នេនុយោ

តតោ ច អាគា សមណោ មម សន្តិកេ(១)

តាវេ ច មាសេ អគមំសុ ឃាទិតុំ

ទ្វយដ្ឋតិក្ខំ ឧភយញ្ច ការិស្សំ(២)

ឥច្ចេវហំ កត្តេ តទា វិចិន្តយំ(៣)

តតោ ច សញ្ញំ បដិលទ្ធយោនិសោ

តទាបិ កត្តេ ទិបី អនន្តកំ

សោ មាសខេត្តំ តុរិតោ អភាសរឹ

បុរាយំ កញ្ចតិ យស្សិទំ ផលំ

តតោ ច កណ្ហោ ឧរគោ មហាវិសោ

អឌំសិ ធាទេ តុរិតស្ស មេ សតោ

ស្វាហំ អដ្ដោម្ហិ ទុក្ខេន បីឡិតោ

---

១ ឱ. ម. សមណោ មមន្តិកេ ។ ២ ឱ. ម. ការយំ ។ ៣ ឱ. អ. វិចិត្តយឹ ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ៗ ឋេ ៗ ផលនៃកម្មនេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស បានប្រមូលមេគោទាំងឡាយ របស់ជនដទៃ ឃ្វាល លំដាប់នោះ សមណៈ (១ អង្គ) មកកាន់សំណាក់ខ្ញុំ ពួកគោសោត ក៏បានស្ទុះទៅប្រផឹងទឹកស៊ីសណ្តែកបាយ (របស់ជនដទៃ) បពិត្រលោកម្ចាស់ដ៏ចំរើន ក្នុងកាលនោះ ខ្ញុំគិតយ៉ាងនេះថា អាត្មាអញធ្វើនូវកិច្ចទាំងពីរ ២ ជង ក្នុងថ្ងៃនេះ បពិត្រលោកម្ចាស់ដ៏ចំរើន លំដាប់នោះ ខ្ញុំបាននូវធម្មសញ្ញា ដោយឧបាយប្រាជ្ញាហើយ ក៏បោះនូវទំសណ្តែក ក្នុងកាលនោះទៀត ខ្ញុំនោះក៏ស្ទុះទៅកាន់ចំការសណ្តែក ដោយស្រួសកន់ ឯពួកគោក៏ជាន់កាប់បំបាក់ចំការសណ្តែកចាស់ ដែលជាទ្រព្យម្ចាស់គេនោះ ក៏ក្នុងចំការចាស់នោះសោត មានពស់វែកមានពិសកាច ស្ទុះមកចឹកជើងរបស់ខ្ញុំ ដែលកំពុងដើរស្រួសកន់ នៅមានស្មារតីចាំបាន ខ្ញុំនោះជាអ្នកត្រូវទុក្ខបៀតបៀនដោយរឿងក្តី

វិមានវត្ថុស្មឹ សត្តមស្ស សុនិក្ខិត្តវគ្គស្ស ឆដ្ឋំ គោបាលវិមានំ

ភិក្ខុ ច តំ មុញ្ចិត្វា អនន្តកំ(១)
អទាសិ កុម្មាសំ មមានុកម្បាយ
តតោ ចុតោ កាលមកតោម្ហិ ទេវតា
តទេវ កម្មំ កុសលំ កតំ មយា
សុខញ្ច កម្មំ អនុភោមិ អត្តនា
តយា ហិ ភន្តេ អនុកម្បិតោ ភុសំ
កតញ្ញុតាយ អភិវាទយាមិ តំ
សទេវកេ លោកេ សមារកេ ច
អញ្ញោ មុនិ នត្ថិ តយានុកម្បកោ
តយា ហិ ភន្តេ អនុកម្បតោ ភុសំ
កតញ្ញុតាយ អភិវាទយាមិ តំ
ឥមស្មឹ លោកេ បរស្មឹ វា បន(២)
អញ្ញោ មុនិ នត្ថិ តយានុកម្បកោ
តយា ហិ ភន្តេ អនុកម្បិតោ ភុសំ
កតញ្ញុតាយ អភិវាទយាមិ តន្តិ ។

គោបាលវិមានំ ឆដ្ឋំ ។

---

១ ឱ. ភិក្ខុ ច តំ សាមំ ភុញ្ជិ បទន្តកំ ។ ម. ភិក្ខុ ច តំ យាមំ មុញ្ចិត្វា អនន្តកំ ។ ២ ម. ឥមម្ហិ លោកេ បរម្ហិ វា បន ។

ភិក្ខុបានស្រាយនំដែលថ្មោងនោះ ហើយប្រទាននំឲ្យ ដោយសេចក្ដីអនុគ្រោះដល់ខ្ញុំ លំដាប់នោះ ខ្ញុំក៏ធ្វើមរណកាលច្យុតចាកមនុស្ស មកកើតជាទេវតា (ក្នុងទេវលោកនេះ) ខ្ញុំបានធ្វើអំពើជាកុសលនោះឯង ទើបខ្ញុំបានទទួលនូវកម្មជាសុខដោយខ្លួនឯង បពិត្រលោកដ៏ចំរើន លោកម្ចាស់អនុគ្រោះហើយក្រៃពេក ខ្ញុំសូមថ្វាយបង្គំ ចំពោះលោកម្ចាស់ ដោយកតញ្ញុភាព អ្នកប្រាជ្ញដទៃ ក្នុងលោក ព្រមទាំងទេវលោកមារលោក ជាអ្នកមានសេចក្ដីអនុគ្រោះ ដូចលោកម្ចាស់មិនមានឡើយ បពិត្រលោកដ៏ចំរើន លោកម្ចាស់អនុគ្រោះក្រៃពេក ខ្ញុំសូមថ្វាយបង្គំ ចំពោះលោកម្ចាស់ ដោយកតញ្ញុភាព អ្នកប្រាជ្ញដទៃក្នុងលោកនេះ ឬក្នុងលោកខាងមុខជាអ្នកមានសេចក្ដីអនុគ្រោះ ដូចលោកម្ចាស់ មិនមានឡើយ បពិត្រលោកដ៏ចំរើន លោកម្ចាស់អនុគ្រោះក្រៃពេកខ្ញុំសូមថ្វាយបង្គំ ចំពោះលោកម្ចាស់ ដោយកតញ្ញុភាព ។

ចប់ គោបាលវិមាន ទី ៦ ។

## សត្តមំ កណ្ឌកវិមានំ

(៨១) បុណ្ណមាយេ យថា ចន្ទោ នក្ខត្តបរិវារិតោ

សមន្តា អនុបរិយាតិ តារកាធិបតិ សសី

តថូបមំ ឥទំ ព្យម្ហំ ទិព្វំ ទេវបុរម្ហិ ច

អតិរោចតិ វណ្ណេន ឧទយន្តោវ រំសិមា

វេឡុរិយសុវណ្ណស្ស ផលិការូបិយស្ស ច

មសារគល្លមុត្តាហិ លោហិតង្គមណីហិ ច

ចិត្រា មនោរមា ភូមិ វេឡុរិយស្ស សន្ថតា

កូដាគារា សុភា រម្មា បាសាទោ តេ សុមាបិតោ

រម្មា ច តេ បោក្ខរណី បុថុលា មច្ឆសេវិតា(១)

អច្ឆោទកា វិប្បសន្នា សោវណ្ណវាលុកា សន្ថតា

នានាបទុមសញ្ឆន្នា បុណ្ឌរីកសមោតតា(២)

សុរភិ សម្បវាយន្តិ មនុញ្ញា មាលុតេរិតា

តស្សា តេ ឧភតោ បស្សេ វនគុម្ពា សុមាបិតា

ឧបេតា បុប្ផរុក្ខេហិ ផលរុក្ខេហិ ចូភយំ

---

១ ម. បុថុលោមនិសេវិតា ។ ២ ម. បុណ្ឌរីកសមោហតា ។

# កណ្ណកវិមាន ទី ៧

(៨១) (ព្រះមោគ្គល្លានសួរថា) ព្រះចន្ទ្រ ក្នុងថ្ងៃពេញបូណ៌មី មានផ្កាយចោមរោម ជាអធិបតីលើពួកផ្កាយ ជាទេវបុត្តមាន ស្នាមរូបទន្សាយ ដើរក្រឡឹងជុំវិញ យ៉ាងណា វិមាននេះជាទិព្វ មានឧបមេយ្យយ៉ាងនោះ តែងរុងរឿងក្នុងទេវបុរីដោយរស្មី ដូចព្រះអាទិត្យដែលទើបនឹងរះឡើង មានជាន់ដ៏វិចិត្រ ដោយកែវពិទូរ្យ និងមាសផង ដោយកែវផលិកនិងប្រាក់ផង ដោយកែវពព្រុះ និងកែវមុក្តាផង ដោយកែវទទឹម និងកែវមណីផង គួរជាទីរីករាយនៃចិត្ត ក្រាលហើយដោយកែវពិទូរ្យ ផ្ទះកំពូលទាំងឡាយដ៏ល្អគួរជាទីរីករាយ ប្រាសាទរបស់អ្នក ក៏បុញ្ញកម្មនិម្មិតហើយដោយប្រពៃ ទាំងស្រះបោក្ខរណីរបស់អ្នក គួរជាទីរីករាយ ដេរដាសដោយមច្ឆជាតិកាន់តាប់ មានទឹកមិនល្អក់ ជាទឹករងថ្លា ក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ធ្លុកធ្លាស់ដោយឈូក-ស មានក្លិនក្រអូប ជាទីជាប់ចិត្ត ត្រូវខ្យល់ផាត់រមែងផ្សាយ គុម្ពផ្កាទាំងឡាយ ក្បែរខាងទាំងពីរនៃស្រះបោក្ខរណីរបស់អ្នកនោះ ក៏បុញ្ញកម្មនិម្មិតហើយដោយប្រពៃ ប្រកបដោយសភាពទាំងពីរ គឺឈើមានផ្កា ១ ឈើមានផ្លែ ១

## វិមានវត្ថុម្ហិ សត្តមស្ស សុនិក្ខិត្តវគ្គស្ស សត្តមំ កណ្ឌកវិមានំ

សោវណ្ណឆទេ បល្លង្កេ មុទុកេ គោណសន្ថតេ
និសិន្នំ ទេវរាជំវ ឧបតិដ្ឋន្តិ អច្ឆរា
សព្វាភរណសញ្ឆន្នា នានាមាលាវិភូសិតា
រមេន្តិ តំ មហិទ្ធិកំ វសវត្តី មោទសិ
ភេរិសង្ខមុទិង្គាហិ វីណាហិ បណវេហិ ច
រមសិ(1) រតិសម្បន្នោ នច្ចគីតេ សុវាទិតេ
ទិព្វា តេ វិវិធា រូបា ទិព្វា សទ្ទា អថោ រសា
គន្ធា ច តេ អធិប្បេតា ផោដ្ឋព្វា ច មនោរមា
តស្មឹ វិមានេ បវរេ ទេវបុត្ត មហប្បភា
អតិរោចសិ វណ្ណេន ឧទយន្តោវ ភាណុមា
ទានស្ស តេ ឥទំ ផលំ អថោ សីលស្ស វា បន
អថោ អញ្ជលិកម្មស្ស តំ មេ អក្ខាហិ បុច្ឆិតោតិ ។
សោ ទេវបុត្តោ អត្តមនោ មោគ្គល្លានេន បុច្ឆិតោ
។ បេ ។ យស្ស កម្មស្សិទំ ផលំ

---

១ ម. អិតសិ ។

ឯពួកស្រីអប្សរ ប្រដាប់ដោយអាភរណៈទាំងពួង ស្អិតស្អាងដោយកម្រងផ្កាផ្សេង ៗ បម្រើអ្នក ដែលអង្គុយនៅលើបល្ល័ង្ក មានជើងជាវិការៈនៃមាស ក្រាលដោយកម្រាល ឈ្មោះគោណកៈ[1] មានសម្ផស្សដ៏ទន់ ដូចសក្កទេវរាជ ញុំាងអ្នកមានឫទ្ធិច្រើន ឲ្យត្រេកអរ អ្នកតែងរីករាយ ដោយស្គរ ស័ង្ខ ទឹងសម្ភោរទាំងឡាយផង ដោយពិណទាំងឡាយផង ដោយបេរនាគទាំងឡាយផង ដូចទេវរាជ វេសវត្តី អ្នកបរិបូណ៌ដោយតម្រេក រមែងត្រេកអរ ក្នុងការរាំ ទឹងការច្រៀង ដែលស្រីអប្សរប្រគំពីរោះហើយផង រូបារម្មណ៍មានប្រការផ្សេង ៗ ដ៏ជាទិព្វ (គួរជាទីត្រេកដល់អ្នក) ទាំងសទ្ទារម្មណ៍ ឬរសារម្មណ៍ ដ៏ជាទិព្វក្តី គន្ធារម្មណ៍ក្តី ផោដ្ឋព្វារម្មណ៍ក្តី ដែលយើងអធិប្បាយហើយ (អារម្មណ៍ទាំងនោះ) គួរជាទីរីករាយនៃចិត្តរបស់អ្នក ទេវបុត្តទាំងឡាយ មានពន្លឺច្រើន ក្នុងវិមានដ៏ប្រសើរនោះ តែងរុងរឿងក្រៃពេកដោយស្មើ ដូចព្រះអាទិត្យ ដែលទើបនឹងរះឡើង នេះជាផលនៃទានឬសីល ឬអញ្ជលិកម្មរបស់អ្នក អាត្មាសួរហើយ ចូរអ្នកប្រាប់នូវហេតុនោះ ៗ

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។ បេ ។ ផលនៃកម្មនេះថា

---

១- ព្រំដែលមានរោមវែងជាង ៤ ធ្នាប់ ។ វិនយបិដកភាគ ៧ ទំព័រ ១៩៦ ។

អហំ កបិលវត្ថុស្មឹ សាកិយានំ បុរុត្តមេ
សុទ្ធោទនស្ស បុត្តស្ស កណ្ឋកោ សហជោ អហុំ
យទា សោ អឌ្ឍរត្តាយំ សម្ពោធាយ(១) អភិនិក្ខមិ
សោ មំ(២) មុទូហិ បាណីហិ ជាលិតម្ពនខេហិ ច(៣)
សត្ថឹ អាកោដយិត្វាន វហ សម្មាតិ មព្រវិ(៤)
អហំ លោកំ តារយិស្សំ បត្តោ សម្ពោធិមុត្តមំ
តំ មេ គិរំ សុណន្តស្ស ហាសោ(៥) មេ វិបុលោ អហុ
ឧទគ្គចិត្តោ សុមនោ អភិសីសឹ តទា អហំ
អភិរូឡ្ហញ្ច មំ ញត្វា សក្យបុត្តំ មហាយសំ
ឧទគ្គចិត្តោ មុទិតោ វហិស្សំ បុរិសុត្តមំ
បរេសំ វិជិតំ គន្ត្វា ឧគ្គតស្មឹ ទិវង្ករេ(៦)
មមំ ឆន្នញ្ច ឱហាយ អនាបេក្ខោ(៧) អបក្កមិ
តស្ស តម្ពនខេ បាទេ ជិវ្ហាយ បរិលេហិសំ(៨)
គច្ឆន្តញ្ច មហាវីរំ រុទមានោ ឧទិក្ខិស្សំ(៩)
អទស្សនេនហំ តស្ស សក្យបុត្តស្ស សិរីមតោ

---

១ ឱ. ម. ពោធាយ ។ ២ ម. សោហំ ។ ៣ ម. មំ ។ ៤ ម. ចព្រវិ ។ ៥ ម. យាសោ ។
៦ ឱ. ឧគ្គតស្មឹ ទិវាករេ ។ ម. ឧដ្ឋរស្មិំ ទិវង្ករេ ។ ៧ ម. ឯត្តន្តរេ សោតិ អត្ថិ ។
៨ ឱ. បរិលេហសឹ ។ ម. បរិលេហិសមំ ។ ៩ ឱ. ឧទិក្ខុស្សំ ។ ម. ឧទក្ខិស្សំ ។

ខ្ញុំជាសេះឈ្មោះកណ្ឋកៈ ជាសហជាត (កើតជំណាលគ្នា) នឹងព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ ក្នុងក្រុងកបិលពស្តុ ជាបុរីដ៏ឧត្តមរបស់ពួកសក្យៈ ក្នុងកាលដែលព្រះរាជបុត្រនោះ ទ្រង់ចេញទៅដើម្បីសម្មាសម្ពោធិញ្ញាណ នាមជ្ឈិមយាមនៃរាត្រី ទ្រង់ទះខ្ញុំត្រង់ភ្លៅដោយព្រះហស្តដ៏ទន់ មានព្រះនខាក្រហមរុងរឿង ហើយទ្រង់ត្រាស់ថា នែសំឡាញ់ អ្នកចូរនាំយើងទៅ បើយើងបានដល់នូវសម្ពោធិ-ញ្ញាណ ដ៏ឧត្តមហើយ នឹងចម្លងសត្វលោក(ពាក់សង្សារវដ្ត)កាលខ្ញុំឮព្រះតម្រាស់នោះ សេចក្តីរីករាយដ៏មានកំឡាំងក៏កើតឡើងដល់ខ្ញុំ ខ្ញុំមានចិត្តខ្ពស់ មានចិត្តរីករាយ បានទទួលយល់ព្រមក្នុងកាលនោះ ខ្ញុំដឹងថា សក្យបុត្តដ៏មានយសជំទ្រង់ជិះខ្ញុំហើយ មានចិត្តខ្ពស់ មានចិត្តរីករាយ (ម្តងទៀត) ទើបនាំបុរសដ៏ឧត្តម ទៅឰដ៏ខាងក្រៅ លុះទៅកន្លងផែននៃបុគ្គលដទៃរួចហើយ កាលថ្ងៃរះឡើង សក្យបុត្តក៏លះបោលខ្ញុំ នឹងឆន្នអាមាត្យ ទ្រង់មិនអាល័យ បៀសចេញទៅ ខ្ញុំលិទ្ធព្រះបាទា របស់សក្យបុត្តនោះ ដែលមានព្រះនខាក្រហមដោយអណ្តាត ខ្ញុំយំក្រឡេកមើលព្រះមហាវីរៈ ដែលស្តេចកំពុងយាងទៅ លុះខ្ញុំមើលមិនឃើញសក្យបុត្ត អ្នកមានសិរីនោះ

វិមានវត្ថុស្មឹ សត្តមស្ស សុនិក្ខិត្តវគ្គស្ស សត្តមំ កណ្ឋកវិមានំ

អលត្ថំ គរុកាពាធំ ខិប្បំ មេ មរណំ អហុ

តស្សេវ អានុភាវេន វិមានំ អាវសាមិទំ[១]

សព្វកាមគុណូបេតំ ទិព្វំ ទេវបុរម្ហិ ច

យញ្ច មេ អហុ ហាសោ សទ្ទំ សុត្វាន ពោធិយា

តេនេវ កុសលមូលេន ផុសិស្សំ អាសវក្ខយំ

សចេ ហិ ភន្តេ គច្ឆេយ្យាសិ សត្ថុ ពុទ្ធស្ស សន្តិកេ

មមាបិ នំ[២] វចនេន សិរសា វជ្ជាសិ វន្ទនំ

អហម្បិ ទដ្ឋុំ គច្ឆិស្សំ ជិនំ អប្បដិបុគ្គលំ

ទុល្លភំ ទស្សនំ ហោតិ លោកនាថាន តាទិនន្តិ ។

សោ ច កតញ្ញូ កតវេទី សត្ថារំ ឧបសង្កមិ

សុត្វា គិរំ ចក្ខុមតោ ធម្មចក្ខុំ វិសោធយិ

វិសោធយិត្វា[៣] ទិដ្ឋិគតំ វិចិកិច្ឆំ វតានិ ច

វន្ទិត្វា សត្ថុនោ បាទេ តត្ថេវន្តរធាយថាតិ[៤] ។

កណ្ឋកវិមានំ សត្តមំ ។

---

១ ឱ. អាវសាមហំ ។ ២ ឥ. មមំ បិ នំ ។ ៣ ម. វិសោធេត្វា ។ ៤ ម. តត្ថេវន្តរធាយតីតិ ។

វិមានវត្ថុ សុនិក្ខិត្តវគ្គ ទី ៧ កណ្ឌកវិមាន ទី ៧

ខ្ញុំក៏បាននូវអាពាធជាទម្ងន់ មរណៈក៏កើតមានដល់ខ្ញុំ យ៉ាងឆាប់ ខ្ញុំនៅគ្រប់គ្រងវិមាន ប្រកបដោយកាមគុណ ពាំងពួង ដ៏ជាទិព្វនេះ ក្នុងទេវបុរី (តាវត្តិង្ស) ដោយអានុភាពនៃសេចក្តីជ្រះថ្លានោះឯង មួយទៀត សេចក្តីរីករាយ កើតមានដល់ខ្ញុំ ព្រោះឮសំឡេង ដើម្បីត្រាស់ដឹង នូវពោធិញ្ញាណ ដោយកុសលមូលណា ខ្ញុំទឹកសង្ឃឹមថា មុខជាបាននូវអាសវក្ខយញ្ញាណ ដោយកុសលមូលនោះឯង បពិត្រលោកដ៏ចំរើន ប្រសិនបើ លោកនិមន្តទៅកាន់សំណាក់នៃព្រះពុទ្ធ ជាសាស្តា សូមលោកម្ចាស់ក្រាបបង្គំទូលនូវកិរិយាថ្វាយបង្គំដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំ ចំពោះអង្គព្រះជាសាស្តានោះ ចំណែកខ្ញុំគង់ទៅជួប នឹងព្រះជិនស្រីដែរ ដែលជាបុគ្គលរកអ្នកដទៃប្រៀបផ្ទឹមមិនបាន (ព្រោះ) ការឃើញនូវព្រះលោកនាថ ជាតាទិបុគ្គល រកបានដោយកម្រ ។

ឯកណ្ឌកទេវបុត្តនោះ ជាអ្នកមានកតញ្ញូកតវេទិតា ចូលទៅគាល់ព្រះសាស្តា លុះបានស្តាប់ព្រះពុទ្ធដីកា (របស់ព្រះសម្មាសម្ពុទ្ធ) ទ្រង់មានចក្ខុ ហើយបានជំរះនូវធម្មចក្ខុ គឺញាណនូវសោតាបត្តិមគ្គ ជំរះនូវទិដ្ឋិ វិចិកិច្ឆា នឹងសីលព្វត ថ្វាយបង្គំព្រះបាទរបស់ព្រះសាស្តាហើយ ក៏បាត់ទៅចាកទីនោះឯង ។

ចប់ កណ្ឌកវិមាន ទី ៧ ។

# អដ្ឋមំ អនេកវណ្ណវិមានំ

